ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Court Suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Jul-2015, 15:20
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីសវនាការលើបណ្តឹងសាទុក្ខ សាធារណៈ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជតក

**ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥**

**ម៉ោង ០៨:៥៧នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រីម ជាប្រធាន

ចៅក្រម យ៉ា ណារិន

ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត
*(Judge Agnieszka KLONOWIECKA-MILART)*

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ
*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម ផ្លូរិនស៍ ដេផែល វ៉ែរឈិន-ម៉ុមបា
*(Judge Florence N. MWACHANDE-MUMBA)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

លោក វុលគ័រ នឺលិច
*(Mr. Volker NERLICH)*

លោក ផន ធឿន

លោក ប៉ៅឡូ ឡូបា *(Mr. Paolo LOBBA)*

លោក សីលា ផៃឡេន *(Mr. Sheila PAYLAN)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ស្រ៊ា រតនៈ

លោក សេង ប៊ុនឃាង

លោក នីកូឡាស គូមជែន
*(Mr. Nicolas Koumjian)*

លោក ត្រាវិស ហ្វារ *(Mr.Travis FARR)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គរ៉ូដ៍ *(Ms. Marie GUIRAUD)*

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ទី ស្រ៊ីនណា

**មេធាវីការពារក្តីលោក នួន ជា**

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

លោក សុន អរុណ

**មេធាវីការពារក្តីលោក ខៀវ សំផន**

លោក គង់ សំអុន

លោក អាកទួរ វែកគែន *(Mr. Arthur VERCKEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម គង់ ស្រ៊ីម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ម៉ុង មុន្នីចរិយា | ខ្មែរ |
| ចៅក្រម សោម សិរិវឌ្ឍ | ខ្មែរ |
| ចៅក្រម យ៉ា ណារិន | ខ្មែរ |
| ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡូាត | អង់គ្លេស |
| ចៅក្រម ផ្លូរិនស៍ ម៉ុមបា | អង់គ្លេស |
| ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ហុង គីមសួន | ខ្មែរ |
| លោក សំ សិទ្ធី (SCW-3) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សីៈ លោក សំ សិទ្ធី** (SCW-3)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ ........ ទំព័រ ២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី៖ ........ ទំព័រ ៥
សួរដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡូត ផ្តើមពី៖ ........ ទំព័រ ២៧
សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី៖ ........ ទំព័រ ២៩
សួរដោយលោក អាកទួរ វែកគែន ផ្តើមពី៖ ........ ទំព័រ ៤០
សួរបន្តដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡូតផ្តើមពី៖ ........ ទំព័រ ៤៩
សួរបន្តដោយលោក អាកទួរ វែកគែន ផ្តើមពី៖ ........ ទំព័រ ៥០
សួរដោយលោក ហុង គីមសួន ផ្តើមពី៖ ........ ទំព័រ ៥៦
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី៖ ........ ទំព័រ ៦១
សួរដោយលោក នីកូឡាស គូមជែន ផ្តើមពី៖ ........ ទំព័រ ៦៩
សួរបន្តដោយលោក អាកទួរ វែកគែន ផ្តើមពី៖ ........ ទំព័រ ៨៩
សួរដោយចៅក្រម សោម សិរិវឌ្ឍ ផ្តើមពី៖ ........ ទំព័រ ១០១
សួរបន្តដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡូត ផ្តើមពី៖ ........ ទំព័រ១០៣
សួរដោយចៅក្រម ផ្លូរិនស៍ ម៉ុមបា ផ្តើមពី៖ ........ ទំព័រ១០៧
សួរដោយចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ ផ្តើមពី៖ ........ ទំព័រ ១០៩
សួរដោយចៅក្រម យ៉ា ណារិន ផ្តើមពី៖ ........ ទំព័រ ១១០
សួរបន្តដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡូត ផ្តើមពី៖ ........ ទំព័រ ១១១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៦:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

ថ្ងៃនេះអង្គជំនុំជម្រះតុលាការកំពូលប្រកាសបន្តសវនាការ ដើម្បីសួរសាក្សី សំ សិទ្ធី ដែលមានរហស្សនាម SW-3។

លោកក្រឡាបញ្ជី តើភាគី មេធាវី ព្រមទាំងសាក្សីមានវត្តមានគ្រប់ចំនួនហើយឬនៅ?

**ក្រឡាបញ្ជី៖**

ជម្រាបប្រសាសន៍ឯកឧត្តមប្រធាន នៅក្នុងសវនាការថ្ងៃទី២នេះ គឺគ្រប់ភាគីមានវត្តមានអស់ហើយ។ នៅក្នុងនោះលោក នួន ជា បានសុំសិទ្ធិលះបង់មិនចូលរួមក្នុងសាលសវនាការ ដូចមានលិខិតភ្ជាប់មកជាមួយ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីដែលចូលរួមថ្ងៃនេះ គឺមាន១០រូបមាន៖ អ្នកស្រី យឹម សុវណ្ណ, អ្នកស្រី មុម សំអឿន, លោក មាស សារ៉ាន់, អ្នកស្រី ឱ រី, អ្នកស្រី ទឹង សុខា, លោក អួន ផល្លី, អ្នកស្រី សាំង រ៉ាត់, អ្នកស្រី ចាន់ សុជាតិ, លោក យិន វំដួល, អ្នកស្រី ប៉ូ ឌីណា។ បាទ សូមអរគុណ។

[០៨:៥៩:០៦]

**ប្រធានអង្គជំនុំ៖**

ដោយហេតុថា ជនជាប់ចោទ នួន ជា សុំសិទ្ធិលះបង់មិនចូលរួមសវនាការនៅទីនេះ ប៉ុន្តែគាត់នឹងចូលរួមនៅតាមដានសវនាការនៅបន្ទប់ឃុំខ្លួនខាងក្រោម។ ហើយទៅតាមកំណត់ហេតុបញ្ជាក់សុខភាពរបស់វេជ្ជបណ្ឌិត ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ បានបញ្ជាក់ថា ជនជាប់ចោទ នួន ជា គឺមានបញ្ហាទាក់ទងនឹងការឈឺចង្កេះ។ ដូច្នេះគាត់មិនអាចអង្គុយយូរនៅក្នុងបន្ទប់សវនាការនេះបាន។

អាស្រ័យហេតុនេះហើយ យោងតាមពាក្យសុំរបស់ជនជាប់ចោទ និងកំណត់ហេតុសុខភាពរបស់ជនជាប់ចោទ គឺអង្គជំនុំជម្រះតុលាការកំពូលអនុញ្ញាតឲ្យគាត់ចូលរួម និងតាមដានសវនាការពីក្នុងបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការធំនេះ។ ដូច្នេះសូមមន្ត្រីខាងសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍ជូនជនជាប់ចោទ ដើម្បីតាមដាន។

ជាបន្តគឺសូមមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រហស្សនាម SCW-3 សំ សិទ្ធី មកចំពោះមុខតុលាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥១]

**ប្រធានអង្គជំនុំ៖**

សាក្សី លោកត្រូវបានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកោះអញ្ជើញលោកឲ្យចូលរួមក្នុងសវនាការ ដើម្បីផ្តល់សក្ខីកម្មជូនតុលាការកំពូល។ អាស្រ័យនេះហើយ គឺតុលាការសូមបញ្ជាក់អំពីអត្តសញ្ញាណរបស់លោក។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកឈ្មោះអីបច្ចុប្បន្ននេះ? ហើយឈ្មោះហៅក្រៅឈ្មោះអ្វីដែរ?

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំបាទ ឈ្មោះ សំ សិទ្ធី។ ហៅក្រៅឈ្មោះ ធី។

**ស៖** លោកកើតនៅថ្ងៃ ខែ ឆ្នាំណា?

**ឆ៖** ខ្ញុំបាទ កើតនៅថ្ងៃទី១៥ ខែ៥ ១៩៦១។

**ស៖** កើតនៅភូមិ ឃុំ ស្រុក ខេត្តណា? លោកឈប់អាលឆ្លើយ ចាំ!

**ឆ៖** ខ្ញុំបាទ កើតនៅនៅភូមិផ្អេរ ឃុំផ្អេរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

**ស៖** ខ្ញុំឃើញនៅក្នុងបញ្ជីប្រកាសសេចក្តីអត្តសញ្ញាណរបស់លោក គឺស្រុកកំពង់ឆ្នាំង ឬក៏ស្រុករលាប្អៀរ? ទីកន្លែងកំណើត សូមបញ្ជាក់ម្តងទៀត បាទ?

**ឆ៖** ខ្ញុំបាទមានភូមិកំណើតនៅភូមិផ្អេរ ឃុំផ្អេរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

[០៩:០៣:៥៤]

**ស៖** លោកមានសញ្ជាតិជាអ្វី? ហើយនិងមុខរបរផង?

**ឆ៖** ខ្ញុំបាទមានសញ្ជាតិជាខ្មែរ។ បច្ចុប្បន្នជាអធិការក្រុងកំពង់ឆ្នាំង។

**ស៖** ឪពុកលោកឈ្មោះអ្វី? ស្លាប់ ឬរស់?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ សំ អ៊ីន។ ម្តាយ ឈ្មោះ អ៊ុង នី (ស្លាប់)។

**ស៖** ប្រពន្ធលោកឈ្មោះអ្វី?

**ឆ៖** ភរិយារបស់ខ្ញុំបាទឈ្មោះ ប្រាក់ សៅនី។

**ស៖** ស្លាប់ ឬក៏រស់? ប្រពន្ធលោក បាទ -- កូនប៉ុន្មាននាក់? ស្រីប៉ុន្មាន ប្រុសប៉ុន្មាន? បច្ចុប្បន្ន លោកមានទីលំនៅនៅកន្លែងណា?

**ឆ៖** បច្ចុប្បន្នខ្ញុំមានទីលំនៅនៅភូមិទ្រា ភូមិទ្រាជើង ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

**ស៖** ម្តងទៀត។ លោកមានទំនាក់ទំនងញាតិជាមួយជនជាប់ចោទទាំងពីរ និង/ឬមួយជាមួយ នឹងដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែរឬទេ?

**ឆ៖** អត់មានទេ។

**ស៖** លោកបានស្បថហើយឬនៅ?

**ឆ៖** មុនខ្ញុំឡើងមកទីនេះ គឺខ្ញុំបានទៅស្បថជាមួយលោកតាដំបងដែករួចហើយ។

**ស៖** លោកបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក នេះដែរឬទេ?

**ឆ៖** ខ្ញុំបាទបានជួបសម្ភាសជាមួយក្រុមការងារ ដែលបានចុះទៅសម្ភាសដល់កន្លែងធ្វើការ របស់ខ្ញុំបាទ ហើយបានដាក់ពាក្យនៅទីនោះហើយ។

[០៩:០៦:២០]

**ស៖** សូមបញ្ជាក់ម្តងទៀត គឺខ្ញុំសួរថា តើលោកបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្ប-វេណី ក្នុងសំណុំរឿងណា ហើយនៅ អ.វ.ត.ក នេះដែរឬទេ?

**ឆ៖** កាលក្រុមការងារលោកចុះទៅហ្នឹង ខ្ញុំអត់បានដឹងថា បានដាក់ឬមិនបានដាក់នោះដែរទេ។

**ស៖** ហើយអ៊ីចឹង លោកអត់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅអ.វ.ត.ក នេះទេ។ អ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបានបញ្ជាក់ប្រាប់ដល់ក្រុមការងារថា ខ្ញុំនឹងធ្វើជាសាក្សីក្នុងការងារនេះ។

**ស៖** ខ្ញុំប្រាប់សិទ្ធិ និងកាតព្វកិច្ចរបស់លោកដែលត្រូវបានផ្តល់សក្ខីកម្មនៅពេលនេះ។ គឺលោក មានសិទ្ធិមិនឆ្លើយនឹងសំណួរ ឬក៏ការធ្វើអំណះអំណាងណាដែលនាំឱ្យមានពិរុទ្ធភាពទៅលើរូបលោក។ ប៉ុន្តែលោកត្រូវឆ្លើយនឹងសំណួរទាំងឡាយ លើកលែងសំណួរណា ឬការអះអាងណាដែលធ្វើឱ្យលោក ហ្នឹងមានពិរុទ្ធភាព។ លោកត្រូវឆ្លើយនូវអ្វីដែលជាការពិត តាមការដឹង ការឮ បានឃើញ ចងចាំ ឬក៏ ធ្លាប់មានបទពិសោធន៍ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬក៏ហេតុការណ៍ពាក់ព័ន្ធនឹង

សំណួរ។ សូមបញ្ជាក់មួយទៀតដែរ គឺលោកធ្លាប់បានធ្វើសម្ភាសជាមួយក្រុមការងារ ហើយលោកបញ្ជាក់អំមិញ គឺតើក្រុមការងារហ្នឹង គឺក្រុមការងារអ្វី?

**ឆ៖** ខ្ញុំបាទ បានជួបសម្ភាសជាមួយក្រុមការងាររបស់ក្រុម កិច្ចការងារស្រាវជ្រាវរកសាក្សីរបស់សម័យ ប៉ុល ពត។

[០៩:០៨:៥២]

**ស៖** ក្រុមការងារនោះ គឺទៅធ្វើកំណត់ហេតុយកចម្លើយពីលោក ឬមួយក៏គ្រាន់តែជាសម្ភាសសួរលោកដើម្បីកំណត់ថាជាសាក្សីទេ?

**ឆ៖** ក្រុមការងារដែលបានចុះទៅនេះ គឺគ្រាន់តែសម្ភាសយកជាកំណត់ហេតុ ដើម្បីធ្វើជាសាក្សីក្នុងកិច្ចការងារ ៣ឆ្នាំ ៨ខែ របស់សម័យនោះទេ។

**ស៖** ក្រុមការងារហ្នឹង គឺពេលដែលចុះទៅសម្ភាសជាមួយលោកហ្នឹង គឺដើម្បីយកចម្លើយក្នុងនាមលោកជាសាក្សី គឺជាអ្នកស៊ើបអង្កេតនៃរបស់សហចៅក្រមស៊ើបអង្កេតដែលបានចុះធ្វើសម្ភាសន៍ជាមួយលោក។ អ៊ីចឹងមែនទេហ្នឹង?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** លោកឆ្លើយម្តងទៀត ដោយមិនទាន់បាន--

**ឆ៖** ខ្ញុំបានជួបសម្ភាសជាមួយក្រុមការងារ ដែលចុះស្រាវជ្រាវរកសាក្សីដូចលោកប្រធានបានស៊ើបសួរអម្បាញ់មិញ។

**ស៖** លោកធ្លាប់បានចូលមកឆ្លើយ នៅចំពោះមុខសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងដែរឬទេ?

**ឆ៖** ខ្ញុំបាទ អត់ដែលបានឡើងមកកាន់ទីនេះទេ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ ជាបន្តគឺសូមអញ្ជើញសហមេធាវីការពារជនជាប់ចោទ នួន ជា តាំងសំណួរដល់សាក្សី។

បាទសូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណឯកឧត្តមប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកនៅព្រឹកនេះ។ តើលោកចាំទេ ថាគេសម្ភាសលោក គេស្តាប់ចម្លើយរបស់លោកហ្នឹងនៅពេលណាដែរ?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ខ្ញុំមិនបានចាំទាំងស្រុងនោះទេ ក៏ប៉ុន្តែក្នុងការជួបសម្ភាសនេះ គឺរយៈពេលជាងមួយឆ្នាំមកហើយ។

[០៩:១១:៣៨]

**ប្រធានអង្គជំនុំ៖**

លោកសាក្សីដូចជាអត់ទាន់បានស្តាប់ឮតាម បាទ។

បាទសូមអញ្ជើញលោកមេធាវីបន្ត!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណឯកឧត្តមប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើខ្ញុំស្តាប់ត្រឹមត្រូវដែរឬទេ អំមិញលោកឆ្លើយថាលោកបានផ្តល់ចម្លើយហ្នឹងកាលពីមួយឆ្នាំមុន អ៊ីចឹងមែនទេ?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ជាងមួយឆ្នាំមុននេះ ខ្ញុំបានផ្តល់ចម្លើយជូនក្រុមការងារ។

**ស៖** តើលោកផ្តល់ចម្លើយនៅកន្លែងណាដែរ ការផ្តល់ចម្លើយរបស់លោក ថាកាលពីមួយឆ្នាំមុនហ្នឹង?

**ឆ៖** ខ្ញុំបានជួបសម្ភាសផ្តល់ចម្លើយនៅកន្លែងធ្វើការរបស់ខ្ញុំបាទផ្ទាល់ នៅអធិការក្រុងកំពង់ឆ្នាំង។

**ស៖** អ៊ីចឹងមានន័យថា លោកផ្តល់ចម្លើយនៅឆ្នាំ២០១៤ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**លោក វិុចទ័រ កូប៉េះ**

ឯកឧត្តមប្រធាន ខ្ញុំហាក់ដូចជាមានការច្រឡូកច្របល់បន្តិច ព្រោះអ្វីដែលខ្ញុំមាននៅចំពោះខ្ញុំ គឺជាចម្លើយដែលធ្វើប្រហែលជា៧ឆ្នាំមុនមកម្ល៉េះ។ ហើយខ្ញុំកំពុងតែមើលទៅលើខាងព្រះរាជអាជ្ញាដែរ ព្រះរាជអាជ្ញាក៏កំពុងតែមាន -- កំពុងតែអាន។ ដូច្នេះខ្ញុំចង់ដឹង ថាតើវាមានចម្លើយ – កំណត់ហេតុស្តាប់ចម្លើយលើកទី២ ឬមួយក៏យ៉ាងដូចម្តេច។

[០៩:១៤:០៥]

**លោក នីកូឡាស គូមជែន៖**

តាមដែលខ្ញុំដឹង គឺថាយើងមិនមានចម្លើយ – កំណត់ហេតុស្តាប់ចម្លើយទី២នោះទេ ព្រោះថាតាមការស្រាវជ្រាវរបស់ខ្ញុំ ឃើញថាវាមានឧបសម្ព័ន្ធមួយភ្ជាប់ទៅនឹងកិច្ចសម្ភាសន៍លើកទី១ហ្នឹង គឺជាកំណត់ហេតុដែលមាន -- ឧបសម្ព័ន្ធដែលមានចុះហត្ថលេខាផងដែរ។

**លោក វិុចទ័រ កូប៉េះ**

ដូច្នេះខ្ញុំសូមបន្តទៅមុខទៀត។

**សួរដោយលោក វិុចទ័រ កូប៉េះ**

**ស៖** លោកសាក្សី តើកាលពី៧ឆ្នាំមុន លោកមានបានផ្តល់ចម្លើយទៅឲ្យអ្នកស៊ើបអង្កេតនៃការិយាល័យនៃសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំអត់ -- ខ្ញុំបានផ្តល់ព័ត៌មាននៅពេលដែលក្រុមការងារចុះទៅស៊ើបសួរ ហើយខ្ញុំបានរាប់រៀបពីរឿងរ៉ាវដែលខ្ញុំបានជួបប្រទះនៅសម័យ ៣ឆ្នាំ ៨ខែនោះ។

**លោក វិុចទ័រ កូប៉េះ**

ឯកឧត្តមប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូនសាក្សីនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ជាភាសាខ្មែរ ហើយខ្ញុំនឹងសាកសួរគាត់ ថាតើគាត់ចាំហត្ថលេខាដែលគាត់ចុះនៅលើកំណត់ហេតុស្តាប់ចម្លើយនេះដែរឬអត់? សូមឯកឧត្តមប្រធានអនុញ្ញាត។

[០៩:១៥:៣៥]

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

អ៊ីចេះខ្ញុំ កុំអាលធ្វើការបង្ហាញកំណត់ហេតុហ្នឹង។ អ៊ីចេះលោកសាក្សី ខ្ញុំសូមរំឭកដើម្បីឲ្យលោក

ចងចាំ ព្រោះទីនេះយើងចង់បានអ្វីដែលលោកត្រូវការចងចាំណា។ អ៊ីចឹងកំណត់ហេតុ ការសួរចម្លើយមានប៉ុន្មានដង ដែលលោកចាំនៅក្នុងកាលដែលក្រុមការងារខាងសាលាក្ដីខ្មែរក្រហមហ្នឹង ចុះសាកសួរ?

**លោក សំ សិទ្ធី៖**

បាទ បើតាមខ្ញុំចាំ មានតែម្ដងទេ។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

បើមានតែម្ដងអ៊ីចឹង លោកព្យាយាមគិតឡើងវិញមើល៍ ថាតើរយៈពេលហ្នឹងវាប៉ុន្មានឆ្នាំមកហើយ? ពីព្រោះថាលោកឆ្លើយថា ឆ្នាំមុន។ ឆ្នាំមុន អ៊ីចឹងឥឡូវឆ្នាំ២០១៥។ អ៊ីចឹងពាក្យថា “ឆ្នាំមុន” ពាក្យខ្មែរយើងមានន័យថា ២០១៤។ អ៊ីចឹងលោកពិចារណា ប៉ុន្តែពេលខ្លះតាមតំបន់របស់យើងទេ អ្នកខ្លះថាឆ្នាំមុន វាអាចមុនអ៊ីចឹង។ អ៊ីចឹងប្រហែលជាប៉ុន្មានឆ្នាំមកហើយ? ហើយលោកព្យាយាមរំឭកថា អ្នកណាគេ អ្នកដែលចុះសួរនៅពេលនោះ។ បាទអ៊ីចឹងអាចនឹកឃើញហើយ ថាពេលណា ប្រហែលជាប៉ុន្មានឆ្នាំមកហើយ។

**លោក សំ សិទ្ធី៖**

តើតាមការគិតស្មានរបស់យើងខ្ញុំ គឺប្រហែលជាជិត២ឆ្នាំហើយៗ ដែលខ្ញុំបានជួបសម្ភាស។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីសួរបន្ត បាទ!

បាទ លោកអំមិញ គឺចង់បង្ហាញឯកសារនុ៎ង គឺដើម្បីបញ្ជាក់អំពីពេលវេលា មែនទេ?

បាទ សូមអញ្ជើញ!

[០៩:១៧:៤៥]

**លោក វ៉ិចទ័រ កូប៉េះ៖**

បាទ ឯកឧត្តមប្រធាន ខ្ញុំគ្រាន់តែចង់បង្ហាញអំពីហត្ថលេខានៅលើឯកសាររបស់គាត់ប៉ុណ្ណោះ មិនមែនខ្ញុំចង់បង្ហាញអំពីខ្លឹមសារនោះឡើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ដូច្នេះសូមលោកសាក្សីមេត្តាពិនិត្យទៅលើទំព័រចុងក្រោយ ហើយពិនិត្យទៅលើហត្ថលេខាថាតើជាហត្ថលេខារបស់អ្នកណា?

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ដើម្បីជាកំណត់ត្រាប្រតិចារឹក ឯកសារដែលមេធាវីបានកំពុងផ្ដល់ជូនសាក្សីនោះគឺឯកសារ E3/5201។ ហើយជាក់ស្ដែងនៅក្នុងកំណត់ត្រានេះ ប្រសិនបើខ្ញុំមើលទៅលើច្បាប់ដើមជាភាសាខ្មែរ គឺអត់មានហត្ថលេខាដែលគាត់ មានថាជាហត្ថលេខាដែលគាត់បានធ្វើដោយផ្ទាល់ទេ គឺមានតែស្នាមម្រាមដៃដែលគាត់ផ្ដិតនៅលើហ្នឹង។ អ៊ីចឹង សូមឲ្យគាត់មើលទៅលើស្នាមម្រាមដៃ ហើយមើលទៅលើឈ្មោះអក្សរខ្មែរដែលគាត់សរសេរហ្នឹង ថាតើគាត់នៅចំណាំអក្សរគាត់បានដែរឬទេ។

[០៩:១៨:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចឹងសាក្សីកំពុងតែពិនិត្យហើយ វានៅក្នុងនេះគឺលោកពិនិត្យឃើញយ៉ាងម៉េចដែរ?

សូមអញ្ជើញ!

**លោក សំ សិទ្ធី៖**

**ឆ៖** ជម្រាបជូនដែរថា ស្នាមមេដៃ និងអក្សរនៅក្រោមស្នាមមេដៃនេះ ពិតជាអក្សររបស់ខ្ញុំបាទផ្ទាល់ និងស្នាមមេដៃរបស់ខ្ញុំបាទផ្ទាល់ហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកអាចពិនិត្យមើលទៅលើកថាខណ្ឌដំបូងបំផុតនៃទំព័រទី១ ដែលនិយាយថា លោកត្រូវបានសម្ភាសកាលពី៧ឆ្នាំមុន នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៨។ តើវាជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ មិនមែន៧ឆ្នាំមុនទេ គឺ២ឆ្នាំមុន។ បាទ ខ្ញុំបានជួបសម្ភាសនៅ២ឆ្នាំមុន។ អ៊ីចឹងខ្ញុំទទួលយកថា ហត្ថលេខា និងឯកសារនេះពិតជាត្រឹមត្រូវទៅតាមការជួបសម្ភាសរបស់ខ្ញុំបាទ។

**ស៖** ខ្ញុំគិតថានេះជាសំណួរ ប្រហែលជាមិនសួរជានេះហើយ ប៉ុន្តែខ្ញុំគិតថាលោកជាអធិការប៉ូលិស ដូច្នេះវាប្រាកដណាស់ថា លោកមិនច្រឡំទេ ដូចថានិយាយ២ឆ្នាំមុន ហើយនិង៧ឆ្នាំមុននោះ។

**ឆ៖** ខ្ញុំសូមរៀបរាប់ជូនដែរថា មិនមែន៧ឆ្នាំមុនទេការជួបសម្ភាសនេះ គឺ២ឆ្នាំ។ អ៊ីចឹង២ឆ្នាំមុននេះ ខ្ញុំគិតថាពិតជាត្រឹមត្រូវហើយ។ តែបើនិយាយថា បានជួបសម្ភាស៧ឆ្នាំមុនហ្នឹង គឺមិនឯកភាពទេ។

**ស៖** វាជារឿងមួយដែលមានបញ្ហាធ្ងន់ធ្ងរណាស់ចំពោះខ្ញុំ។ លោកសាក្សីតើលោកចាំទេ ថាលោកធ្លាប់និយាយជាមួយមនុស្សម្នាក់ដែលគាត់មកសម្ភាសលោក ហើយបានកត់ត្រាសំឡេងរបស់គាត់

ហើយនៅពេលដែលកត់ត្រាសំឡេងហ្នឹង គឺម៉ាស៊ីនថតសំឡេងហ្នឹងវាមានបញ្ហាថ្ម។ តើលោកចាំអំពីហេតុការណ៍នេះទេ?

[០៩:២២:១៥]

**ឆៈ** ក្នុងការសម្ភាស គឺខ្ញុំបានសម្ភាសហើយ ប៉ុន្តែរឿងឧបករណ៍ ខ្ញុំអត់បានដឹងទេ។ រឿងថាបញ្ហាកើតឡើងពីថ្ម មិនចាប់មិនអី អស់ថ្មអស់អី ខ្ញុំអត់ដឹងទេ។

**សៈ** លោកសាក្សីលោកចាំហត្ថលេខារបស់លោក។ ដូច្នេះលោកចាំទេថា លោកធ្លាប់អានខ្លឹមសារនៃកិច្ចសម្ភាសន៍នេះ? លោកចាំថា លោកធ្លាប់អានទេ?

**ឆៈ** បាទ ខ្ញុំនៅពេលដែលខ្ញុំបានធ្វើការសម្ភាសហើយ ខ្ញុំបានពិនិត្យមើល ថាពិតជាត្រឹមត្រូវដូចការសម្ភាសរបស់ខ្ញុំហើយ។ ក៏ប៉ុន្តែក្រោយមក ខ្ញុំបាទអត់បានអានទេ ព្រោះវាយូរឆ្នាំដែរហើយ។ អ៊ីចឹងហើយ រាល់កិច្ចការដែលសរសេរនៅក្នុងអត្ថបទ នៅក្នុងឯកសារនេះខ្ញុំជឿថា ជាឯកសារពិតដែលខ្ញុំបានទទួល បានជួបជជែកសម្ភាសជាមួយក្រុមការងារ ដ៏ពិតប្រាកដហើយ។

**សៈ** តើគេមានផ្ដល់ឯកសារមួយច្បាប់ឲ្យលោកដែរឬទេ? ប្រសិនបើគេផ្ដល់ឯកសារនេះជូនលោក ថាតើលោកទុកឯកសារហ្នឹងនៅកន្លែងណាដែរ? លោកទុកនៅផ្ទះ ឬក៏ទុកនៅប៉ុស្តិ៍ប៉ូលិសរបស់លោក?

**ឆៈ** ឯកសារនេះខ្ញុំបានទទួលពីក្រុមការងារទៅ គឺខ្ញុំបានពិនិត្យ អានបានមួយលើក ជាពីរលើកដែរ ប៉ុន្តែរយៈពេលវាយូរ។ វា២ឆ្នាំមកហើយ ហើយដល់ថ្ងៃនេះ លោកក្រុមការងារបានកោះអញ្ជើញខ្ញុំមកកាន់សវនាការនេះ ខ្ញុំអត់បានអានឡើងវិញទេ។ ក៏ប៉ុន្តែបើសិនណាជាឲ្យខ្ញុំរាប់រៀប ខ្ញុំហ្នឹងអាចរាប់រៀបបាន ដោយមិនបាច់មើលឯកសារ។

[០៩:២៤:៤៩]

**សៈ** ខ្ញុំចង់សួរលោកបន្តិចទៀតអំពីបញ្ហានេះ មុនខ្ញុំបន្តទៅមុខ។ តើលោកនៅតែអះអាងថាការស្ដាប់ចម្លើយហ្នឹង គឺធ្វើឡើងប្រហែលជា ១ឆ្នាំ ២ឆ្នាំមុន មិនមែន៧ឆ្នាំមុនទេ តើលោកនៅតែអះអាងបែបនេះដដែលមែនដែរឬទេ?

**ឆៈ** បាទ ខ្ញុំអះអាងថា ក្នុងអំឡុង២ឆ្នាំ។

**លោក វ៉ិចទ័រ កូប៉េះ**

ដើម្បីជាកំណត់ត្រាប្រតិចារឹក ឯកឧត្តមប្រធាន គឺថាខ្ញុំដឹងថា ឯកសារនេះត្រូវបានបង្កើតឡើង

នៅថ្ងៃ០១ ខែតុលា ២០០៨។ ដូច្នេះដោយសារតែមានពេលវេលាមានកំណត់ ខ្ញុំសូមបន្តទៅមុខ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

លោកប្រធាន ខ្ញុំសូមកាត់ផ្តាច់។ ខ្ញុំមានឯកសារជាភាសាបារាំង គឺឯកសារកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ដែលមានត្រាមួយចុះថ្ងៃទី២០ មិថុនា ឆ្នាំ២០០៩ លោកប្រធាន។ សុំទោស តាមពិតថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ដែលជាថ្ងៃដែលឯកសារហ្នឹងត្រូវបានទទួលដោយតុលាការយើងនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំនឹងបន្តបញ្ហានេះនៅពេលក្រោយ ប៉ុន្តែឥឡូវនេះខ្ញុំសូមបន្តទៅមុខ ដោយសារតែពេលវេលាមានកំណត់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីតើលោកចាំទេថា មានអ្វីកើតឡើងនៅថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ នោះ?

[០៩:២៦:៥៣]

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំសូមឆ្លើយបំភ្លឺចំពោះមុខលោកប្រធានថា ខ្ញុំបាទ ជាជនរងគ្រោះម្នាក់នៅក្នុងអំឡុង ៣ឆ្នាំ ៨ខែ នៅសម័យប៉ុលពត។ អ៊ីចឹងខ្ញុំបាទ បានធ្វើការជម្លៀសចេញពីលំនៅដ្ឋានទៅកាន់ទីភ្នំ គឺបានទៅដល់វត្តច្រកស្តេច។ ហើយទៅដល់វត្តច្រកស្តេចនេះ គេបានប្រកាសចំពោះមន្ត្រីរាជការ គ្រូបង្រៀន ទាហានដើម្បីបើកអង្ករយកធ្វើដំណើរទៅកាន់ការងារដើមរបស់ខ្លួនវិញ។

**ស៖** ឥឡូវនេះ ខ្ញុំចង់បញ្ជាក់បន្តិចគឺថ្ងៃ១៧ មេសា ៧៥ តើលោករស់នៅទីណាដែរ? ហើយមានអ្វីកើតឡើងចំពោះលោក និងក្រុមគ្រួសាររបស់លោកនៅថ្ងៃនោះ?

**ឆ៖** ឆ្នាំ៧៥ គឺខ្ញុំបានជម្លៀសចេញទៅតាមតំបន់ព្រៃភ្នំនោះ គឺដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹងថា អត់ទាន់បានជ្រកកោននៅក្នុងសហករណ៍ណានៅឡើយទេ។ ពេលនោះ គឺបានចុះឈ្មោះបើកអង្ករ បើកអង្ករហើយ ក្រុមការងាររបស់គាត់បាននិយាយថា បើកអង្ករហើយ ដើម្បីវិលមកខេត្តវិញ ហើយដើម្បីបម្រើ ធ្វើការងារបន្ត។ អ៊ីចឹងហើយក៏បានបើកអង្ករហ្នឹងមកហើយ គេយកទៅសម្លាប់ចោលទាំងអស់តែម្តង។

**ស៖** លោកសាក្សីសូមស្តាប់សំណួរខ្ញុំ គឺថ្ងៃ១៧ មេសា ៧៥ តើមានអ្វីកើតឡើងនៅថ្ងៃ នៅសប្តាហ៍ទី១ គឺថ្ងៃ១៧ ដល់ថ្ងៃ២៤? ថាតើក្នុងរយៈពេល៧ថ្ងៃដំបូងហ្នឹងលោកធ្វើអ្វី លោកដើរ ឬក៏លោក

នៅកន្លែងណាមួយ?

[០៩:២៩:២១]

**ឆ៖** ពេលនោះគឺខ្ញុំដើរ ព្រោះពេលនោះមានការជម្លៀសចេញ ដោយគិតថា នាំប្រជាពលរដ្ឋចេញពីផ្ទះ ពីលំនៅដ្ឋាន ដោយគាត់បានបញ្ជាក់ថា កុំនៅទីនេះ ឲ្យចេញទៅតាមការណែនាំរបស់គាត់ ហើយបន្តិចក្រោយមកទៀតនេះ មុខតែយន្តហោះរបស់អាមេរិកមកទម្លាក់គ្រាប់បែកកម្ទេចនៅទីនេះហើយ។ ដល់អ៊ីចឹងនាំគ្នាភ័យខ្លាច ក៏វេចបង្វេចជម្លៀសទៅតាមការណែនាំរបស់ក្រុមគាត់។

**ស៖** តើឪពុកម្ដាយលោកចាកចេញជាមួយគ្នា រួមជាមួយបងប្អូនលោកដែរឬទេ នៅពេលនោះ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ជូនដែរថា ក្រុមគ្រួសារខ្ញុំមានឪពុកម្ដាយ និងប្អូនបួននាក់។ អ៊ីចឹងអ្នកដែលត្រូវគេសម្លាប់ គឺឪពុកម្ដាយ និងប្អូនពីរនាក់។ រីឯខ្ញុំបាទនេះ ក៏ត្រូវគេសម្លាប់ដែរ ហើយនិងប្អូនម្នាក់ធ្វើគ្រូនោះ ក៏គេត្រូវយកទៅសម្លាប់ទាំងអស់គ្នា ទាំងគ្រួសារតែម្ដង។ ក៏ប៉ុន្តែក្នុងនោះ ខ្ញុំអាយុប្រហែលជាដប់បួនដប់ប្រាំឆ្នាំហើយ ខ្ញុំបាទបានធ្វើពុតជាស្លាប់នៅក្នុងរង្វង់សាកសពប្រាំពីរគ្រួសារ ដែលសុទ្ធតែជាទាហាន។ អ៊ីចឹងនៅពេលដែលគេបណ្ដើរយើងទៅ គេឲ្យយើងអង្គុយម៉ូ មួយជុំទាំងប្រាំពីរគ្រួសារហ្នឹង ហើយគេបាញ់សំដៅ បំបិទមាត់តែម្ដង។

**ស៖** លោកសាក្សី សូមលោកស្ដាប់ខ្ញុំបន្តិច។ ខ្ញុំចង់សួរលោកអំពីលោក ហើយនិងបងប្អូន ព្រមទាំងឪពុកម្ដាយបានចាកចេញ។ ខ្ញុំអត់ចង់សួរអំពីអ្វីដែលកើតឡើងនៅពេលក្រោយទេ។ ដូច្នេះខ្ញុំចង់ដឹងថាតើលោកដើរទៅទីណា? ហើយលោកដើរទៅដល់ទីណា ជាមួយក្រុមគ្រួសាររបស់លោក? ហើយលោកចេញពីភូមិផ្អេរ ហ្នឹងទៅដល់ណា? ដូច្នេះសូមលោកប្រាប់ខ្ញុំឲ្យបានច្បាស់បន្តិចពីចំណុចនេះ។

[០៩:៣១:៤៨]

**ឆ៖** បាទ ខ្ញុំធ្វើដំណើរចេញពីភូមិផ្អេរទៅ គឺទៅនៅដល់ គឺទៅដល់វត្តច្រកស្ដេច។

**ស៖** តើលោកប្រើពេលប៉ុន្មានថ្ងៃទៅដល់វត្តច្រកស្ដេច? តើឪពុកម្ដាយ បងប្អូន និងរូបលោកផ្ទាល់នេះចំណាយពេលប៉ុន្មានថ្ងៃដែរ ដើម្បីដើរទៅដល់វត្តច្រកស្ដេច?

**ឆ៖** បាទ រយៈពេលដែលត្រូវធ្វើដំណើរហ្នឹង គឺមិនមែនសំដៅទៅវត្តច្រកស្ដេចហ្នឹងតែម្ដងទេ គឺយើងមានការធ្វើដំណើរយឺតយ៉ាវជាទីបំផុត ព្រោះការធ្វើដំណើរនេះទៅដល់ព្រៃភ្នំ។ ចុះពីព្រៃភ្នំមកវិញបានធ្លាក់មកដល់វត្តច្រកស្ដេចនេះឯង។ ដល់មកដល់វត្តច្រកស្ដេចនេះ គឺអស់រយៈពេលជិត១០ថ្ងៃ។

**ស៖** តាមផ្លូវពីភូមិផ្អេរទៅវត្តច្រកស្ដេច តើលោកមានបានឈប់នៅភូមិមួយហៅថា ខ្ពង់ពពក?

**ឆ៖** បាទ ជម្រាបដែរថា ការធ្វើដំណើរយើងមិនអាចក្នុងមួយថ្ងៃហ្នឹងធ្វើដំណើរបាន៣ទៅ៤គីឡូនោះទេ ព្រោះពេលនោះឯង គឺមនុស្សច្រើនណាស់ មីរដេរដាសពេញផ្លូវតែម្តង។ អ៊ីចឹងការធ្វើដំណើរនេះ មួយព្រឹកស្មើនឹងកន្លះគីឡូដីយ៉ាងច្រើន។ បាទ កន្លះគីឡូទៅមួយគីឡូដីតាមផ្លូវធំ ផ្លូវតូច។ អ៊ីចឹងគេអត់ឲ្យយើងដើរតែប៉ាតណាប៉ាតណីទេ គេឲ្យដើរតាមផ្លូវឲ្យមូលគ្នាទាំងអស់។ អ៊ីចឹងមិនមែនតែមួយគ្រួសារខ្ញុំទេ ដែលដើរធ្វើដំណើរនេះ គឺរាប់ពាន់នាក់ដែលត្រូវធ្វើដំណើរជម្លៀសចេញទៅព្រៃភ្នំនេះ។

**ស៖** លោកសាក្សី សូមមេត្តាស្តាប់សំណួររបស់ខ្ញុំ ហើយសូមឆ្លើយខ្លីៗបានហើយ។ តើគ្រួសាររបស់លោក និងលោកមានឈប់នៅភូមិខ្ទុងពពក តាមផ្លូវនោះដែរឬទេ?

**ឆ៖** បាទ មានឈប់នៅខ្ទុងពពក នៅពេលថ្ងៃ។ បាទថ្ងៃបាយថ្ងៃត្រង់ គឺឈប់នៅនឹងវត្តខ្ទុងពពក។

[០៩:៣៤:៥៤]

**ស៖** ហើយបន្ទាប់មកទៀត តើត្រឹមត្រូវដែរឬទេ ដែលលោកធ្វើទៅភ្នំជំរាយ ស្រុកសាមគ្គី-មានជ័យ?

**ឆ៖** បាទ ខ្ញុំបានធ្វើដំណើរបន្តពីវត្តខ្ទុងពពកទៅគឺឆ្ពោយទៅដល់ភ្នំជំរាយ ស្រុកសាមគ្គីមានជ័យហ្នឹងនៅលើកំពូលភ្នំតែម្តងហើយ។

**ស៖** សូមអរគុណ។ ហើយបន្ទាប់មកលោកបន្តៗដំណើរទៅទិសខាងត្បូង ទៅភ្នំជំរាយ ហើយបានចុងក្រោយគឺថាទៅដល់វត្តច្រកស្តេច។ អ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** ការទៅដល់ភ្នំជំរាយហើយ គឺគាត់ត្រូវយកយើងមកខាងក្រោមវិញ ហើយយកមកខាងក្រោមហ្នឹងគឺដើម្បីឲ្យរកសហករណ៍នៅ។ អ៊ីចឹងខ្ញុំចេញពីជំរាយមក គឺសំដៅមកវត្តច្រកស្តេចនេះឯងតែម្តង។

**ស៖** សូមលោកគិតប្រមាណមើល៍ តើរយៈពេលប៉ុន្មានថ្ងៃពីភូមិផ្អេរទៅដល់វត្តច្រកស្តេច? បាទ សរុបទៅ តើលោកត្រូវដើរអស់រយៈពេលប៉ុន្មានថ្ងៃ?

**ឆ៖** ខ្ញុំឲ្យ និយាយឲ្យវាច្បាស់តែម្តងហ្នឹង គឺវាមិនច្បាស់ពេកទេ។ ក៏ប៉ុន្តែការធ្វើដំណើរពេលនោះខ្ញុំធ្វើការសន្និដ្ឋានទៅប្រហែលជា ជាង១០ថ្ងៃហ្នឹងហើយ គឺទៅដល់វត្តច្រកស្តេចនេះ។

**ស៖** នៅពេលលោកទៅដល់វត្តច្រកស្តេច តើលោកបានឃើញអ្វីខ្លះ? តើលោកនៅចាំអ្វីខ្លះ មានបទពិសោធន៍ជួបប្រទះអ្វីខ្លះ ពេលទៅដល់វត្តច្រកស្តេច?

[០៩:៣៧:០១]

**ឆ៖** បាទ ជម្រាបដែរថា នៅពេលនៅខ្ញុំធ្វើដំណើរទៅដល់វត្តច្រកស្តេចនេះ គឺដាច់ស្បៀង។ ដាច់ស្បៀង អស់អង្ករ និយាយជារួមថា អស់អង្ករហូបហើយ។ ហើយដល់ពេលដែលក្រុមការងាររបស់គណៈកម្មការ របស់ក្រុម៣ឆ្នាំ ៨ខែ ដែលហៅថា ប៉ុល ពត នេះគឺគាត់បានឃោសនាបើកអង្ករឲ្យយើងដើម្បីវិលត្រឡប់ទៅធ្វើការងារដើមវិញ។ អ្នកណាធ្វើអ្វី ឲ្យទៅធ្វើហ្នឹងវិញ។

**ស៖** លោកសាក្សី ពេលនោះលោកមានអាយុតែ១៤ឆ្នាំទេ លោករស់នៅជាមួយឪពុកម្តាយហើយនិងប្អូនស្រីរបស់លោក។ តើឪពុកម្តាយរបស់លោក គាត់ធ្វើអ្វី? ហើយនៅពេលទៅដល់វត្តច្រកស្តេចនោះ តាមដែលលោកចាំ តើលោកបានឃើញអ្វីខ្លះ? សូមលោករៀបរាប់ជូនតុលាការឲ្យបានលម្អិតបន្តិច។

**ឆ៖** បាទ អរគុណ។ អ៊ីចឹងក្នុងឯកសារនេះ ខ្ញុំមានឆ្លើយម្តងហើយ តែពេលនេះខ្ញុំមិនបាច់មើលឯកសារទេ ព្រោះរឿងនេះ គឺវាកើតមានព្រឹត្តិការណ៍ឃើញនឹងភ្នែករបស់ខ្ញុំផ្ទាល់។ អ៊ីចឹងខ្ញុំសូមរាប់រៀបពីបញ្ហានេះបន្តិច វាវែងបន្តិចរឿងនេះ។ នៅពេលដែលបើកអង្ករបានហើយៗ ម៉ោងប្រហែលជា១មួយគេត្រូវនាំចេញទៅរកសហករណ៍នៅ។ ដល់តែពេលនាំចេញទៅរកសហករណ៍នៅ គឺយើងបើកអង្ករបានគឺគេបញ្ចេញហើយ។ គេបញ្ចេញទៅ ដល់តែពេលដើរទៅដល់ភូមិមួយ ដីទួលមួយដែលហៅ ព្រៃរូងខ្លា។ អ៊ីចឹងរហូត – ធ្វើដំណើរតាំងពីម៉ោងមួយ រហូតទៅដល់ព្រៃរូងខ្លានេះ គឺគាត់ឲ្យយើងដាក់សំពាយ បង្វេចនៅ១មួយឆ្លងអូរខាងនេះ ខាងជើង ហើយគេឲ្យដើរតែខ្លួនចេញទៅខាងត្បូងអូរ។ នៅពេលដើរទៅដល់ខាងត្បូងអូរនោះ គឺមានកងទ័ពប្រដាប់ដោយអាវុធ មកភ្ជង់ ក្រៀកយកទៅកណ្តាលដីទួលរូងខ្លានេះ។ ហើយឲ្យអង្គុយជាដុំ ដូចខ្ញុំបានជដែកអំមិញអ៊ីចឹងថា ឲ្យអង្គុយជាដុំ ហើយគេថយមកគេបាញ់ផ្ទាច់សម្លាប់ទាំងអស់ សូម្បីតែកូនតូចគឺចាប់យួរជើងឡើង វៃក្បាលនឹងគល់ឫស្សី នឹងគល់ល្ហៀង។ រួចហើយគេអូសយកទៅទម្លាក់ក្នុងរណ្តៅគ្រាប់បែក។ គេអូសសាកសពហ្នឹង យកទៅទម្លាក់ក្នុងរណ្តៅគ្រាប់បែកកាប់ស្លឹកឈើគ្រប ហើយគេទៅផ្ទះអស់ទៅ។ ខ្ញុំក៏បានលូនចេញពីក្នុងរណ្តៅហ្នឹងមក បាទព្រោះខ្ញុំ កាលសម័យនុ៎ង ខ្ញុំធំដែរហើយ ខ្ញុំមានស្មារតីមួយថា មិនត្រូវស្រែក មិនត្រូវយំទេ ធ្វើពុតជាស្លាប់នៅទីនោះជាមួយនឹងសាកសព។ ហើយគេអូសទាំងខ្ញុំហ្នឹង ទៅទម្លាក់ក្នុងរណ្តៅអាបេមួយនុ៎ងហើយ គេកាប់ស្លឹកឈើគ្រប មេឃរកភ្លៀងផង គេក៏ចេញទៅផ្ទះបាត់ទៅ។ ចេញទៅផ្ទះបាត់ទៅ ខ្ញុំលូនឡើងចេញពីសាកសពទាំងប្រាំពីរគ្រួសារ។ កាយឡើងមកលើ ហើយខ្ញុំស្រែកហៅមកបានគ្នាប្អូននាក់។ នៅសល់ជន

រងគ្រោះប្អូននាក់ ដែលត្រូវដំបងបែកក្បាលខ្លះ ខ្លះបាក់ឆ្អឹងជំនី ខ្លះបែកក្បាល។ ខ្ញុំក៏មើលទៅលទ្ធភាពដែលមិនអាចយកមកបាន ខ្ញុំទុកចោលនៅក្នុងរណ្តៅហ្នឹង ព្រោះថាវាមិនអាចរស់បាន ហើយអ្នកដែលអាចរស់បាន គឺខ្ញុំឲ្យដើរមកតាមខ្ញុំ។ លូនចេញពីរណ្តៅមក មកតាមខ្ញុំ ខ្ញុំដឹកនាំចូលទៅកាន់វត្តច្រកស្តេចនោះវិញ។

[០៩:៤១:០៣]

ទៅដល់វត្តច្រកស្តេចនោះហើយ មានអ្នកស្គាល់ ដែលជាៗបងប្អូន សាច់ញាតិ។ មានអ្នកស្គាល់គេឃើញខ្ញុំត្រូវគេបណ្តើរទៅចែកអង្ករហើយ ជម្លៀសចេញទៅហើយ គេសួរៗរកឪពុកម្តាយ។ គេសួររកឪពុកម្តាយ ខ្ញុំសល់បងប្អូនប្អូននាក់ហ្នឹង ក៏សុំបាយគេហូបអីហើយ ខ្ញុំខ្សឹបប្រាប់គេថា ឪពុកម្តាយខ្ញុំត្រូវគេយកទៅបាញ់ចោលអស់ហើយ។ ហើយនៅពេលនោះ កម្លាំងសន្តិសុខរបស់គាត់ គឺតាមស្រាវជ្រាវ ៗរកក្មេងប្អូននាក់ហ្នឹង។ ខ្ញុំចេះតែដឹកដៃបងប្អូនទាំងប្អូនហ្នឹងគេច នៅក្នុងចង្កោមមនុស្សដ៏ច្រើនកុះករហ្នឹង បាទគេច។ ល្ងាចម៉ោងប្អូនឡើងបានផ្ទុះ។ យើងនិយាយថា ដូចគោក្នុងក្រោលដែលអត់បញ្ចេញវាឲ្យស៊ីស្មៅអ៊ីចឹង។ ដល់វាបែកពីខ្ញុំហ្នឹងទៅគឺផ្ទុះ អ្នកខ្លះថាទេខ្ញុំទៅភ្នំពេញវិញ អ្នកខ្លះថាខ្ញុំទៅកំពង់ចាម ខ្លះថាទៅបាត់ដំបងវិញ។ គឺប្រមូលផ្តុំកម្លាំងនៅទីនេះ គឺគ្រប់ខេត្តក្រុង។ បាទ ខ្លះកំពង់សោមអ៊ីចឹងទៅ ខ្លះពោធិ៍សាត់អ៊ីចឹងទៅ។ អ៊ីចឹងដល់ពេលផ្ទុះសកម្មភាពនេះឡើង កម្លាំងរបស់គាត់ទប់ស្កាត់អត់បាន។ អ៊ីចឹងត្រូវបណ្តោយ បណ្តោយឲ្យអ្នកណាទៅណាទៅនុ៎ង ប៉ុន្តែគាត់មានកម្លាំងសេះគាត់ និងកងឈ្លបគាត់ បណ្តើរយើងទៅ អ្នកណាទៅណាទៅនុ៎ងទៅ ប៉ុន្តែមិនមែនទៅជាក្រុមតូចតាចទេ គឺទៅទាំងហ្វូងៗតែម្តង។

**សៈ** លោកសាក្សី ខ្ញុំនៅតែសួរទៅតាមលំដាប់លំដោយ។ នៅពេលដែលគ្រួសាររបស់លោក និងលោកទៅដល់នៅវត្តច្រកស្តេច តើលោកបានឃើញមនុស្សរាប់ពាន់នាក់ តើលោកបានឃើញអ្វីខ្លះនៅពេលលោកទៅដល់វត្តច្រកស្តេច?

**ឆៈ** បាទ វត្តច្រកស្តេចនេះ ជាកន្លែងដែលក្រុមការងាររបស់បន ប៉ុល ពត គាត់ប្រមូលផ្តុំកម្លាំងហ្នឹង ឲ្យជួបជុំគ្នានៅទីហ្នឹងតែម្តង បាទដើម្បីចម្រាញ់។ អ៊ីចឹងហើយ ដូចខ្ញុំបាននិយាយពីខាងដើមអ៊ីចឹងថា ត្រូវចាញ់ឃោសនា អ្នកខ្លះរត់ស៊ីក្លូទេ អួតថាខ្លួនឯងជាទាហាន ហើយដើម្បីបានអង្ករនោះ បានអង្ករដែលគេបើកឲ្យនោះ យកទៅបរិភោគ។ អ៊ីចឹងហើយ កន្លែងច្រកស្តេចនេះ គឺជាផែនការដែលគាត់ប្រមូលផ្តុំកម្លាំងប្រជាពលរដ្ឋទាំងអស់ បាទ ទៅៗៗជួបជុំគ្នានៅទីនុ៎ង។

[០៩:៤៣:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ សូមឲ្យបង្គាប់ឲ្យសាក្សីឆ្លើយខ្លីៗចំសំណួររបស់ខ្ញុំ។ ខ្ញុំយល់ឃើញថា ខ្ញុំមិនអាចជំរុញឲ្យសាក្សីឆ្លើយចំៗសំណួរខ្ញុំទេ។ ដូច្នេះសូមអន្តរាគមន៍។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកបានឃើញអ្វីនៅពេលលោកទៅដល់វត្តច្រកស្តេច? លោកទៅដល់ទីនោះនៅម៉ោងប៉ុន្មាន? ហើយតើស្ថានភាពនៅវត្តច្រកស្តេចហ្នឹង វាមានសភាពបែបណា? សូមឆ្លើយឲ្យចំៗសង្ខេប។

**លោក នីកូឡាស គូមជែន៖**

ប្រហែលជាវាមានសារប្រយោជន៍។ សូមឲ្យមេធាវីការពារក្តីសួរឲ្យចំចំណុចតែម្តង ពីព្រោះសាក្សីនិយាយថា គ្រួសារបានទៅដល់ហ្នឹង។ ហើយក្រោយមក ក៏មានឧបទ្ទវហេតុនេះកើតឡើង ព្រឹត្តិការណ៍នេះកើតឡើង។ ដូច្នេះ ដើម្បីជាកំណត់ត្រាប្រតិចារឹកឲ្យបានច្បាស់លាស់ សូមឲ្យមេធាវីការពារក្តីសួរឲ្យចំៗ។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

[០៩:៤៤:៤៧]

**ប្រធានអង្គជំនុំ៖**

ចុះ លោកមេធាវីសួរឲ្យចំចំណុចទៅ ហើយសាក្សីហ្នឹងក៏អ៊ីចឹងដែរ គឺលោកសួរ -- ឆ្លើយវែងពេក ដែលមិនត្រូវនឹងសំណួររបស់មេធាវីដែលសួរ។ ដូច្នេះគឺលោកត្រូវស្តាប់ថា សំណួរគេចង់សួរប៉ុណា អ៊ីចឹងយើងឆ្លើយខ្លីៗបានហើយ។ សូមអញ្ជើញបន្តលោមមេធាវី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណឯកឧត្តមប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅពេលលោកទៅដល់ភ្នំ -- ចេញពីភ្នំជំរាយ ក៏ទៅបន្តដំណើរទៅដល់វត្តច្រកស្តេច។ លើកដំបូងដែលលោកទៅដល់ច្រកស្តេចនេះ ថាតើលោកបានឃើញអ្វី? លោកបានឮអ្វី?

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំបាទបានធ្វើដំណើរទៅដល់វត្តច្រកស្ដេចនេះ គឺឃើញប្រជាពលរដ្ឋយ៉ាងច្រើន ហើយនិងកម្លាំងសមត្ថកិច្ចរបស់ក្រុមការងារ ប៉ុល ពត ហ្នឹងគឺគេនៅទីនោះ។

**ស៖** តើលោកពិតជាបានឃើញរាប់ពាន់គ្រួសារនៅទីនោះមែនទេ?

**ឆ៖** បាទ ខ្ញុំរាប់ -- ខ្ញុំគិតថាមិនខុសទេ គឺប្រជាពលរដ្ឋនៅទីនោះរាប់ពាន់គ្រួសារតែម្ដង។

**ស៖** ហើយបន្ទាប់មកទៀតមានអ្វីកើតឡើង? សូមរៀបរាប់ ថាតើមានអ្វីកើតឡើងពេលលោកទៅដល់ នៅថ្ងៃបន្ទាប់មានអ្វីកើតឡើង?

**ឆ៖** ពេលខ្ញុំទៅដល់ហ្នឹង គឺគេៗធ្វើការអំពាវនាវហៅរកអ្នកដែលបានធ្វើការនៅៗតាមបណ្ដាខេត្តដើម្បីយកទៅធ្វើការវិញ។

[០៩:៤៦:៥៥]

**ស៖** ហើយមានអ្វីកើតឡើងបន្ទាប់ពីនេះមកទៀត?

**ឆ៖** ខ្ញុំបាននិយាយអំមិញដែរថា ក្រោយពេលចាញ់ឃោសនាបើកអង្គរហើយ គេយកទៅបាញ់ចោលតែម្ដង។

**ស៖** លោកសាក្សី លោកទើបតែឆ្លើយថាមានប្រជាជនរាប់ពាន់គ្រួសារ ហើយនិងមានការប្រកាសនៅទីនោះ។ តើមានអ្វីកើតឡើង? តើគេមានតុ មានកៅអីអង្គុយដើម្បីសរសេរប្រវត្តិរូបប្រជាជនទេ? តើកងទ័ពខ្មែរក្រហមនេះ អាចបញ្ជាក់ថាអ្នកណាជាទាហាន លន់ នល់ អ្នកណាមិនមែនជាទាហាន លន់ នល់ បានដោយរបៀបណា? សូមលោកបញ្ជាក់ឲ្យបានច្បាស់លាស់។

**ឆ៖** បាទ ក្នុងពេលនោះ គឺគាត់ដាក់មីក្រូប្រកាសរកអ្នកដែលធ្វើទាហាន អ្នកមន្ត្រីរាជការហើយហៅឲ្យមកបើកអង្គរដើម្បីទៅធ្វើការងារនោះវិញ។ មានការកត់ហើយ នៅពេលយើងចូលទៅបើកអង្គរគឺគេកត់ហើយ គេកត់ឈ្មោះហើយ។ បាទ ឈ្មោះអី ប្រពន្ធឈ្មោះអី កូនប៉ុន្មាននាក់។ អ៊ីចឹងគេកត់ គេបើកឲ្យរបបហ្នឹងតាមហ្នឹងមក ហើយគេឲ្យយើង -- គេកុហកយើងថាឲ្យយើងចេញទៅធ្វើការនៅកន្លែងដដែលវិញ។

**ស៖** បាទ សូមសួររបៀបផ្សេងវិញ។ លោក និងគ្រួសាររបស់លោកឮគេប្រកាសតាមមីក្រូនេះ។ តើគ្រួសាររបស់លោក អ៊ីចឹងបន្ទាប់មកធ្វើអ្វី?

[០៩:៤៨:៥៣]

**ឆ៖** ក្រុមគ្រួសារដែលជាឪពុកម្ដាយខ្ញុំហ្នឹង បានទៅចុះឈ្មោះបើកអង្ករជាមួយគេ។

**ស៖** តើឪពុករបស់លោកពិតជាអតីតមន្ត្រីរបប លន់ នល់មែនទេ?

**ឆ៖** បាទ ជម្រាបប្រសាសន៍ថា ឪពុកខ្ញុំកាលជំនាន់ លន់ នល់ គឺគាត់ធ្វើទាហាន។

**ស៖** នៅពេលដែលឪពុករបស់លោកសរសេរឈ្មោះរបស់គាត់ និងមុខងាររបស់គាត់ តើគាត់សរសេរថាជាទាហាន ឬក៏អត់ទេ?

**ឆ៖** បាទ គាត់ចុះឈ្មោះជាទាហាន។

**ស៖** តើឪពុករបស់លោកមានបានប្រាប់លោកអំពីទម្រង់បែបបទហ្នឹង ទម្រង់បែបបទប្រវត្តិរូបហ្នឹង តើគាត់ត្រូវសរសេររយៈពេលប៉ុន្មានដើម្បីបញ្ជាក់ទៅប្រាប់គេហ្នឹង? ហើយគាត់បានសរសេរថាគាត់ហ្នឹងធ្លាប់ធ្វើជាទាហាន អ៊ីចឹងមានអ្វីកើតឡើងបន្ទាប់មកទៀត ក្រោយពីសរសេរប្រវត្តិរូបហើយ?

**ឆ៖** បាទ ក្រោយពីទៅចុះឈ្មោះបើកអង្ករហើយ គឺគេបើកអង្ករបានហើយ គេហៅឈ្មោះយើងចេញជាក្រុមគ្រួសារទៅ គឺគេយកទៅខាងត្បូងវត្ត។ ចេញច្រកតូចមួយខាងត្បូងវត្ត។ គេប្រាប់យើងថាទៅរកផ្ទះនៅ។

**ស៖** ខ្ញុំកំពុងតែនិយាយនៅក្នុងម៉ោពេលវេលាដែលឪពុករបស់លោកចុះឈ្មោះហ្នឹង តាមដែលលោកចាំហ្នឹង ថាគាត់សរសេរថាគាត់ធ្វើជាទាហាន។ តើមានអ្វីក្រៅពីនេះទៀត ដែលលោកអាចចាំបាន? តើគាត់មានប្រាប់លម្អិតថា គាត់សរសេរអំពីអ្វីខ្លះ ឬអ្នកដទៃមានបានប្រាប់លោកថា គេសរសេរអំពីខ្លះដែរទេ?

[០៩:៥១:១៩]

**ឆ៖** បាទ គាត់អត់មានបានសរសេរអីក្រៅពីហ្នឹងទេ ព្រោះពេលនោះ គឺគេកំពុងអំពាវនាវរកអ្នកណាធ្វើទាហាន។ អ៊ីចឹងទៅចុះឈ្មោះជាទាហាន គេបើកអង្ករឲ្យតែម្ដង។

**ស៖** ដោយសារតែមានប្រជាជនរាប់ពាន់គ្រួសារអ៊ីចឹង បើលោកដឹង តើគេត្រូវការរយៈពេលប៉ុន្មានដែរ ដើម្បីចុះបញ្ជីសរសេរប្រវត្តិរូបហ្នឹង?

**ឆ៖** បាទ ក្នុងនោះមិនដឹងជាគេត្រូវធ្វើប៉ុន្មានថ្ងៃទេ ព្រោះវាច្រើនពេក ច្រើនគ្រួសារពេក។ និយាយទៅថាក្នុងទីធ្លាវត្តហ្នឹង ក្នុងបរិវេណវត្តហ្នឹង ពេញទៅដោយមនុស្ស។ ហើយនៅលើសាលាឆាន់មួយ សាលាឆាន់ឈើមួយហ្នឹង វាមានកម្ពស់ប្រហែលជា៣ម៉ែត្រ អ៊ីចឹងគេលើកអង្ករទៅដាក់លើហ្នឹង ហើយគេប្រកាសមីក្រូ។ អ្នកណាបើកបានគេនាំចេញៗ។

**ស៖** ថាតើនៅថ្ងៃនុ៎ង ឬក៏ថាគិតចាប់តាំងពីថ្ងៃរំដោះហ្នឹងមក តើឪពុករបស់លោកមានស្លៀកពាក់ឯកសណ្ឋានទាហានទេ ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់គាត់ទេ?

**ឆ៖** បាទ គាត់ស្លៀកខោទាហានប៉ារ៉ា ហើយពាក់អាវយឺតស។

**ស៖** បន្តបន្ទាប់មកទៀត ចាប់ពីពេលចុះឈ្មោះ តើគ្រួសាររបស់លោក ឪពុកម្តាយ ប្អូនស្រី គឺថាបន្ទាប់មកចាកចេញពីវត្តនោះទៅ ឬក៏យ៉ាងណា?

[០៩:៥៣:៣៤]

**ឆ៖** បាទ ក្រោយពេលបើកអង្គរបាន ចុះឈ្មោះបើកអង្គរបានហើយ គឺគេនាំចេញ។ គេនាំចេញដូចខ្ញុំបានជម្រាបអ៊ីចឹង នាំចេញទៅច្រកខាងត្បូងវត្ត ច្រកតូចមួយខាងត្បូងវត្ត គឺគេប្រាប់ថា ទៅរកផ្ទះនៅ ហើយគេយកទៅសម្លាប់តែម្តង។

**ស៖** លោកថា លោកចេញទៅទិសខាងត្បូង ដើម្បីចូល ដើម្បីសំដៅទៅខាងភូមិព្រៃរូងខ្លា។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើត្រឹមត្រូវដែរឬទេ ថាភូមិព្រៃរូងខ្លានេះមានចម្ងាយ៧គីឡូម៉ែត្រ នៅទិសខាងជើងត្រឹមត្រូវដែរទេ?

**ឆ៖** មិនដល់៧គីឡូម៉ែត្រទេ បើខ្ញុំស្មានមើលទៅ ប្រហែលជា២គីឡូដីទេ នៅទិសខាងត្បូង។

**ស៖** ប្រហែលជា -- និយាយថា៧០គីឡូ នៅទិសខាងជើងហ្នឹង គឺយើងនិយាយពីចម្ងាយថាមាន៧០គីឡូនៅទិសខាងជើង។ តើត្រឹមត្រូវដែរទេ?

**ឆ៖** មិនត្រឹមត្រូវទេ។ ខុសទាំងទិស ព្រោះខ្ញុំនិយាយប្រាប់ថា គេបើកអង្គរហើយ គេនាំទៅទិសខាងត្បូង ប្រមាណ២គីឡូម៉ែត្រពីវត្តច្រកស្តេច។

**ស៖** មានភូមិមួយឈ្មោះព្រៃរូងខ្លា នៅទិសខាងជើង។ លោកធំធាត់ដឹងក្តីនៅកំពង់ឆ្នាំង លោកជាអធិការ។ តើលោកដឹងទេថា ភូមិព្រៃរូងខ្លាមានចម្ងាយ៧០ៗគីឡូម៉ែត្រពីវត្តច្រក ស្រុក -- គឺ៧០គីឡូម៉ែត្រពីស្រុកច្រកស្តេច ត្រូវដែរឬក៏អត់?

**ឆ៖** បាទ មិនត្រឹមត្រូវទេ។

**ស៖** ដូច្នេះក្រុមគ្រួសាររបស់ចាកចេញពីវត្តច្រកស្តេច។ សូមជម្រាបតុលាការថាមានអ្វីកើតឡើង?

[០៩:៥៦:៤៥]

**ឆ៖** បាទ នៅពេលដែលចេញផុតពីវត្តច្រកស្តេចទៅ គឺគេយកផ្លូវអូរមួយ ហើយគេឲ្យយើងដាក់សម្ភាយសម្ភារៈហ្នឹងនៅខាងត្បូងអូរ ហើយគេឲ្យយើងដើរទៅ -- ខាងជើងអូរ ហើយគេនាំតែមនុស្ស ដោយគ្មានកាន់បង្វេចអីទៅជាមួយទេ ឆ្លងអូរទៅខាងត្បូង។ ឆ្លងអូរទៅខាងត្បូង នៅពេលដែលឆ្លងមាត់អូរហ្នឹងទៅ គឺកងកម្លាំងយោធាគេដែលប្រើប្រាស់ដោយអាវុធនោះ គេមកឆ្កកយកតែម្តង។ យកៗទៅសម្លាប់តែម្តង។

**ស៖** តើមានអ្វីកើតឡើងតែម្តងនោះ? តើមានប្រជាជនប្រហែលជាប៉ុន្មាននាក់ដើរទៅហ្នឹងជាមួយលោក?

**ឆ៖** និយាយជារួម គឺអ្នកដែលទៅជាមួយហ្នឹងគឺសាច់សាលោហិត ក្រុមញាតិមិត្តរបស់ឪពុកខ្ញុំហ្នឹងប្រាំពីរគ្រួសារ។

**ស៖** លោកចង់និយាយប្រាំពីរហ្នឹង គឺចំនួនប្រាំពីរគ្រួសារ ឬក៏គ្រួសារមួយដែលមានគ្នាប្រាំពីរនាក់?

**ឆ៖** ខ្ញុំចង់និយាយថាក្នុងមួយគ្រួសារមិនក្រោមពីប្រាំពីរនាក់ទេ។ បាទ អ៊ីចឹងប្រាំពីរគ្រួសារហ្នឹងវាជិតពេញ បើរាប់ទៅថា វ៉ៃអូសទម្លាក់ទៅក្នុងរណ្តៅអាបេហ្នឹង គឺជិតពេញតែម្តង។

**ស៖** លោកកុំនិយាយទៅជ្រៅពេក។ ឥឡូវខ្ញុំសួរសិន ថាតើលោកដើរជាមួយអ្នកណាខ្លះ? ហើយលោកដើរទៅទិសដៅណាខ្លះទៅព្រៃរូងខ្លានោះ?

[០៩:៥៩:០៤]

**ឆ៖** និយាយជារួមថា ខ្ញុំទៅជាមួយញាតិមិត្ត បងប្អូនរបស់ឪពុកម្តាយខ្ញុំហ្នឹងប្រាំពីរគ្រួសារដោយខ្ញុំចាំឈ្មោះមិនអស់ទេ ដល់បច្ចុប្បន្ននេះនោះ។ ខ្ញុំអត់ចង់សួរអំពីឈ្មោះទេ ប៉ុន្តែខ្ញុំចង់ដឹងថាតើក្រុមហ្នឹងមានចំនួនប៉ុន្មាននាក់? មានទំហំប៉ុនណាដែរ?

**ស៖** ខ្ញុំក្តាប់អត់បានទេ ដល់លម្អិតពេកអ៊ីចឹង។ គ្រួសារខ្លះវាមានប្រាំនាក់ គ្រួសារខ្លះវាមានដល់ទៅ១០នាក់។ បាទហើយគ្រួសារខ្លះនោះ វាមានដល់ទៅ១២នាក់ណោះខ្មែរ។ បាទ ហើយអ៊ីចឹងក្នុងចង្កោមប្រាំពីរគ្រួសារហ្នឹង គឺគេយកទៅវ៉ៃចោលនៅចំណុចហ្នឹងតែមួយ។

**ស៖** មិនអីទេលោកសាក្សី ខ្ញុំបន្តទៅមុខទៀត។ លោកដើរជាមួយគ្រួសារចំនួនប្រាំពីរគ្រួសារ។ ដូច្នេះខ្ញុំចង់ដឹងថា តើមានអ្វីកើតឡើងបន្តទៀត?

**ឆ៖** អត់មានអីកើតឡើងតទៅទៀតទេ បើគេទៅវ៉ៃចោលហើយ។ រួចខ្ញុំហ្នឹងសល់ពីស្លាប់មកហើយ ដែលរត់ចេញមក។ សល់ពីស្លាប់ហ្នឹងប្អូននាក់ ប្អូនស្រីពីរ ជីដូនមួយៗពីរនាក់ និងបងប្អូនបង្កើតខ្ញុំពីរនាក់ ប្រុសមួយស្រីមួយដូចគ្នា។

**ស៖** លោកសាក្សី លោកជាអធិការប៉ូលិស ដូច្នេះលោកដឹងច្បាស់អំពីការសួរលម្អិត។ ដូច្នេះលោកសូមជម្រាបឲ្យបានលម្អិតបន្តិច គឺលោកនិយាយថា លោកដើរទៅជាមួយក្រុមគ្រួសារចំនួនប្រាំពីរ ដូច្នេះតើលោកអាចផ្តល់ព័ត៌មានលម្អិតបន្ថែមបានទេថា លោកឃើញអ្វី? លោកឮអ្វី?

[១០:០១:១៨]

**ឆ៖** ខ្ញុំមានបានឃើញថា នៅពេលដែលធ្វើដំណើរទៅ គឺមានកងទ័ពប្រដាប់ដោយអាវុធ ពេលឆ្លងអូរមួយហ្នឹងទៅ គឺមានកងទ័ពប្រដាប់អាវុធមកភ្ជង់យកទៅចូលក្នុងរូងព្រៃខ្លាហ្នឹងឯង ហើយធ្វើការកាប់សម្លាប់ បាញ់សម្លាប់។

**ស៖** មានម្តងហ្នឹងលោកនិយាយថា លោកឃើញទាហានប្រដាប់អាវុធ។ តើពួកគេធ្វើអ្វី? ពួកគេនិយាយអ្វី? សូមលោកជម្រាបដល់តុលាការឲ្យបានច្បាស់ នៅពេលដែលក្រុមប្រជាជនហ្នឹងឃើញទាហានទាំងអស់ហ្នឹង តើពួកគាត់មានអ្វីកើតឡើង?

**ឆ៖** បាទ នៅពេលដែលគេបណ្តើរទៅ គឺគេភ្ជង់កាំភ្លើងយើងទៅ ហើយគេប្រាប់ថាឲ្យដើរទៅមុខឲ្យត្រង់ កុំរត់ បើរត់បាញ់ចោល។ នៅពេលដែលយើង -- គេបណ្តើរយើងទៅដល់គេឲ្យយើងអង្គុយម្តុំ ទាំងប្រាំពីរគ្រួសារហ្នឹងគឺអង្គុយម្តុំ។

**ស៖** តើប្រជាជននៅក្នុងក្រុមហ្នឹងមានប្រតិកម្មអ្វីដែរ? តើមានការពិភាក្សាគ្នារវាងឪពុកលោក និងទាហានទាំងអស់នោះដែរឬទេ? តើមានអ្វីកើតឡើង?

**ឆ៖** អត់បានពិភាក្សាអីគ្នាទេ ព្រោះយើងអត់មានអាវុធអីជាប់ខ្លួន សូម្បីតែកាំបិត ពូថៅហ្នឹងក៏អត់មានផង គឺគេឲ្យដាក់សម្ភារៈហ្នឹងម្តុំ ហើយខាងជើងអូរ ហើយគេនាំឲ្យមនុស្សហ្នឹងដើរទៅខាងត្បូងអូរ។ ក្រោយពេលដើរទៅខាងត្បូងអូរហើយ មានកម្លាំងប្រដាប់អាវុធនោះមកភ្ជង់យកទៅសម្លាប់តែម្តង។

[១០:០៣:៤៥]

**ស៖** លោកនិយាយថា ឪពុកលោកគឺជាទាហាន លន់ នល់ ចុះអ្នកដទៃទៀតនៅក្នុងក្រុមហ្នឹងមានអ្នកណាម្នាក់ -- មានអ្នកដទៃទៀតជាទាហាន លន់ នល់ ដែរឬទេ?

**ឆ៖** បាទ បើតាមខ្ញុំមើលក្នុងប្រាំពីរនាក់ហ្នឹងមានពេទ្យ ៗមួយគ្រួសារ ពេទ្យស៊ីវិលទេ ហើយមានគ្រូបង្រៀនមួយគ្រួសារ ហើយក្រៅពីនោះសុទ្ធទាហានទាំងអស់។

**សៈ** អ៊ីចឹងមានន័យថា ទាហាននុំងគេភ្ជង់កាំភ្លើងលោក ហើយបណ្តើរចេញទៅ។ ហើយលោកនិយាយថា លោកឮស្រែក មានសំឡេងស្រែក ហើយមានអ្វីកើតឡើងបន្តទៀត?

**ឆ៖** នៅពេលដែលគេឱ្យយើងអង្គុយម្ដុំហ្នឹង គឺគេថយចេញមកក្រៅ ហើយគេបាញ់សម្លាប់។ សល់ពីការបាញ់សម្លាប់ នៅកូនក្មេងតូចតាចហ្នឹង គឺគេដើរទៅវៃសម្លាប់នៅជាមួយម្ដាយហ្នឹងតែម្ដង។

**សៈ** នៅក្នុងចម្លើយរបស់លោកដែលយើងបានទទួលបាននោះគឺថា លោកនៅក្នុងក្រុមទី១ គឺថាមានមនុស្សមួយក្រុមដំបូង គេបំបែកយកចេញទៅ ហើយបន្ទាប់មកបានគេយកមួយក្រុមបន្តទៀត។ តើអ៊ីចឹងមែនដែរឬទេ? វាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ បើតាមការសន្និដ្ឋានរបស់ខ្ញុំ ខ្ញុំជឿថា មិនមែនមានតែមួយក្រុមដែលយកក្រុមគ្រួសារបងប្អូនម៉ែឪខ្ញុំទៅសម្លាប់ហ្នឹង តែមួយក្រុមហ្នឹងទេ។ នេះគេៗចែកជាក្រុមៗ របស់គេហើយៗ។ ចាំតែបើកអង្គរហើយ មួយទៅក្រុមនេះ មួយទៅក្រុមនោះ ហើយមានកម្លាំងគេសម្រាប់កម្ទេចហ្នឹងជាស្រេចអស់ហើយ។

**សៈ** លោកសាក្សីខ្ញុំមិនចាប់អារម្មណ៍ទៅលើការសន្និដ្ឋានរបស់លោកទេ ប៉ុន្តែខ្ញុំចាប់អារម្មណ៍ទៅលើការដែលបែងចែកក្រុមទៅជាក្រុមស្ត្រី និងក្រុមបុរស គឺជាចម្លើយដែលលោកបានផ្តល់នៅពេលលើកមុន។ តើអ៊ីចឹងមែនទេ?

[១០:០៦:២៣]

**ឆ៖** បាទ ពិតមែន។ ជំហានដំបូង គឺគេឱ្យប្រុសៗ ឪពុក -- មនុស្សនិយាយរួមៗ ថាមនុស្សដែលមានកម្លាំងទប់ទល់នឹងគេនោះ ក្រុមហ្នឹងទៅមុន ឆ្លងអូរទៅមុន។ បន្ទាប់មកៗយកប្រពន្ធកូនទៅតាមក្រោយ។

**សៈ** តើបុរសៗដែលៗនៅក្នុងក្រុមហ្នឹង ស្តាប់បង្គាប់ដែរឬទេ ស្តាប់បង្គាប់ទាហានហ្នឹងដែរទេ? ហើយទាហានហ្នឹង គេប្រាប់ទៅក្រុមបុរសៗហ្នឹងថាយ៉ាងម៉េច? ពាក្យសម្តីដែលគេនិយាយហ្នឹងវាយ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំនិយាយទៅពេលហ្នឹង គឺខ្ញុំនៅតូច។ ខ្ញុំរត់តាមឪពុកខ្ញុំទៅ ដោយសារគេប្រាប់ថា ឱ្យទៅកាប់ឈើ បោះជំរំនៅសិន ព្រោះជិតយប់ហើយ។ អ៊ីចឹងឆ្លងអូរទៅដើម្បីទៅកាប់ឈើ មកធ្វើជំ ឯប្រពន្ធ

កូននៅខាងជើងអូរនៅឡើយទេ។ ដល់តែពេលនាំបណ្ដើរផុតពីអូរទៅ ខ្ញុំឃើញទាហានហ្នឹងចេញមកភ្ជង់ឪពុកខ្ញុំ និងអ្នកប្អូនដប់នាក់ទៀតដែលថាញាតិមិត្តប្រុសៗដែលមានកម្លាំង កំលោះ ជំទង់អីហ្នឹង គឺគេយកទៅមុនហើយ។ តែខ្ញុំវានៅទាប នៅតូច គេអត់យកទេ គេដេញឲ្យមកក្រោយវិញ ដេញឲ្យខ្ញុំរត់មកក្រោយវិញ។ ខ្ញុំគ្រាន់តែក្រឡេកឃើញថាគេភ្ជង់យកទៅហើយ ខ្ញុំរត់មកប្រាប់ម្ដាយមីងមានៅខាងក្រោយវិញ ថាគេយកប៉ាទៅបាញ់ចោលហើយ ឲ្យនាំគ្នារត់ តែគាត់អត់ជឿ។ រហូតដល់គេបាញ់សម្លាប់មនុស្សប្រុសទាំងអស់ហ្នឹងហើយ បានគេមកត្រឡប់មកយកប្រពន្ធកូនទៅតាមក្រោយ យកទៅកន្លែងដដែលហ្នឹង។

[១០:០៨:២៥]

**ស៖** តើកងទ័ពខ្មែរក្រហមបានឃើញលោកដើរតាមក្រុមបុរសៗហ្នឹងដែរទេ? ហើយតើទាហានខ្មែរក្រហមហ្នឹងមាននិយាយអ្វីប្រាប់លោកដែរឬទេ? តើលោកអាចបញ្ជាក់ឲ្យបានលម្អិតបន្តិចទៅលើចំណុចនេះបានទេ?

**ឆ៖** បាទ ជាដំបូងហ្នឹងគឺគេមកបំបែកក្រុមបុរសៗហ្នឹង គឺជាកងសេនាជនទេ អត់មានកាំភ្លើងទេ មានតែកាំបិតកកុកមួយ កន្សែងបង់កមួយទេ ដែលនាំបុរសៗទៅហ្នឹង ឆ្លងអូរទៅហ្នឹង។ នៅពេលដែលទៅដល់ ឆ្លងអូរផុត បានមានកងកម្លាំងប្រដាប់អាវុធ មកភ្ជង់យកទៅសម្លាប់។ ហើយខ្ញុំឃើញអ៊ីចឹង ខ្ញុំក៏រត់មកក្រោយវិញ។ រត់មកក្រោយវិញ មកប្រាប់ម្ដាយ មីងមាទាំងអស់ថា គេយកទៅសម្លាប់ហើយ។ គេយកប៉ាទៅសម្លាប់ហើយ ហើយគាត់អត់ជឿ។ នៅពេលដែលគេបាញ់ផ្ទួងផាំង នៅតំបន់ហ្នឹងហើយ គេមកយកយើងទៀត។ ឈ្លបហ្នឹងតាមមកយកយើងទៀត។ ដល់មកយកហ្នឹងដោយទាំងខ្ញុំអីទៅជាមួយហ្នឹងតែម្ដង។

**ស៖** ខ្ញុំមិនប្រាកដថាខ្ញុំអាចតាមយល់អ្វីដែលលោកនិយាយនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំដឹងអំពីម៉ោងពេល ប៉ុន្តែគាត់ហាក់ដូចជា -- សាក្សីដូចជាមានការលំបាកក្នុងការឆ្លើយទៅនឹងសំណួរដែលខ្ញុំសួរ។ ដូច្នេះខ្ញុំសូមអនុញ្ញាតពីឯកឧត្តមប្រធាន ដើម្បីសុំម៉ោងបន្ថែមសួរសំណួរទៅលើសាក្សីរូបនេះ។

[១០:១០:០៨]

**លោក នីកូឡាស គូមជែន៖**

ឯកឧត្តម លោក លោកស្រីចៅក្រម ខ្ញុំចង់ជម្រាបថា សាក្សីហ្នឹង គាត់ប្រាប់នូវចម្លើយទាំងអស់ ប៉ុន្តែសំណួរដែលសួរគឺថាស្មុគស្មាញ ហើយយើងក៏មិនជំទាស់ទៅលើមេធាវីការពារក្តីដែរ។ ដូច្នេះ ប៉ុន្តែយ៉ាងណាក៏ដោយ យើងមិនជំទាស់ទៅលើការស្នើសុំបន្ថែមម៉ោងនោះទេ ប៉ុន្តែយើងសូមជំទាស់ទៅលើ--

**ប្រធានអង្គជំនុំ៖**

តាមការស្តាប់របស់ខ្ញុំ គឺសាក្សីឆ្លើយមានលក្ខណៈច្បាស់លាស់ មិនមែនស្រពេចស្រពិលទេ។ ប៉ុន្តែសំណួររបស់លោកទេ ដែលសួរទៅ ខ្ញុំពិនិត្យឃើញថា មានលក្ខណៈជាដដែលច្រើន ច្រំដែលច្រើន ប៉ុន្តែខ្ញុំមិនហាម មិនឃាត់ទេ។ អ៊ីចឹងហើយ គឺសូមលោកជ្រើសរើសនូវសំណួរណាដែលសំខាន់ ហើយខ្លី ដើម្បីងាយស្រួលដល់សាក្សីក្នុងការឆ្លើយ។ អ៊ីចឹងតាមការពិភាក្សាគ្នារបស់ខ្ញុំ គឺថាអាចថែមពេលវេលាឲ្យលោកហ្នឹង១០នាទីបន្ថែមទៀត។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំគិតថា មិនយុត្តិធម៌ទេ ដែលថាខ្ញុំសួរសំណួរស្មុគស្មាញ ប៉ុន្តែខ្ញុំព្យាយាមរកឲ្យឃើញ ព្រោះថាខ្ញុំគិតថា សាក្សីគាត់ប្រឌិតរឿងទាំងអស់នេះឡើង។ ហេតុដូច្នេះហើយទើបខ្ញុំត្រូវស្វែងរកព័ត៌មានលម្អិត ដើម្បីឲ្យខ្ញុំជឿជាក់បាន។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំសូមបន្តទៅមុខទៀត ឯកឧត្តមប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មានៗម្តងគឺថានៅត្រង់ នៅមួយពេលនោះ គឺគេបាញ់លោក។ តើមានអ្វីកើតឡើងបន្ទាប់មកទៀត ក្រោយពេលដែលគេបាញ់លោក?

[១០:១១:៥៦]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ក្រោយពេលគេបាញ់សម្លាប់ មិនតែម្នាក់ខ្ញុំទេ បាញ់ទាំងអស់។ បាញ់សម្លាប់ទាំងអស់ហ្នឹងហើយ ខ្ញុំនេះក៏ធ្វើពុតជាស្លាប់។ ដេកទៅជាមួយសាកសពដែលត្រូវគ្រាប់ហ្នឹង ហើយគេអូសយកទៅទម្លាក់ក្នុងរណ្តៅទាំងអស់គ្នា ទាំងខ្ញុំ ទាំងសាកសពដទៃទៀត។

**ស៖** តើលោកអាចប្រាប់ទេថា លោកធ្វើពុតហ្នឹងយ៉ាងម៉េចដែរ ឬក៏លោកយ៉ាងម៉េចដែរ?

**ឆ៖** បានជាខ្ញុំធ្វើពុតហ្នឹង ព្រោះខ្ញុំដឹង ខ្ញុំឃើញៗគាត់យកឪពុកខ្ញុំទៅដំបូងហ្នឹង គឺយកទៅៗ

បាញ់សម្លាប់ចោលនោះហើយ បានជាខ្ញុំរត់មកក្រោយវិញ។ មកប្រាប់ម្ដាយមីងមាខ្ញុំ ថាឲ្យនាំគ្នារត់ហើយគាត់--

**ប្រធានអង្គជំនុំ៖**

លោកសាក្សី សូមលោកបញ្ជាក់ឲ្យបានច្បាស់។ អំមិញសំណួររបស់គាត់ មិនសំណួរអ៊ីចឹងទេ គឺសំណួរសួរថា លោកហ្នឹងធ្វើពុតជាស្លាប់ របៀបនៃការធ្វើពុតរបស់លោកហ្នឹង ធ្វើយ៉ាងម៉េច?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ឯកឧត្ដម ជម្រាបប្រសាសន៍ នៅពេលដែលម្ដាយខ្ញុំអង្គុយខាងមុខ ហើយខ្ញុំអង្គុយពីក្រោយ ពីក្រោយខ្នងគាត់ ដល់គេបាញ់មកចំដើមទ្រូងគាត់ ដើមដោះគាត់នេះ ហើយគាត់ដួលគ្រឹបទៅ។ ដល់គាត់ដួលគ្រឹបទៅ ខ្ញុំក៏ធ្វើពុតដួលទៅតាមគាត់ហ្នឹងទៅ។ គេបាញ់រះ ទាល់តែៗក្រាបអស់មនុស្សហ្នឹង តែនៅកូនក្មេងហ្នឹង គឺគេដើរវាយដូចក្បាលត្រីអ៊ីចឹង។

[១០:១៣:៤៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយអ៊ីចឹងប្អូនលោក ហើយនិងជីដូនមួយលោកហ្នឹងក៏ធ្វើពុតស្លាប់ដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ្នកខ្លះក៏សន្លប់ អ្នកខ្លះក៏ធ្វើពុត។ តែបើតាមខ្ញុំមើលទៅ ជីដូនមួយខ្ញុំពីរនាក់នុ៎ង ប្រុសមួយស្រីមួយហ្នឹងធ្វើពុតទេ តែបើប្អូនខ្ញុំបង្កើតមួយនោះ គឺគេវាយត្រូវក្បាលហ្នឹងបែកឡើងប៉ល់ ប្រឡាក់សុទ្ធតែឈាម។

**ស៖** តើពួកលោកទាំងបួននាក់ហ្នឹងធ្វើពុតជាស្លាប់ហ្នឹង អស់រយៈពេលប៉ុន្មានម៉ោង ប៉ុន្មាននាទីអីដែរ?

**ឆ៖** ពេលដែលគេកំពុងតែធ្វើឃាតយើងហ្នឹង កំពុងតែសម្លាប់យើងហ្នឹង គឺពេលវេលាវាខ្ចីពេកហើយ។ វាម៉ោងបួនកន្លះទៅប្រាំហើយ បាទម៉ោងប្រាំ ថាម៉ោងប្រាំចុះម៉ោងប្រាំ ហើយមេឃរកភ្លៀងទៀត។ អ៊ីចឹងទៅដល់កន្លែងសម្លាប់ហ្នឹង វាចូលម៉ោងប្រាំកន្លះទៅប្រាំមួយហើយ។ ដល់តែពេលគេធ្វើសកម្មភាពហ្នឹង វាដូចជាងងឹត មេឃងងឹតរកភ្លៀង អ៊ីចឹងគេប្រញាប់ប្រញាល់ គេអូសទម្លាក់ទៅក្នុងរណ្ដៅ ហើយគេដើរចេញទៅ។ ខ្ញុំក៏ស្រែកហៅបងប្អូនឡើងមក អ្នកដែលនៅសេសសល់ពីស្លាប់ គឺឡើងជាមួយខ្ញុំបានបួននាក់។

**ស៖** តើលោកធ្វើពុតជាស្លាប់ហ្នឹងប៉ុន្មានម៉ោង? មួយម៉ោង ពីរម៉ោង ឬក៏កន្លះម៉ោងដែរ?

**ឆ៖** បាទ យូរដែរ វាចង់ចូលពីរម៉ោងហើយ ទម្រាំគេបាញ់សម្លាប់ហើយ គេអូសយកទៅទម្លាក់រណ្តៅ វាចូលពីរម៉ោងហើយ បានគេទៅផ្ទះ។ គេទៅផ្ទះ បានខ្ញុំងើបចេញមក។

[១០:១៥:៥៥]

**ស៖** តើលោកអាចពន្យល់បានទេ តើលោកហើយនិងប្អូនស្រីរបស់លោក ព្រមទាំងជីដូនមួយរបស់លោក អ៊ីចឹងធ្វើយ៉ាងណាដើម្បីបោកបញ្ឆោតទាហាន ឬក៏បោកបញ្ឆោតយោធាខ្មែរក្រហមហ្នឹងឲ្យពួកគេជឿថាលោក ប្អូនស្រីរបស់លោក ហើយនិងជីដូនមួយរបស់លោកហ្នឹងស្លាប់ លោកធ្វើដោយរបៀបណា?

**ឆ៖** ដូចខ្ញុំបាននិយាយហើយថា មេឃវាចង់រកភ្លៀង ហើយវាយប់ផង មកយប់ងងឹតផង អ៊ីចឹងវាអស់ម៉ោងធ្វើការងារ។ អ៊ីចឹងគេធ្វើហ្នឹងវាមិនស្អាត បើគេធ្វើឲ្យស្អាត គេអូសម្នាក់ម្តងមួយយកទៅរ៉ៃថែម ម្នាក់មួយរ៉ៃថែម វាងាប់ទាំងអស់នោះហើយ។ ប៉ុន្តែគេធ្វើមិនស្អាតដោយគេប្រញាប់ គេប្រញាប់ទៅយកអាជយភណ្ឌដែលខ្ញុំដាក់ចោលនៅខាងៗត្បូងអូរ -- ខាងជើងអូរ ដើម្បីយកទៅផ្ទះគេ។ អ៊ីចឹងវាសេសសល់ពួកខ្ញុំហ្នឹងឯង។

**ស៖** អ៊ីចឹងមានន័យថា គេអត់បានកប់ពួកលោកទេ គេអត់បានជីករណ្តៅកប់ពួកលោកទេ មែនទេ? ហើយពួកគេប្រញាប់ចេញទៅវិញដោយសារភ្លៀង អ៊ីចឹងមែនទេ?

**ឆ៖** បាទ រណ្តៅហ្នឹងវាមានស្រាប់ហើយ។ បងប្អូនខ្មែរយើងស្គាល់ហើយរណ្តៅអាបេនោះ ដែល ប៉ុល ពត ជម្លៀសទៅ យើងដើរឃ្វាលគោឃ្វាលក្របីអី ឃើញហើយ ស្គាល់ហើយរណ្តៅគ្រាប់បែកធុនបេ។ អ៊ីចឹងវាធំៗណាស់ មាត់លើវាៗចូលប្រាំពីរប្រាំបីម៉ែត្រនោះ ហើយជម្រៅទៅក្រោមហ្នឹងប្រហែលជាចូលបីម៉ែត្រនោះ។ បាទ អ៊ីចឹងគេយកទៅទម្លាក់ក្នុងរណ្តៅហ្នឹង ហើយអត់បានកប់ទេ គេកាប់ស្លឹកឈើយកមកគ្របពីលើសាកសពហ្នឹង ហើយក៏នាំគ្នាចេញបាត់ទៅ។

[១០:១៨:០៥]

**ស៖** អ៊ីចឹងបានន័យថា គេទុកសាកសពហ្នឹងនៅចោលនៅទីនោះ អ៊ីចឹងមែនទេ? ហើយតើនៅពេលក្រោយមក គេមានរកឃើញសំណល់សាកសព ដូចជាលលាដ៍ក្បាល ដូចជាឆ្អឹងអីនៅសល់នៅកន្លែងហ្នឹងដែរឬទេ?

**ឆ៖** បាទ គេដាក់សាកសពចោលនៅទីនោះ។ ហើយកាលសម័យ ប៉ុល ពត ហ្នឹងគឺមិនដឹងជាគេកប់ គេមិនកប់ទេ ប៉ុនខ្ញុំដើរឃ្វាលគោហ្នឹង ខ្ញុំឃើញឆ្អឹងចង្រ្កឹងចង្រ្កាងនៅ ឲ្យតែក្នុង ឲ្យតែមានរណ្តៅ

អាបេហ្នឹងសុទ្ធតែឆ្អឹងខ្មោចហើយ។ អ៊ីចឹងគោរអង្កៀមខ្លះទៅ គេចោលហាលវាលហាលផ្សេងហ្នឹងទៅ គេអត់មានកប់ទេ។

**ស៖** លោកសាក្សីតើលោកអាចពន្យល់បានទេ ថាហេតុអ្វីបានជាមជ្ឈមណ្ឌលឯកសារកម្ពុជារកឃើញរណ្តៅកប់សពរួមតែមួយនៅតំបន់និរតី គឺថានៅ គេហៅថានៅក្បែរច្រកស្តេចហ្នឹង?

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំចង់ជម្រាបថាគាត់គឺជាអធិការប៉ូលិសផងដែរ។

**លោក នីកូឡាស គូមជែន៖**

ដូច្នេះសាក្សីគាត់មិនអាចដឹងថាគាត់ -- ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើអ្វី មានតួនាទីអ្វី ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅស៊ើបអង្កេតកន្លែងណាខ្លះ ស៊ើបអង្កេតទាំងអស់។ ដូច្នេះវាជាការមិនត្រឹមត្រូវនោះទេ ដោយសួរសាក្សីថាតើហេតុអ្វីបានជាមជ្ឈមណ្ឌលឯកសារកម្ពុជារកឃើញតែមួយ ឬក៏សួរអំពីគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

[១០:២០:០២]

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន គឺថាខ្ញុំគិតថា សាក្សីជាអធិការប៉ូលិស ហើយខ្ញុំតាំងពីដំបូងមក ខ្ញុំគិតថាគាត់និយាយកុហក ប្រឌិតតាំងពី “ក” ដល់ “អ”។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតធ្វើការកត់សម្គាល់មួយ។ ចាប់ពីផ្តើមសួរមក គឺថាគាត់សួរនិយាយពីភូមិរូងខ្លា ដែលនៅចម្ងាយប្រហែលជា៦០គីឡូម៉ែត្រពី -- ៧០គីឡូម៉ែត្រពីកន្លែងដែលគាត់រស់នៅ។ ហើយអ៊ីចឹងមិនអាចផ្ទៀងផ្ទាត់បានព័ត៌មានដែលមេធាវីគាត់ផ្អែកទៅលើ ដើម្បីអះអាងនោះដែលថាចម្ងាយ៧០គីឡូម៉ែត្រ ដែលសាក្សីនោះគាត់និយាយថា២គីឡូម៉ែត្រទេ។ អ៊ីចឹងយើងអត់មានព័ត៌មានអីនៅក្នុងសំណុំរឿងយើងទេ។ យើងមិនអាចទាំងដឹងថា តើភូមិតែមួយដូចគ្នាទេ? តើអ៊ីចឹងយើងអាចដឹងថាព័ត៌មានដែលឲ្យ យើងនិយាយថា ភូមិហ្នឹងនៅចម្ងាយ៧០គីឡូម៉ែត្រហ្នឹង ហើយមិនមែន២គីឡូម៉ែត្រទេនោះ។ យើងមានមូលដ្ឋានអីដើម្បីប្រៀប--

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

[១០:២១:០៤]

**ចៅក្រម អាកនីស្កា គ្លូណូវីកកា មីឡាត៖**

ដូច្នេះ ដើម្បីសម្រួលបញ្ហា ខ្ញុំសូមអនុញ្ញាតឯកឧត្តមដើម្បីសួរសំណួរទៅសាក្សី។

**សួរដោយចៅក្រម អាកនីស្កា គ្លូណូវីកកា មីឡាត៖**

**ស៖** តើលោកសាក្សីដឹងអំពីការជីកគាស់រណ្ដៅសាកសពទាហាន លន់ នល់ នៅក្នុងតំបន់នោះដែរឬទេ?

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំជម្រាបជូនដែរថា អត់ដឹងពីការគាស់រណ្ដៅសាកសពហ្នឹងឯណាទេ។ ប៉ុន្តែនៅក្រោយ ៧៩ គឺរដ្ឋាភិបាលបានអំពាវនាវដល់ប្រជាពលរដ្ឋ ដែលស្គាល់រណ្ដៅសាកសពហ្នឹង យកមកតាំងនៅខេត្ត។ បាទ យកប្រមែប្រមូលធាតុហ្នឹង យកមកតាំងនៅខេត្ត គ្រប់ខេត្តក្រុងអ៊ីចឹង ដែលមានការកាប់សម្លាប់ ហើយយកធាតុហ្នឹង យកមកតាំងដើម្បីធ្វើបុណ្យប្រចាំឆ្នាំរបស់រដ្ឋាភិបាល។

**ស៖** តើលោកមានឆ្លើយតបទៅនឹងការអំពាវនាវ ហើយនាំទៅដល់ការជីករករណ្ដៅនៅទីនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានទៅដល់ចង្អុលបង្ហាញទេ។ ក៏ប៉ុន្តែការអំពាវនាវរបស់រាជរដ្ឋាភិបាល គឺលោកអំពាវនាវត្រូវប្រមូលសាកសពឆ្អឹងសពទាំងអស់ហ្នឹង យកមកតម្កល់ទុកនៅសារមន្ទីរតាមបណ្ដាខេត្តនីមួយៗ។ អ៊ីចឹងប្រជាពលរដ្ឋ មេស្រុក មេឃុំនៅទីនោះ គេស្គាល់ហើយ គេប្រមូលយកមកឲ្យហើយ។

**ស៖** អរគុណលោកសាក្សី។

[១០:២៣:០១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបទៅនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមិនផ្អែកទៅលើឯកសារអ្វីទេ។ ខ្ញុំពឹងផ្អែកទៅលើហ្គូហ្គោល ផែនទីហ្គូហ្គោល ដែលមានចម្ងាយប្រហែលជា៦០ ទៅ៧០ពីច្រកស្ដេច។ ដូច្នេះ ខ្ញុំសូមដកសំណួរខ្ញុំចេញវិញ។

**ប្រធានអង្គជំនុំ៖**

អ៊ីចេះៗ លោកមេធាវីទាំងពីរ ហើយអ៊ីចឹងមិនបាច់ចាំធ្វើការឆ្លើយតបទេ ហើយសូមលោក

មេធាវីមានសំណួរអីបន្តទៀត។ សូមអញ្ជើញ ដើម្បីបញ្ចប់ បាទ។

**លោក វ៉ិចទ័រ កូប៉េះ**

ឯកឧត្តមប្រធាន និយាយឲ្យត្រង់ទៅ ខ្ញុំត្រូវការពេលដល់ទៅពីរបីម៉ោងឯណោះ ឲ្យខ្ញុំតែ១០នាទី វាជារឿងចម្លែកមួយមែនទែន ចំពោះខ្ញុំ។

**ប្រធានអង្គជំនុំះ**

អ៊ីចឹង--

**លោក នីកូឡាស គូមជែនះ**

សាក្សីប្រហែលជានៅសល់សំណួរសំខាន់បំផុត ដូច្នេះប្រសិនបើអាច យើងគួរតែទុកឱកាសចុងក្រោយឲ្យគាត់ សួរអាសំណួរដែលថាសំខាន់បំផុតនោះ។

**លោក វ៉ិចទ័រ កូប៉េះ**

ប្រសិនបើយើងនៅតែបន្តបែបនេះ ខ្ញុំសូមដកសំណួរទាំងអស់របស់ខ្ញុំចេញ។

**ប្រធានអង្គជំនុំះ**

ឥឡូវយើងដល់ម៉ោងដប់ ម្ភៃប្រាំមួយនាទីហើយ។ អ៊ីចឹងគឺតុលាការប្រកាសសម្រាកចំនួន ២០នាទីសិន។ ហើយចាំយើងចូលមកវិញ អ៊ីចឹងចាប់ពីម៉ោង -- ដល់ម៉ោងដប់ សែសិបប្រាំមួយនាទី យើងនឹងចូលមកវិញ។

ប្រកាសសម្រាក!

*(សវនាការសម្រាកពីម៉ោង ១០:២៥ នាទី ដល់ម៉ោង ១០:៤៧ នាទី)*

[១០:៤៧:១១]

**ប្រធានអង្គជំនុំះ**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។ ហើយជាបន្តទៅនេះគឺតាមការពិភាក្សារបស់អង្គជំនុំជម្រះបានសម្រេចថា ដោយសារមានភាពចាំបាច់នៃការសួរចម្លើយ ហើយជាតម្រូវការរបស់តុលាការកំពូលផងដែរ ដូច្នេះគឺអង្គជំនុំជម្រះតុលាការកំពូលនឹងអនុញ្ញាតឲ្យមេធាវីរបស់ជនជាប់ចោទទាំងពីរ ទាំង ខៀវ សំផង ទាំង នួន ជា ហ្នឹងគឺផ្តល់ឱកាសរហូតដល់ម៉ោងដប់ពីរ ចាប់ពេលនេះទៅ រហូតដល់ម៉ោងដប់ពីរ។ ប៉ុន្តែគឺលោកមេធាវីទាំងពីរគួរបែងចែកពេលវេលាគ្នាទៅ តើត្រូវការប្រើប៉ុន្មាននាក់? ប៉ុន្តែខ្ញុំ

សូមរំឭកបន្ថែមដែលថា ទាក់ទងនឹងបញ្ហាការសួរសំណួរសុំឲ្យលោកមេធាវីហ្នឹងជ្រើសរើសយកសំណួរណាដែលសំខាន់ មកសួរ។ បាទសំណួរសំខាន់។ ហើយជាសំណួរសាមញ្ញដើម្បីឲ្យសាក្សីងាយស្រួលនឹងឆ្លើយ និងងាយស្រួលក្នុងការបកប្រែផងដែរ។ ដូច្នេះសូមអញ្ជើញ! បាទសូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន។ សូមគោរពអង្គសវនាការ។ ខ្ញុំសូមឲ្យលោកប្រធានបញ្ជាទៅខាងអ្នកបកប្រែពីអង់គ្លេស ឬពីបារាំងមកខ្មែរ សូមឲ្យនិយាយខ្លាំងជាងរាល់ពេលបន្តិច ព្រោះអីស្តាប់អត់សូវឮទេ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអ្នកបកប្រែនិយាយឲ្យខ្លាំងបន្តិច បាទ។ សូមអញ្ជើញលោកមេធាវី!

[១០:៤៩:១៩]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមចូលទៅនិយាយអំពីពេលវេលាមួយនោះ ដែលលោកនិយាយថា លោកនៅជាមួយនឹងក្រុមមនុស្សដែលត្រូវបានគេបាញ់សម្លាប់។ សូមលោកចាប់ផ្តើមនិយាយអំពី ចេញពីពេលដែលចាប់ផ្តើមឮសូរគ្រាប់កាំភ្លើង ហើយតើមានអ្វីកើតឡើងបន្តបន្ទាប់?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ខ្ញុំសុំការអនុញ្ញាតពីលោកប្រធានដើម្បីបំភ្លឺជុំវិញសំណួរនេះ។ ខ្ញុំបានៗទទួលការសាកសួររបស់លោកមេធាវីច្រើនលើកហើយជុំវិញបញ្ហានេះ។ អ៊ីចឹង ខ្ញុំសុំបញ្ជាក់ម្តងទៀតថា នៅពេលដែលខ្ញុំរត់តាមឪពុកខ្ញុំទៅហ្នឹង គឺគេដេញឲ្យមកក្រោយវិញ ដោយសារយើងនៅតូច។ គេយកតែមនុស្សដែលពេញកម្លាំងទៅកាប់ឈើ ធ្វើជម្រកនៅ។ ហើយដល់ពេលខ្ញុំឈរមើលគេ ខ្ញុំលបឈរមើលគេក្រោយពេលគេយកឪពុកខ្ញុំចូលទៅដល់ព្រៃរូងខ្លាហ្នឹងហើយ គេបាញ់សម្លាប់ហើយ ខ្ញុំរត់មកក្រោយវិញ។ ដល់ខ្ញុំរត់មកក្រោយវិញ ខ្ញុំមកប្រាប់មីងមាម៉ែម្តាយនៅខាងក្រោយឲ្យនាំគ្នារត់ គាត់មិនរត់។ ហើយគេសម្លាប់ឪពុកខ្ញុំអស់ហើយ បានគេមកយកមីងមាម្តាយ រួមទាំងរូបខ្ញុំនេះទៅជាលើកទី២។

[១០:៥១:២០]

**ស៖** បាទ ខ្ញុំនឹងរំលងចំណុចនេះ ប៉ុន្តែសូមមេត្តាជម្រាបជូនតុលាការនូវអ្វីដែលលោកបានឃើញ បានឮស្នូរគ្រាប់កាំភ្លើងដែលចាប់ផ្តើមបាញ់ទៅក្រុមនុ៎ង ទៅលើឪពុកម្តាយរបស់លោក។ អ្នកណាជាអ្នកបាញ់? បាញ់ចេញពីទីណាមក? ហើយលោកឈរនៅទីណាពេលគេបាញ់នុ៎ង? ម្តាយរបស់លោកឋិតនៅត្រង់កន្លែងណា នៅពេលដែលស្នូរគ្រាប់កាំភ្លើងឮសូរឡើងហ្នឹង?

**ឆ៖** បាទ ខ្ញុំបានជម្រាបរួចហើយ ឥឡូវខ្ញុំបកស្រាយជូនម្តងទៀត ក្រែងលោថាខ្ញុំវង្វេង។ ខ្ញុំនៅពេលដែលគេនាំឪពុកទៅសម្លាប់ហើយ ទៅបាញ់សម្លាប់ហើយនុ៎ង ខ្ញុំត្រូវទទួលការមកកោះ មកហៅមួយក្រុមទៀត--

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកសាក្សី តាមការអនុញ្ញាតពីលោកប្រធាននេះ ខ្ញុំនឹងសុំសួរលោកឲ្យសួរ ឲ្យលោករៀបរាប់តែអំពីការបាញ់ប្រហារដែលឈានទៅដល់ការសម្លាប់ម្តាយរបស់លោក។ សូមលោកឆ្លើយកន្លែងហ្នឹង។ ឆ្លើយតែចំណុចហ្នឹងបានហើយ។ មិនបាច់និយាយអ្វីមុននេះ មិនបាច់និយាយអ្វីខាងក្រោយនេះទេ។ សូមនិយាយរៀបរាប់អំពីតែការបាញ់សម្លាប់នេះបានហើយ។ អ្វីកើតឡើងមកលើលោក? លើឪពុកម្តាយ? អ្នកណាជាអ្នកចាប់ផ្តើមបាញ់? បាញ់ដោយរបៀបណា?

[១០:៥២:៥០]

**លោក សំ សិទ្ធី៖**

**ឆ៖** ការបាញ់សម្លាប់នេះគឺ ខ្ញុំនៅក្នុងរង្វង់ហ្នឹងជាមួយគ្នា ហើយក្រុមប្រដាប់ដោយអាវុធដែលគ្មានឯកសណ្ឋានអីត្រឹមត្រូវទេ។ នៅពេលដែលគេយកយើងទៅអង្គុយម៉ុំហ្នឹង ហើយគេថយចេញមកក្រៅ គេបាញ់ផ្ទាច់ទៅសំដៅហ្វូងមនុស្សហ្នឹងតែម្តង។ នៅពេលដែលម្តាយខ្ញុំអង្គុយពីខាងមុខ ខ្ញុំអង្គុយចំហៀងគាត់ ឃើញម្តាយខ្ញុំត្រូវគ្រាប់ហើយ ខ្ញុំធ្វើពុតជាស្លាប់នៅពីក្រោយខ្នងម្តាយតែម្តង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ្នកណាជាអ្នកបាញ់ ហើយបាញ់ចេញពីណាមក? តើមានអ្វីកើតឡើងទៅអ្នកដទៃទៀតនៅក្នុងក្រុមមនុស្សនោះដែរ?

**ឆ៖** បាទ អ្នកដែលបាញ់នុ៎ងគឺមនុស្សដែលគេបណ្តើរយើង គេឆ្កកយើងយកទៅហ្នឹងហើយ។ ប្រដាប់ដោយអាវុធហ្នឹង គេឆ្កកយើង យើងឆ្លងអូរទៅគឺចេញមនុស្សដែលមានអាវុធហ្នឹងឆ្កកយើងទៅទៅដល់ឲ្យយើងអង្គុយម៉ុំ ហើយគេព័ទ្ធជុំវិញ គេបាញ់ផ្ទាច់ទៅតែម្តង។

**ស៖** តើប្អូនស្រីរបស់លោកអង្គុយនៅកន្លែងណា? បងប្អូនរបស់លោកពីរនាក់ហ្នឹង នៅកន្លែងណាដែរពេលនុំង?

**ឆ៖** នៅក្នុងរង្វង់ហ្នឹងទាំងអស់គ្នា។

[១០:៥៤:៣១]

**ស៖** តើប្អូនស្រីរបស់លោក បងប្អូនទាំងអស់ទៀតនៅពីខាងក្រោយលោក នៅឈរពីខាងក្រោយខ្នងម្តាយលោក ឬក៏នៅក្បែរលោក? ឈរនៅត្រង់កន្លែងណា?

**ឆ៖** គេអត់ឲ្យឈរទេ ទាំងដល់កន្លែងហ្នឹងគឺគេឲ្យអង្គុយម៉ុំ។ បាទ ខ្ញុំអត់បានចាប់អារម្មណ៍មើលថាប្អូនខ្ញុំហ្នឹងអង្គុយត្រង់ណា ប្អូនជីដូនមួយហ្នឹងអង្គុយត្រង់ណាទេ តែខ្ញុំអង្គុយនៅពីក្រោយម្តាយខ្ញុំ។ ហើយនៅពេលដែលគេបាញ់សម្លាប់ហើយ គេអូសទម្លាក់រណ្តៅ ខ្ញុំក៏បានស្រែកហៅ ឡើងមកអ្នកដែលសេសសល់។

**ស៖** ឥឡូវ ខ្ញុំសូមសួរអំពីប្អូនស្រីរបស់លោក។ តើលោកបានឃើញគ្រាប់កាំភ្លើងដែលបាញ់ចំប្អូនស្រីរបស់លោកទេ? ឃើញវាដួលទេ ឬក៏អីទេ? តើមានអ្វីកើតឡើងចំពោះប្អូនស្រីរបស់លោក?

**ឆ៖** បាទ ប្អូនស្រីខ្ញុំមិនបានត្រូវគ្រាប់កាំភ្លើងហ្នឹងទេ ព្រោះនៅតូច គេបាញ់ហ្នឹងគឺបាញ់តែមនុស្សធំៗទេ ហើយមនុស្សតូចៗហ្នឹងគេវាយនឹងដំបង។ ហើយប្អូនខ្ញុំហ្នឹងវា គេវាយត្រូវកៗនេះមួយដំបង ហើយប្រហែលជាសន្លប់ ក៏មិនដឹងអីមិនដឹង បានត្រូវគេអូសទៅទម្លាក់រណ្តៅជាមួយខ្ញុំហ្នឹងដែរ។

**ស៖** តើលោកចាំថា ការបាញ់សម្លាប់នេះ គេបាញ់ដោយអន្លើៗ ឬក៏គេបាញ់សំដៅទាំងក្រុមតែម្តង ឬក៏គេបាញ់ហ្នឹង ដោយមានការជ្រើសរើសតែក្រុម តែមនុស្សជាក់លាក់?

[១០:៥៦:៣៧]

**លោក នីកូឡាស គូមជែន៖**

សំណួរនេះ គឺថាមានច្របូកច្របល់ណាស់ គឺថា តើៗការដែលសួរ ថាតើទាហានទាំងអស់ហ្នឹងមានបំណងបាញ់ទៅលើអ្នកណា ប្រហែលជាគាត់ពិបាកនឹងឆ្លើយនឹងសំណួរនេះណាស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ខ្ញុំសូមប្តូរ។ លោកសាក្សី តើមានអ្វីកើតឡើងពិតប្រាកដចំពោះប្អូនស្រីរបស់លោក? សូមលោកនិយាយឲ្យបានលម្អិតតែចំពោះថា អ្វីកើតឡើងដល់ប្អូនស្រីរបស់លោក?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ប្អូនស្រីរបស់ខ្ញុំនេះគឺខ្ញុំឃើញជាក់ស្តែងនឹងភ្នែក គឺត្រូវនឹងដំបង អត់បានត្រូវនឹងគ្រាប់កាំភ្លើងទេ។ តែម្តាយ មីងមាខ្ញុំទាំងអស់ហ្នឹង គឺត្រូវគ្រាប់កាំភ្លើង។

**ស៖** ប្អូនស្រីរបស់លោកគឺត្រូវនឹងដំបង។ អ៊ីចឹងក្រោយពេលគេត្រូវនឹងដំបង -- ក្រោយត្រូវនឹងដំបងហើយ មានអ្វីកើតឡើងមកលើរូបគាត់ទៀត?

**ឆ៖** បាទ ពេលហ្នឹងអត់ដឹងទេ។ ខ្ញុំបានជម្រាបហើយថា នៅពេលដែលគេចេញទៅអស់ ខ្ញុំស្រែកសួរនៅក្នុងរណ្តៅហ្នឹង អ្នកណានៅរស់ខ្លះ ហើយចេញមក បងនៅៗចាំដើម្បីនាំផ្លូវទៅវត្តច្រកស្តេចនេះវិញ។

**ស៖** តើក្រោយមកប្អូនស្រីរបស់លោកបានប្រាប់លោកថា មានអ្វីកើតឡើងចំពោះរូបនាងទេ? តើគាត់មានប្រាប់លោកថា គាត់ធ្វើពុតជាស្លាប់ដែរទេ?

**ឆ៖** បាទ គាត់អត់មានប្រាប់ទេ ប៉ុន្តែការឃើញនឹងភ្នែករបស់ខ្ញុំ គឺប្អូនខ្ញុំបែកក្បាលមួយចំហៀងនៅកញ្ចឹងកនេះ ត្រូវគេវាយនឹងដំបង។

[១០:៥៨:៥៥]

**ស៖** តើប្អូនស្រីរបស់លោកសន្លប់ឬក៏អត់ ឬក៏ស្រែក ឬក៏យ៉ាងណា?

**ឆ៖** អត់បានដឹងដែរក្នុងពេលហ្នឹង។ ខ្ញុំសង្ស័យថា ពេលនុ៎ងគឺគាត់សន្លប់ ព្រោះបែកក្បាលហ្នឹងបែកខ្លាំង។ អ៊ីចឹងហើយប្រហែលជាឃើញសន្លប់ ហើយត្រូវទទួលការអូសចូលទម្លាក់រណ្តៅ។

**ស៖** លោកសាក្សី ខ្ញុំសួរអំពីប្អូនស្រីរបស់លោក។ លោកពិតណាស់ថា ប្អូនស្រីរបស់លោក មិនបានប្រាប់លោកថា មានអ្វីកើតឡើងចំពោះគាត់ទេ? តើប្អូនស្រីរបស់លោកមានបានប្រាប់លោកថា គេបានបោកបញ្ឆោតដល់កងទ័ពខ្មែរក្រហម ដោយធ្វើពុតជាស្លាប់ដែរទេ?

**ឆ៖** បាទ អត់មានទេ។ អត់មានបោកបញ្ឆោតដូចខ្ញុំទេ បើខ្ញុំមានការបោកបញ្ឆោត ធ្វើល្បិចជាស្លាប់។ តែសម្រាប់ប្អូនស្រីមិនអ៊ីចឹង ខ្ញុំជឿថាពេលហ្នឹង គឺគាត់សន្លប់។

**ស៖** តើខ្ញុំ -- ថាតើគាត់ធ្វើពុតជាស្លាប់ ឬក៏យ៉ាងណានោះ ខ្ញុំជឿថា លោក ហើយនិង--

**លោក នីកូឡាស គូមជែន៖**

នេះ មិនមែនជាសំណួរទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមដកចំណុចនេះចេញវិញអ៊ីចឹង។ ចុះបងប្អូនពីរនាក់ផ្សេងទៀត មានអ្វីកើតឡើងចំពោះពួកគេទេ?

[១១:០០:៣៥]

**លោក សំ សិទ្ធី៖**

**ឆ៖** ចំណែកប្អូនជីដូនមួយខ្ញុំពីរនាក់ទៀត អត់មានឃើញត្រូវរបួសអីទេ។ ហើយពីរនាក់ទៀតហ្នឹង នាបច្ចុប្បន្នហ្នឹង ស្លាប់ប្រុសមួយទៀតហើយ នៅតែស្រីមួយទេ។ ហើយខាងខ្ញុំនេះ ប្អូនខ្ញុំដែលត្រូវនឹងដំបងនោះ វាទៅជាតេតាណូស ហើយឥឡូវស្លាប់បាត់ទៅហើយ។

**ស៖** បងប្អូនពីរនាក់នេះ ក៏ជាអ្នកដើរនៅក្នុងក្រុមដែលគេបាញ់សម្លាប់ហ្នឹងដែរឬក៏អត់? តើលោកដឹងថា មានអ្វីកើតឡើងដល់បងប្អូនជីដូនមួយពីរនាក់នេះទេ? តើមានគេវាយពួកគាត់ហ្នឹងនឹងដំបង ឬក៏គេបាញ់រះមកលើពួកគាត់ហ្នឹងដែរទេ? ដឹងថាមានអ្វីកើតឡើងចំពោះបងប្អូនជីដូនមួយពីរនាក់នេះទេ?

**ឆ៖** បាទ ដឹង។ ដឹងច្បាស់ថា នៅក្នុងរង្វង់តែមួយ ហើយគេមកបាញ់ផ្តួចទៅលើមនុស្សក្នុងរង្វង់ហ្នឹងឯង។ ហើយនៅពេលនោះ ប្អូនខ្ញុំ បើនិយាយរួមថា ក្មេងតូចៗគេអត់បាញ់ទេ។ គេដើរយកដំបងទៅវាយ។ បាទ ហើយគេបាញ់ឡើងស្ងាត់មនុស្សចាស់ ស្រែកយំហ៊ោកញ្ជៀវពេញហ្នឹងហើយស្ងាត់ឈឹងហើយ បានគេទាញដំបង ខ្ញុំលួចបើកភ្នែកមើល ឃើញគេទាញដំបងទៅ អាកូនក្មេងតូចតាចដែលៗម្តាយស្លាប់ហើយហ្នឹង លូនទៅរកម្តាយ ឱបម្តាយ រកបៅដោះក៏មាន។ ហើយទៅដល់ គាត់ចាប់ទាញជើងឡើង គាត់សំយុងក្បាលមកក្រោម គាត់វាយនឹងៗគល់ឈើ ហើយបោះ។ វាយបោះៗ នៅៗលើគំនរហ្នឹងតែម្តង។

[១១:០២:៣២]

**ស៖** លោកសាក្សី លោកអាចឃើញហេតុការណ៍ទៅលើទារកនោះបាន។ ដូច្នេះខ្ញុំចង់ដឹងថា ហេតុអ្វីលោកអាចឃើញហេតុការណ៍កើតចំពោះកូនទារកនុ៎ង ប៉ុន្តែលោកមិនអាចឃើញហេតុការណ៍ដែលកើតឡើងចំពោះបងប្អូនជីដូនមួយរបស់លោកទាំងពីរនាក់ហ្នឹង? លោកអាចពន្យល់បានទេ?

**ឆ៖** បាទ ព្រឹត្តិការណ៍ហ្នឹង គឺវាច្រើនគ្នា។ ដូចខ្ញុំជម្រាបអ៊ីចឹងថា វាប្រាំពីរគ្រួសារហ្នឹង វាច្របល់គ្នាហើយ មួយជុំហ្នឹង ប្រហែលជា១០ -- ៨ម៉ែត្របួនជ្រុងហ្នឹង គឺអង្គុយគរផ្តុំគ្នាហ្នឹងទាំងអស់។ អ៊ីចឹងមិនដឹងប្អូនខ្ញុំអង្គុយត្រង់ណា មិនដឹងជាជីដូនមួយខ្ញុំហ្នឹងអង្គុយត្រង់ណា ខ្ញុំអត់ដឹងទេ។ តែខ្ញុំរើស

បាននៅពេលដែលខ្ញុំងើបពីរណ្តៅមក គឺនៅសល់គ្នាប្អូននាក់ហ្នឹង។ តែម្នាក់ត្រូវនឹងដំបង ប្អូនបង្កើតរបស់ខ្ញុំ ឯពីរនាក់ទៀត អត់មានត្រូវអីទេ។ អ៊ីចឹងបែបប្រហែលជាគាត់ធ្វើពុតជាស្លាប់ ដូចខ្ញុំដែរក៏មិនដឹង។

**ស៖** តើបងប្អូនរបស់លោកនៅពេលក្រោយ មានប្រាប់លោកៗទេ ថាតើពួកគេធ្វើយ៉ាងណាដើម្បីបោកបញ្ឆោតពួកទាហានទាំងអស់នោះបាន?

[១១:០៣:៥៩]

**ឆ៖** បាទ ខ្ញុំអត់បានសាកសួរទេ ព្រោះថាចេញពីរណ្តៅសាកសពហ្នឹងមក គឺនាំគ្នាដឹកដៃប្អូនរត់ចូលទៅក្នុងវត្តហ្នឹង វត្តច្រកស្តេចហ្នឹងវិញ ព្រោះវាដល់ម៉ោងឃ្លានហើយ។ ដល់តែចូលក្នុងហ្នឹងវិញ មានអ្នកស្គាល់ហ្នឹង គេឲ្យបាយ ឲ្យទឹក។ ហើយអ៊ីចឹងហើយ ខ្ញុំគ្រាន់តែបានតែខ្សឹបប្រាប់គេ ហើយដឹកដៃប្អូនរត់ជុំវិញហ្នឹងទាំងអស់ ដើរពីកន្លែងចល័តពីកន្លែងមួយទៅកន្លែងមួយ។ ដោយសារមានការស្រែកបញ្ជារបស់ក្រុមការងាររបស់គាត់ហ្នឹង បញ្ជាថា ឲ្យតាមរកក្មេងប្អូននាក់ហ្នឹង នៅទីណា ព្រោះក្មេងនេះជា សេ.អ៊ី.អា របស់អាមេរិក។ អ៊ីចឹងកងឈ្លបយើងកំពុងតែចាត់វិធានការតាមចាប់ក្មេងហ្នឹងហើយ។ អ៊ីចឹងខ្ញុំច្របល់ ខ្ញុំចេះតែដឹកដៃប្អូនរត់ វល់ពេញតែៗទីវត្តហ្នឹងទៅ ប្រជ្រៀតចូលនៅក្នុងចង្កោមមនុស្សរាប់ពាន់គ្រួសារហ្នឹងទៅ។

**ស៖** ខ្ញុំចង់និយាយថយក្រោយបន្តិចលោកសាក្សី គឺថាគេបាញ់កាំភ្លើង គេវ៉ៃនឹងដំបង ខ្ញុំចង់ដឹងថាក្រោយមកទៀតមានអ្វីកើតឡើង? តើទាហាន គេមានចាប់ផ្តើមលើកយកសាកសពទៅទីកន្លែងណាផ្សេងទេ? ហើយប្រសិនបើគេលើកយកសាកសពទៅទីកន្លែងផ្សេង តើគេយកសាកសពហ្នឹងទៅទីណា?

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកសាក្សី ខ្ញុំអាចជួយសម្រួលបន្តិចដល់ការងាររបស់លោកគឺថា ទាក់ទងទៅនឹងចំណុចនេះ តើលោកអាចរៀបរាប់បានទេ ថាតើទាហានទាំងអស់នោះ ក្រោយពេលដែលពួកគេឈប់បាញ់ហ្នឹង តើគេធ្វើអ្វីបន្តទៀត? គឺថាក្រោយពេលដែលគេឈប់បាញ់ រហូតទៅដល់ពេលពួកគេចាកចេញពីកន្លែងហ្នឹង តើលោកអាចរៀបរាប់បានទេ អ្វីដែលលោកបានដឹង ហើយអំពីអ្វីដែលទាហានបានធ្វើ ហើយសូមប្រាប់យើងថាលោកឃើញអ្វី? គឺនិយាយតែពីអ្វីដែលលោកឃើញ មិនមែននិយាយអំពីអ្វីដែលលោកទាយស្មាននោះទេ។ ដូច្នេះសំណួរគឺនិយាយតែទៅលើអាចន្លោះពេលដែលទាហានឈប់បាញ់ រហូតទៅដល់ពេលដែលទាហានចាកចេញពីកន្លែងសម្លាប់មនុស្សហ្នឹង។

[១១:០៦:៣៣]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទជម្រាបដែរថា នៅពេលដែលគេបាញ់ប្រហារហើយ គេអូសទម្លាក់ទៅក្នុងរណ្តៅ។ គេអូសទម្លាក់ទៅក្នុងរណ្តៅហើយ គេកាប់មែកឈើប្រហែលបួនប្រាំមែកយកទៅគ្របពីលើទេ គេអត់បានកប់ ហើយក៏អត់យកទៅណាបែកពីគ្នាដែរ គឺប្រាំពីរគ្រួសារហ្នឹង គឺដាក់តែមួយរណ្តៅហ្នឹងតែម្តង។ អ៊ីចឹងហើយគេយកអាបង្វេចបន្តិចបន្តួចដែលយើងកាន់មកជាប់នឹងដៃហ្នឹង គេឲ្យដាក់នៅគោក ហើយគេឲ្យមកអង្គុយម្តុំហ្នឹង គឺគេនាំគ្នាមកយកអាបង្វេចដែលយើងយួរនឹងដៃហ្នឹង នាំគ្នាដើរទៅផ្ទះអស់ទៅ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមលោករៀបរាប់ តើគេយួរ តើគេលើកលោកទៅរណ្តៅហ្នឹង គេលើកដោយរបៀបណា? តើគេសែងខ្លួនលោកទៅរណ្តៅហ្នឹង គេសែងដោយរបៀបណាដែរ? លោកអាចរៀបរាប់បានទេ?

**ឆ៖** បាទ នៅពេលហ្នឹង គេអត់មានសែងមានអីទេ គេអូសបញ្ច្រាសជើងទៅតែម្តង។ អូសបញ្ច្រាសជើងទៅ គេគ្រវីទៅក្នុងរណ្តៅហ្នឹងតែម្តង។

**ស៖** តើលោកចាំទេ អ្នកដែលគេអូសលោកទៅហ្នឹង គេមានពិនិត្យមើលថាលោកស្លាប់ ឬក៏រស់អត់ទេ?

[១១:០៨:១៨]

**ឆ៖** បាទ ជម្រាបដោយត្រង់ដែរថា មុននឹងគេអូសខ្ញុំទៅហ្នឹង គឺខ្ញុំធ្វើពុតជាស្លាប់ហ្នឹង គឺគេបានយកដំបងមកវ៉ៃ មកវ៉ៃក្បាលខ្ញុំមួយដំបង ប៉ុន្តែវា។ជាគុណបុណ្យជួយដែរ ចុងដំបងហ្នឹងគឺវាប៉ះទៅលើដីហ្នឹងធ្ងន់ជាងអាប៉ះមកលើក្បាលខ្ញុំ។ ហើយខ្ញុំចេះតែធ្វើឲ្យទន់ល្អៀចទៅ គេយួរជើងអូស យកទៅទម្លាក់រណ្តៅតែម្តង។

**ស៖** តើលោកនៅក្នុងរណ្តៅហ្នឹងអស់រយៈពេលប៉ុន្មានម៉ោង?

**ឆ៖** ខ្ញុំស្មានមើលទៅប្រហែលជាមិនក្រោមពីរម៉ោងទេ ព្រោះទម្រាំតែគេវ៉ៃហើយ គេអូសយកទៅទម្លាក់រណ្តៅ អូសទៅទម្លាក់រណ្តៅហ្នឹងហើយ ខ្ញុំកម្រើកខ្លួនចេញពីរណ្តៅឡើងមកមាត់រណ្តៅ ហើយខ្ញុំអើតមើលឆ្វេងស្តាំ ក្រែងលោគេពួនចាំមើលយើង។ អ៊ីចឹងក្នុងអំឡុងហ្នឹង គឺប្រហែលជាពីរម៉ោងនៅក្នុងរណ្តៅ យប់ងងឹត មេឃភ្លៀង។

**ស៖** តើមានសាកសពមនុស្សនៅក្បែរលោក ឬក៏នៅលើលោកដែរឬទេ នៅពេលនៅក្នុងរណ្តៅ

នោះ?

**ឆ៖** បាទ ខ្ញុំបើនិយាយទៅ ថាគេសង្កត់ពីលើហ្នឹង ប្រហែលជាចង់ពីរជាន់ហើយ។ បាទពីរត្រួតហើយពីលើខ្ញុំ តែខ្ញុំត្បុរចេញមក។ ខ្ញុំញែកសាកសពចេញឡើងមកលើ។

**ស៖** អ៊ីចឹងលោកនិយាយអំមិញថា មានសាកសពផ្សេងនៅពីលើលោក។ អ៊ីចឹងអាសាកសពផ្សេងសង្កត់លើលោកហ្នឹង ប៉ុន្មានម៉ោងដែរ?

[១១:១០:២៨]

**ឆ៖** សាកសពផ្សេងៗហ្នឹង បើ -- ខ្ញុំវានៅអែបមាត់រណ្តៅ ដល់តែគេបោះទៅ វាទៅផ្ទប់អាមាត់រណ្តៅខាងម្ខាងទៀតនោះ ហើយខ្ញុំយកដង្ហើមខ្ញុំទៅផ្ទប់មាត់រណ្តៅហ្នឹង ហើយគេសង្កត់ពីលើហ្នឹង ថាពីរនាក់ទៀតចុះ។ បាទ អ៊ីចឹងការដកដង្ហើមរបស់ខ្ញុំនៅធ្វើចលនាបានស្រួលបួលនៅពេលនោះ។

**ស៖** ខ្ញុំសួរលោកម្តងទៀត ថាតើលោកធ្វើពុតស្លាប់ហ្នឹង ធ្វើពុតហ្នឹងដោយរបៀបណា? ខ្ញុំចង់និយាយថា លោកបិទភ្នែករហូត ឬក៏លោកបិទខ្លះ បើកខ្លះ?

**ឆ៖** បាទ ការធ្វើពុត យើងដឹងហើយ។ វាមានល្បិចរៀងៗខ្លួន។ អ៊ីចឹងនៅពេលដែលគេវ៉ៃខ្ញុំរួចហើយហ្នឹង គឺខ្ញុំធ្វើពុត -- គេបាញ់ហើយហ្នឹង ខ្ញុំធ្វើពុតស្លាប់។ អ៊ីចឹងខ្ញុំបានលួចបើកភ្នែកមើលប្រិមៗចំពោះសកម្មភាពរបស់ពួកគាត់។

**ស៖** ចុះប្អូនស្រីរបស់លោក ហើយនិងជីដូនមួយពីរនាក់របស់លោក តើពួកគេនៅកន្លែងណាដែរក្នុងរណ្តៅហ្នឹង?

**ឆ៖** ដែលខ្ញុំរើសបានមក គឺខ្ញុំ មុននឹងខ្ញុំឡើងទៅអើតមើលគេចេញអស់នៅហ្នឹង ខ្ញុំត្រឡប់ទៅក្រោមវិញ ខ្ញុំចុះទៅក្នុងរណ្តៅវិញ ខ្ញុំស្រែកសួរ ខ្ញុំស្រែកសួរថា "មើល៍មានអ្នកណានៅរស់ខ្លះ? ងើបមកយើងទៅៗ វត្តច្រកស្តេចវិញ"។ អ៊ីចឹងប្អូនមួយនៅមាត់រណ្តៅខាងក្រោយ -- ខាងមុខខ្ញុំ ស្រែកថា "បង! ជួយយកខ្ញុំផង" ព្រោះវាសាកសពហ្នឹងសង្កត់ពីលើ។ ខ្ញុំក៏លូនទៅតាម ទៅពីលើសាកសពហ្នឹងទៅ ទៅកកាយសាកសពចេញ យកឲ្យប្អូនឡើងចេញមក បានមួយ។ ក្រោយមកខ្ញុំឮប្អូនមួយទៀត ស្រែកមួយទៀត ខ្ញុំក៏លូនទៅខាងទុំងមួយទៀត ទៅទាញសាកសពចេញ ដើម្បីឲ្យប្អូនឡើងមក។ អ៊ីចឹងបីនាក់ប្អូនបង្កើតមួយ និងប្អូនជីនដូនមួយមួយហ្នឹង គឺនៅវាយក្នុងរណ្តៅហ្នឹងទាំងអស់។

**ស៖** ដូច្នេះមានន័យថា មានតែប្អូនស្រីលោក ហើយនិងជីដូនមួយពីរនាក់ទេដែលនៅរស់អ្នកដទៃទៀតស្លាប់ អ៊ីចឹងមែនទេ?

[១១:១៣:១៦]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគ្រាន់តែចំណុចសម្គាល់ទេ គាត់និយាយថា បងប្អូន ប៉ុន្តែបងប្អូនហ្នឹង គឺជីដូនមួយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះខ្ញុំចង់សួរថា តើមានតែប្អូនស្រីលោក និងជីដូនមួយរបស់លោកពីរនាក់ហ្នឹងទេឬ ដែលនៅរស់?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ វានៅប្អូននាក់។ បីនាក់ អត់ត្រូវរបួសធ្ងន់ធ្ងរទេ តែម្នាក់ត្រូវរបួសក្បាលធ្ងន់ធ្ងរ ជាប្អូនស្រីបង្កើតរបស់ខ្ញុំ។

**ស៖** អ៊ីចឹងប្អូនស្រីរបស់លោក ហើយនិងបងប្អូនពីរនាក់ទៀតរបស់លោកហ្នឹង ពួកគាត់នៅរស់ទេឬ ក្នុងពេលឥឡូវនេះ?

**លោក នីកូឡាស គូមជែន៖**

ដើម្បីជាកំណត់ត្រា គួរតែកុំប្រើពាក្យ "បងប្អូន" ប្រើ "ជីដូនមួយ"។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះខ្ញុំសូមកែ គឺថាតើប្អូនស្រីរបស់លោក និងជីដូនមួយពីរនាក់របស់លោកនៅរស់រានមានជីវិតដែរឬទេ នៅពេលបច្ចុប្បន្ននេះ?

[១១:១៤:២១]

**លោក សំ សិទ្ធី៖**

**ឆ៖** បច្ចុប្បន្ននេះ ប្អូនជីដូនមួយខ្ញុំ ប្រុសមួយស្រីមួយ គឺស្លាប់ប្រុសហើយ នៅប្អូនស្រី ជីដូនមួយស្រីមួយ។ រីឯប្អូនបង្កើតរបស់ខ្ញុំនេះស្លាប់ដែរហើយ ដោយសារកើតរោគ ហៅថាសរសៃប្រសាទ ដែលត្រូវនឹងដំបងនោះ មើលមិនជា។ ឥឡូវក៏បានស្លាប់ទៅបាត់ហើយ។

**ស៖** តើជីដូនមួយស្រីរបស់លោកដែលហ្នឹង ឈ្មោះអីដែរ?

**ឆ៖** ឈ្មោះ គឹមសុខ។ ត្រកូលគាត់ សំ គឹមសុខ។

**ស៖** តើគាត់រស់នៅកន្លែងណាដែរក្នុងពេលឥឡូវនេះ?

**ឆ៖** បច្ចុប្បន្នគាត់រស់នៅជិតផ្ទះខ្ញុំហ្នឹងដែរ ក្នុងភូមិ ឃុំ តែមួយជាមួយគ្នា។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺថាជីដូនមួយស្រីរបស់លោកហ្នឹង គឺជាមនុស្សតែមួយគាត់ដែលនៅរស់ ដែលអាចបញ្ជាក់អះអាងទៅលើរឿងរ៉ាវ និងហេតុការណ៍ដែលលោកជួបប្រទះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គាត់អាចបញ្ជាក់បាន។

[១១:១៦:០២]

**ស៖** អរគុណច្រើនលោកសាក្សី។ លោក ប្អូនស្រីរបស់លោក និងជីដូនមួយពីរនាក់របស់លោក គឺងើបចេញពីរណ្តៅ។ តើលោកអាចពន្យល់បានទេ ថាហេតុអ្វីមានតែក្រុមគ្រួសាររបស់លោកដែលអាចនៅរស់រានមានជីវិត ចំណែកអ្នកដទៃទៀត គេស្លាប់ទាំងអស់គ្នាហ្នឹង តើហេតុអ្វី?

**ឆ៖** សំណួរនេះដូចជាលំបាកបន្តិច។ គ្រាន់ថាការបាញ់ប្រហារ ការវាយនឹងដំបង វាអត់រើសមុខទេ បាទ។ ប៉ុន្តែអាយុវាមិនអស់ បានជាវាត្រូវនៅរស់នេះនោះ ដូចជាខ្ញុំជាដើម។

**ស៖** នៅពេលដែលលោក ប្អូនស្រី និងជីដូនមួយទាំងពីរនាក់របស់លោកងើបចេញពីរណ្តៅថា ពួកលោកជជែកគ្នាយ៉ាងដូចម្តេចដែរ? ហើយតើពួកលោកសម្រេចចិត្តថាធ្វើអ្វី? ហើយបន្តដំណើរទៅណាដែរ?

**ឆ៖** បាទ នៅពេលដែលខ្ញុំប្រមូលបងប្អូនមកនៅជុំគ្នាក្នុងមាត់រណ្តៅហើយ ខ្ញុំនេះលូនឡើងពីក្នុងរណ្តៅ។ លូនឡើងពីក្នុងរណ្តៅ រើសបានដុំថ្មៗហើយខ្ញុំគប់។ វាដូចហៅថាក្បាច់ទាហានដែរអាហ្នឹង។ គប់ទៅឆ្វេងផង ទៅស្តាំផង ទៅមុខផង ទៅក្រោយផង ហើយរង់ចាំស្តាប់ មានសន្ធឹកមនុស្សអត់។ ហើយដល់តែពេលគប់ទៅ វាស្ងាត់។ ដល់ស្ងាត់ខ្ញុំនាំបងប្អូនខ្ញុំទាំងបីនាក់ហ្នឹង លូនឡើងមកលើ។ លូនរហូតទៅដល់ចូលព្រៃ ព្រោះអាមាត់រណ្តៅហ្នឹងវាវាល។ វាលប្រហែលពីនេះទៅតុ លោកមេធាវីអ៊ីចឹង។ អ៊ីចឹងនាំគ្នាលូនពីមាត់រណ្តៅហ្នឹងទៅឡើង ទៅចូលព្រៃហ្នឹង។ ហើយទៅដល់ក្នុងព្រៃហ្នឹងហើយ ប៉ុន្តែព្រៃហ្នឹងមិនព្រៃធំទេ ព្រៃល្បាស់ៗទេ។ ទៅជ្រកក្នុងព្រៃល្បាស់ហ្នឹង ភ្នែកបន្ទោមក ឲ្យបងប្អូនជួយមើលផ្លូវ។ បាទ ជួយមើលថាឃើញដើមស្វាយ ស្រមោលដើមស្វាយនៅត្រង់ណា។ អ៊ីចឹងអង្គុយទល់ខ្នងគ្នាទាំងបួននាក់។ ក្រោយពេលភ្នែកបន្ទោព្រាកមក ប្អូនខាងក្រោយខ្នងថា "បង! ខ្ញុំឃើញស្រមោលដើមឈើនេះធំ"។ អ៊ីចឹងខ្ញុំទៅអង្គុយពីមុខប្អូនដែលឃើញស្រមោលដើមឈើហ្នឹង។ បែរទៅមើលស្រមោលហ្នឹង ខ្ញុំសម្គាល់បានថាស្រមោលហ្នឹងជាស្រមោលដើមស្វាយ ដែលគេនាំខ្ញុំដើរកាត់ក្រោមដើមស្វាយហ្នឹងមក។ អ៊ីចឹងខ្ញុំក៏ដឹកនាំប្អូនខ្ញុំដើរសំដៅទៅដើមស្វាយហ្នឹង។ ហើយមិនមែនដើរត្រង់ទេ

ដូចថាដើររបៀបជាយុទ្ធវិធី ដើរដូចទាហានអ៊ីចឹង។ ឱនៗទៅ សំដៅទៅដើមស្វាយហ្នឹង បានទៅដល់ គល់ស្វាយហ្នឹងហើយ រកផ្លូវឆ្លងអូរមកៗវត្តវិញបាន។

[១១:១៩:០៧]

តែពេលនោះខ្ញុំមិនអាចទៅវត្តវិញបានទេ ព្រោះយប់ងងឹតណាស់។ ហើយខ្ញុំទៅវង្វេងនៅ កណ្តាលស្រែមួយទៀត ដែលមានគេដាំកប្បាស ហើយនាំគ្នាដេកនៅកណ្តាលស្រែហ្នឹង។ រង់ចាំស្តាប់ មាន់រងាវរបស់អ្នកស្រុក។ ដល់មាន់រងាវរបស់អ្នកស្រុក ម៉ោងរៀបភ្លឺ វាក្រហមៗ បានខ្ញុំស្គាល់ថាឯណា ឯលិច ឯណាឯកើត។ អ៊ីចឹងក៏ខ្ញុំនាំប្អូនហ្នឹងរត់។ បោកខោអាវ អាអាវប្រឡាក់ឈាមហ្នឹងសិន យកទៅ បោកនឹងថ្លុកក្របី ព្រោះអាវមានតែមួយ។ យកទៅបោកនឹងថ្លុកក្របី ដើម្បីបំភ័ន្តឈាមហ្នឹងសិន បានខ្ញុំ យកមកពួតឲ្យប្អូនស្រីដែលបែកក្បាលហ្នឹងពាក់ឡើងវិញ។ ពាក់ហើយក៏ដឹកដៃបងប្អូនរត់សំដៅទៅ ចេញពីវាលស្រែហ្នឹង ដំបូកហ្នឹងទៅ សំដៅចូលព្រៃ។ កន្លែងដែលគេឲ្យខ្ញុំទុកកង់សម្រាប់អូសអីវ៉ាន់នុង។ ដល់តែទៅដល់ហ្នឹង គេយកអស់ហើយអីវ៉ាន់ហ្នឹង។ ខ្ញុំក៏សាដានហ្នឹង ទៅលើវត្តច្រកស្តេចហ្នឹងតែម្តង។

**ស៖** លោកសាក្សី លោកអាចពន្យល់បានទេថា ហេតុអ្វីលោក ប្អូនស្រីរបស់លោក ហើយនិង ជីដូនមួយពីរនាក់របស់លោកហ្នឹង អាចចាំដើមស្វាយនោះ? ព្រោះថាទីតាំងហ្នឹងនៅឆ្ងាយ៦០, ៧០គីឡូ ម៉ែត្រ ពីភូមិរបស់លោកឯណោះ ហើយលោកអាយុទើបតែ ១០ឆ្នាំជាង?

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

មេធាវី គឺថាតាមដែលខ្ញុំចាំ គាត់បានបដិសេធហើយថាមិនមែន៦០, ៧០គីឡូទេ គឺតែ២គីឡូ។

[១១:២០:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

អ្វីដែលខ្ញុំដឹង គឺនិយាយពីភូមិកំណើតរបស់គាត់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកនៅទីតាំងសម្លាប់ដែលមានចម្ងាយប្រហែលជា៦០ ទៅ៧០គីឡូម៉ែត្រ ពីភូមិកំណើតរបស់លោក។ ដូច្នេះ តើលោកធ្វើយ៉ាងណាអាចចាំអ្វីៗដែលមាននៅក្នុងទីតាំងនោះបាន?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ជម្រាបប្រសាសន៍ដែរថា នៅពេលដែលគេយកយើងទៅ គឺខ្ញុំសម្គាល់ទុក ព្រោះខ្ញុំដឹង ថាគេយកទៅសម្លាប់ហើយ។ អ៊ីចឹងខ្ញុំសម្គាល់ពីភូមិសាស្ត្រហ្នឹង កន្លែងដាក់អីវ៉ាន់ ដាក់កង់ អូសទៅ មាន

វ៉ាលិស មានការុងហ្នឹង អូសទៅហ្នឹងគេឲ្យដាក់ម៉ុំនៅខាងត្បូងអូរ -- ខាងជើងអូរ ហើយគេនាំទៅខាងត្បូងអូរ យកទៅសម្លាប់។ អ៊ីចឹងខ្ញុំត្រូវសម្គាល់មើលឲ្យគ្រប់ជ្រុងជ្រោយហើយ។ បាទ បើនិយាយទៅថាពូជៗទាហាន ចរិតខ្ញុំហ្នឹងក៏វាទាហានដែរ។ អ៊ីចឹងខ្ញុំចេះស្គាល់ពីភូមិសាស្ត្រ ខ្ញុំចេះស្គាល់ពីកម្រិតនៃការពួន គេចខ្លួន បាទ។

[១១:២២:០៥]

**ស៖** ទោះបីថាខ្ញុំមានសំណួរច្រើនក៏ដោយ ប៉ុន្តែខ្ញុំសួរលោកមួយទៀតទេ។ ដូច្នេះខ្ញុំចង់ដឹងថាហេតុអ្វីបានជាលោកសម្រេចត្រឡប់ទៅវត្តច្រកដែក -- ច្រកស្តេចវិញ? លោកមកពីវត្តច្រកស្តេចហ្នឹងហេតុអីលោកសម្រេចចិត្តត្រឡប់ទៅក្រោយវិញ ត្រឡប់ទៅទីនោះវិញ?

**ឆ៖** បាទ ការសម្រេចចិត្តរបស់ខ្ញុំដែលសម្រេចចិត្តថា វិលទៅវត្តច្រកស្តេចហ្នឹងវិញហ្នឹង ព្រោះខ្ញុំដឹងថា កន្លែងនោះវាច្របូកច្របល់ មនុស្សច្រើន ខ្ញុំអាចលាក់ខ្លួន ហើយខ្ញុំអាចជួបបងប្អូនសុំបាយគេហូបបាន។ អ៊ីចឹងបង្ខំចិត្ត ត្រូវវិលទៅកន្លែងនោះវិញ ដើម្បីគេចខ្លួនជាមួយហ្វូងមនុស្សដ៏ច្រើនហ្នឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់វេទិកាជូនទៅសហការីរបស់ខ្ញុំ បើទោះបីជាខ្ញុំមានសំណួរនៅសល់ច្រើនហូរហៀរក៏ដោយ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកសហមេធាវី ខៀវ សំផន!

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន ជម្រាបសួរលោកសាក្សី។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ ខ្ញុំសូមត្រឡប់មកនិយាយអំពីការពិភាក្សារបស់លោកជាមួយលោកមេធាវី កូប៉េពីព្រលឹម។ លោកបាននិយាយថា កាលពី២ឆ្នាំមុនហ្នឹង លោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងក្រុមការងារមួយ។ នេះគឺជាពាក្យដែលលោកបានប្រើប្រាស់កាលពីព្រឹកមិញ។ អ៊ីចឹង ខ្ញុំសុំឲ្យលោកពិពណ៌នាអំពីចំនួនសមាជិកក្រុមការងារហ្នឹង តើមានមនុស្សប៉ុន្មាននាក់ដែរ នៅក្នុងក្រុមការងារហ្នឹង?

[១១:២៤:១១]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ការសម្ភាស ការជួបសម្ភាសជាមួយខ្ញុំហ្នឹងវាយូរឆ្នាំដែរហើយ។ អ៊ីចឹងក្រុមការងារនេះ គឺទៅមួយឡាន គ្នាប្រហែលជាបួននាក់។

**ស៖** តើលោកនៅចាំឈ្មោះពួកគាត់ទាំងអស់គ្នាទេ? លោកនៅចាំមុខងាររបស់មនុស្សទាំងបួននាក់ហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានចាំអស់ទេ។ រហូតមកដល់ពេលនេះ ឃើញមុខក៏អត់ស្គាល់ដែរ។ ប៉ុន្តែខ្ញុំទទួលយកឯកសារនេះ។ ឯកសារនេះគឺជាឯកសារដែលខ្ញុំបានបំភ្លឺជូនគាត់ កាលពីពេលនោះ។

**ស៖** អ៊ីចឹងគឺបានន័យថា អ្នកទាំងបួននាក់ហ្នឹងគេសម្ភាសលោក ហើយក្រោយមកបានចេញជាលទ្ធផល គឺបានកំណត់ហេតុស្តាប់ចម្លើយលោកហ្នឹង។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតប្រាកដហើយ។

**ស៖** ហើយនៅកន្លែងប៉ុស្តិ៍ប៉ូលិសរបស់លោកហ្នឹង លោកអង្គុយនៅកន្លែងណាដែរនៅកន្លែងអធិការដ្ឋាននគរបាលរបស់លោកហ្នឹង លោកអង្គុយនៅកន្លែងណានៅពេលដែលអ្នកទាំងបួននាក់ហ្នឹងសម្ភាសលោក?

**ឆ៖** ខ្ញុំនៅអង្គុយនៅប៊ុយរ៉ូធ្វើការរបស់ខ្ញុំ។

[១១:២៦:១៤]

**ស៖** អ៊ីចឹងបានន័យថា លោកមានការការិយាល័យធំអាចដាក់កៅអីប្រាំបាន ព្រោះលោកម្នាក់ហើយគេសម្ភាសលោកនោះមានតែបួន -- ដល់តែបួននាក់ឯណោះ?

**ឆ៖** បាទ ការិយាល័យខ្ញុំធំ ហើយមានកៅអីដល់១២ សម្រាប់ប្រជុំនៅទីហ្នឹងតែម្តង ប្រជុំកូនចៅ។

**ស៖** តើអ្នកទាំងបួននាក់ហ្នឹងដែលបានជួបលោកនៅថ្ងៃហ្នឹងៗ ពីមុនមកលោកមានធ្លាប់បានជួបគាត់ដែរឬទេ? ហើយធ្លាប់ស្គាល់គាត់ដែរឬទេ ពីមុនថ្ងៃ -- តាំងពីមុនថ្ងៃសម្ភាសហ្នឹងទៀតហ្នឹង?

**ឆ៖** បាទ អត់ដែលស្គាល់គាត់ទេ។ តែព័ត៌មាននេះប្រហែលជាដឹងពីសារព័ត៌មាន បានជាកម្លាំងគាត់ទៅ ព្រោះមុនហ្នឹងខាងសារព័ត៌មានគេៗសម្ភាស គេចុះផ្សាយពីប្រវត្តិរបស់ខ្ញុំ។ ហើយក្រោយមកស្រាប់តែឃើញកម្លាំងការងារហ្នឹង ក្រុមការងារហ្នឹងចុះទៅដល់ សុំសម្ភាសខ្ញុំ។

**ស៖** នៅក្នុងអត្ថបទកាសែតហ្នឹង តើលោកបានរៀបរាប់អំពីជីវិតរបស់លោកនៅក្នុងអំឡុងឆ្នាំ

១៩៧៥ ដោយសារមូលហេតុហ្នឹងហើយបានជាគេចាប់អារម្មណ៍លើប្រវត្តិរបស់លោក ឬក៏យ៉ាងណា?

**ឆ៖** បាទ សារព័ត៌មានបានចុះផ្សាយមុន បាន១ចុះសម្ភាសខ្ញុំមុន ហើយគេវាយក្នុងទំព័រកាសែត។ ហើយក្រោយហ្នឹងមក ប្រហែលជាវំលងប្រហែលជា២ខែបានឃើញក្រុមការងារហ្នឹងចុះទៅដល់ ២ទៅ៣ខែបានឃើញក្រុមការងារហ្នឹងចុះទៅដល់។

[១១:២៨:២៤]

**ស៖** ពួកគេទៅជួបលោកដោយផ្ទាល់តែម្តង ឬក៏មុននឹងគេទៅជួបលោកហ្នឹងគេបានទាក់ទងលោកតាមទូរស័ព្ទនិយាយគ្នាមុនសិន ឬក៏គេទៅតែម្តង គេទៅជួបលោកនៅក្នុងការិយាល័យរបស់លោកតែម្តង?

**ឆ៖** បាទ អត់បានទាក់ទងគ្នាតាមទូរស័ព្ទ ឬក៏លិខិតស្នាមអីទេ ព្រោះគាត់បានឃើញសារព័ត៌មានហ្នឹង ឃើញកាសែត។ ដល់ឃើញកាសែត វំលងបានមួយខែកន្លះទៅពីរខែហ្នឹង ស្រាប់តែឃើញក្រុមគាត់ហ្នឹងចុះទៅស្រាវជ្រាវតាមទំព័រកាសែតហ្នឹង។ ព្រោះកាសែតហ្នឹងគេសួរខ្ញុំមុខងារខ្ញុំធ្វើអ្វីខ្ញុំនៅភូមិណា ឃុំណា។ អ៊ីចឹងគេចុះទៅស្រាវជ្រាវតាមការចុះ ការសរសេររបស់សារព័ត៌មាន។

**ស៖** បាទ ដើម្បីឲ្យច្បាស់តែម្តង តើនៅក្នុងអត្ថបទកាសែតនោះ លោកមានបាននិយាយអំពីការដែលលោករួចរស់រានមានជីវិត ផុតពីគ្រោះនៅក្នុងអង្កាល់ពីឆ្នាំ១៩៧៥ហ្នឹងដែរឬទេ? លោកមានបាននិយាយពីការដែលលោករួចផុតពីការស្លាប់ហ្នឹងដែរឬទេ នៅក្នុងអត្ថបទកាសែតហ្នឹង?

**ឆ៖** បាទ ពេលនោះគឺខ្ញុំនិយាយមិនខុសទេ ប្រវត្តិដែលខ្ញុំដែលបានចុះក្នុងឯកសារនេះ។ ហើយអ៊ីចឹងហើយសារព័ត៌មានក៏អ៊ីចឹងដែរ ខ្ញុំនិយាយលម្អិត តាំងពីចេញដំណើរពីមូលដ្ឋាន -- ពីផ្ទះទៅរហូតទៅដល់កន្លែងគេសម្លាប់។ ទៅដល់កន្លែងគេសម្លាប់ហើយ ខ្ញុំភៀសខ្លួនចេញពីកន្លែងសម្លាប់ដូចក្នុងឯកសារនេះអ៊ីចឹង។

[១១:៣០:២៦]

**ស៖** ហើយអង្កាល់នុ៎ង អត្ថបទកាសែតហ្នឹង កាសែតហ្នឹងឈ្មោះអីដែរ?

**ឆ៖** កាសែតហ្នឹងឈ្មោះកាសែតកោះសន្តិភាព។

**ស៖** បាទ ខ្ញុំគិតថាលោកប្រហែលជារក្សាទុកមួយច្បាប់ហើយ តើលោកមានរក្សាទុកអត្ថបទហ្នឹងដែរឬទេ?

**ឆ៖** អត្ថបទនៃសារព័ត៌មានហ្នឹង ខ្ញុំអត់បានរក្សាទុកទេ ព្រោះអីវាយូរណាស់ យូរពេកហើយ

វា២ឆ្នាំទៅហើយនោះ។

**ស៖** បាទ សូមអរគុណ។ បាទ ក្រៅពីការលំបាកដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះ ព្រោះថាយើងមានកាលបរិច្ឆេទនៅនេះ គឺថា៧ឆ្នាំកន្លងមកហើយ មិនមែន២ឆ្នាំទេ។ ហើយមានបញ្ហាមួយទៀត គឺកើតមកពីថានៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកហ្នឹង គឺថាមានសរសេរថា មានឈ្មោះអ្នកស៊ើបអង្កេតលោកតែម្នាក់ទេគឺឈ្មោះ លឹម សុគន្ធា ហើយគ្មានអ្នកណាអមគាត់ទេ។ អ៊ីចឹងដល់ថា បីនាក់ទៀតហ្នឹង ខ្ញុំមិនឃើញមានសរសេរនៅក្នុងហ្នឹងទេ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយហ្នឹង។ អ៊ីចឹងមើលទៅឃើញដូចមិនធម្មតាទេ តើលោកនៅតែអះអាងថា គេសម្ភាសលោកហ្នឹងដល់ទៅបួននាក់ អ៊ីចឹងប្រាំនាក់រួមទាំងរូបលោកនោះ លោកនៅតែរក្សាចម្លើយហ្នឹងដែរឬទេ?

**ឆ៖** សូមជម្រាបដែរថា ការជួបសម្ភាសការផ្ញើលអ្នកទៅជួបសម្ភាសខ្ញុំហ្នឹងតាមរយៈសារព័ត៌មានហ្នឹង មិនដឹងជាក្រុមណាអីក្រុមណាខ្លះទេ។ ខ្ញុំអត់ចាំទេ វាមានពីរបីក្រុមឯណោះដែលគេត្រូវចុះទៅតាមជួបសម្ភាសជាមួយខ្ញុំ។

**ស៖** ហើយក្រុមការងារផ្សេងៗហ្នឹងគឺថា សមាជិកក្រុមការងារគេហ្នឹងសុទ្ធតែមនុស្សប្លែកៗគ្នារហូត ឬក៏យ៉ាងណា?

[១១:៣៣:០៣]

**ឆ៖** បាទ តាមខ្ញុំវិភាគមើលគឺដូចជាក្រុមផ្សេងៗគ្នា។

**ស៖** ហើយរាល់ដងនោះអ្នកទាំងអស់ហ្នឹងមកសួរសំណួររបស់លោក ទាក់ទងទៅនឹងហេតុការណ៍ឆ្នាំ១៩៧៥ ដែលលោកបានឆ្លងកាត់ ហើយនិងសួរលោកពីរឿងដែលលោករួចផុតពីការស្លាប់ហ្នឹង។ អ៊ីចឹង តើក្រុមផ្សេងៗដែលមកសម្ភាសលោកហ្នឹង គេសម្ភាសលោកតែលើរឿងដែលលោករួចពីការស្លាប់ហ្នឹងទេ កាលពីឆ្នាំ៧៥ហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ការស៊ើបសួរសម្ភាសហ្នឹង គឺគេចង់បញ្ជាក់តែពីរឿងរ៉ាវដែលយើងរួចខ្លួនពីការស្លាប់នេះទេ។

**ស៖** ការលោកប្រើពាក្យថា "ក្រុមការងារ" ហ្នឹង ខ្ញុំគិតថា "ក្រុមការងារ" ពាក្យនេះវាទូលំទូលាយណាស់ មិនមានខ្លឹមសារច្បាស់លាស់ទេ។ ខ្ញុំគិតថាមនុស្សដែលទៅសម្ភាសលោកទាក់ទងនឹងរឿងផ្ទាល់ខ្លួនរបស់លោកហ្នឹង ពួកគាត់ហ្នឹងគួរគឺថាណែនាំខ្លួនឲ្យស្គាល់ហើយ។ គេប្រាប់លោកថាគេហ្នឹងមកពីស្ថាប័នណាហើយ ព្រោះថាទៅដល់កន្លែងស្នងការដ្ឋានផងនោះ ត្រូវតែប្រាប់ ដូចលោកធ្វើ

ការងារក៏លោកត្រូវប្រាប់គេដែរថាលោកធ្វើអ្វី។ អ៊ីចឹង គេមានប្រាប់លោកទេ ថាគេមកពីអង្គការណា ពីស្ថាប័នណា ដើម្បីមកសម្ភាសលោកហ្នឹង គេមានប្រាប់លោកទេ?

**ឆ៖** បាទ ការទៅជួបសុំការអនុញ្ញាតដើម្បីសម្ភាសសួរនាំនេះ គឺគេបានប្រាប់របស់គេ តែខ្ញុំមិនបានកត់ត្រាទុកជាចំណាំ។ អ៊ីចឹងគេគ្រាន់តែ ខ្ញុំនឹកថា គេគ្រាន់តែចង់ដឹងថា ការរួចខ្លួនរបស់ខ្ញុំពីសេចក្តីស្លាប់នេះ មកវិញនេះ វាដំណើររឿងហ្នឹងវាម៉េច។ អ៊ីចឹងខ្ញុំរាប់រៀបតែដំណើររឿងហ្នឹងជូនទៅគាត់។ បាទហើយឲ្យខ្ញុំយកជាកំណត់ត្រាទុកថាក្រុមណា អង្គភាពណា ខ្ញុំអត់បានកត់ត្រាទេ។

**សៈ** ចំពោះលោកហ្នឹង គឺការចាំថាអ្នកណាមកសម្ភាសលោកហ្នឹងមិនសំខាន់ទេ ឬក៏យ៉ាងណា?

**ឆ៖** បាទ គឺខ្ញុំដឹងថាការចង់ដឹង ចង់ឮទិដ្ឋភាពហ្នឹង វាសំខាន់ហើយ។ បាទវាសំខាន់ហើយបានគេតាមទៅសួរយើងដល់កន្លែង ជួបសម្ភាសសួរនាំយើងដល់កន្លែង។ តែសម្រាប់ខ្ញុំៗគ្រាន់តែជួយបកស្រាយឲ្យដឹងថា ការសម្លាប់នេះគឺពិតមែន។ ការយកប្រជាពលរដ្ឋទៅសម្លាប់នេះ គឺពិតមែន។ ខ្ញុំនេះឯងជាជនរងគ្រោះ។ អ៊ីចឹងខ្ញុំរាប់រៀបរឿងរ៉ាវហ្នឹងជូនគាត់ ហើយគាត់ថតជាខ្សែអាត់ទុក គាត់សរសេរជាលាយលក្ខណ៍អក្សរទុករបស់គាត់។

[១១:៣៦:៣៧]

**សៈ** កាលពីព្រឹកមិញ តាំងពីព្រឹកមិញមកហ្នឹង គឺថាយើងនិយាយអំពីព្រឹត្តិការណ៍ដែលកើតឡើងមកហ្នឹង ៤០ឆ្នាំហើយ ប៉ុន្តែឥឡូវនេះ យើងនិយាយអំពីរឿងរ៉ាវដែលកើតឡើងពី២ឆ្នាំមុននោះទេ។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើលោកឲ្យគេសម្ភាសប៉ុន្មានដងជាមួយក្រុមការងារផ្សេងៗទៀត? ហើយ ឬក៏លោកមិនចាំថា អ្នកដែលមកសម្ភាសលោកហ្នឹងមកពីស្ថាប័នណា ពីអង្គការណា ពីអង្គភាពណាទេ? មិនចាំទាំងឈ្មោះផង ឬយ៉ាងណា?

**ឆ៖** ខ្ញុំគ្រាន់បញ្ជាក់អ៊ីចេះថា រឿងហេតុវាកើតឡើងមកហ្នឹងវា៣០, ៤០ឆ្នាំហើយ ក៏ប៉ុន្តែអ្នកដែលទៅជួបសម្ភាសខ្ញុំហ្នឹង ក្នុងអំឡុង២ឆ្នាំនេះ បាទក្នុងរយៈពេល២ឆ្នាំនេះ។ អ៊ីចឹងគាត់ទៅជួបសម្ភាសខ្ញុំហ្នឹងវាពីរបីៗក្រុមនោះ ទាំងសារព័ត៌មានផង ទាំងអង្គការឯណាណោះផង ទាំងក្រុមខាងតុលាការ-កំពូលនេះផង។ អ៊ីចឹងខ្ញុំអត់បានកត់ត្រាចំណាំថា អ្នកណា ក្រុមណាមកថ្ងៃណាៗនោះទេ ខ្ញុំអត់បានកត់ត្រាទេ។

**សៈ** លោកៗមើលទៅដូចចាប់ផ្តើមចាំឡើងវិញហើយ ប៉ុន្តែមើលទៅដូចជាមិនសម្រួលដល់ការងារខ្ញុំសោះ។ លោកនិយាយថា មានក្រុមការងារជាច្រើនមកសម្ភាសលោក មកពីតុលាការនេះ

មកៗៗសម្ភាសលោក។ អ៊ីចឹង ខ្ញុំសួរថា មានក្រុមការងារពីតុលាការនេះ ប៉ុន្មានក្រុមដែរមកសម្ភាសលោក?

[១១:៣៨:២៨]

**ឆៈ** មានតែមួយក្រុម ហើយបានអញ្ជើញទៅតែម្តង។ តែដល់ថ្ងៃក្រោយនេះ ប៉ុន្មានថ្ងៃមុននេះ គាត់បានទៅធ្វើនេះ ខ្ញុំម្តងទៀត បញ្ជាក់ថា ខ្ញុំត្រូវតុលាការកំពូលអញ្ជើញមកទីនេះ ដើម្បីធ្វើជាសាក្សី។

**សៈ** លោកសាក្សី លោកដឹងហើយថាយើង មានខ្សែអាត់នៃការសន្ទនារបស់លោកជាមួយមនុស្សតែម្នាក់ទេ ដែលបុគ្គលនោះធ្វើការនៅតុលាការនេះ មិនមែន២ឆ្នាំមុនអីនេះទេ គឺថាតាំងពី៧ឆ្នាំមុនឯណោះ។ ហើយមានផ្នែកមួយនៃខ្សែអាត់ហ្នឹង ដែលនៅក្នុងផ្នែកហ្នឹងលោកនិយាយអំពី និយាយយោងទៅកិច្ចសម្ភាសន៍របស់លោកកាលពីមុនមក។ អ៊ីចឹងខ្ញុំសូមឱ្យលោកស្តាប់ផ្នែកហ្នឹង គឺក្នុងខ្សែអាត់ហ្នឹង គឺនាទី១៤:១៨សឹហ្គុង ទៅដល់១៤នាទី៤១វិនាទី។ ពេលនោះ លោកកំពុងតែនិយាយពីប្រធានបទថ្មីមួយ លោកមិនបាននិយាយអ្វីពីមុនមកទេ ក៏ប៉ុន្តែមើលទៅឃើញដូចលោកយោងទៅលើការសន្ទនាដែលលោកបាននិយាយជាមួយគាត់កាលពីមុនមក។

**លោក អាកទួរ វែកគែនៈ**

អ៊ីចឹងលោកប្រធាន ខ្ញុំសូមអនុញ្ញាតចាក់ខ្សែអាត់នេះ ដើម្បីឱ្យលោកសាក្សី គាត់ស្តាប់បានឮអំពីអ្វីដែលគាត់បានពិភាក្សាជាមួយនឹងអ្នកសម្ភាសគាត់។ ហើយផ្នែកបច្ចេកទេស គេត្រៀមលក្ខណៈរួចហើយ អស់ហើយលោកប្រធាន ដែលគេត្រៀមតែនឹងចាក់ខ្សែអាត់ហ្នឹងទេ។

**ប្រធានអង្គជំនុំៈ**

សូមអញ្ជើញ!

[១១:៤១:០៤]

*(ការបង្ហាញឯកសារជាសំឡេង)*

"សៈ[...] ជាការនាំដើររបស់ខ្មែរក្រហម? ឆៈ បាទ ការៗៗនាំដើររបស់ខ្មែរក្រហមហ្នឹង ចេះតែបណ្តើរយើងរហូតទៅដល់ភ្នំជំរាយ ភ្នំឱរ៉ាល់។ ថាដូចបងថា គេដើរជម្រុះស្បៀង។ បាទអស់ស្បៀងទៅបានគេបង្វិលយើងមកចូលរកសហករណ៍។ ហើយ[...]"

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[១១:៤១:៥៩]

**លោក អាកទូរ វែកគែន៖**

លោកប្រធាន ខ្ញុំមើលឃើញថា មានការបកប្រែចេញជាភាសាបារាំងនោះ គឺដូចជាមានបញ្ហា លោកប្រធាន។ ខ្ញុំសូមផ្ទៀងផ្ទាត់ការបកប្រែផ្ទាល់មាត់អម្បាញ់មិញបន្តិច លោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** បាទ ទោះយ៉ាងណាក៏ដោយ អម្បាញ់មិញនេះ ខ្ញុំបកបាន -- ឮៗថា បកប្រែអំមិញ គឺថា ដូចដែលខ្ញុំបានថា។ ហើយបើតាមពិតទៅ បើតាមនែលោកនិយាយហ្នឹង ដូចដែលលោកនិយាយ តាមពិត លោកនិយាយទៅកាន់អ្នកសួរលោក លោកនិយាយថា “ដូចបងថា” ទេ។ អ៊ីចឹងខ្ញុំមិនចំណាយពេលវេលា យូររឿងបកប្រែហ្នឹងទេ ក៏ប៉ុន្តែនៅពេលដែលលោកនិយាយថា “ដូចបងថា” បានន័យថា លោកនិយាយ ជាមួយគេពីមុនមកហើយ។ តើខ្ញុំ -- អ៊ីចឹងខ្ញុំចង់ដឹងថា តើថ្ងៃហ្នឹងលោកជួបអ្នកស៊ើបអង្កេតហ្នឹង ជាលើកទី១ ឬក៏ធ្លាប់ជួបពីមុនមកហើយ ពិភាក្សាគ្នា?

[១១:៤៣:១១]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ អ្នកដែលចុះទៅហ្នឹង ដូចខ្ញុំថាវាពីរបីក្រុមឯណោះ ប៉ុន្តែសម្ដីអំមិញដែលខ្ញុំស្ដាប់អំមិញ នេះ គ្រាន់តែបញ្ជាក់អ៊ីចេះ បញ្ជាក់ថាគាត់ចង់ជីកសួរថា ចុះហេតុអីក៏ដើរឆ្ងាយ រហូតដល់ព្រៃភ្នំ ចេញ ជំរាយ ទៅដល់ឱរ៉ាល់។ អ៊ីចឹងហើយ ខ្ញុំបានបញ្ជាក់ថា ហ្នឹងហើយកម្មវិធីគេដើរនាំយើងដើរ ដើម្បីជម្រុះ ស្បៀង។ ដល់តែពេលយើងដើរជ្រុះស្បៀងអស់ហើយ គេនឹងមានវិធានការឲ្យចូលមកជួបជុំគ្នានៅតំបន់ វត្តច្រកស្ដេចនេះ ចែកស្បៀង។ ចែកស្បៀងដើម្បីទៅធ្វើការកន្លែងដើមវិញ។ បាទ អ្នកណាធ្វើអី ទៅធ្វើ នុ៎ងវិញ។ ហើយដល់អ៊ីចឹងទៅ បានជាកើតផែនការកាប់សម្លាប់នេះ នៅត្រឹមវត្តច្រកស្ដេចនេះតែម្ដង។ អានេះសម្រាប់ក្រុមខ្ញុំ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីសក្ខីកម្មរបស់លោកវិញម្ដង។ អម្បាញ់មិញលោកនិយាយថា នៅពេលដែលលោកទៅដល់វត្តហ្នឹង វត្តដែលគេៗឲ្យមនុស្សទាំងអស់គ្នា ហ្នឹងចុះឈ្មោះហ្នឹង លោកបាននិយាយថា នៅមានអ្នកបើកទុកទុកដើម្បីចុះឈ្មោះ ហើយដើម្បីសុំស្រូវ អង្ករ។ ខ្ញុំដូចជាមិនយល់។ លោកចង់និយាយអំពីអី មាននែគេជិះទុកទុក ហើយចុះឈ្មោះសុំអង្ករសុំអី?

**ឆ៖** បាទ ជម្រាបដែររឿងហ្នឹង។ អ្នកដែលដាច់ស្បៀង គឺថាគ្នាអត់អង្ករហូបហើយ អ៊ីចឹងនៅ ពេលដែលឮគេប្រាប់ថាអ្នកណាធ្វើមន្ត្រីរាជការ ធ្វើទាហានឲ្យមកចុះឈ្មោះដើម្បីបើកស្បៀង បើកអង្ករ

នេះយកទៅហូប អ៊ីចឹងដែលគ្នាដាច់ហើយ អ្នកខ្លះរត់រ៉ឺម៉ក រត់ស៊ីក្លូសោះ អ៊ីចឹងដើម្បីអាហារ -- ដើម្បីក្រពះ ត្រូវតែចុះឈ្មោះ ភរគេថាខ្លួនធ្វើទាហានដើម្បីបានអាស្បៀងហ្នឹងមកចិញ្ចឹមគ្រួសារ។

[១១:៤៥:៤២]

**ស៖** តើលោកដឹងដែរឬទេថា គេមានផ្ទៀងផ្ទាត់ដែរឬទេ ថាតើគេមានផ្ទៀងផ្ទាត់ឲ្យដឹងថាន៎អ្នកដែលចុះឈ្មោះហ្នឹងពិតជាអតីតយោធាមែនដែរឬទេ? លោកដឹងថាមានគេផ្ទៀងផ្ទាត់អីដែរឬទេ?

**ឆ៖** បាទខ្លះទៅក៏មានសញ្ញាណឲ្យដឹងថាជាទាហាន ហើយខ្លះទៅអត់មានសញ្ញាណមិនដឹងថាទាហានទេ។ មានសញ្ញាណដឹងថាទាហាន អ្នកខ្លះស្លៀកខោទាហាន អ្នកខ្លះពាក់អាវយឺតទាហានទៅសុំចុះឈ្មោះនឹងគេដើម្បីបានអង្ករ ហើយអ្នកខ្លះហ្នឹងអត់មានឯកសណ្ឋានទាហានផង ជាស៊ីវិល ហើយទៅប្រាប់គេថា ខ្ញុំធ្វើទាហាននៅទីនេះទីនោះ។ អ៊ីចឹងគេកត់ត្រាចូល ឈ្មោះអី មានគ្រួសារប៉ុន្មាននាក់ គេបើកអង្ករឲ្យតាមហ្នឹងដើម្បីយកទៅចិញ្ចឹមជីវិត។ ហើយពេលនោះអត់មានទីផ្សារទេ អត់មានកន្លែងលក់ដូរដោះដូរអង្ករ ត្រីសាច់អីអត់មានទេ។

**ស៖** អ៊ីចឹងនៅពេលដែលលោកនៅកន្លែងហ្នឹង លោកបានឃើញពួកគាត់ទាំងអស់នោះត្រូវបែងចែក ទាញចេញពីក្រុង -- ចេញពីក្រុមហើយ ចេញ មានតែអ្នកមានប្រដាប់អាវុធហ្នឹង គេនាំយកទៅកន្លែងផ្សេង លោកឃើញអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំបានជម្រាបម្ដងហើយ។ នៅពេលដែលយើងចុះឈ្មោះបើកអង្ករហើយ គឺកងឈ្លបដែលមិនប្រើប្រាស់ដោយប្រដាប់អាវុធទេ បាទកងឈ្លបគេហ្នឹង គឺគេបើក -- យើងបើកអង្ករហើយ កងឈ្លបគេនាំយើងទៅ។ ក្នុងមួយគ្រួសារឈ្លបពីរនាក់ ឬម្នាក់អ៊ីចឹងទៅ នាំយើងទៅដើម្បីទៅរកកន្លែងនៅបាទរកកន្លែងស្នាក់នៅ។ ដល់ទៅពេលយប់ឡើង គេ -- អានេះនិយាយពីរឿងខ្ញុំទេ ហើយអ្នកដទៃក៏ដូចខ្ញុំអ៊ីចឹងដែរ។ ដល់ទៅពេលបានអង្ករទៅ គេនាំចេញទៅបាត់ហើយ ចេញពីៗវង្វង់វត្តហ្នឹង វត្តច្រកស្ដេចហ្នឹង ចេញទៅៗចូលព្រៃហើយ។ ហើយអ៊ីចឹងគេធ្វើសកម្មភាពពេលហ្នឹងតែម្ដង។

[១១:៤៨:០៨]

**ស៖** បាទ សូមអរគុណ។ ដោយសារមិនមានឈ្លបពីរនាក់អ្នកមើលគ្រួសារ មួយគ្រួសារ អ៊ីចឹងដោយសារមានប្រាំពីរគ្រួសារ អ៊ីចឹងបានន័យថាមានឈ្លបនោះដល់ទៅ១៤នាក់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចេះ ខ្ញុំចង់បញ្ជាក់អ៊ីចេះថា ក្នុងក្រុមគ្រួសារមួយដែលទៅចុះឈ្មោះបើកអង្ករហើយហ្នឹងណា គេឲ្យនៅផ្ដុំ។ អ៊ីចឹងអ្នកដែលមានឈ្មោះបើកអង្ករហើយ ឲ្យនៅផ្ដុំហើយ ប្រមូលគ្នាមក បាន

ប្រាំមួយប្រាំពីរគ្រួសារហ្នឹងទៅឈ្លបតែម្នាក់ទេ ឬពីរនាក់តែប៉ុណ្ណោះដែលនាំយើងទៅ ក្នុងប្រាំមួយប្រាំពីរគ្រួសារហ្នឹង ឈ្លបហ្នឹងអ្នកនាំទៅ។ ទៅចូលព្រៃហ្នឹង បានមានកម្លាំងប្រដាប់អាវុធចេញមកភ្ជង់។ អានេះជារឿងពិតដែលខ្ញុំឃើញនឹងភ្នែក។

**ស៖** ចុះរូបលោកផ្ទាល់នោះ ជាមួយនឹងគ្រួសាររបស់លោកនោះ តើមានឈ្លបប៉ុន្មាននាក់ដែរដែលគេយកលោកចេញទៅចូលព្រៃនោះ?

**ឆ៖** បាទ ក្រុមខ្ញុំនេះវាច្រើនប្រើប្រាស់អាវយឺតទាហាន ខោទាហាន អ៊ីចឹងគេជឿថាប្រាកដជាទាហានហើយ។ អ៊ីចឹងពេលឈ្លបនាំចេញពីវត្តច្រកស្តេចនេះទៅនេះ គឺមានឈ្លបបីនាក់អ្នកនាំទៅ។

**ស៖** តើអ្នកដែល -- ឈ្លបទាំងបីនាក់ហ្នឹងមានកាន់អាវុធអីទេ មិនប្រកាន់ថាអាវុធអីទេ តើគាត់មានកាន់អាវុធទេ?

**ឆ៖** គាត់អត់មានអាវុធទេ ប៉ុន្តែនិយាយទៅថាកាំបិតហ្នឹងក៏ជាអាវុធដែរ។ គាត់កាន់កាំបិតកកុកមួយ បង់កក្រមា ហើយនាំយើងទៅ។ តែដល់ពេលចូលដល់ក្នុងព្រៃរូងខ្លាហ្នឹង បានមានកងកម្លាំងប្រដាប់អាវុធមកភ្ជង់បណ្តើរយើង យកទៅសម្លាប់។ បាញ់សម្លាប់។

[១១:៥០:៤១]

**ស៖** បាទ ហ្នឹងគឺសំណួរដែលខ្ញុំចង់សួរហើយអម្បាញ់មិញហ្នឹង។ តើលោកអាចបញ្ជាក់បានទេថានៅក្នុងបរិបទណាដែលក្រុមទី២ នៅពេលណាដែលលោកឃើញក្រុមហ្នឹងជាលើកទី២ ក្នុងកាលប្បវត្តិ លំដាប់លំដោយពេលវេលាហ្នឹង សួរថាពេលណាឲ្យច្បាស់លាស់តែម្តង ក្រុមទី២ហ្នឹង?

**ឆ៖** ក្រុមទី២ម៉េច ខ្ញុំស្តាប់អត់ច្បាស់។ អ៊ីចឹងលោកចង់សួរថា ក្រុមទី១ កងឈ្លបអ្នកនាំទៅ? ហើយក្រុមទី២ហ្នឹង គឺក្រុមប្រដាប់អាវុធ ឬមួយយ៉ាងម៉េច?

**ស៖** បាទ ខ្ញុំសូមសួរលោកជាដំបូងនោះ ថាលោកដើររយៈពេលប៉ុន្មានជាមួយឈ្លបបីនាក់ហ្នឹងដែលដើរទៅចូលព្រៃ។ អ៊ីចឹងចង់សំណួរទី១ហ្នឹង សួរថាដើររយៈពេលប៉ុន្មានទម្រាំទៅដល់ចូលក្នុងព្រៃ?

**ឆ៖** បាទ ការធ្វើដំណើរចេញពីវត្តច្រកស្តេចទៅ ចម្ងាយដីបើខ្ញុំស្មាន២គីឡូម៉ែត្រ។ ២គីឡូម៉ែត្រហ្នឹង គឺគេឲ្យយើងស្តុបសម្ភាររបស់យើងដែលយើងអូសតាមកង់ រែកតាមដងរែកទៅហ្នឹង គេឲ្យស្តុបនៅមាត់ព្រៃខាងត្បូង -- អ៎! ខាងជើង ជាប់នឹងព្រៃ ព្រំនឹងច្រកវត្តច្រកស្តេចហ្នឹង។ ហើយគេឲ្យយើងស្តុបអីវ៉ាន់នៅហ្នឹងហើយ បានគេនាំយើងឆ្លងវាលស្រែមក ឆ្លងអូរ--

**ស៖** លោកសាក្សី ខ្ញុំមានពេលវេលាតិចទេ។ ខ្ញុំគ្រាន់តែចង់សួរលោក ថាតើលោកដើរប៉ុន្មាន

អស់រយៈពេលប៉ុន្មានដែរ ពីវត្តច្រកស្តេចហ្នឹងទៅក្នុងព្រៃនេះ ដែលឈ្លបបីនាក់នាំលោកទៅហ្នឹង?

**ឆ៖** វាប្រើពេលយូរដែរ។ បើថានាំពីច្រកស្តេចទៅ ទៅឈប់នៅកន្លែងអាមាត់ព្រៃខាងជើងហ្នឹងម្តងហើយ អ៊ីចឹងវាចង់១ម៉ោង។ ហើយនាំពីមាត់ព្រៃខាងជើងហ្នឹង ទៅចូលព្រៃរូងខ្លាហ្នឹង វាចង់១ម៉ោងទៀត។ អ៊ីចឹងខ្ញុំសន្និដ្ឋានថា ២ម៉ោង ក្នុងចម្ងាយផ្លូវ២គីឡូហ្នឹង។

**ស៖** បាទ លោកនិយាយថា២ម៉ោង គួរឲ្យចាប់អារម្មណ៍ដែរ។ នៅពេលដែលលោកទៅដល់ក្នុងព្រៃហើយហ្នឹង បានមានក្រុមឈ្លបទី២ហ្នឹងចេញមក។ អ៊ីចឹងមែនទេ លោកចង់និយាយថាអ៊ីចឹង គេនាំលោកទៅដល់ក្នុងព្រៃហើយ មានក្រុមឈ្លបមួយក្រុមទៀតមកយកលោកបន្តទៅទៀត ឬក៏យ៉ាងម៉េច?

[១១:៥៣:២៧]

**ឆ៖** បាទ ឈ្លបដែលនាំចេញពីវត្តច្រកស្តេចទៅ អត់មានអាវុធទេ មានតែកាំបិតមួយទេ បីនាក់ហ្នឹង។ មានតែកាំបិតមួយម្នាក់ទេ ដោយសារគាត់ថា នាំយើងទៅកាប់ព្រៃ -- អ៎! កាប់ឈើធ្វើជម្រក។ ហើយដល់តែពេលឆ្លងអូរទៅដល់ចូលព្រៃរូងខ្លាហ្នឹង បានមានកម្លាំងប្រដាប់អាវុធ មកឆ្កកយើងយកទៅសម្លាប់តែម្តង។ អ៊ីចឹងរយៈពេលហ្នឹង វាចូល២ម៉ោងហើយ។

**ស៖** នៅពេលដែលឈ្លបទាំងអស់ហ្នឹង លេចមុខចេញមកហ្នឹង មកយកបន្តហ្នឹង តើលោកចាំទេថាពួកគេហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ? ខ្ញុំនិយាយអំពីក្រុមឈ្លប ឬដូចពាក្យលោកនិយាយអំមិញ ប្រដាប់អាវុធហ្នឹង ចេញមកយកបន្តហ្នឹង។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកមេធាវី សូមអភ័យទោសដែលកាត់លោក។ ប៉ុន្តែនៅពេលដែលលោកសួរ តាមការបកប្រែគឺលោកនិយាយ "ឈ្លប" ប៉ុន្តែចំពោះសាក្សីគាត់និយាយថាជា "ទាហាន"។ ដូច្នេះខ្ញុំចង់ដឹងច្បាស់ ថាតើភាសាខ្មែរ ថាតើសាក្សីគាត់ប្រើពាក្យតែមួយទេ ឬក៏គាត់ប្រើពាក្យពីរ។

**សួរបន្តដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

**ស៖** លោកសាក្សី តើលោកអាចឆ្លើយនឹងសំណួរខ្ញុំបានដែរឬទេ ថាអ្នកដែលចេញពីក្នុងព្រៃ គឺអ្នកដែលលោកជួបនៅក្នុងព្រៃហ្នឹងជាអ្នកណា? គឺថាអ្នកដែលលោកហៅថា ជាកងប្រដាប់អាវុធហ្នឹង ថាតើពួកគាត់ហ្នឹងគឺជាក្រុមតែមួយ ដូចនឹងអ្នកដែលនាំលោកទៅក្នុងព្រៃ ឬមួយក៏ជាអ្នកដែលមានលក្ខណៈខុស? តើពួកគេដូចគ្នា ឬក៏ខុសគ្នា? តើពួកគេមានឯកសណ្ឋានអ្វីដែរទេ? សូមលោករៀបរាប់។

[១១:៥៥:២៨]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ជម្រាបរាយការណ៍ជូនផងដែរថា ដែលហៅថាកងឈ្លបហ្នឹង អត់ប្រើប្រាស់អាវុធទេ អត់ប្រើកាំភ្លើងទេ។ បាទគាត់មានតែកាំបិតកកុកមួយម្នាក់ទេ។ តែដល់តែចូលឆ្លងព្រៃ ឆ្លងអូរទៅចូលព្រៃរូងខ្លាហ្នឹង បានមានមនុស្សដែលប្រើប្រាស់ទៅដោយអាវុធ គ្នាប្រាំមួយនាក់។ ម្ដងបីៗភ្ជង់យកទៅយកទៅសម្លាប់នោះ។ អ៊ីចឹងអត់មានឯកសណ្ឋានអីឲ្យត្រឹមត្រូវថាជាទាហាន ជាកងឈ្លប។ អត់មានឯកសណ្ឋានអីត្រឹមត្រូវទេ។ ប៉ុន្តែដឹងថាមានអាវុធ យកទៅសម្លាប់ទៅដោយអាវុធ និងដំបង។

**ស៖** តើពួកគេមានអាវុធអ្វីដែរ? តើពួកគេកាន់អាវុធអ្វីដែរ?

**ឆ៖** បាទ ពេលនោះខ្ញុំស្គាល់កាំភ្លើងច្បាស់អស់ហើយ។

**ស៖** ខ្ញុំចង់សួរអ្នកដែលលោកថាប្រដាប់អាវុធហ្នឹង តើគេកាន់កាំភ្លើងអ្វីដែរ?

**ឆ៖** នៅពេលដែលគេភ្ជង់យើងទៅហ្នឹង គេប្រើប្រាស់ដោយអាវុធ អា.កា។ ហ្នឹងសម្រាប់ដែលខ្ញុំឃើញតែអមខ្លួនខ្ញុំទេណ៎ា អមក្រុម ប្រាំពីរគ្រួសារទៅហ្នឹង គឺប្រើប្រាស់ដោយអាវុធ អា.កា ប្រាំមួយនាក់។ តែគេនៅពួនឯណាឯណីទៀតខ្ញុំអត់ដឹងទេ ដែលចេញមកភ្ជង់យកទៅហ្នឹង គឺប្រាំមួយនាក់ដោយអាវុធ អា.កា។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោក។

**សួរបន្តដោយលោក អាកទួរ វែកគែន៖**

**ស៖** តើពួកអ្នកដែលមានប្រដាប់អាវុធកាន់កាំភ្លើង អា.កា ហ្នឹងគ្នាគេប៉ុន្មាននាក់ដែរ?

[១១:៥៧:៤០]

**លោក សំ សិទ្ធី៖**

**ឆ៖** ដូចខ្ញុំបានជម្រាបហើយថា នៅពេលដែលយើងចេញពីមាត់អូរទៅហ្នឹង ចូលក្នុងព្រៃហ្នឹង គឺឃើញតែប្រាំមួយទេ កាន់កាំភ្លើង អា.កា ភ្ជង់យើងយកទៅតែម្ដង។ តែរឿងគេនៅពួនឯណាឯណីទៀតខ្ញុំអត់បានឃើញទេ អត់ដឹងទេ។ អ៊ីចឹងប្រាំមួយនាក់ហ្នឹងប្រើប្រាស់ទៅដោយអាវុធប្រាំមួយដើម អា.កា។

**ស៖** នៅពេលដែលអ្នកទាំងប្រាំមួយនាក់ មានកាន់អាវុធហ្នឹងមកដល់ តើមានអ្នកណាខ្លះនៅហ្នឹង? មានលោកព្រោះលោកនៅទីហ្នឹង តើអ្នកណាផ្សេងទៀត ក្រុមគ្រួសារផ្សេងៗកូនក្មេង មានតែបុរសស្ត្រី ឬក៏មានទាហាន អតីតទាហានដែលគេនាំមកពីវត្តហ្នឹងដែរ? អ៊ីចឹងលោកអាចជម្រាបជូន

តុលាការបានទេថា នៅពេលដែលឈ្លប -- មនុស្សប្រដាប់អាវុធទាំងប្រាំមួយនាក់ចេញមកហ្នឹង មានអ្នកណាខ្លះ មានវត្តមាននៅទីនោះ?

**ឆ៖** បាទ ជម្រាបផងដែរថា ខ្ញុំនិយាយនេះ គឺនិយាយតែក្រុមប្រាំពីរគ្រួសាររបស់ខ្ញុំនេះទេ ដែលជួបនូវឧប្បត្តិហេតុហ្នឹង ជួបនូវព្រឹត្តិការណ៍បែបហ្នឹង។ អ៊ីចឹងក្រុមដទៃទៀត ខ្ញុំអត់បានដឹងទេ។ ប៉ុន្តែខ្ញុំ -- ខ្ញុំជឿថាវិធានការហ្នឹង គឺជាវិធានការតែមួយ គេនឹងធ្វើដូចក្រុមខ្ញុំអ៊ីចឹងដែរ។

**ស៖** លោកសាក្សីខ្ញុំសូមកាត់ផ្តាច់លោក ព្រោះថាខ្ញុំចង់និយាយអំពីអ្វីដែលកើតឡើងចំពោះរូបលោក។ ខ្ញុំចង់សួរលោកថា តើម្តាយលោកនៅទីនោះដែរឬទេ នៅពេលដែលអ្នកប្រដាប់អាវុធទាំងអស់ហ្នឹងមកដល់? ហើយម្តាយលោកក៏ឃើញមនុស្សទាំងអស់ហ្នឹងដែរឬក៏យ៉ាងម៉េច?

[១១:៥៩:៥០]

**ឆ៖** បាទ ឃើញទាំងអស់គ្នា។ នៅពេលដែលយើងឆ្លងព្រៃ គឺយំបណ្តោយ។ នៅពេលឆ្លងព្រៃទៅ គេមកភ្ជង់គឹប យំឱបខ្ញុំតែម្តង ព្រោះខ្ញុំអ្នកញុះគាត់ឲ្យរត់ ថារត់ទៅ គេយកប៉ាទៅហ្នឹងគេយកទៅបាញ់ចោលបាត់ហើយ។ អ៊ីចឹងឲ្យនាំគ្នានេះរត់ចេញ គាត់អត់រត់ទេ។ ដល់តែពេលអត់រត់ទេ គាត់ចាប់ខ្ញុំយកមកក្នុងចង្កោមជាមួយនឹង ដើរចូលទៅក្នុងរង្វង់ការភ្ជង់របស់គេហ្នឹងទាំងអស់គ្នា។ ហើយឃើញកាំភ្លើងមកភ្ជង់ស្រែកយំរំងូង ថាខ្ញុំនេះនិយាយរឿងពិត មិនស្តាប់កូន។ កូនប្រាប់ឲ្យរត់មិនរត់ យំឱបខ្ញុំទាំងអស់គ្នា ចូលទៅរណ្តៅមរណៈហ្នឹងតែម្តង។

**ស៖** ពួកគេទាំងអស់នោះ មិនអាចឱបលោកអីបាននោះទេ ព្រោះថាគេភ្ជង់ទៅហើយ ត្រូវតែធ្វើយ៉ាងម៉េច?

**ឆ៖** បាន១ ព្រោះមនុស្សច្រើន គ្រាន់តែគេភ្ជង់ពីប បែរមកឱបខ្ញុំ ដើរបណ្តើរយំបណ្តើរទៅដល់កន្លែងពិឃាត។

**ស៖** តើអ្នកដែលកាន់អាវុធទាំងប្រាំមួយនាក់ហ្នឹងហើយដែលយកប្រុស១ យកទៅមុន យកទៅសម្លាប់នៅក្នុងរណ្តៅ បេ-៥២ ហ្នឹង? មនុស្សទាំងប្រាំមួយនាក់ហ្នឹងដដែលឬ ឬក៏អ្នកផ្សេងទេ?

**ឆ៖** ខ្ញុំអត់បានស្គាល់មុខទេ ប៉ុន្តែខ្ញុំគ្រាន់តែឃើញសកម្មភាព ព្រោះខ្ញុំវានៅតូច ខ្ញុំរត់តាមឪពុកទៅ។ ដល់រត់តាមឪពុកទៅ គេដេញមកវិញ ខ្ញុំអត់មក ខ្ញុំនៅលួចមើល ក្រោយពេលគាត់ឆ្លងផុតអូរទៅ គឺគេភ្ជង់របៀបដូចយកប្រពន្ធកូនទៅតាមក្រោយអ៊ីចឹង ដូចគ្នា។

[១២:០២:១២]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងលោកនៅជាមួយឪពុករបស់លោក នៅពេលដែលមនុស្សទាំងប្រាំមួយនាក់ហ្នឹងចេញមក ឬក៏យ៉ាងម៉េច? លោកត្រូវបានគេបំបែកចេញពីក្រុមស្ត្រី ឬក៏យ៉ាងណា?

**ឆ៖** អត់អ៊ីចឹងទេ គេយកតែមនុស្សពេញកម្លាំងយកទៅមុន ជាប្រុស យកទៅមុន។ ហើយខ្ញុំហ្នឹងតូចជាងគេរត់តាមឪពុកទៅ ហើយគេដេញមកក្រោយវិញ ដេញឲ្យមកនៅជាមួយម្តាយវិញ អត់ឲ្យទៅជាមួយឪពុកទេ។ តែខ្ញុំមិនមក ខ្ញុំនៅលួចមើលសកម្មភាពហ្នឹង។ សកម្មភាពហ្នឹងបណ្តើរចូលផុតព្រៃផុតអូរហ្នឹងទៅ គឺប្រាំមួយនាក់ហ្នឹងចេញមកភ្ជង់យកទៅតែម្តង។ ហើយមួយស្របក់ក្រោយមក ឮស្នូរផ្ទុះអាវុធ ខ្ញុំរត់មកប្រាប់ម្តាយ មីងមាខាងក្រោយនេះ ថាឲ្យនាំគ្នារត់ទៅ គេយកប៉ាទៅបាញ់ចោលអស់ហើយ។ គាត់អត់ជឿ។

**ស៖** ហើយអ្នកទាំងអស់ហ្នឹង ដែលអ្នកដែលលោកប្រាប់ថា ឪពុកលោកនោះត្រូវបានគេយកទៅសម្លាប់ចោលហើយហ្នឹង គាត់អត់បានឮស្នូរកាំភ្លើងទេ អ៊ីចឹងហើយបានជាពួកគាត់មិនជឿលោក ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំជឿថាឮ ព្រោះគ្រាន់តែពេលដែលបាញ់ប្រាវហើយ ខ្ញុំរត់មកក្រោយវិញ ខ្ញុំមកប្រាប់គាត់ឲ្យនាំគ្នារត់ ហើយគាត់មិនជឿខ្ញុំ គាត់ថា គេបាញ់សត្វទេកូន មិនមែនគេយកប៉ាទៅបាញ់ចោល។ ខ្ញុំថាអត់ទេ យកប៉ាទៅបាញ់ចោលអស់ហើយ។ ហើយខ្ញុំឲ្យគាត់រត់ គាត់អត់រត់។

[១២:០៤:២០]

**ស៖** មើលទៅដូចជាចម្លែកដែរ ព្រោះថា នៅក្នុងកំណត់ហេតុស្តាប់ចម្លើយលោកកាលពី៧ឆ្នាំមុននោះ លោកនិយាយខុសពីហ្នឹង។ ខ្ញុំសូមឲ្យលោកឆ្លើយតបទៅនឹងចម្លើយរបស់លោកនេះ ដែលលោកបានរៀបរាប់ ទើបតែរៀបរាប់អម្បាញ់មិញនេះដែរហ្នឹង។ គឺកំណត់ហេតុស្តាប់ចម្លើយរបស់លោកថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៨ គឺឯកសារE3/5201។ ខ្ញុំសូមអាន ERN ជាភាសាបារាំងគឺ 00275145, ជាភាសាខ្មែរ 00212121, ជាភាសាអង់គ្លេស 00275139។ លោកនិយាយថា បាទខ្ញុំសុំដកស្រង់ នៅពេលដែលលោកនិយាយថា៖ "ម្នាក់ហ្នឹង ថាខ្មែរក្រហមដែលមានក្រមាបង់ក ក្រមាក្រហម គាត់ឲ្យយើងទម្លាក់អីវ៉ែអីវ៉ាន់យើងចោល ហើយបន្ទាប់មកទៀតប្រើឲ្យអ្នកនៅពេញកម្លាំងហ្នឹងទៅកាប់ព្រៃឈើនៅព្រៃដើម្បីសង់ខ្ទមផ្ទះបណ្តោះអាសន្ន ហើយនារីៗ និងកុមាររួមទាំងខ្ញុំផងហ្នឹង ត្រូវនៅទីនោះសិន។ ម្នាក់នោះនាំបុរសៗ និងក្រុមខ្ញុំចំនួន១២នាក់ ឪពុកខ្ញុំផងដើរកាត់ស្រែចូលទៅក្នុងព្រៃ។ នៅពេលដែលខ្ញុំដើរតាម បន្ទាប់មកខ្ញុំបានឃើញខ្មែរក្រហមប្រាំប្រាំមួយនាក់ចេញពីព្រៃមកភ្ជង់កាំភ្លើង រួចហើយ

បុរសៗទាំងនោះចូលទៅក្នុងព្រៃទៅ។ ខ្ញុំក៏រត់ប្រាប់ក្រុមនារីៗរួមទាំងម្ដាយខ្ញុំផង ហើយនិងប្អូនៗខ្ញុំផង ដែល ប្រហែល៣០នាក់ដែលកំពុងតែចាំអំពីហេតុការណ៍ដែលខ្ញុំឃើញ។ ប្រហែលមួយម៉ោងក្រោយមក ខ្ញុំឮសូរស្នូរកាំភ្លើងនៅក្នុងព្រៃ នៅតាមទិសដែលគេបណ្ដើរក្រុមបុរសៗទាំងនោះទៅ។ បន្ទាប់មកអ្នកពាក់ក្រមាក្រហមហ្នឹងបានមកនាំក្រុមស្ត្រី រួមទាំងម្ដាយបងប្អូនខ្ញុំផងដែរទៅទិសដដែល។”

អ៊ីចឹងលោកមើលទៅថា ឃើញមាន លោកនិយាយក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកនេះ មានមនុស្សតែម្នាក់ទេបង់ក្រមាក្រហមនាំមនុស្សទាំងប្រាំពីរគ្រួសារហ្នឹងទៅ ហើយវាផ្ទុយពីអ្វីដែលលោកបាននិយាយ។ លោកអត់មានបានចាំមើលការសម្លាប់ឪពុករបស់លោកនោះទេ លោករត់ចេញភ្លាមតែម្ដង នៅពេលដែលឃើញ -- ពេលលោកដឹងថាពួកមានកាន់កាំភ្លើងនេះមកយកពួកគាត់ទៅហ្នឹង ហើយលោកបានមកជួបស្ត្រីៗ មករៀបរាប់រឿងប្រាប់ពួកគាត់។ ហើយមួយម៉ោងក្រោយមកទៀតបាន លោកឮស្នូរកាំភ្លើងនៅក្នុងទិសដែលគេនាំយកបុរសៗហ្នឹងទាំងអស់ទៅនោះ។ អ៊ីចឹង លោកអាចពន្យល់ភាពផ្ទុយគ្នានេះបានដែរឬទេ? ឃើញថារយៈពេល តាមពេលវេលាហ្នឹង លំដាប់លំដោយពេលវេលាហ្នឹងឃើញថាវាខុសគ្នាអំពីអ្វីដែលលោកទើបនឹងនិយាយនៅក្នុងសវនាការនេះ។

[១២:០៧:៣៤]

**លោក នីកូឡាស គូមជែន៖**

ឯកឧត្ដម លោក លោកស្រីចៅក្រម គឺថា អ្វីដែលគាត់អានគឺវាវែងពេក ហើយវាហាក់ដូចជាមិនមែនជាសំណួរទេ គឺគាត់និយាយថា គាត់បានឃើញឪពុក។ ប៉ុន្តែសាក្សីពន្យល់ច្បាស់ហើយថា គាត់ឃើញគេយកឪពុកគាត់ទៅ ហើយបន្ទាប់មកទៀត គាត់ឮសូរស្នូរកាំភ្លើង។

**លោក អាកឡូរ វែកគែន៖**

បាទ ខ្ញុំអត់យល់ពីអ្វីដែលសហព្រះរាជអាជ្ញាបាននិយាយទេ។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** ខ្ញុំនៅតែសួរសំណួរហ្នឹងដដែលលោកសាក្សី។ ខ្ញុំសួរលោកថា ហេតុអ្វីក៏ក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកនោះ លោកនិយាយថាមានអ្នកនាំទៅហ្នឹងតែម្នាក់ទេ ឈ្លបតែម្នាក់ទេ បង់ក្រមាក្រហម។ ហើយអម្បាញ់មិញនេះ លោកនិយាយថាមានដល់ទៅបីនាក់។ ហើយលោកនិយាយថា ហើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកហ្នឹង លោកនិយាយថា លោករត់មកភ្លាមពេលដែលឮសំឡេងបាញ់នោះ តែមុននេះអម្បាញ់មិញ លោកនិយាយថា ឮភ្លាម។ អ៊ីចឹង ខ្ញុំមើលទៅឃើញថា ម្ដងថា

ឮភ្លាម ហើយម្តងថា មួយម៉ោងក្រោយមកបានឮសូរស្នូរបាញ់អ៊ីអ៊ឹចឹង។ លោកអាចពន្យល់បានទេ ភាពចម្រូងចម្រាសនេះ?

[១២:០៨:៥៣]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ខ្ញុំសុំបំភ្លឺជុំវិញបញ្ហានេះឲ្យបានជ្រាបឡើងវិញ។ ថាកងឈ្លបបីនាក់ហ្នឹង គឺគេជូនចេញពីវត្តមក មិនប្រើប្រាស់ដោយអាវុធទេ ប្រើប្រាស់កាំបិត។ មកដល់កន្លែងទុកអីវ៉ែអីវ៉ាន់ហ្នឹង គេត្រូវបំបែកគ្នា ពីរនាក់នៅយាមប្រពន្ធ ម្នាក់នាំប្តីចេញទៅកាំឈើ ទៅកាប់ឈើដើម្បីបោះជំរំនៅ ព្រោះវាជិតយប់ហើយ។ នៅពេលដែលបណ្តើរចូលទៅក្នុងព្រៃនោះ ខ្ញុំក៏រត់ទៅតាម ឮថាទៅកាប់ឈើ ខ្ញុំរត់ទៅតាមឪពុកខ្ញុំ។ ដល់តែពេលគេដេញមកក្រោយវិញ ខ្ញុំអត់មក។ ខ្ញុំចេះតែតាមមើលគាត់រហូត។ ដល់ពេលចូលទៅផុតព្រៃនោះ ឃើញកម្លាំងប្រដាប់អាវុធប្រាំមួយនាក់ហ្នឹង ហើយឈ្លបមួយដែលនាំទៅ តែម្នាក់ទេនាំទៅ ពីរនាក់ទៀតនៅចាំប្រពន្ធកូននៅកន្លែងនេះ នៅឯណេះនៅឡើយទេ យកប្រុសៗទៅមុន។ អ៊ីចឹងមានតែឈ្លបម្នាក់ទេ យកប្រុសៗទៅមុនហ្នឹងនោះ ថាទៅកាប់ឈើហ្នឹងនោះ។ នៅសល់ពីរនៅនឹងកន្លែងប្រពន្ធកូន។ ហើយខ្ញុំរត់តាម ដល់ខ្ញុំរត់តាមទៅ ខ្ញុំឃើញសកម្មភាពហ្នឹង ឃើញសកម្មភាពភ្ជង់ហ្នឹងហើយ ខ្ញុំដឹងថាគេយកទៅសម្លាប់ហើយ។ អ៊ីចឹងគ្រាន់តែក្រឡេកឃើញគេភ្ជង់ឪពុកហើយ ខ្ញុំក៏រត់មកក្រោយ ខ្ញុំថា “គេយកប៉ាទៅបាញ់ចោលហើយ”។ អ៊ីចឹងខ្ញុំឲ្យគាត់រត់ គាត់អត់រត់ទេ គាត់ថា គាត់មិនជឿខ្ញុំទេ។ ក្រោយប្រហែលជាមួយម៉ោង ឮផ្ទុះអាវុធ ឮផ្ទុះអាវុធនៅៗចំណុចដែលខ្ញុំសង្ស័យថាយកទៅសម្លាប់ហ្នឹងហើយ ខ្ញុំថា “ហ្ន៎ ឮទេ ឮគេបាញ់ទេ គេបាញ់ចោលអស់ហើយ”។ ខ្ញុំរត់ ខ្ញុំរត់ចេញពីរង្វង់ម្តាយ រត់ទៅក្រោយវិញ គាត់រត់តាមទៅចាប់ខ្ញុំយកមកវិញ។ ហ្នឹងហេតុការណ៍ហ្នឹងវាអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហើយឥឡូវលោកក៏អស់ពេលហើយ លើសពេលរហូតដល់១២នាទីហើយបាទ។ អ៊ីចឹងគឺខ្ញុំសូមសម្រាកនៅពេលនេះសិន ហើយនៅពេលនេះក៏ត្រូវប្តូរ ឌី.វី.ឌី ដែរ។ អ៊ីចឹងសវនាការសូមឲ្យផ្អាកនៅពេលនេះសិន គឺដល់ម៉ោងមួយ យើងនឹងចូលបន្តទៅទៀត។

ហើយទាក់ទងបញ្ហាមេធាវី ចាំក្រុមប្រឹក្សានឹងពិចារណាមើល តើគួរធ្វើយ៉ាងម៉េចទៀត។ បាទ អ៊ីចឹងសូម--

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១១ នាទី ដល់ម៉ោង ១២:៥៩ នាទី)*

[១២:៥៩:២៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះតុលាការកំពូលសូមប្រកាសបន្តសវនាការ។ ហើយជាបន្តទៅនេះ គឺសូមអញ្ជើញសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីតាំងសំណួរដល់សាក្សី។

បាទ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណឯកឧត្ដមប្រធាន--

**លោក អាកទួរ វែកគែន៖**

លោកប្រធាន មុនពេលឈប់សម្រាក ឯកឧត្ដមប្រធានបានបញ្ជាក់ថា ប្រហែលជាអាចអនុញ្ញាតឱ្យខ្ញុំសួរបន្តក្នុងពេលមួយចំនួន ប៉ុន្តែៗឥឡូវនេះ លោកប្រធានបែរជាឱ្យខាងសហព្រះរាជអាជ្ញាទៅវិញ។

**ប្រធានអង្គជំនុំ៖**

តាមការពិភាក្សាទៅ ខ្ញុំមិនបានជម្រាបជូនលោក អ៊ីចឹងខ្ញុំជម្រាបតែម្ដងទៅ។ តាមការពិភាក្សាថា ទុកឱ្យខាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខធ្វើសំណួរសិន ហើយបើសិនជានៅសល់ពេលខាងក្រោយ នឹងអនុញ្ញាតឱ្យលោកបន្តទៅទៀត។ អ៊ីចឹងចាំឱ្យព្រះរាជអាជ្ញា សហព្រះរាជអាជ្ញា និងមេធាវីនាំមុខធ្វើបន្តិចសិន បាទ។

សូមអញ្ជើញអំមិញសហមេធាវីនាំមុខ! សូមអញ្ជើញ បាទ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណឯកឧត្ដមប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់វេទិកានេះ ជូនសហភាតារបស់ខ្ញុំ គឺលោក

មេធាវី ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

បាទ មេធាវី ហុង គឹមសួន សូមគោរពឯកឧត្តមប្រធាន សូមគោរពលោកស្រី លោកចៅក្រម ក្រុមប្រឹក្សា និងអង្គសវនាការជាទីគោរព។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរខ្លះៗសួរទៅលោកបន្ថែមលើសំណួរដែលខាងមេធាវីការពារក្តីបានសួរពីព្រឹកមិញ បញ្ជាក់បន្ថែមបន្តិច។ សំណួរទី១ គឺនៅពេលដែលមានការជម្លៀសចេញ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ការធ្វើដំណើររបស់លោក និងក្រុមគ្រួសារថា ធ្វើដំណើរវែងឆ្ងាយ។ នេះជាបំណងរបស់លោក ឬយ៉ាងម៉េចបាទ? សូមបញ្ជាក់បន្តិច។

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ខ្ញុំបាទសូមគោរព និងឆ្លើយនូវសំណួររបស់លោកព្រះរាជអាជ្ញា។ ការធ្វើដំណើរវែងឆ្ងាយនេះ វាមិនមែនជាគំនិតរបស់ក្រុមគ្រួសារនោះទេ វាជាគោលការណ៍របស់ថ្នាក់ដឹកនាំសម័យនោះ។

[១៣:០២:៥៣]

**ស៖** សូមៗលោកបញ្ជាក់ឱ្យច្បាស់ ថ្នាក់ដឹកនាំសម័យនោះ ចង់សំដៅទៅលើសម័យណាមួយ?

**ឆ៖** យើងក្រោយ៧០ -- ឆ្នាំ៧៥នេះ យើងត្រូវបានជម្លៀស ក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត។ អ៊ីចឹងហើយគោលការណ៍នេះ ខ្ញុំជឿថាវាជាគោលការណ៍របស់ ប៉ុល ពត ដែលបានចាត់វិធានការឱ្យយើងជម្លៀសចេញពីមូលដ្ឋានទៅកាន់ទីព្រៃភ្នំ។

**ស៖** បាទ សូមអរគុណ។ សូមខ្លីៗបានហើយ ព្រោះខ្ញុំក៏មានពេលខ្លីដែរ បាទ ព្រោះបានបញ្ជាក់ព្រឹកមិញច្រើន។ តើនៅតាមផ្លូវធ្វើដំណើរហ្នឹង លោកមានឃើញទិដ្ឋភាពមនុស្សដែលធ្វើដំណើរជាមួយលោកហ្នឹងយ៉ាងម៉េចខ្លះដែរ មានចាស់ក្មេង ស្ត្រីអីហ្នឹង មានជួបតាមផ្លូវ លោកឃើញយ៉ាងម៉េចដែរ? អាចជម្រាបជូនបានទេ?

**ឆ៖** បាទ ខ្ញុំអាចជម្រាបជូនបានថា នៅពេលដែលរំដោះចេញពីមូលដ្ឋាន ពីផ្ទះសម្បែងទៅនេះ គឺៗចេញទៅទាំងអស់ ទាំងកូនង៉ែត កូនង៉ា ក្មេងចាស់ ប្រុសស្រី យើងធ្វើដំណើរសន្សឹមៗ អត់មានពេលលឿនទៅមុខបានទេ ព្រោះមនុស្សកុះករតាមដងផ្លូវដែលត្រូវធ្វើដំណើរនោះ។ អ៊ីចឹងហើយមិនអាច

លឿនបានទេ។

**ស៖** អ៊ីចេះៗ សូមកាត់ប្រសាសន៍បន្តិច។ សំណួរខ្ញុំសួរថា លោកមានឃើញទិដ្ឋភាពនៅតាមផ្លូវហ្នឹង មនុស្សធ្វើដំណើរហ្នឹង មានអ្នកណាកើតអីខ្លះទេ តាមផ្លូវ? ខ្ញុំចង់ដឹងកន្លែងហ្នឹង បាទ។

**ឆ៖** បាទ ការធ្វើដំណើរខ្លះក៏ដាច់ជីវភាព ហើយខ្លះក៏ត្រូវខ្យល់គដួលនៅតាមផ្លូវក៏មាន ប៉ុណ្ណឹងទេ បាទ។

[១៣:០៤:៥៧]

**ស៖** អ៊ីចឹងពេលហ្នឹង មានការត្រៀមលក្ខណៈជួយសង្គ្រោះពីខាងក្រុមពួកខ្មែរក្រហម ដែលជម្លៀសហ្នឹងដែរទេ?

**ឆ៖** បាទ ពេលហ្នឹងដូចជាអត់មានទេ មានតែការជំរុញឱ្យលឿនៗទៅមុខ ហើយការជម្លៀសមានពេទ្យមានអីតាមជួយតាមដងផ្លូវហ្នឹងគឺគ្មានទេ។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះដោយសារព្រឹកមិញ លោកបានឆ្លើយជូនអង្គសវនាការច្រើនហើយ ខ្ញុំសូមឈានទៅដល់ ទាក់ទងជាមួយការធ្វើដំណើរចុះពីភ្នំជំរាយមកវត្តច្រកស្តេចវិញ។ លោកមានប្រសាសន៍ព្រឹកមិញថា នៅទីនោះមានប្រជាពលរដ្ឋរាប់ពាន់នាក់ ឬក៏ច្រើនរយគ្រួសារ។ ហើយពេលនោះហើយដែលថាលោកដាច់ស្បៀង ពួកក្រុមឈ្លបនៃពួកក្រុមខ្មែរក្រហមហ្នឹង គេប្រកាសមីក្រូស្វែងរកអ្នកណាធ្វើជា -- ធ្លាប់ធ្វើជាអតីតទាហាន លន់ នល់ ឬអ្នករដ្ឋការ លន់ នល់។ អ៊ីចឹងតើពេលហ្នឹងមានមនុស្សច្រើនទេ ដែលទៅចុះឈ្មោះថាខ្លួនហ្នឹងជាប់និន្នាការ ឬចង់ត្រឡប់មកធ្វើការក្នុងរបបដូចៗដើមវិញនោះ មានមនុស្សច្រើនទេ?

**ឆ៖** បាទ ក្នុងពេលនោះខ្ញុំពិនិត្យមើលឃើញថា វាមិនច្រើន ហើយក៏វាមិនតិច អ្នកដែលគេមានស្បៀងហើយៗក៏គេមិនទៅទទួលយកស្បៀង ហើយអ្នកដែលគ្មានស្បៀង ដាច់ស្បៀង ត្រូវទៅចុះឈ្មោះទទួលយកស្បៀង។

[១៣:០៦:៣៨]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងចង់សួរលោកអ៊ីចេះដែលថា ព្រឹកមិញសំណួររបស់ខាងមេធាវីការពារក្តីសួរអំពីអ្នកដែលទៅចុះឈ្មោះហ្នឹង ដែលអះអាងអំពីថាជាប់និន្នាការ ធ្វើជាអតីតទាហានរបបលោក លន់ នល់ ឬក៏រដ្ឋការក្នុងរបបលោក លន់ នល់ ហ្នឹងណា។ ថាតើមានការទៅៗចុះឈ្មោះហ្នឹងវាៗចំនួនដណ្តើមគ្នាមានអ្នក -- ព្រឹកមិញឮសួរថាអ្នករត់តុកតុក ឬអ្នករត់ស៊ីក្លូជាដើមអ៊ីចឹងណ៎ះ។ អាហ្នឹង

ដែលខ្ញុំចង់ដឹងថា ចំនួនដែលទាហានលោកចំណាំបាន និងប្រជាពលរដ្ឋហ្នឹង តើវាមានចំនួនខុសគ្នាច្រើន តិចយ៉ាងម៉េចដែរ?

**ឆ៖** បាទ ក្នុងពេលនោះ ខ្ញុំពិនិត្យមើលឃើញថា អ្នកខ្លះក៏ទាហានច្រើនទៅ ហើយអ្នកខ្លះ ប្រជាជនដែលគាត់ដាច់ស្បៀងហ្នឹងក៏ចូលរួមទៅបើកយករបបនេះច្រើនដែរ។

**ស៖** អ៊ីចឹងសំណួរខ្ញុំសួរបន្ថែមថា ពេលដែលចុះឈ្មោះហ្នឹង គេឲ្យក្រដាសមកឪពុកលោកអ្នក បំពេញ ឬក៏គ្រាន់តែឈរប្រាប់គេៗអ្នកកត់ឈ្មោះបញ្ចូល?

**ឆ៖** បាទ ពេលនោះ ខ្ញុំដើរពីក្រោយគាត់ទៅដែរ។ គាត់បានទៅចុះឈ្មោះនឹងគេ ដោយសារគេ សួរយកតែក្រុមគ្រួសារហ្នឹងទេ។ គេសួរថា "លោកធ្វើទាហាននៅឯណា? អ៊ីចឹងមានកូនប៉ុន្មាននាក់? ប្រពន្ធមួយ -- ប្រពន្ធកូនប៉ុន្មាននាក់?" ហើយអ៊ីចឹងគេចែកអង្ករហ្នឹងទៅតាមរបបមនុស្សហ្នឹង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបន្ទាប់ពីចុះឈ្មោះបើកអង្ករហើយ លោកបានជម្រាបជូនអង្គ សវនាការអំពីពួកឈ្លបដែលនាំក្រុមគ្រួសាររបស់លោក រួមទាំងអស់ប្រាំពីរគ្រួសារទៅឯព្រៃរូងខ្លា។ អ៊ីចឹងខ្ញុំសូមសួរបន្តិច ចូលទៅដល់កន្លែងក្រោយពេលដែលបាញ់សម្លាប់ហើយតែម្តងចុះ ព្រោះកុំឲ្យវា សំណួរដដែលៗ។ លោកថាពេលដែលខ្មែរក្រហម ពួកយោធាហ្នឹងបាញ់សម្លាប់ហើយ ចាប់អូស បញ្ច្រាសជើងបោះទៅក្នុងរណ្តៅអាបេ។ ហើយលោកត្រូវបានបោះផ្ទប់ទៅជញ្ជាំង ឬក៏ទៅគៀនរណ្តៅ ហើយមានសាកសពប្រហែលជាពីរនាក់នៅៗសង្កត់អបពីលើលោក។ លោកថាលួចបើកភ្នែកមើល តិចៗ។ តើលោកក្រៅពីបើកភ្នែកមើលតិចៗហ្នឹង លោកមានបានឮសំឡេង ឬសម្តីពួកទាហាន ខ្មែរក្រហមដែលបានបាញ់សម្លាប់ហ្នឹង វានិយាយ ឬវាថាយ៉ាងម៉េចមកៗហ្នឹងទៀតដែរទេ?

[១៣:០៩:២៨]

**ឆ៖** បាទ ខ្ញុំនៅពេលដែលខ្ញុំថា ខ្ញុំលួចបើកភ្នែកមើលតិចៗហ្នឹងគឺគេអត់អូសទម្លាក់រណ្តៅទេ។ គេបាញ់ងាប់ស្លាប់អស់ហើយហ្នឹង អាក្មេងៗហ្នឹងគេដើររើហើយ គេស្រែកថា "ពួកឯងរាល់គ្នាហ្នឹង ជាន់ដើមទ្រូងអញរាប់សិបឆ្នាំមកហើយ ឥឡូវនេះអញជាន់ដើមទ្រូងពួកឯងវិញម្តង"។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងសំណួរបន្តទៅទៀត ខ្ញុំសួរថា នៅពេលដែលលោករត់ចេញពី រណ្តៅសាកសពបានហើយ ជាមួយនឹងបងប្អូនបីនាក់ទៀត រួមទៅវាបួននាក់។ ពេលដែលលោកទៅដល់ វត្តច្រកស្តេចវិញ ដែលលោកថា មុនពេលដែលមានការភ្ញាក់ផ្អើលបែកខ្ញែកនោះ មានពួកក្រុមពួកយោធា គេប្រកាសស្វែងរកចាប់ក្មេងប្អូននាក់ ដែលជា សេ.អ៊ុ.អា។ តើពាក្យ "សេ.អ៊ុ.អា" ហ្នឹងលោកឮសួរ

ផ្ទាល់ ឬមួយក៏យ៉ាងម៉េចដែរពេលហ្នឹង?

**ឆ៖** បាទ ជម្រាបប្រសាសន៍ ពេលនោះគឺកម្លាំងគេដែលនៅកំពុងតែឈរបើកអង្គរហ្នឹង--

**លោក អាកទួរ វែកគែន៖**

ខ្ញុំសូមជំទាស់លោកប្រធាន។ ការសង្ខេបនូវចម្លើយរបស់សាក្សីដោយលោកមេធាវី គឺមិនត្រឹមត្រូវទេ។ យើងទទួលបានចម្លើយមិនច្បាស់ទេ។ សូមឲ្យលោកមេធាវីសង្ខេបចម្លើយរបស់សាក្សីឲ្យបានច្បាស់ លោកមេធាវី។

[១៣:១១:១០]

**លោក ហុង គឹមសួន៖**

សូមជម្រាបឯកឧត្តមប្រធាន ពីព្រឹកមិញ គឺខ្ញុំបាទបានឮច្បាស់ហើយថា ពេលដែលគាត់មកដល់វត្តច្រកស្ដេចវិញ មានពួកខាងខ្មែរក្រហម គេតាមស្វែងរកកុមារបួននាក់ដែលជា សេ.អ៊ី.អា។ អ៊ីចឹងខ្ញុំចង់សួរគាត់ទៅវិញថា តើពាក្យថា "កុមារបួននាក់ជាខ្សែ សេ.អ៊ី.អា" ហ្នឹងគាត់បានឮការប្រកាសផ្ទាល់ត្រចៀកគាត់ដែរឬទេ? នេះជាអ្វីដែលខ្ញុំចង់ឲ្យគាត់ឆ្លើយបាទ។

**លោក អាកទួរ វែកគែន៖**

លោកនិយាយអំពីការប្រកាសអី សាក្សីគាត់និយាយពីពេលណាដែរ ពីការប្រកាសហ្នឹង ខ្ញុំដូចជាស្ដាប់មិនឮទេ លោកមេធាវី។

**លោក ហុង គឹមសួន៖**

សូមជម្រាបឯកឧត្តមប្រធាន សូមឆ្លើយតបនឹងមេធាវីការពារក្ដី។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ឥឡូវបើសិនអ៊ីចឹង ខ្ញុំដូរសំណួរ។ ថាតើព្រឹកមិញលោកបាននិយាយអំពីពេលដែលលោកត្រឡប់មកដល់វត្តច្រកស្ដេចវិញ ដែលមានការភ្ញាក់ផ្អើលត្រូវបានពួកក្រុមពួកឈ្លបខ្មែរក្រហមតាមស្វែងរកចាប់កុមារបួននាក់ ដែលជា សេ.អ៊ី.អា មាននិយាយអ៊ីចឹងដែរទេ?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ព្រឹកមិញនេះ តាមការសាកសួររបស់មេធាវី គាត់បានជីកសួរខ្ញុំរឿងហ្នឹង។ នៅពេលដែលខ្ញុំវិលត្រឡប់មកកាន់វត្តច្រកស្ដេចវិញនេះ ហើយខ្ញុំបានសុំបាយគេញ៉ាំហើយ ហើយក៏បានជួបនឹងមិត្តភក្ដិរបស់ឪពុកម្ដាយខ្ញុំ គេសួរថាខ្ញុំនេះ -- ឪពុកម្ដាយខ្ញុំទៅណា? ខ្ញុំថា គេយកទៅសម្លាប់ចោលអស់

ហើយ។ ខ្ញុំបាននិយាយព្រឹកមិញអ៊ីចឹង។ ហើយក្នុងនោះកើតការជ្រួលច្របល់ក្នុងវត្តហ្នឹង កើតការជ្រួលច្របល់ផ្អើលពីមួយទៅមួយៗ ខ្ញុំក៏នាំបងប្អូនគេច។ ហើយក្នុងនោះដែរ ក៏ការប្រកាសរបស់ក្រុមការងាររបស់គាត់ហ្នឹង ខ្មែរក្រហមហ្នឹង ដែលកំពុងតែចែកអង្ករហ្នឹង កាន់មីក្រូប្រកាសថា៖ "បងប្អូនកុំជឿឃោសនារបស់ពួក សេ.អ៊ី.អា ព្រោះកងឈ្លបរបស់យើងកំពុងតែតាមចាប់ពួក សេ.អ៊ី.អា ទាំងបួននាក់នេះហើយ"។ ខ្ញុំបាននិយាយអ៊ីចឹងព្រឹកមិញ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងសំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់សួរអ៊ីចេះលោក លោកបានជម្រាបអង្គសវនាការពីព្រឹកមិញថា ឪពុកលោកក៏ជាអតីតទាហានក្នុងរបបលោក លន់ នល់ ដែរ។តើលោកនៅចាំបានទេថា កាលគាត់នៅជាទាហានរបបលោក លន់ នល់ ហ្នឹងគាត់ពាក់ស័ក្តិប៉ុន្មានដែរទេ? ឋានន្តរសក្តិអីដែរបាទ?

**ឆ៖** បាទ ជម្រាបដោយត្រង់ ឪពុករបស់ខ្ញុំធ្វើទាហាននៅបន្ទាយចាន់សារិ មានឋានន្តរសក្តិស័ក្តិ៣ បើកឡានឲ្យឧត្តមសេនីយ៍នាយទាហាននៅចាន់សារិហ្នឹងតែម្តង។

[១៣:១៣:៥៤]

**ស៖** បាទ សំណួរចុងក្រោយ អំមិញថាចុងក្រោយ ឥឡូវចុងក្រោយថា តើរហូតក្រោយពេលថ្ងៃប្រាំ -- ក្រោយថ្ងៃ០៦ មករា ១៩៧៩ តើលោកដែលបានឮដំណឹងអំពីឪពុករបស់លោកឡើងវិញដែរទេ?

**ឆ៖** បាទ អត់ដែលបានឮដំណឹងទេ ហើយក៏ខ្ញុំអត់បានស៊ើបសួររកអីដែរ ព្រោះខ្ញុំឃើញនឹងភ្នែកថា គេយកទៅសម្លាប់ហើយ។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណច្រើនលោកសាក្សី។ ឯកឧត្តមប្រធាន ខ្ញុំបាទមានសំណួរប៉ុណ្ណឹង សូមឲ្យខាងសហការីខ្ញុំបន្តទៀតបាទ។ សូមអរគុណ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណឯកឧត្តមប្រធាន។ សូមគោរពឯកឧត្តមប្រធាន អង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំចង់ចាប់ផ្តើមពីសំណួរមួយ ហើយខ្ញុំដឹងថា ប្រហែលជា

វាពិបាកចំពោះលោក។ កាលពីមិញនេះ មេធាវីការពារក្តីបាននិយាយថា គាត់មិនជឿនូវលើរឿងហេតុដែលលោកបានឆ្លើយប្រាប់នៅក្នុងអង្គសវនាការកាលពីព្រឹកមិញនេះ។ គាត់ថា វាដូចជារឿងប្រឌិត។ ខ្ញុំចង់ឱ្យឆ្លើយតបទៅនឹងប្រតិកម្មដែលមេធាវីបានឆ្លើយ បានលើកឡើងថា រឿងរ៉ាវដែលលោកបានប្រាប់នោះ គឺជារឿងប្រឌិត។ តើលោកមានការឆ្លើយតបយ៉ាងណាដែរ ចំពោះបញ្ហានេះ?

[១៣:១៥:២៨]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ អរគុណនឹងសំណួរនេះ។ ខ្ញុំគិតថា មេធាវីការពារក្តី គាត់បាននិយាយចោទប្រកាន់មកលើខ្ញុំថា ក្នុងនាមខ្ញុំជាអធិការ អ៊ីចឹងការ -- របាយការណ៍ដែលខ្ញុំរៀបរាប់ជូនទាំងអស់នេះ គាត់ថា ខ្ញុំជាអ្នកប្រឌិតឡើង។ ហើយខ្ញុំបានបញ្ជាក់ប្រាប់គាត់វិញថា ខ្ញុំមិនមែនប្រឌិតឡើងទេ ខ្ញុំឃើញហេតុ-ការណ៍ហ្នឹងផ្ទាល់នឹងភ្នែក។ ហើយមុននឹងឡើងមកសវនាការនេះ ខ្ញុំបានទៅស្បថជាមួយនឹងអ្នកតារួចហើយ។ ខ្ញុំសូមនិយាយតែការពិត។

**ប្រធានអង្គជំនុំ៖**

លោកស្រីបញ្ជាក់ឈ្មោះផង ហើយដើម្បីឱ្យខាងអ្នកបកប្រែដឹងផង។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ ខ្ញុំជាតំណាងសហព្រះរាជអាជ្ញាជាតិឈ្មោះ សុង ឆវ័ន្ត ហើយនៅសល់សំណួរមិនច្រើនទេ ហើយខ្ញុំនឹងសួរសំណួរបន្ត។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចង់ឱ្យលោកបញ្ជាក់ឱ្យខ្លីថា រឿងរ៉ាវដែលកើតឡើងចំពោះគ្រួសាររបស់លោក នៅក្នុងហេតុការណ៍ដែលមានការបាញ់សម្លាប់នោះ ជារឿងពិត ឬរឿងប្រឌិត?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ហើយថា រឿងនេះជារឿងពិត ហើយខ្ញុំអត់មានឱ្យពន្លើសក្នុងសភាពការណ៍ណាមួយ គឺមិននិយាយឱ្យលើសទេ។ ព្រោះខ្ញុំជំនឿជឿជាក់ថា ខ្ញុំស្បថរួចហើយថា ខ្ញុំនិយាយតែការពិត។ មើលឃើញប៉ុនណា ថាប៉ុណ្ណឹង។

[១៣:១៧:០៩]

**ស៖** ចាស សូមអរគុណ។ មុននេះ ខាងតំណាងក្រុមមេធាវីនាំមុខខាងជាតិបានសួរលោកថា

ក្រុម -- លោកបានប្រើពាក្យថា "ក្រុមការងាររបស់ខ្មែរក្រហម"។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកថា ពាក្យថា "ក្រុមការងារ" ហ្នឹងជាទាហានខ្មែរក្រហម ជាកងទ័ពខ្មែរក្រហម ឬក៏ជាមនុស្សប្រភេទណាដែរ? សូមឲ្យលោកបញ្ជាក់ពាក្យនេះឲ្យច្បាស់។

**ឆ៖** បាទ បានជាខ្ញុំហៅថា "ក្រុមការងារហ្នឹង" ព្រោះក្រុមហ្នឹង គេកំពុងតែនៅឈរនៅលើវេទិកា ហៅថាសាលាបុណ្យនុំង សាលាឆាន់របស់លោកនៅក្នុងវត្តហ្នឹង។ ហើយមានគំនរអង្ករដែលរៀបចំទុកដាក់ជាស្រេចហ្នឹង ហើយប្រកាសឈ្មោះរកអ្នកណាធ្វើការហ្នឹង ដើម្បីបើកអង្ករ។ អ៊ីចឹងក្រុមនេះហើយជាក្រុមការងារ ដោយមានកងឈ្លប ដោយមានក្រុមប្រដាប់អាវុធតិចតួចដែលបង្ហាញមុខនៅទីនោះ។

**សៈ** អ៊ីចឹងក្រុមការងារ ឬក៏ក្រុមកងទ័ពខ្មែរក្រហមដែលលោកបានរៀបរាប់ថា នៅលើវេទិកាហ្នឹង មានគ្នាប្រហាក់ប្រហែលជាប៉ុន្មាននាក់ទៅ ពេលហ្នឹង?

**ឆ៖** បាទ វាមិនច្រើនទេ របៀបជាអង្គរក្ស។ ពីរបីនាក់សម្រាប់ការពារអ្នកធំនៅទីនោះ ហើយក្រុមកិច្ចការងារគេហ្នឹង ក្រុមការងារគេហ្នឹង អ្នកណាបើកអង្ករបើកទៅ អ្នកណាស្រង់ឈ្មោះស្រង់មក។

[១៣:១៨:៤៩]

**សៈ** ចុះការផ្សព្វផ្សាយ ឬក៏ប្រកាសអំពីដល់ប្រជាពលរដ្ឋនៅពេលហ្នឹង តើគេធ្វើសកម្មភាពអីគេខ្លះដែរ? ហើយបើសិនបើលោកអាចចាំបាន តើពេលហ្នឹងគេប្រើពាក្យពេចន៍ ឬក៏សម្តីយ៉ាងណាដែរ ដើម្បីប្រកាសប្រមូលប្រជាពលរដ្ឋហ្នឹង?

**ឆ៖** បាទ ពេលនោះគឺគេប្រកាសសួររកអ៊ីចឹង។ គេសួររកមន្ត្រីរាជការ ទាំងស៊ីវិល ទាំងយោធា សុំឲ្យមកចុះឈ្មោះបើកអង្ករ ដើម្បីវិលត្រឡប់ទៅបម្រើការងារនៅកន្លែងដដែលវិញ។

**សៈ** សូមលោកជួយបញ្ជាក់ឲ្យច្បាស់ថា ប្រមូល គាត់ប្រកាសហ្នឹង ប្រមូលហៅមនុស្សក្រុមប្រភេទណាដែរ?

**ឆ៖** តាមឮការប្រកាសហ្នឹង គឺមិនសំដៅទៅរក ទៅដល់ប្រជាជនស្លូតត្រង់នោះទេ គឺប្រកាសរកតែមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ។

**សៈ** ប្រកាសរកមន្ត្រីរាជការ ឬកងប្រដាប់អាវុធនៅក្នុងរបបមួយណាដែរ? សូមលោកជួយបញ្ជាក់ឲ្យរឹតតែច្បាស់។

**ឆ៖** បាទ គេប្រកាសរកមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធដែលធ្លាប់បម្រើការងារក្នុងរបប

លន់ នល់។

**លោក គង់ សំអុន៖**

លោកប្រធាន សូមធ្វើការកត់សម្គាល់។ ត្រង់ភាសាខ្មែរគឺថាក្នុងរបប លន់ នល់ គេមិនហៅ "មន្ត្រីរាជការ" គេហៅ "មន្ត្រីរដ្ឋការ"។ បាទ សូមអរគុណ។

[១៣:២១:០៤]

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណចំពោះការកត់សម្គាល់នេះ។ ខ្ញុំគ្រាន់តែយោងលើពាក្យសាក្សី ហើយសួរគាត់បញ្ជាក់ប៉ុណ្ណោះ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** អ៊ីចឹងលោកសាក្សី ដើម្បីឱ្យច្បាស់ទាំងអស់គ្នា តើមន្ត្រីរាជការ ឬមន្ត្រីរដ្ឋការហ្នឹង នៅក្នុងរបបហ្នឹង តើលោកគិតថាដូចគ្នា ឬក៏ខុសគ្នា ឬវាមានន័យយ៉ាងណាដែរចំពោះការយល់ឃើញរបស់លោក?

**លោក សំ សិទ្ធី៖**

**ឆ៖** លោកបានឡើងបកស្រាយអម្បាញ់នេះ សួរនាំអម្បាញ់នេះ ពិតជាត្រឹមត្រូវហើយ។ ខ្ញុំនិយាយនេះ គឺនិយាយក្នុងរបបយើងបច្ចុប្បន្ន។ តែរបប លន់ នល់ គឺលោកបានដឹងច្បាស់ហើយថា គេមិនហៅ "មន្ត្រីរាជការ" ទេ។ បាទ អ៊ីចឹងខ្ញុំសូមឯកភាពតាមលោកមេធាវី បាទ។

**ស៖** ចាស សូមអរគុណ។ ខ្ញុំចូលទៅដល់ប្រធានបទថ្មីមួយទៀត ទាក់ទងទៅនឹងហេតុការណ៍ដែលបានកើតឡើងនៅពេលដែលលោកទៅដល់ឃុំក្រាំងល្វា។ សូមឱ្យលោកជួយរៀបរាប់ដល់អង្គ-សវនាការនៅពេលដែលហេតុការណ៍កើតឡើងចំពោះគ្រួសាររបស់លោក ត្រូវបានសម្លាប់ហើយ លោករត់គេចទៅដល់ឃុំក្រាំងល្វាហ្នឹង តើលោកបានទៅធ្វើអីនៅទីនោះ?

[១៣:២២:៣០]

**ឆ៖** បាទ ជម្រាបប្រសាសន៍ដែរថា នៅពេលដែលយើងបែកគ្នាពីវត្តច្រកស្តេចទៅ គឺគាត់ដឹកនាំជាក្រុមៗទៅតាមឃុំ។ បាទ ទៅតាមឃុំ ឃុំណាត្រូវទទួលប៉ុន្មានរយគ្រួសារៗ អ៊ីចឹងគេបំបែកទៅតាមឃុំ ឱ្យឃុំហ្នឹងគ្រប់គ្រង ក្នុងសហករណ៍ហើយអាហ្នឹង ចូលក្នុងសហករណ៍ហើយ។ អ៊ីចឹងកាលនោះខ្ញុំក៏បានទៅរស់នៅភូមិអូរកាខុប ជាដំបូង។ ដល់ទៅភូមិអូរកាខុបជាដំបូង ក្រោយមកគេយកចេញពីភូមិ

អូរកាខុបមក មកនៅភូមិជំទាវជ្រែង។ ចេញពីភូមិជំទាវជ្រែងទៅ បានគេយកទៅឲ្យនៅក្នុងសហករណ៍មួយហៅថា សហករណ៍ឃុំក្រាំងល្វា -- អ៎! ភូមិតាំងគ្រួស ឃុំក្រាំងល្វា។

**ស៖** ចុះពេលដែលលោកទៅដល់សហករណ៍ឃុំក្រាំងល្វាហ្នឹង តើគេឲ្យលោកធ្វើអ្វីដែរ នៅពេលនោះ?

**ឆ៖** បាទ នៅពេលនោះខ្ញុំនៅតូច គេបញ្ជូនខ្ញុំទៅមណ្ឌលកុមារ។ គេបញ្ជូនទៅមណ្ឌលកុមារ គេឲ្យយើងធ្វើជី រើសអាចម៍គោ កាប់ទន្រ្ទានខែត្រធ្វើជីដើម្បីទុកឲ្យកងយុវជនយកទៅដាក់ស្រែ។

**ស៖** អ៊ីចឹងនៅក្នុងអំឡុងពេលដែលលោកធ្វើការនៅកងកុមារហ្នឹង លោកមានដែលប្រព្រឹត្តកំហុស ឬក៏ធ្វើឲ្យខុសឆ្គងដែលមានទោសកំហុសណាមួយទេ? ឬធ្លាប់ទទួលបានវិន័យណាមួយទេ?

**ឆ៖** បាទ មិនប៊ានប្រហែសទេ ព្រោះយើងដឹងហើយ យើងដឹងពីរបបហើយ អត់ប៊ានប្រហែសខ្លួនឲ្យមានទោសមានកំហុសទេ។ គឺគេប្រើធ្វើអី ធ្វើហ្នឹង។

**លោក អាកទ្វូរ វែកគែន៖**

លោកប្រធាន កាលពីអម្បាញ់មិញនេះ លោកប្រធានបញ្ជាក់ថា មេធាវីការពារក្តី ខៀវ សំផន ប្រហែលជាអាចមានពេលខ្លះ នៅពេលចុងក្រោយប្រសិនបើសល់ពេល។ ក៏ប៉ុន្តែខ្ញុំសន្និដ្ឋានឃើញ -- ខ្ញុំយល់ឃើញថា បើតាមវិធីសាស្រ្តរបស់សហព្រះរាជអាជ្ញានេះ ប្រហែលជាខ្ញុំមិនមានពេលទេមើលទៅ ព្រោះថា សំណួរសុទ្ធតែនៅក្រៅវិសាលភាពទាំងអស់។ ដូច្នេះនេះជាវិធីសាស្រ្តរបស់សហព្រះរាជអាជ្ញា ដើម្បីចំណេញពេលវេលាប្រើពេលឲ្យអស់តែម្តង ដើម្បីកុំឲ្យមេធាវីការពារក្តីមានពេលសួរនៅពេលចុងក្រោយ។ ប្រហែលជាអ៊ីចឹងហើយ ខ្ញុំសុំជំទាស់ទៅនឹងការសួរសំណួរបែបនេះ លោកប្រធាន។ ខ្ញុំសូមអរគុណ។

[១៣:២៥:២៩]

**កញ្ញា សុង ឆវ័ន្ត៖**

លោកប្រធាន ខ្ញុំសុំឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

បាទ លោកព្រះរាជអាជ្ញាសួរបន្ត។ ហើយសំណើរបស់លោកមេធាវី តុលាការនឹងពិចារណា។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន ហើយខ្ញុំគិតថាសហព្រះរាជអាជ្ញានឹងខិតខំប្រឹងប្រែងឲ្យអស់

លទ្ធភាពដើម្បីសួរសំណួរឲ្យពាក់ព័ន្ធ ហើយប្រសិនបើមេធាវីមិនព្យាយាមកាត់ទេ ប្រហែលជាយើងអាចនៅសល់ពេលខ្លះ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**សៈ** មុននេះ យើងនិយាយគ្នាដល់សហករណ៍ក្រាំងល្វា ហើយខ្ញុំសួរលោក ថាលោកមានធ្លាប់មានបញ្ហា ឬត្រូវវិន័យ ឬក៏ត្រូវគេបញ្ជូនទៅកន្លែងអប់រំកែប្រែណាមួយទេ? សូមឲ្យជួយបញ្ជាក់ម្តងទៀត។

**លោក សំ សិទ្ធី៖**

**ឆៈ** បាទ ជម្រាបជូនដែរថា ខ្ញុំក្រោយពេលមានសហករណ៍នៅហើយនោះ ខ្ញុំបានប្រាប់ប្អូនៗទាំងអស់ថា ឲ្យខិតខំប្រឹងប្រែងធ្វើការ កុំឲ្យខុសនឹងគោលការណ៍របស់អង្គការជំនាន់នោះ ព្រោះជំនាន់នោះបើថាខុសគោលការណ៍គឺយកទៅដាក់ពិន័យហើយ។ ហើយក៏អាចឈាននឹងយកទៅសម្លាប់ចោល បើខុសធ្ងន់ បើខុសស្រាលចូលទៅក្នុងគុក ដើម្បីធ្វើការដាក់ពិន័យ។

[១៣:២៦:៥៩]

**សៈ** ហេតុអ្វីបានជាលោកណែនាំបងប្អូនរបស់លោកឲ្យខិតខំធ្វើការ ហើយខ្លាចត្រូវពិន័យ? ធ្លាប់មានបទពិសោធន៍ ឬក៏ជួបព្រឹត្តិការណ៍ ហេតុការណ៍ណាកើតឡើងដែរ?

**ឆៈ** ខ្ញុំធ្លាប់ជួបប្រទះហើយនូវព្រឹត្តិការណ៍អស់នេះ។ ឃើញកុមារតូចៗ ខ្លះក៏គេវាយគេដំ ខ្លះទៅក៏គេយកទៅដាក់កន្លែងមន្ទីរកែប្រែទៅ។ ហើយសំខាន់បំផុតគឺបងប្អូនខ្ញុំទាំងប្អូននាក់នេះ គឺកំពុងតែជាប់ការអង្កេត បាទ កំពុងតែជាប់ការអង្កេត។ នៅពេលដែលខ្ញុំទៅសហករណ៍នោះ ខ្ញុំបានអប់រំហើយថាយើងជាប់ការអង្កេតរបស់គេហើយ កុំឲ្យមានទៅលួចដំឡូងលួចអីនាំគេដាក់ គេចាប់ទៅដាក់ពិន័យទៅ ចាប់ទៅដាក់គុកទៅ ខ្លាចលោវាបែកការណ៍រឿងយើងប្អូននាក់នេះ ដែលជាកូនទាហានគេយកទៅសម្លាប់ ហើយរត់រួចខ្លួនមកនេះ។ ខ្ញុំអប់រំបងប្អូនអ៊ីចឹង។ អ៊ីចឹងហើយខំប្រឹងធ្វើការទាំងបងទាំងប្អូន ទៅតាមគោលការណ៍របស់គេ។

**សៈ** ចាស លោកសាក្សីនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/5201, នៅត្រង់ ERN ជាភាសាខ្មែរគឺ 0021 2122 ដល់ 23 និង ERN ជាភាសាអង់គ្លេសគឺ 00275140 ដល់ 41, ERN ជាភាសាបារាំងគឺ 0027 5146 ដល់ 47។ លោកនិយាយដល់មន្ទីរឃុំឃាំង ឬក៏គុកមួយកន្លែងឈ្មោះគឺហៅថា “គុកក្រាំងល្វា”

ហើយអំមិញនេះ យើងកំពុងពិភាក្សាគ្នានៅសហករណ៍ក្រាំងល្វា។ អ៊ីចឹងខ្ញុំចង់ឲ្យលោករៀបរាប់អំពីព្រឹត្តិការណ៍ដែលលោកនិយាយដល់គុកក្រាំងល្វា ដែលលោកធ្លាប់ជួបបទពិសោធន៍ដោយផ្ទាល់នោះ។

[១៣:២៩:១០]

**ឆ៖** បាទ អរគុណ។ ខ្ញុំកាលណោះ គេឲ្យខ្ញុំមើលគោ។ គេឲ្យមើលគោ ហើយខ្ញុំហ្នឹងកើតជំងឺលឿងសាច់នោះ ហើយវាហត់ដើរអត់ទាន់ទេ ដើរអត់ទាន់គោទេ។ គោហ្នឹងវាដល់ទៅបួនប្រាំនោះ ហើយអ៊ីចឹងខ្ញុំចងកន្ទុយខ្សែវាហ្នឹងជាប់គ្នា ចងបន្តជាប់គ្នាទៅ កុំឲ្យវាដើរលឿនពេក។ អ៊ីចឹងខ្ញុំកាន់នៅនឹងដៃខ្លះ ខ្ញុំចងបន្តោងជាប់គ្នាខ្លះ ហើយម្ចាស់គោនេះ ដែលទៅពីស្រុកភូមិជាមួយខ្ញុំនេះ ទៅរាយការណ៍ប្រាប់ប្រធានល្អបថា ខ្ញុំនេះចងគោបង្អត់ស្មៅ ចងគោបន្តោងទៅលើដើមស្វាយចន្ទី អត់ឲ្យគោស៊ីស្មៅទេ។ តែពិតអត់អ៊ីចឹងទេ គ្រាន់តែចងបន្ត ព្រោះខ្ញុំដើរវាអត់ទាន់ វាហត់ កើតរោគលឿងហ្នឹង។ ដល់អ៊ីចឹងគេយកខ្ញុំទៅដាក់មន្ទីរឃុំឃាំង។

**ស៖** ចុះនៅពេលដែលលោកទៅដល់មន្ទីរឃុំឃាំងហ្នឹង តើមានហេតុការណ៍អ្វីបានកើតឡើងចំពោះលោកនៅក្នុងមន្ទីរឃុំឃាំងនោះ? លោកបានឃើញអ្វី ជួបប្រទះអ្វីខ្លះនៅពេលនោះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន១ ខ្ញុំគិតថាវាជារឿងគួរឲ្យចាប់អារម្មណ៍ ប្រសិនបើសាក្សីគាត់និយាយអំពីទីតាំងសម្លាប់មនុស្ស ប៉ុន្តែវានៅក្រៅវិសាលភាព។ ហើយយើងក៏គួរតែដឹងដែរអំពីវិសាលភាពដែលយើងត្រូវសួរសាក្សីនេះ។ ដូច្នេះសូមឯកឧត្តមប្រធាន បង្គាប់ទៅព្រះរាជអាជ្ញាឲ្យសួរសំណួរណាដែលស្ថិតនៅក្នុងវិសាលភាព កុំសួរសំណួរដែលនៅក្រៅវិសាលភាពបែបនេះ។

[១៣:៣០:៤៩]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

គឺខ្ញុំគិតថា ព្រះរាជអាជ្ញាប្រហែលជាចង់ពិនិត្យទៅលើភាពអាចជឿជាក់បាននៃសាក្សីហ្នឹង។ តើអ៊ីចឹងមែនទេ ព្រះរាជអាជ្ញា?

**កញ្ញា សុង ឆវ័ន្ត៖**

ចង់ -- លោកស្រីចៅក្រម ទី១ ខ្ញុំចង់ពិនិត្យមើលភាពជឿជាក់បាននូវអង្គហេតុដែលសាក្សីបានរៀបរាប់កន្លងមក និងទី២ មានព័ត៌មានដែលទាក់ទងទៅនឹងមន្ទីរសន្តិសុខនៅក្នុងឃុំក្រាំងល្វាហ្នឹង ហើយខ្ញុំចង់សួរបញ្ជាក់ថា តើមន្ទីរសន្តិសុខនោះ សាក្សីនៅក្នុងអំឡុងពេលនៃបទពិសោធន៍របស់គាត់នៅទីនោះ១

មានដែលបានឃើញការសម្លាប់ ឬក៏កន្លែងហ្នឹងអាចក្លាយទៅជាកន្លែងសម្លាប់មនុស្សដែរឬទេ តាមបទពិសោធន៍នោះ ដែលគាត់បានឆ្លងកាត់នៅកន្លែងនោះ។

**ប្រធានអង្គជំនុំ៖**

អ៊ីចេះៗ លោកមេធាវី ខ្ញុំចង់សួរទៅលោកសាក្សីបន្តិចពាក់ព័ន្ធនឹងបញ្ហាហ្នឹងដែរ។ ថាលោកកាលដែលលោកឃ្វាលគោ ហើយត្រូវបានគេយកទៅដាក់នៅក្នុង ឃុំឃាំងក្រាំងល្វាហ្នឹង គឺនៅក្នុងឆ្នាំប៉ុន្មាន? នៅក្នុងឆ្នាំណា?

**លោក សំ សិទ្ធី៖**

យើងជម្លៀសចេញទៅឆ្នាំ៧៥។ អ៊ីចឹងឯកឧត្តម។

[១៣:៣២:១២]

**ប្រធានអង្គជំនុំ៖**

ចង់បញ្ជាក់ថា ពេលដែលលោកឃ្វាលគោ ហើយត្រូវម្ចាស់គេថាលោកហ្នឹងយក -- ចងគោបង្អត់ស្មៅនោះ។ តើអង្គហេតុហ្នឹង វាកើតនៅក្នុងឆ្នាំណា?

**លោក សំ សិទ្ធី៖**

អង្គហេតុហ្នឹងនៅក្នុងៗឆ្នាំ៧៥ហ្នឹងហើយឯកឧត្តម។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមអញ្ជើញលោកមេធាវីបន្ត!

**ស្លរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាសសូមអរគុណលោកសាក្សី ខ្ញុំនឹងចាប់ផ្តើមសួរបន្តទៀត។ អំមិញនេះខ្ញុំសួរថាតើនៅពេលដែលលោក គេដាក់នៅក្នុងមន្ទីរឃុំឃាំងនោះ--

**លោក អាកទួរ វែកគែន៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា មន្ទីរសន្តិសុខហ្នឹង មិនមានទាំងថែងនៅក្នុងដីកាដំណោះស្រាយផង គឺវានៅក្រៅវិសាលភាពទាំងស្រុងតែម្តង។ ដូច្នេះខ្ញុំឃើញថា គាត់សួររាល់ ជាច្រើនម៉ោងមកហើយ គឺអត់មានពាក់ព័ន្ធទៅនឹងសំណុំរឿងទាល់តែសោះ។

[១៣:៣៣:១៤]

**ចៅក្រម អាកនីស្កា ក្លួណូវីកកា មីឡាត៖**

ក្រោយពីពិភាក្សាគ្នាបន្តិចនៅក្រុមប្រឹក្សាជំនុំជម្រះ គឺយើងចង់ឲ្យឆ្លើយសំណួរនេះ គឺយើងចង់ឲ្យសាក្សីគាត់ឆ្លើយទៅលើសំណួរនេះ។ ប្រសិនបើមានបញ្ហាទៅលើការបន្ថែមម៉ោង ឬអត់ចំពោះមេធាវីការពារក្តីនោះ យើងចង់បញ្ជាក់ថា យើងអាចនឹងចែករំលែកនូវពេលវេលារបស់ចៅក្រម ដើម្បីជូនទៅមេធាវីការពារក្តី។ ដូច្នេះហើយគឺថា យើងមិនយកពេលវេលារបស់ខាងព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទេ។ ដូច្នេះគឺយើងអាចអនុវត្តតាមវិធីសាស្ត្រនេះ ប្រសិនបើជាបញ្ហា។

**កញ្ញា សុង ឆវ័ន្ត៖**

ខ្ញុំគិតថា បើសិនអង្គជំនុំជម្រះមានសន្តានចិត្តដល់មេធាវីដូច្នេះ ប្រហែលជាមិនមានការផ្តាច់ញើកញាប់ដូច្នេះទៀតទេ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមទោសលោកសាក្សី ខ្ញុំត្រឡប់មកនិយាយជាមួយលោកពីប្រធានបទ គឺមន្ទីរសន្តិសុខដែលលោកបានឆ្លងកាត់ គឺក្រាំងល្វានេះដដែល។ សូមឲ្យលោករៀបរាប់អំពីស្ថានភាពនៅពេលដែលគេយកលោកទៅដល់ក្នុងគុកក្រាំងល្វាហ្នឹង តើមានរឿងអ្វីកើតឡើងចំពោះលោក? ហើយលោកបានឃើញអ្វីខ្លះនៅពេលនោះ?

[១៣:៣៤:៣៨]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ នៅពេលដែលគេយកខ្ញុំទៅដល់មន្ទីរឃុំឃាំងឃុំក្រាំងល្វាហ្នឹង ខ្ញុំពិនិត្យឃើញថាមានអ្នកទោសប្រមាណជាង១២នាក់។ ប្រហែល១២នាក់ ដែលត្រូវគេដាក់ខ្នោះជើងជាប់នៅនឹងផ្ទះមួយដែលហៅថា "ផ្ទះមន្ទីរឃុំឃាំង" នោះ។ អ៊ីចឹងដល់តែខ្ញុំទៅក្រោយហ្នឹង គេត្រូវកាសយកមនុស្សចាស់ហ្នឹងយកទៅដាក់ឲ្យជាប់ៗគ្នាទៅ គេដាក់ខ្ញុំនៅចុង។ បាទ ដាក់នៅចុង ព្រោះរង្វង់ខ្នោះហ្នឹង គេធ្វើអំពីឈើហើយគេដោតដែកកណ្តាល ដើម្បីខ្ទាស់កុំឲ្យយើងដកជើងរួច។ អ៊ីចឹងហើយគេយកខ្ញុំទៅដាក់អាប្រលោះដែលគេលាក់ទៅវាតូចជាងគេហ្នឹង គេយកខ្ញុំទៅដាក់ប្រលោះហ្នឹង គេកាសមនុស្សចាស់ហ្នឹងឲ្យទៅប្តូររង្វង់ធំ។ អ៊ីចឹងខ្ញុំក៏នៅជាមួយគាត់ហ្នឹងរហូតដល់ -- ជាមួយពួកគាត់ហ្នឹង ខ្ញុំឃើញ ពិនិត្យឃើញថាការងារ ដល់ម៉ោងគឺគេដោះចេញ ដោះខ្នោះចេញ គេឲ្យទៅធ្វើពលកម្ម លើករងដំឡូង។ បាទទាំងមនុស្សចាស់ ទាំងខ្ញុំកុមារហ្នឹង ទាំងអស់គ្នា។

**ស៖** ចុះលោកឃើញមនុស្សនៅក្នុងគុកហ្នឹង ប្រហែលជាប៉ុន្មាននាក់ដែរ? ហើយស្ថានភាពមនុស្សហ្នឹង ប្រភេទណាដែរ? មានប្រុស មានស្រី មានចាស់ មានក្មេងយ៉ាងម៉េចដែរ?

**ឆ៖** បាទ ពេលនុ៎ង គឺខ្ញុំក្មេងជាងគេហើយ។ ហើយមនុស្សចាស់ ក៏អត់មានស្រីដែរ សុទ្ធតែមនុស្សប្រុស។ ប្រមាណស្មើនឹង១០ ទៅ១២នាក់។

[១៣:៣៦:៣៤]

**ស៖** ចាស អរគុណ។ ហើយលោកបានជាប់នៅក្នុងគុកនោះរយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំជាប់នៅកន្លែងឃុំឃាំងហ្នឹង ប្រហែលជា២ខែ។ នៅពេលដែលប្រធានសហករណ៍ ហើយគេហៅថាមេកង គាត់ដើរទៅឃើញ គាត់ទៅពិនិត្យអ្នកទោសនៅទីនុ៎ង ហើយគាត់សួរថា "ចុះកុមារាហ្នឹងមានទោសពីអី?" គាត់សួរថា "មានទោសពីអី?" ប្រធានឈ្លបហ្នឹង គេឆ្លើយប្រាប់ថា ខ្ញុំនេះមានទោសពីចងគោបង្អត់ស្មៅ។ ដល់អ៊ីចឹងប្រធានសហករណ៍នុ៎ង គាត់បានបញ្ជាឱ្យមេឈ្លបហ្នឹង ដោះខ្ញុំចេញមក។ បាទ ដោះខ្ញុំចេញមក គាត់យកទៅជាមួយទៅ។ យកខ្ញុំទៅជាមួយ យកខ្ញុំទៅឱ្យមើលគោរបស់គាត់ បាទ។ ហើយគ្រាន់តែស្នាក់នៅៗនឹងផ្ទះជាមួយមេសហករណ៍ហ្នឹងទៅ មេឃុំហ្នឹងទៅ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស អរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរ សូមផ្ទេរវេទិកាឱ្យទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោក លោកស្រីចៅក្រម។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណលោកសាក្សី។ លោកសាក្សី នៅក្នុងឆ្នាំ៧៥ តើលោកធ្លាប់ឮអំពីមន្ទីរខ្មែរក្រហមមួយហៅថា ប-៥ ដែរឬទេ?

[១៣:៣៨:២៣]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ខ្ញុំនៅតូច ខ្ញុំដើរមើលគោ វាមានមន្ទីរមួយ គេហៅ -- នៅលើខ្នងទួល ចេញពីភូមិទៅ

ចេញពីភូមិក្រាំល្វាហ្នឹងទៅ ប្រមាណជាមួយគីឡូកន្លះដី នេះបើតាមការស្មាន។ ហើយវាឡើងនឹងខ្នងទួលហ្នឹង ខ្ញុំពួកមូលដ្ឋានចាស់ទេ គេនិយាយ គេថានេះមន្ទីរតាពត បាទ មន្ទីរតាពត។ អ៊ីចឹងវានៅក្នុងព្រៃធំមួយ ខ្នងទួលហ្នឹង។ ហើយគេថា ហ្នឹងហើយមន្ទីរតាពត ។ ប៉ុន្តែមន្ទីរហ្នឹងរបៀបជាមន្ទីរយោធា។

**ស៖** តើលោកដឹងទេថា មន្ទីរនោះនៅក្នុងឃុំអី?

**ឆ៖** នៅក្នុងឃុំក្រាំងល្វា។

**ស៖** សូមអភ័យទោសដែលខ្ញុំមិនយល់ ខ្ញុំមិនដឹងអំពីទីតាំងភូមិសាស្ត្រនៅៗកម្ពុជា ប៉ុន្តែចង់ដឹងថាតើឃុំហ្នឹងឆ្ងាយពីៗឃុំញាន ប៉ុន្មានគីឡូម៉ែត្រដែរ?

**ឆ៖** ដូចអត់មានឈ្មោះឃុំញានហ្នឹង។

**ស៖** សូមអភ័យទោសដែលខ្ញុំអានឈ្មោះមិនច្បាស់។ តើលោកស្គាល់ឃុំចាន់តីក្នុងស្រុកកំពង់ត្រឡាចដែរឬទេ? ខ្ញុំគិតថាគួរឲ្យសហការីខ្មែររបស់ខ្ញុំ គាត់អានឈ្មោះឲ្យបានត្រឹមត្រូវវិញ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាន់តី។

**លោក សំ សិទ្ធី៖**

**ឆ៖** និយាយជារួម កាលសម័យនោះ អ្នកណានៅត្រង់ណានៅត្រង់ហ្នឹងហើយ មិនអាចដើរឆ្លងពីភូមិមួយទៅភូមិមួយបានទេ ហើយឈ្មោះឃុំចាន់តីហ្នឹងក៏ដូចអត់ដែលឮដែរ។

[១៣:៤១:០៥]

**លោក នីកូឡាស គូមជែន៖**

សូមទោសផងដែរដែលខ្ញុំសួរលោកអំពីភូមិឃុំបែបនេះ។ ឥឡូវនេះ ខ្ញុំសូមឲ្យសហការីខ្មែរខ្ញុំគាត់សួរលោកអំពីឈ្មោះតំបន់សិន ហើយខ្ញុំនឹងសួរបន្តពីគាត់។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់ ដោយសារសហព្រះរាជអាជ្ញាហាក់ដូចជាកំពុងប្រើប្រាស់នូវឯកសារណាមួយទាក់ទងនឹងផែនទីនេះ។ ដូច្នេះសូមឲ្យសហព្រះរាជអាជ្ញាបង្ហាញពីឯកសារយោងពាក់ព័ន្ធទៅនឹងចំណុចដែលលោកត្រូវលើកនេះផងបាទ។ សូមអរគុណ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំរីករាយនឹងផ្តល់ជូន ប្រសិនបើលោកចង់បាន។ ហេតុផលដែលខ្ញុំសួរ គឺខ្ញុំអានសក្ខីកម្មរបស់

នួន ជា ឯកសារ E1/14.1 អង់គ្លេសមានលេខ 00756159, ខ្មែរមានលេខ 00755354, ហើយបារាំងមានលេខ 00756300។

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកឧត្តមប្រធាន នេះមិនត្រឹមតែជាឯកសារដែលអង្គជំនុំជម្រះហាមឃាត់នោះទេ ប៉ុន្តែវាជាការសួរអំពីមន្ទីរសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជាគឺ មន្ទីរប-៥។ ដូច្នេះ ខ្ញុំគិតថាយើងមិនអាចសូម្បីតែស្រមៃក៏ដែលគិតថាសាក្សីដែលមានអាយុ១៤ឆ្នាំនៅពេលនេះ គាត់អាចដឹងពីបញ្ហានេះទេ។

[១៣:៤៣:០៥]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមៗឆ្លើយតប គឺខ្ញុំនឹងលើកយកឯកសារដែលមេធាវីការពារក្តីនិយាយអំពីនេះ ព្រោះថា នួន ជា គាត់បានផ្តល់អំពីទីតាំងហ្នឹង ហើយនេះគឺជាមន្ទីរសម្ងាត់ ហើយនេះគឺជាមន្ទីរនៅក្នុងតំបន់ នៅក្នុងឆ្នាំ៧៥។ ហើយមន្ទីរនេះ គឺនិយាយអំពីការសម្លាប់រង្គាលនៅតំបន់ដែលសាក្សីបាននិយាយ។ ហើយខ្ញុំគិតថាចំណុចទាំងអស់នេះមាននៅក្នុងសំណុំរឿង០០២/០២។ ដូច្នេះ ខ្ញុំគ្រាន់តែចង់ដឹង ថាតើទីតាំងហ្នឹងវាមានអ្វីពាក់ព័ន្ធជាមួយនឹងគាត់ ក៏ដូចជាវត្តច្រកស្តេចដែរ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា ឯកសារ E1/14.1 នេះត្រូវបានតុលាការកំពូលសម្រេចថា មិនឲ្យសហព្រះរាជអាជ្ញាប្រើប្រាស់ទេ ទៅតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ ហើយមន្ទីរប-៥ នេះតាមការស្តាប់របស់ខាងសាក្សីបានលើកឡើងនោះគឺ មន្ទីរហ្នឹងវាមានជាប់ពាក់ព័ន្ធនឹងវិសាលភាពហ្នឹងដែរឬទេ ដែលលោកចង់សួរទៅសាក្សីហ្នឹង? ហើយតាមខ្ញុំមើលទៅ ដូចជានៅក្នុងមន្ទីរប-៥ ហ្នឹងដូចជាវាអត់មានជាប់ពាក់ព័ន្ធទេ ឬយ៉ាងណាដែរលោកៗមេធាវីអាចបញ្ជាក់បន្តិចបានទេ? -- លោកព្រះរាជអាជ្ញា?

**លោក នីកូឡាស គូមជែន៖**

សូមអរគុណឯកឧត្តមប្រធាន។ ការពិតទៅ ខ្ញុំមិនមានគម្រោងលើកយកឯកសារនេះមកដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ ឬសាក្សីនោះឡើយ ព្រោះវាជាសក្ខីកម្មសំណុំរឿង០០២/០២។ ប៉ុន្តែសាក្សីបាននិយាយអំពីអ្វីដែលកើតឡើងនៅវត្តច្រកស្តេច ហើយសក្ខីកម្មរបស់គាត់នៅក្នុងសវនាការកន្លែងដដែលនេះ នួន ជា និយាយអំពី ប៉ុល ពត ដែលជាលេខាបក្សបានផ្លាស់ទីលំនៅនៅមុនពេលដែលមានការវាយប្រហារនៅទីក្រុងភ្នំពេញ គឺទៅច្រកស្តេច ក្នុងស្រុកកំពង់ត្រឡាចគឺ ប៉ុល ពត ផ្លាស់ទីទៅ

ឃុំពាម។ ដូច្នេះខ្ញុំគិតថា នេះជាចំណុចតូចមួយដែលខ្ញុំចង់លើកឡើង។ ហើយខ្ញុំគិតថា ការកោះហៅសាក្សីនេះមកបង្ហាញ គឺបង្ហាញ -- គឺជាការសំខាន់ គឺការបង្ហាញអំពីគោលនយោបាយរបស់មេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ គឺថាហេតុការណ៍នេះវាកើតឡើងជាមួយនឹងមេដឹកនាំ។ ហេតុដូច្នេះខ្ញុំគិតថាវាជាការសំខាន់មួយ។

[១៣:៤៦:១៣]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកព្រះរាជអាជ្ញា តើលោកអាចអានលេខឯកសារម្ដងទៀតបានទេ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមអាន គឺឯកសារ E1/14.1 ហើយអង់គ្លេសមានលេខ 00756159 ហើយខ្មែរគឺមានលេខ 00755354។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំកំពុងតែពិនិត្យមើលថា តើមាននៅលើបញ្ជី ឬអត់?

**លោក នីកូឡាស គូមជែន៖**

ឯកសារនេះគឺទើបបានដកចេញពីបញ្ជី។ ហេតុដូច្នេះហើយទើបខ្ញុំសួរតែអំពីទីតាំងតែប៉ុណ្ណោះ គឺថាវាត្រូវបានដកចេញពីសេចក្ដីសម្រេចដកឯកសាររបស់អង្គជំនុំជម្រះតុលាការកំពូលរួចទៅហើយ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

តើភាពពាក់ព័ន្ធនៃការសួរសំណួរទាំងអស់នេះ តើវាសំខាន់ចំពោះសំណុំរឿងដទៃទៀតទេ?

**លោក នីកូឡាស គូមជែន៖**

ភាពពាក់ព័ន្ធ គឺពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១ ប៉ុណ្ណោះ។ ភាពពាក់ព័ន្ធគឺថាទីតាំងនេះគឺ នួន ជា និយាយថាមេដឹកនាំ គឺថាតើទីតាំងរបស់មេដឹកនាំហ្នឹង វាមានអាចពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងជាមួយសាក្សីដែរឬក៏អត់? ឧទាហរណ៍ដូចជាការផ្ដល់ប្រវត្តិរូបរបស់យោធា លន់ នល់ បន្ទាប់មកត្រូវបានគេយកទៅសម្លាប់ ឬក៏--

[១៣:៤៧:៤៥]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

តើលោកនិយាយអំពីចម្លើយរបស់ នួន ជា នៅក្នុងសំណុំរឿង០០២/២ មែនទេ?

**លោក នីកូឡាស គូមជែន៖**

នេះគឺមិនមែន ០២/២ ទេ គឺ០២/១។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

អ៊ីចឹងមានន័យថា លោកនិយាយខុស។

**លោក នីកូឡាស គូមជែន៖**

សូមទោស ខ្ញុំនិយាយខុស។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

អ៊ីចឹងលោកព្រះរាជអាជ្ញាគិតថា លោកបានប្រើប្រាស់ពេលវេលាលោកឲ្យល្អ ឲ្យអស់ពីលទ្ធភាព ហើយមែនទេ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំនឹងព្យាយាមប្រើប្រាស់ពេលវេលារបស់ខ្ញុំ ហើយខ្ញុំគ្រាន់តែចង់ឲ្យសាក្សីបញ្ជាក់អំពីទីតាំងនេះ ហើយបង្ហាញថា តើវាមានអ្វីពាក់ព័ន្ធជាមួយនឹងវត្តដែលគេចុះបញ្ជី គឺបានន័យថា ជាទីតាំងវត្តដែលគេបោកបញ្ឆោតមនុស្សឲ្យទៅកត់ត្រា ធ្វើប្រវត្តិរូបនោះ។

[១៣:៤៨:៣៥]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

អ៊ីចឹងយើងអនុញ្ញាត ប្រសិនបើលោកមានហេតុផលជឿជាក់ថា សាក្សីអាចដឹងអំពីចំណុចនេះ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី អ៊ីចឹងខ្ញុំគ្រាន់តែចង់សួរលោកទាក់ទងទៅនឹងទីតាំង គឺទីតាំងរបស់វត្តដែលលោកនិយាយថា គេឲ្យទៅចុះឈ្មោះនៅវត្តនោះ។ ហើយសហការីខ្ញុំគាត់នឹងអានឈ្មោះនៅទីតាំងទាំងអស់នេះ បន្ទាប់មកសូមលោកប្រាប់យើងខ្ញុំថា លោកស្គាល់ឈ្មោះទីតាំងទាំងអស់នេះដែរឬក៏អត់?

**កញ្ញា សុង ឆវ័ន្ត៖**

លោកសាក្សី ទីតាំងដែលសហការីអន្តរជាតិបានអានឲ្យលោកអម្បាញ់មិញហ្នឹង គឺនៅក្នុងភូមិបឹងតាឡុង ខាងត្បូងភូមិច្រកស្ដេច គឺស្ថិតនៅក្នុងឃុំពាម ស្រុកកំពង់ត្រឡាច។

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ពីដើមវាមានកំពង់ត្រឡាចហ្នឹងវាពីរ។ កំពង់ត្រឡាចលើ កំពង់ត្រឡាចក្រោម ហើយ

ដល់មកបច្ចុប្បន្ននេះ តំបន់នេះគឺស្រុកសាមគ្គីមានជ័យ។ បាទ បើរាប់ពីស្រុកសាមគ្គីមានជ័យ ខ្ញុំស្គាល់តែដល់រាប់កំពង់ត្រឡាចលើ កំពង់ត្រឡាចក្រោមហ្នឹង ខ្ញុំគ្រាន់តែដឹងថា ខាងកើតផ្លូវជាតិ កំពង់ត្រឡាចក្រោម ហើយខាងលិចផ្លូវជាតិ កំពង់ត្រឡាចលើ។ ប៉ុណ្ណឹងទេ។

[១៣:៥០:០៩]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី បើសិនជាខ្ញុំយល់មិនខុសទេ គឺលោកនិយាយថា ការចុះឈ្មោះ ហើយនិងការបំបែកប្រជាជន គឺយោងទៅតាមតួនាទីរបស់ពួកគេ ហើយគេធ្វើឡើងនៅភូមិវត្តច្រកស្តេចក្នុងឃុំពាម។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។ ហើយជាគេប្រមូលប្រជាពលរដ្ឋ និងមន្ត្រីរាជការហ្នឹង គឺនៅក្នុងឃុំច្រកស្តេចហ្នឹងតែម្តង -- អ៎! ឃុំពាម វត្តច្រកស្តេច ភូមិច្រកស្តេច។ វត្តហ្នឹង វានៅក្នុងភូមិច្រកស្តេចហ្នឹងតែម្តង ហើយបើឃុំ វាជាឃុំពាម។

**ស៖** ដូច្នេះខ្ញុំចង់សួរថា ការចុះឈ្មោះហ្នឹង គេធ្វើនៅកន្លែងណាដែរ? តើការចុះឈ្មោះហ្នឹងនៅក្នុងភូមិវត្តច្រកស្តេច គឺទីតាំងដែលសហការីខ្ញុំទើបតែអានហ្នឹង ឬមួយក៏នៅខុសគ្នា? តើវាមួយណាដែលត្រឹមត្រូវ?

**ឆ៖** ដែលកាលដែលខ្ញុំទៅចុះឈ្មោះហ្នឹង គឺនៅក្នុងវត្តច្រកស្តេចហ្នឹងតែម្តង។ អាហ្នឹងគេមកបច្ចុប្បន្ននេះ ភូមិច្រកស្តេច ឃុំពាម។ ឈ្មោះបច្ចុប្បន្ននេះ ក្នុងស្រុកសាមគ្គីមានជ័យ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំដឹងថា លោកអស់កម្លាំងច្រើន ប៉ុន្តែខ្ញុំចង់និយាយពិភាក្សាជាមួយលោកបន្តិច អំពីហេតុការណ៍នៅថ្ងៃ១៧ មេសា ៧៥ ហើយខ្ញុំចង់ឲ្យលោកប្រាប់ខ្ញុំថា តើមានអ្វីកើតឡើង ដែលធ្វើឲ្យគ្រួសារលោកចាកចេញពីផ្ទះ នៅថ្ងៃនោះ?

[១៣:៥២:២៤]

**ឆ៖** ខ្ញុំជម្រាបជូនផងដែរថា ឆ្នាំ៧៥នេះគឺរបប លន់ នល់ ត្រូវដួលរលំ ដោយរបប ប៉ុល ពត វាយដណ្តើមបាន។ ហើយពេលនោះរបប ប៉ុល ពត ចូលកាន់អំណាច គឺត្រូវជម្លៀសប្រជាពលរដ្ឋចេញពីផ្ទះ ចេញពីផ្ទះសម្បែងរបស់ខ្លួន ដោយបំភ័យថា បើមិនចេញទេ យន្តហោះអាមេរិកាំងមកទម្លាក់គ្រាប់បែកកម្ទេចនៅទីនេះឥឡូវហើយ។ អ៊ីចឹងទាំងអស់គ្នាភ័យខ្លាច ត្រូវរត់ចេញទៅតាមផែនការរបស់គាត់ ទៅតំបន់ព្រៃភ្នំ។

**សៈ** អរគុណ។ តើនៅថ្ងៃ១៧ មេសាហ្នឹង តើអ្នកណាខ្លះរស់នៅក្នុងផ្ទះជាមួយលោក? គឺខ្ញុំចង់សួរថា អ្នកណាខ្លះដែលរស់នៅជាមួយលោកនៅថ្ងៃនោះ?

**ឆៈ** បាទ ថ្ងៃនោះគឺមានក្រុមគ្រួសារខ្ញុំ មានឪពុកម្តាយខ្ញុំ ប្អូនស្រីពីរនាក់ និងប្អូនប្រុសខ្ញុំពីរនាក់ ស្មើនឹងខ្ញុំមួយ ប្រាំនាក់ ដែលធ្វើដំណើរចេញពីផ្ទះទៅ ដែលរស់នៅក្នុងដំបូលផ្ទះតែមួយ។

**សៈ** សូមអរគុណ។ អ៊ីចឹងមនុស្សដែលលោកនិយាយ ដែលលោកថា ជាជីដូនមួយរបស់លោកនោះ តើលោកអាចរៀបរាប់អំពីទំនាក់ទំនងរវាងលោកជាមួយនឹងពួកគាត់ហ្នឹង តើលោកមានទំនាក់ទំនងជិតស្និទ្ធ ឬក៏យ៉ាងម៉េចដែរ ជាមួយគ្នា? លោកអាចរៀបរាប់បានទេ?

**ឆៈ** បាទ ឪពុកខ្ញុំត្រូវជាបងបង្អស់របស់ប្អូន -- អ៊ំ! អាដែងម្តាយឪពុកជីដូនមួយរបស់ខ្ញុំហ្នឹង។ ហើយនៅពេលដែលជម្លៀសចេញទៅ ទៅជួបគ្នាតាមផ្លូវ ហើយក៏នាំគ្នាជាក្រុមហ្នឹងទៅជាមួយគ្នាទៅស្រុកលើតែម្តង។

[១៣:៥៤:៤១]

**សៈ** តើជីដូនមួយរបស់លោកហ្នឹង រស់នៅក្នុងភូមិជាមួយលោកដែរអត់ទេ?

**ឆៈ** បើនៅឯស្រុកកំណើត រស់នៅជាមួយគ្នា។ ហើយដល់តែពេលក្រោយការសម្លាប់មក ក៏រស់នៅជាមួយគ្នា។

**ប្រធានអង្គជំនុំៈ**

លោកមេធាវី -- លោកសាក្សី អំមិញហ្នឹងគឺខ្ញុំស្តាប់មិនច្រឡំទេ ព្រះរាជអាជ្ញាចង់សួរថា អាពេលជម្លៀសនោះ តើបងប្អូនជីដូនមួយឪពុកលោកហ្នឹងនៅក្នុងភូមិជាមួយគ្នា ឬក៏អត់? ដល់លោកឆ្លើយ ឆ្លើយទៅឯណាណោះវិញ។

**លោក សំ សិទ្ធីៈ**

**ឆៈ** គោរពឯកឧត្តមប្រធាន។ សំណួររបស់លោកព្រះរាជអាជ្ញាលោកបានសួរអ៊ីចឹងហើយ ក៏ប៉ុន្តែខ្ញុំស្មានតែគាត់សួរថា ពេលស្លាប់ហ្នឹង ហើយពេលដែលនេះហ្នឹងនៅជាមួយគ្នា។ ប៉ុន្តែអ៊ីចេះ គ្រាន់តែខ្ញុំជម្រាបថា វានៅជិតគ្នាដែរ។ គ្រាន់ថាពីផ្ទះរបស់ឪពុកមាខ្ញុំហ្នឹង ហើយនិងផ្ទះខ្ញុំហ្នឹង វាចម្ងាយពីគ្នាប្រហែលជា៣គីឡូទេ ភូមិនៅជាប់គ្នា។

**សួរដោយលោក នីកូឡាស គូមជែនៈ**

**សៈ** លោកសាក្សី លោកបាននិយាយថា ប្រជាជនខ្លាចការទម្លាក់គ្រាប់បែក គឺការទម្លាក់គ្រាប់

បែករបស់អាមេរិក។ ហេតុអ្វីបានជាលោក ក៏ដូចជាប្រជាជនខ្លាច? តើគេមានធ្លាប់ប្រាប់លោកអំពីគ្រោះថ្នាក់នៃការទម្លាក់គ្រាប់បែកហ្នឹងដែរឬទេ?

[១៣:៥៦:២៩]

**ឆ៖** បាទ សម័យនុ៎ង គឺកំពុងតែពេញសង្គ្រាមហើយ រវាងកងទ័ព លន់ នល់ និងកងទ័ពខ្មែរក្រហមនេះ កំពុងតែពេញសង្គ្រាមនឹងគ្នាហើយ។ ការបាញ់ប្លោង ការទម្លាក់គ្រាប់បែក គឺមើលឃើញស្ទើរតែរៀងរាល់ថ្ងៃ។ អ៊ីចឹងនៅពេលដែលគេគំរាមថា យន្តហោះអាមេរិកមកទម្លាក់គ្រាប់បែកហ្នឹង វារឹតតែភ័យហើយ វាមិនត្រូវនាំគ្នាចេញ បាទ។

**ស៖** អរគុណ។ នៅពេលដែលលោកនិយាយថា “ភ័យ” តើមានអ្នកណាគេប្រាប់លោកថាហេតុអ្វីបាននេះទេ ឬមួយក៏លោកស្តាប់ឮតាមវិទ្យុ ឬក៏គេប្រាប់លោក ឬមួយក៏លោកខ្លួនឯងជឿដោយខ្លួនឯងថាដូច្នេះ?

**ឆ៖** បាទខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ពីព្រឹកៗ គឺមានកងទ័ពខ្មែរក្រហមហ្នឹងដែលប្រើប្រាស់ឯកសណ្ឋានខ្មៅលើ ខ្មៅក្រោមហ្នឹង ស្ពាយដោយអាវុធហ្នឹង គេធ្វើព្យុហយាត្រាចូលទៅក្នុងខេត្ត ហើយមិនដឹងទៅច្រកណា មកច្រកណាទេ គ្រាន់តែឆ្លងកាត់បាត់ទៅ។ ហើយដល់ពេលល្ងាចឡើង ព្រលប់ៗមានកងទ័ពដើរមកប្រាប់តាមផ្ទះតែម្តង មានកងទ័ពប្រដាប់ដោយអាវុធដើរមកប្រាប់តាមផ្ទះ កៀងឲ្យចេញ។ បាទ ដូចភាពយន្តឯកសារដែលយើងចាក់ពី នៅក្នុងភាពយន្តអ៊ីចឹង។ ដើរមកគំរាមឲ្យចេញៗជាបន្ទាន់។

[១៣:៥៨:១៩]

**ស៖** នៅពេលដែលលោកនិយាយថា គំរាមកំហែង តើលោកដឹងទេថា មានអ្នកជិតខាង ឬក៏មានអ្នកណាផ្សេងនិយាយថា ខ្ញុំអត់ចង់នៅផ្ទះ ឬក៏អត់ចង់នៅកន្លែងហ្នឹងអីដែរឬទេ?

**ឆ៖** នៅពេលនុ៎ងចាប់បង្ខំឲ្យចេញទាំងអស់តែគ្នា ទៅទាំងខ្ញុំ ទៅទាំងគ្រួសារគេ ទៅទាំងអស់អត់មានអ្នកណាប៉ានទទឹងរឹងរូស ថាមិនចេញ ហីក៏មិនទៅទេ។

**ស៖** ខ្ញុំដឹងថា វាកើតឡើងតាំងពី ៤០ឆ្នាំជាងហើយ ប៉ុន្តែលោកចាំទេថា តើទាហាននោះ គេមាននិយាយស្អី? គេមានប្រាប់ក្រុមគ្រួសារលោកអ្វីខ្លះនៅពេលដែលគេមកដល់ផ្ទះលោកនោះ?

**ឆ៖** គេប្រាប់អ៊ីចឹងហើយ គេប្រាប់ថា ឲ្យយើងជម្លៀសចេញពីផ្ទះ។ បន្តិចទៀតនេះ ដែលយន្តហោះអាមេរិកាំងមកទម្លាក់គ្រាប់បែកហើយ។

**សៈ** តើក្រុមគ្រួសារលោកមានសុំគេថា -- អ៎! ខ្ញុំរៀបចំអីវ៉ាន់ ខ្ញុំរៀបចំម្ហូបអាហារអីសិន តើក្រុមគ្រួសារលោកមានសុំគេបែបហ្នឹងទេ?

**ឆៈ** បាទ យើងគ្រាន់តែថា ខ្មែរក្រហមឈ្នះហើយ យើងត្រៀមអង្ករឈើព្រៃ ឆ្នាំងបាយ ឆ្នាំងសម្លអីហើយអស់ហើយ។ នៅពេលដែលគេមកគំរាមឲ្យចេញ គឺប្រមូលយកអាសម្ភារៈហ្នឹងដាក់លើកង់រូសចេញទៅតែម្ដង។ អត់មានសុំអង្វរកថា អ្ហឺ! ចាំខ្ញុំយកនេះ យកនោះអីទេ។

[១៤:០០:១៨]

**សៈ** អ៊ីចឹង បានន័យថាគ្រួសារលោកចាកចេញទៅហ្នឹងមានម្ហូបអាហារស្បៀងអីតាមខ្លួនខ្លះដែរ អ៊ីចឹងមែនទេ?

**ឆៈ** បាទ មាន។ សូម្បីតែបច្ចុប្បន្នហ្នឹងក៏អ៊ីចឹងដែរ តែផ្អើលម្ដងៗហ្នឹងរកត្រីងៀតត្រីឆ្អើរ អង្ករឈើព្រៃទុកស្រេចហើយ។ ហើយជំនាន់នុ៎ងក៏អ៊ីចឹងដែរ ដូចតែគ្នា សុទ្ធតែត្រៀមរៀងៗខ្លួនហ្នឹងឯង។

**សៈ** អ៊ីចឹង គឺនៅថ្ងៃ១៧ មេសា ៧៥ ហ្នឹងតើនៅថ្ងៃហ្នឹង ឪពុករបស់លោកហ្នឹងនៅជាទាហាននៅឡើយ តើមែនទេ? គឺនៅថ្ងៃដែលដួលរំលំភ្នំពេញហ្នឹង តើឪពុកលោកនៅជាទាហាននៅឡើយ អ៊ីចឹងមែនទេ?

**ឆៈ** ក្រោយពេលកម្លាំងខ្មែរក្រហមចូល គឺគេបញ្ជាឲ្យទាហានទម្លាក់អាវុធ ១ចុះ ហើយបើនៅរឹងរូសមិនទម្លាក់អាវុធ គេនឹងកម្ទេច។ អ៊ីចឹងតាមការអំពាវនាវ កាលហ្នឹងដូចជាមានសម្ដេច នរោត្តម ផង បញ្ជាឲ្យកូនចៅទម្លាក់អាវុធចុះនោះ។ អ៊ីចឹងហើយ ត្រូវទម្លាក់អាវុធចុះ ដោះខោអាវចោល ហើយរត់រកប្រពន្ធកូនតាមផ្ទះ។

**សៈ** នៅពេលដែលលោកចាកចេញពីផ្ទះរបស់លោក តើក្រុមគ្រួសារលោកដឹងទេថា ពេលណាដែលលោកត្រឡប់មកវិញនេះ? តើមាននរណាម្នាក់ប្រាប់លោក ឬក៏ក្រុមគ្រួសារលោកថាត្រូវត្រឡប់មកផ្ទះវិញនៅពេលណាទេ?

[១៤:០២:១៧]

**លោក វ៉ិចទ័រ កូប៉េះ**

ឯកឧត្តមប្រធាន ខ្ញុំគិតថាប្រហែលជាព្រះរាជអាជ្ញាគាត់កំពុងតែសួរ ប៉ុន្តែខាងមេធាវីការពារក្ដីយើងមិនដែលជំទាស់ទៅលើការជម្លៀសប្រជាជននេះទេ។ ឥឡូវយើងចំណាយពេលមួយម៉ោងប្រាំនាទីទៅហើយ ហើយគេសួរសំណួរដដែលៗទៅលើចំណុចទាំងអស់នេះ។ ខ្ញុំដឹងថាវាអាស្រ័យទៅលើ

ព្រះរាជអាជ្ញាក្នុងការប្រើប្រាស់ពេលវេលារបស់គេ ដែលគេយល់ថាសមស្រប។ ប៉ុន្តែៗព្រះរាជអាជ្ញាអ្វីដែលព្រះរាជអាជ្ញាកំពុងតែធ្វើ គឺបានន័យថា ព្រះរាជអាជ្ញាកំពុងតែលួចយកម៉ោងដែលគេប្រុងនឹងផ្តល់ឲ្យមេធាវីការពារក្តី គឺគាត់យកទៅប្រើដោយខ្លួនឯង។

**លោក នីកូឡាស គូមជែន៖**

តាមដែលខ្ញុំយល់ គឺយើងអាចសួរអ្វីក៏បានដែរឲ្យតែស្ថិតនៅក្នុងវិសាលភាពសំណុំរឿង០០២/០១។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញាសូមអញ្ជើញបន្ត!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ ឯកឧត្តមប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី ខ្ញុំសុំសួរសំណួរនេះឡើងវិញ។ តើលោកមានសញ្ញាណបញ្ជាក់ ឬក៏ការបញ្ជាក់ណាមួយថា ឪពុកម្តាយរបស់លោកអាចនឹងវិលត្រឡប់មកផ្ទះសម្បែងវិញទេ?

[១៤:០៣:៣២]

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំដូចជាគ្មានការរំពឹងទុកថា គាត់មានអាយុជីវិតដើម្បីវិលត្រឡប់មកផ្ទះសម្បែងវិញទេ ព្រោះខ្ញុំបានឃើញការស្លាប់របស់គាត់ផ្ទាល់នឹងភ្នែក។

**ស៖** ប្រហែលជាសំណួរខ្ញុំមិនច្បាស់លាស់ហើយមើលទៅ។ នៅពេលដែលគេប្រាប់លោកថា ទ័ពខ្មែរក្រហមចូលមកផ្ទះរបស់លោក គំរាមកំហែងឲ្យលោកចាកចេញ។ តើមានសញ្ញាណបញ្ជាក់ ឬការបញ្ជាក់ណាមួយថា លោកអាចនឹងត្រឡប់មកវិញនៅពេលណាដែរទេ?

**ឆ៖** បាទ ទទួលបានសំណួរនេះ។ មិនទៀងទាត់ទេ ព្រោះការវេចបង្វេចចេញទៅនេះ គេអត់មានកំណត់ថា ម៉ោងឯណាទេ។ គ្រាន់ថា ឲ្យជម្លៀសចេញក្នុងពេលឆាប់ៗនេះ មួយរយៈពេល បាទ មួយរយៈពេល ខ្លាចលោកអាមេរិកមកទម្លាក់គ្រាប់បែក។ គេនិយាយតែប៉ុណ្ណឹងទេ។ ហើយយើងក៏អត់មាននឹកស្មានថា បានមកផ្ទះវិញ ឬក៏មិនបានដែរ។

**ស៖** ហើយលោកសាក្សី លោកឆ្លើយថា គ្រួសាររបស់លោកដើរយឺតៗអស់រយៈពេល បីបួនថ្ងៃ ហេតុអ្វីបានជាការធ្វើដំណើរនេះយឺតយ៉ាងហ្នឹង? ព្រឹកមិញលោកបានឆ្លើយថា ដើរមួយថ្ងៃ ជួនកាលបាន

ត្រឹមតែកន្លះគីឡូ ឬមួយគីឡូដីទេ?

[១៤:០៥:១៤]

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបព្រឹកមិញហើយថា មនុស្សវាច្រើនពេក។ មនុស្សហ្នឹង ដើរសឹងតែថាមួយចំហៀងខ្លួន អត់បានដើរទទឹងខ្លួនទៅទេ ព្រោះវាណែនក្តន់ តាន់តាប់តែម្តង។ ហើយក្នុងការដើរនេះគឺមានកងទ័ពដើរអមខាងៗ។ អ៊ីចឹងអត់អាច អាមួយដើរទៅផ្លូវនេះ អាមួយដើរទៅផ្លូវនោះបានទេ គឺគេដើរអមផ្គួកតាមផ្លូវរហូត។ គេបណ្តាក់គ្នាតាម ជាកង់ៗតាមយើង ផ្លូវដែលគេត្រូវឲ្យដើរហ្នឹងរហូតទៅៗដល់ព្រៃភ្នំ។

**សៈ** តើប្រជាជនប្រភេទណាដែលលោកបានឃើញពួកគាត់ធ្វើដំណើរតាមផ្លូវហ្នឹង? ដូចជាថាក្មេងអាយុប៉ុន្មានដែរ ហើយចាស់ហ្នឹងអាយុប៉ុន្មានទៅប៉ុន្មានដែរ?

**ឆ៖** បាទ ជម្រាបប្រសាសន៍ ថាទៅទាំងគ្រួសារហ្នឹងវាមានតូចមានធំ មានចាស់មានក្មេងហ្នឹងហើយ។ អ៊ីចឹងបងហ្នឹងពប្អូនទៅ ម្តាយពកូនទៅក៏មាន អ៊ីចឹងហើយវាជ្រៀតគ្នាដើរទៅហ្នឹងគឺវារួមទាំងៗជីដូនជីតា ចាស់កោងខ្នងហ្នឹង ក៏វាទៅដែរ ទៅទាំងអស់ ទាំងក្មេងទាំងចាស់ ប្រុសស្រី។ អ៊ីចឹងហើយក្នុងមួយគ្រួសារៗហ្នឹង គឺត្រូវទូលសំពាយហ្នឹងហើយ ទូលបង្វេចហ្នឹង ដើរតាមគ្នាដោយរំកិលបន្តិចម្តងៗទៅទេ អត់មានដើរតាមល្បឿនដែលយើងគិតថាចង់ទៅលឿន ហើយទៅបានដូចចិត្តទេ។

[១៤:០៧:០៦]

**សៈ** តើអាកាសធាតុហ្នឹង មានសភាពបែបណាដែរពេលហ្នឹង?

**ឆ៖** អាកាសធាតុហ្នឹងវាអាប់អួរហើយ ប៉ុន្តែនៅពេលដែលយើងធ្វើដំណើរនេះ យើងនៅពេលដែលយើងធ្វើដំណើរទៅដល់កន្លែងណាដែលមានទឹក គឺមនុស្សទៅគរនៅត្រង់ហ្នឹងហើយ ដើម្បីដោះស្រាយដាំបាយ ដាំទឹក។ អ៊ីចឹងទៅមួយកន្លែងៗ ៗណាមួយអណ្តូងទៅ ឈប់ត្រង់ហ្នឹងទៅ កន្លែងណាមានស្រះទឹកទៅឈប់ហ្នឹងទៅ។ បាយរួចបន្តដំណើរទៅទៀតទៅ។ គេអត់ឲ្យយើងនៅបោះទីតាំងនៅកន្លែងមានទឹកហ្នឹងតែម្តងទេ។ អ៊ីចឹងវាធ្វើការរំកិលបន្តិចម្តងៗ ជារៀងរាល់ម៉ោង លុះត្រាតែពេលយប់ អាហ្នឹងគេឲ្យសម្រាកនៅហ្នឹងតែម្តង។

**សៈ** តើមានប្រជាជនណាម្នាក់ ដែលលោកបានឃើញត្រូវបានគេបង្ខំឲ្យចាកចេញនៅក្នុងសភាពមួយមិនល្អ នៅក្នុងស្ថានភាពមួយដែលមិនល្អដែរទេ?

**ឆ៖** ដូចជាអត់ដែរទេ ពេលហ្នឹង។ វាគ្រាន់តែថា អ្នកណាដែលជួបផលលំបាក ម្តាយចាស់ជរា

ដើរមិនរួចអីហ្នឹង គ្រាន់តែថាទៅជ្រកនៅកន្លែងមានទឹកហ្នឹងបានមួយម៉ោងពីរម៉ោងអ៊ីចឹងទៅ ដួសទឹក ដួសអី ដាក់ដប ដាក់បីដុងអ៊ីចឹងទៅ បន្តទៅទៀតទៅ។ អត់មានការដែលគំរាមកំហែង វាយតប់ ជំរុញ ឬក៏គំរាមរកបាញ់រកបោះអី ហ្នឹងអត់មានទេ បាទ។

[១៤:០៨:៥៦]

**ស៖** តើលោកបានឃើញអ្នកណាម្នាក់មើលទៅទំនងដូចជាឈឺដែរទេ?

**ឆ៖** បាទ ឃើញ។ ឃើញមានរបៀបចាស់ជរា ឃើញមានរបៀបខ្យល់គតាមផ្លូវ។

**ស៖** សូមអរគុណលោក។ ត្រឡប់ទៅនិយាយអំពីព្រឹត្តការណ៍ដែលគេបំបែកឪពុករបស់លោក ហើយគេក៏បំបែកគ្រួសាររបស់លោកនៅវត្តមួយនោះ។ លោកថាមានគ្រួសារចំនួនប្រាំពីរគ្រួសារ។ គ្រួសារមួយគឺថាមានធ្វើគ្រូបង្រៀន ហើយគ្រួសារមួយទៀតគឺជា គឺធ្វើពេទ្យ។ គ្រួសារបួនទៀត ក្រៅពីឪពុករបស់លោក គឺថាធ្វើជាទាហាន។ តើលោកដឹងថា អ្នកដែលធ្វើទាហានហ្នឹង មានពាក់ឋានន្តរស័ក្តិប៉ុនណាទេ? បើលោកដឹង ក៏ឆ្លើយថា ដឹង។ បើមិនដឹង ក៏ឆ្លើយថា មិនដឹង។

**ឆ៖** អត់បានដឹងទេ ប៉ុន្តែគ្រាន់តែថា ធ្លាប់ដឹងគាត់ធ្វើទាហាន។ ហើយបើដឹង ដឹងតែឪពុកខ្ញុំផ្ទាល់ទេ។ តែដល់ពូ មាទាំងអស់ហ្នឹង អត់បានដឹងថា គាត់ពាក់ស័ក្តិប៉ុន្មាន អីស័ក្តិប៉ុន្មានទេ។

**ស៖** ក្រោយពីលោករួចផុតអាយុជីវិតពីការសម្លាប់នេះ លោកឆ្លើយថា ប្អូនស្រីរបស់លោកស្លាប់។ លោកអាចជម្រាបជូនតុលាការបានទេ ប្អូនស្រីរបស់លោកស្លាប់នៅពេលណា?

**ឆ៖** ជម្រាបជូនបាន តែខ្ញុំគ្រាន់ជម្រាបថា ការកើតជំងឺហ្នឹង គឺដោយសារការវាយនឹងដំបង។ គាត់ចេះតែឈឺក្បាលរហូត។ គាត់ចូលរៀនៗគ្រូនៅក្រុងតាខ្មៅនេះ គាត់រៀនអត់កើត។ បានមួយអាទិត្យពីរអាទិត្យហ្នឹង ចាប់ផ្តើមឈឺក្បាលម្តង។ រហូតដល់តែពេលរៀនគ្រូចប់ ទៅធ្វើការ ទៅៗបង្ហាត់វិញ រហូតដល់គាត់មានរោគសរសៃប្រសាទ។ រោគសរសៃប្រសាទ រហូតដល់គាត់ចងកសម្លាប់ខ្លួន ដោយខ្លួនឯង។

[១៤:១២:០០]

**ស៖** ដូច្នេះប្អូនស្រីរបស់លោក គឺថាបានធ្វើអត្តឃាត ក្រោយរបបនោះដួលរលំ គឺក្រោយឆ្នាំ១៩៧៩។ អ៊ីចឹងឬក៏អត់ទេ?

**ឆ៖** បាទ ក្រោយ៧៩។ គាត់បានចូលធ្វើគ្រូហើយ ក៏ប៉ុន្តែវាដូចជាជាប់នៅអាការៈ ហៅថារោគសរសៃប្រសាទ។ អ៊ីចឹងការថ្នាំងថ្នាក់ទឹកចិត្តលិចកើត ក្នុងការសិក្សា ក្នុងការបង្ហាត់បង្រៀនក៏មិន

ដឹង អីក៏មិនដឹងដែរ បានជាកើតរឿងស្រ្គេស រហូតដល់ចងកដោយខ្លួនឯងស្លាប់ទៅ។

**ចៅក្រម អាកនីស្តា ក្លូណូវីកកា មីឡាត៖**

លោកសាក្សី លោកអាចប្រាប់កាលបរិច្ឆេទនៃការចងកនេះបានទេ? ថ្ងៃខែឆ្នាំ ឬក៏តែជាឆ្នាំនេះ គឺជាអ្វីដែលលោកសហព្រះរាជអាជ្ញាសួរទៅលោកថា ប្អូនស្រីរបស់លោកហ្នឹង បានស្លាប់នៅពេលណា?

**លោក សំ សិទ្ធី៖**

បាទ ខ្ញុំគ្រាន់គិតថា ប្អូនស្រីខ្ញុំស្លាប់រហូតមកដល់ថ្ងៃនេះ គឺ៣ឆ្នាំហើយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**សៈ** ខ្ញុំសូមសួរចំណុចបញ្ជាក់មួយថា តើៗការចូលរៀននៅសាលាគរុកោសល្យដែលនិយាយអម្បាញ់មិញហ្នឹង មុន៧៩ ឬក៏ក្រោយ៧៩?

**លោក សំ សិទ្ធី៖**

**ឆៈ** បាទ ក្រោយ៧៩។ អ៊ីចឹងខ្ញុំគ្រាន់តែលើកថា គាត់ៗជាប់ប្រវត្តិគេវាយក្បាលហ្នឹងមកហើយ បានធ្លាក់មកដល់កើតរោគសរសៃប្រសាទហ្នឹង។ រៀនចប់ រៀនគ្រូចប់ហើយ មកបង្អាត់នៅអនុវិទ្យាល័យហើយ តែដល់ពេលគាត់មានអាការៈហ្នឹងជាប់ខ្លួនរហូតដល់មានបញ្ហាដល់ចងកសម្លាប់ខ្លួនហ្នឹងក្រោយ៧៩ហើយ។ អ៊ីចឹងរាប់ទៅថា គាត់ស្លាប់៣ឆ្នាំហើយ អ៊ីចឹងវាមិនក្រោយ៧៩។ ទល់ថ្ងៃនេះ ស្លាប់បាន៣ឆ្នាំហើយ។

[១៤:១៤:១៩]

**សៈ** លោកសាក្សី នៅពេលដែលលោករួចរស់រានមានជីវិតពីការសម្លាប់នោះ គេឱ្យលោកវិលត្រឡប់ទៅឃុំរបស់លោក។ តើគេមានស្រង់ប្រវត្តិរូបលោកទេ?

**ឆៈ** ការ -- ខ្ញុំសូមសួរម្ដងទៀតថា ស្រង់ប្រវត្តិរូបហ្នឹងនៅសម័យ ប៉ុល ពត ឬក៏សម័យយើងបច្ចុប្បន្ន?

**សៈ** ខ្ញុំ -- ការបកប្រែមកជាភាសាអង់គ្លេស គឺខ្ញុំយល់មិនបានច្បាស់ទេ។ អ៊ីចឹងខ្ញុំសូមសួរសំណួរខ្ញុំឡើងវិញ ប្រហែលជាដោយសារសំណួរខ្ញុំវាមិនច្បាស់ដែរ។ លោកបាននិយាយពីការធ្វើដំណើរទៅក្រាំងល្វា តើត្រឹមត្រូវដែរទេ?

**ឆៈ** បាទ ត្រឹមត្រូវ។

**សៈ** នៅសហករណ៍ក្រាំងល្វានោះ គេមានឱ្យលោកសរសេរប្រវត្តិរូបទេ ឬក៏គេស្រង់ប្រវត្តិរូប

លោកទេ?

**ឆ៖** អត់មានទេ។ អត់មានសួរយកប្រវត្តិរូបយកអីទេ គេយកតែចំនួនគ្រួសារ ចំនួនមនុស្ស ដើម្បីធ្វើការគ្រប់គ្រងនៅក្នុងសហករណ៍។

**ស៖** នៅសហករណ៍នោះ តើប្រជាជនដែលនៅទាំងអស់ -- ទីនោះ ទាំងអស់សុទ្ធតែជាប្រជាជនមូលដ្ឋាន ឬក៏ជាប្រជាជនដែលចេញទៅពីកន្លែងផ្សេងដូចលោកដែរ?

[១៤:១៦:៣០]

**ឆ៖** បាទ នៅក្នុងសហករណ៍ហ្នឹង គឺវាមានមូលដ្ឋានចាស់ និងមូលដ្ឋានថ្មី។ អ៊ីចឹងហើយ មូលដ្ឋានចាស់ហ្នឹងតិចទេ តែមូលដ្ឋានថ្មីដែលទៅជ្រកកោនជាមួយមូលដ្ឋានចាស់ហ្នឹងវាច្រើន។ បាទ ក្រោយពេលយើងបែកឆ្នាំ៧៥ទៅហ្នឹង គឺគេយកទៅនៅជ្រកជាមួយក្រុមមូលដ្ឋានចាស់ហ្នឹង តាមបណ្តាឃុំនីមួយៗហ្នឹង គឺច្រើនៗណាស់។

**ស៖** ពាក្យដែលលោកទើបប្រើនេះ និយាយពីមូលដ្ឋានចាស់ មូលដ្ឋានថ្មី គេប្រើនៅពេលនោះ ឬក៏អត់? ហើយបើសិនជាគេៗប្រើនេះថាពាក្យថា "ប្រជាជនមូលដ្ឋាន" និង "ប្រជាជនថ្មី" នេះអ្នកណាជាអ្នកប្រើ?

**ឆ៖** បើនិយាយទៅវា និយាយជាទូទៅតែម្តងនៅតាមសហករណ៍គេច្រើន ជាគោលការណ៍ក៏មិនដឹងអីក៏មិនដឹងទេ ប៉ុន្តែគ្រាន់តែថា "មូលដ្ឋានចាស់" "មូលដ្ឋានថ្មី" ហ្នឹងគឺវារត់មាត់អ៊ីចឹងហ្មងហើយ។ ពួកបែកទៅឆ្នាំ៧៤, ៧៣, ៧៤ ក៏ចូលមូលដ្ឋានចាស់របស់គេហើយ តែដល់ទៅយើង៧៥ ទៅក្រោយគេនេះ អាហ្នឹងគេដាក់ពួក៧មេសា ពួកមូលដ្ឋានថ្មីអាហ្នឹងនោះ ពួកជម្លៀស គេហៅថា "ពួកជម្លៀស"។ ពួកជម្លៀសហ្នឹងពួកៗមូលដ្ឋានថ្មីហើយ។

**ស៖** ចុះលោកវិញស្ថិតនៅក្នុងប្រភេទណាមួយ?

**ឆ៖** ខ្ញុំស្ថិតនៅក្នុងប្រភេទពួកជម្លៀសហ្នឹងហើយ ពួកមូលដ្ឋានថ្មីហ្នឹងហើយ។

**ស៖** លោកសាក្សី នៅសហករណ៍នោះ តើ -- មានការជំទាស់ ខ្ញុំសូមផ្អាកសិន។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ឥឡូវនេះគឺថាអស់ពេល១ម៉ោង ២០នាទីហើយ ហើយនៅតែមិនទាន់សួរអំពីការសម្លាប់រង្គាលនៅឡើយ។ ដូច្នេះ ខ្ញុំសូមសំណូមពរឲ្យអង្គជំនុំជម្រះតុលាការកំពូលបង្គាប់ ឬក៏ណែនាំ ឬក៏សូមឲ្យសហព្រះរាជអាជ្ញាសួរអំពីការសម្លាប់រង្គាលដូចដែលបានចោទប្រកាន់។

[១៤:១៩:០៣]

**លោក នីកូឡាស គូមជែន៖**

មេធាវីការពារក្តី ហាក់បីដូចជាជំទាស់គ្រប់ទាំងអស់ រួមទាំងការជម្លៀសដោយបង្ខំផងដែរ។ មេធាវីការពារក្តីសួរសំណួរទាំងអស់នេះមកកាន់សាក្សីរូបនេះ គឺចាដដែលៗព្រឹកមិញនេះ ជាង៣ម៉ោង។ សំណួរជាច្រើនជាសំណួរដដែល គឺអំពីការសម្លាប់រង្គាល--

**ប្រធានអង្គជំនុំ៖**

អ៊ីចេះលោកមេធាវី -- លោកសហព្រះរាជអាជ្ញាដើម្បីកុំឱ្យខាតពេលវេលា ដូច្នេះជំទាស់របស់មេធាវីអំមិញដូចជាមិនសមស្របទេ។ ហើយអ៊ីចឹងសូមលោកអញ្ជើញបន្តសំណួរទៅទៀតបាទ សូមអញ្ជើញ ដើម្បីឱ្យចប់ម៉ោងហ្នឹង។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើមានការប្រព្រឹត្តខុសៗគ្នាដែរទេ រវាងប្រជាជនមូលដ្ឋានចាស់ និងប្រជាជនមូលដ្ឋានថ្មី?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ បើនិយាយទៅ វាមានការខុសគ្នា មួយមានសិទ្ធិ។ មូលដ្ឋានចាស់គេមានសិទ្ធិច្រើនជាងយើងមូលដ្ឋានថ្មី។ យើងមូលដ្ឋានថ្មី យើងអត់មានសិទ្ធិដាំដុះដំឡូង ឬសាគូអីនៅតាមផ្ទះអី ទៅដកហូបអីអត់បានទេ។ បន្លែបង្ការអីដាំនៅតាមផ្ទះ ដកហូបអត់បានទេ បានត្រឹមដាំ ហើយយកទៅដាក់សហករណ៍។ តែដល់បងប្អូនមូលដ្ឋានចាស់ គេដាក់សហករណ៍ខ្លះ គេទុកចិញ្ចឹមគ្រួសារគេនៅខាងក្រៅខ្លះបាន។ បាទ សិទ្ធិវាខុសគ្នាអ៊ីចឹង។ ហើយការធ្វើការងារក៏អ៊ីចឹងដែរ។ ការធ្វើការងារ គឺគេគ្រប់គ្រងលើយើងហ្នឹង។ បាទ មនុស្សចាស់គ្រប់គ្រងមនុស្សចាស់ ដែលជាប្រជាជនថ្មី។ ក្មេងគ្រប់គ្រងក្មេង ដែលជាប្រជាជនថ្មី -- មូលដ្ឋានថ្មី។ មូលដ្ឋានចាស់ គ្រប់គ្រងលើមូលដ្ឋានថ្មី ទាំងក្មេង ទាំងចាស់។ អ៊ីចឹងបានថា សិទ្ធិវាអត់ដូចគ្នាទេ។ សិទ្ធិមូលដ្ឋានចាស់ គេធំទូលំទូលាយជាង។

[១៤:២១:២៩]

**ស៖** នៅពេលដែលលោកនៅសហករណ៍ តើលោកមានដែលគិតថា លោកមកផ្ទះបានទេ?

ហើយបើសិនណាជាលោកចង់មកផ្ទះ ហើយមកមិនបាន មូលហេតុអី?

**ឆ៖** មិនអាចមកបានទេ បាទ ព្រោះថាយើងនៅម៉ោង ដែលយើងត្រូវចេញទៅធ្វើពលកម្ម មានមេគ្រប់គ្រង មានម្ចាស់ -- មានមូលដ្ឋានចាស់ដែលជាប្រធាននោះ គេគ្រប់គ្រងយើង។ យើងអត់មានពេលអី សុំថាឥឡូវខ្ញុំសុំទៅលេងផ្ទះម្ភៃពីរអី អត់បានទេ។ ធ្វើការអស់ម៉ោង យើងសម្រាកនៅកន្លែង ដល់ម៉ោងធ្វើការឡើងធ្វើការទៀត។ មិនមែនដល់ធ្វើការអស់ម៉ោងហើយ មកសម្រាកផ្ទះ ហើយដល់ម៉ោងធ្វើការទៅធ្វើវិញបាន អត់ទេ។

**លោក អាកទូរ វ៉េកគែន៖**

លោកប្រធាន ច្បាស់ណាស់ថា សំណួររបស់សហព្រះរាជអាជ្ញា គឺវាមិនពាក់ព័ន្ធទៅនឹងប្រធានបទនៃបណ្តឹងសាទុក្ខទេ។ ខ្ញុំសូមបញ្ជាក់ថា យើងស្ថិតនៅក្នុងសំណុំរឿង០០២/០១ មិនមែន ០០២/០២ទេ។ យើងមានដីកាបំបែកនីតិវិធីហើយ។ យើងកំពុងតែដំណើរការនូវនីតិវិធីបណ្តឹងសាទុក្ខ ហើយលោកសួរនេះដូចជាផ្តេសផ្តាសណាស់។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ដូចមេធាវីការពារក្តីបានដឹងហើយ គឺថាផ្នែកនៃការផ្តន្ទាទោសនៅក្នុងសាលក្រមនេះ គឺពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម និងគោលនយោបាយផ្សេងៗ រួមទាំងការដាក់ប្រជាជនឲ្យក្លាយទៅជាទាសករនៅតាមសហករណ៍ផងដែរ។ ដូច្នេះខ្ញុំយល់ឃើញថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យខ្ញុំសួរអំពីការប្រព្រឹត្តផ្សេងៗមកលើប្រជាជន។

[១៤:២៣:៣១]

**លោក វ៉ិចទ័រ កូប៉េ៖**

សហព្រះរាជអាជ្ញាកំពុងសុំធ្វើអន្តរាគមន៍ផង គាត់កំពុងធ្វើលើកឡើងមិនត្រឹមត្រូវទេ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកសហព្រះរាជអាជ្ញា យើងដឹងថា សាលក្រមមិនស្ថិតនៅក្នុង -- សហករណ៍មិនស្ថិតនៅក្នុងសាលក្រមទេ។ ដូច្នេះ ខ្ញុំគិតថាការប្រើប្រាស់ពេលវេលាសាកសួរអំពីផ្នែកនេះ គឺវាមិនពាក់ព័ន្ធទេ ដូច្នេះ ខ្ញុំសូមឲ្យលោកចាប់ផ្តើមសួរអំពីការសម្លាប់រង្គាលតែម្តងទៅ។

**លោក នីកូឡាស គូមជែន៖**

បាទ បើ -- ហើយពេលនេះ ក៏វាដល់ពេលសម្រាកផងដែរ។ ដូច្នេះខ្ញុំនឹងចូលទៅនិយាយគោល

នយោបាយចំពោះការកំណត់គោលដៅមកលើខ្មាំងនៅពេលក្រោយ។

**ចៅក្រម អាកនីស្តា ក្លូណូវីកកា មីឡាត៖**

ដូច្នេះ គឺជាទូទៅហើយ វាពិបាកពាក់ព័ន្ធណាស់ ប៉ុន្តែសូម -- ចំពោះរឿងបញ្ហាសហករណ៍វិញ គឺមិនបានលើកយកមកជំទាស់តវ៉ានៅក្នុងសាលក្រមទេ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនជំទាស់ទេ គឺខ្ញុំនិយាយអំពីសហឧក្រិដ្ឋកម្មរួម ហើយនិងការដាក់ប្រជាជនឲ្យទៅជាទាសករ។ ខ្ញុំបន្តទៅមុខទៀតទៅចុះ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នៅសហករណ៍ លោកដែលឮគេនិយាយគ្នាអំពីពាក្យ "ខ្មាំង" ទេ? ក្រោយពីលោករួចផុតពីការសម្លាប់ គឺចាប់ពីថ្ងៃ១៧ មេសា ៧៥ ដល់០៦ មករា ៧៩ តើលោកដែលឮគេនិយាយរបបអ្នកដឹកនាំរបបនោះ ឬក៏អ្នកណាម្នាក់និយាយអំពីគោលនយោបាយចំពោះខ្មាំងទេ?

[១៤:២៥:២៦]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ តាមតែ បើនិយាយទៅអាពាក្យហៅថា "ខ្មាំង" ហ្នឹងតែមានទោស គេហៅថា "ខ្មាំង" ហ្នឹងហើយ កាលសម័យនោះ។ លួចដំឡូងគេមួយដុំ ក៏គេហៅ "ខ្មាំង" គេយកយើងទៅដាក់មន្ទីរឃុំឃាំង។ ដំឡូងដាំខ្លួនឯង ទៅដកយកមកញ៉ាំខ្លួនឯង ក៏គេថាខ្មាំង។ អ៊ីចឹងយក ចាប់អ្នកម្ចាស់ដំឡូងហ្នឹង យកទៅដាក់គុក ព្រោះនេះជាខ្មាំងរបស់បដិវត្តន៍។

**ស៖** ក្រោយពីលោករស់រានមានជីវិតពីការបាញ់សម្លាប់នោះ តើលោកមានដែលជួបព្រឹត្តិការណ៍ណាមួយ ដូចជាថារបបហ្នឹងស្រាវជ្រាវ ឬក៏រែកមុខរកអតីតមន្ត្រីរដ្ឋការ ឬក៏អតីតទាហានរបប លន់ នល់ ដែរឬទេ?

**ឆ៖** បាទ មាន។ អ៊ីចឹងហើយ ក្រោយពីការកាប់សម្លាប់ឪពុកម្តាយខ្ញុំអស់ហើយហ្នឹង គឺខ្ញុំឃើញព្រោះខ្ញុំនៅនឹងភូមិក្រាំងល្វានេះ -- អំ! នៅនឹងភូមិតាំងគ្រួសនេះ ក្នុងឃុំក្រាំងល្វានេះ ខ្ញុំឃើញគេប្រមូលអ្នកទោសរាប់រយនាក់ ប៉ុន្តែមិនដឹងគេដាក់ឯណា គេទុកឯណាទេ ខ្ញុំអត់ដឹងទេ។ គ្រាន់តែថាព្រលឹមឡើងគឺគេចងខ្សែមួយជន្លាសអ៊ីចឹងទៅ ប្រហែលជា១០០នាក់ ៥០នាក់អ៊ីចឹងទៅ ដើរកាត់ភូមិហ្នឹង មកកើតអ៊ីចេះបាត់មក បាទ។ មិនដឹងជាយកទៅណា យកទៅណីទេ។ អ៊ីចឹងឃើញចេញតែកាត់ភូមិក្រាំងល្វា

ហ្នឹង -- អ៎! ភូមិតាំងគ្រួសហ្នឹង ម្តងៗមួយជន្លាសៗទៅ ទៅកើតអ៊ីចឹងទៅ មកលើក្រាំងល្វា។ ខ្ញុំនៅរស់នៅនឹងក្នុងភូមិតាំងគ្រួស ហើយខ្ញុំមើលគោនៅចុងភូមិតាំងគ្រួសហ្នឹង ឃើញគេបណ្តើរមួយខ្សែៗទៅហ្នឹង សុទ្ធតែរបៀបជាទាហាន។ ដឹងគេស្រាវជ្រាវអី ហើយមិនដឹងគេយកពីគុកណាមក អត់ដឹងទេ។

[១៤:២៧:៤៨]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន បើសិនណាជាលោកប្រធានឈប់សម្រាកសិនក៏បាន ប៉ុន្តែបើមិនដូច្នោះទេ ខ្ញុំអាចនឹងលើកកថាខណ្ឌ៦(១៥) យកមកនិយាយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ព្រឹត្តិការណ៍ដែលលោកទើបតែបាននិយាយ លោកអាចជ្រាបតុលាការបានទេ វាកើតឡើងនៅឆ្នាំណា? បើសិនណាជាលោកមិនដឹងទេ សូមកុំស្មាន ឬក៏លោកអាចគ្រាន់តែថាប្រហាក់ប្រហែល។ បើមិនដឹងចម្លើយទេ សូមមេត្តាកុំស្មាន។ បើនឹកមិនឃើញ ប្រាប់ថានឹកមិនឃើញ។ បើលោកអាចចងចាំឆ្លើយថាចងចាំ។

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំសូមសួរអ៊ីចេះ គាត់ចង់និយាយជាមួយខ្ញុំពីរឿងអី? និយាយពីរឿងដែលខ្ញុំឃើញគេបណ្តើរអ្នកទោសហ្នឹង ឬមួយក៏រឿងអ្វី?

**ស៖** បាទ ត្រឹមត្រូវហើយ។ ខ្ញុំសួរនិយាយអំពីបណ្តើរអ្នកទោសនេះ។

**ឆ៖** បាទ ការឃើញបណ្តើរអ្នកទោសទាំងខ្សែៗនេះ គឺខ្ញុំឃើញដោយពិតនឹងភ្នែក។ ព្រោះនៅពេលហ្នឹង គឺខ្ញុំនៅឃ្វាលគោនៅតាមៗស្រែ ហើយមានចម្ការមៀនមួយហ្នឹង ខ្ញុំទៅជ្រកនៅនឹងចម្ការមៀនហ្នឹង ហើយខ្ញុំឃើញគេបណ្តើរកាត់ហ្នឹង ទាំងខ្សែៗ ពិតប្រាកដមែន។ របៀបជាអ្នកទោសចងខ្សែ ចងដៃ បណ្តោងគ្នារហូត បណ្តាក់គ្នារហូត។ ម្តង៥០, ៦០នាក់ទៅ ជួនកាលឃើញខ្សែហ្នឹងវាវែងទៅ ៥០, ៦០នាក់ទៅ ជួនកាលឃើញ ៣០, ៤០នាក់អ៊ីចឹងទៅ ចងជាខ្សែៗបណ្តើរ។ ប៉ុន្តែមិនដឹងយកទៅណា។ បណ្តើរពីលិចទៅកើត។

[១៤:៣០:០០]

**ស៖** តើលោកដឹងទេថា តើវានៅក្នុងឆ្នាំ៧៥, ៧៦ ឬក៏នៅពេលក្រោយមកទៀតទេ?

**ឆ៖** បាទ ខ្ញុំគិតថា វានៅក្នុងឆ្នាំ ចុងឆ្នាំ៧៥។

**ស៖** អ្នកដែលលោកឃើញគេចងហ្នឹង ថាតើជាបុរស ជានារី ឬក៏មានទាំងបុរស មានទាំងនារី?

**ឆ៖** បើខ្ញុំស្មានមិនខុសទេថា មើលទៅឆ្អឹងឆ្អែង មើលទៅចរិតជាទាហានសម័យ លន់ នល់។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញា ឥឡូវនេះគឺខាងខ្សែវីដេអូ ឌីវីឌី ហ្នឹងត្រូវបានអស់ហើយ ហើយសុំសម្រាកមួយនាទីដើម្បីប្តូរ។ ហើយម៉ោងលោកហ្នឹងក៏អស់ពេលហ្នឹងដែរហើយ។ អ៊ីចឹងលោកមានសល់ច្រើនសំណួរទេ?

**លោក នីកូឡាស គូមជែន៖**

សូមអភ័យទោសលោកប្រធាន អំមិញដោយសារសហការីគាត់ជជែកជាមួយខ្ញុំ ខ្ញុំស្តាប់អត់ទាន់បាន។ សុំពេលបន្តិចលោកប្រធាន។ ឯកឧត្តមប្រធាន ខ្ញុំគិតថា ខ្ញុំអាចត្រូវការពេលវេលាបន្តិចបន្តួចទេដើម្បីបញ្ចប់សំណួររបស់ខ្ញុំ សូមលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

យើងមិនចាប់អារម្មណ៍ជាមួយហេតុការណ៍ដែលលោកនិយាយនេះទេ។ ដូច្នេះ សូមលោកប្រើពេលវេលាដែលនៅសល់បន្តិចបន្តួចនិយាយទៅលើការសម្លាប់រង្គាលនោះតែម្តងទៅ។

*(សម្រាករយៈពេលខ្លី)*

[១៤:៣២:២៤]

**ប្រធានអង្គជំនុំ៖**

បើអ៊ីចឹងសូមលោកសហព្រះរាជអាជ្ញាធ្វើសំណួរ តាំងសំណួរចុងក្រោយទៅ ហើយដើម្បីនឹងបញ្ចប់ ប្រហែលជាពីរបីនាទីហ្នឹងបានហើយ។ បាទ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមានការព្រួយបារម្ភបន្តិច ព្រោះថាសហការីខ្ញុំ គាត់បានប្រាប់ខ្ញុំថា សំណួរពីរបីចុងក្រោយដែលយើងសួរហ្នឹងប្រហែលជាអត់មាននៅក្នុងកំណត់ត្រាទេ។ ដូច្នេះតើយើងអាចធ្វើយ៉ាងម៉េចដឹង ថាតើសំណួរពីរបីសំណួរចុងក្រោយហ្នឹងមាននៅក្នុងកំណត់ត្រា ឬក៏អត់? តើយើងគួរធ្វើយ៉ាងណាដើម្បីឲ្យដឹងថា វាបានថតចម្លងចូលទៅក្នុងកំណត់ត្រា ឬក៏អត់?

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកចាំទេ ចាំអំពីមនុស្សដែលលោកបានឃើញទាំងអស់នោះទេ?

**លោក សំ សិទ្ធី៖**

**ឆ៖** សួរថា ខ្ញុំចាំពីអ្នកណា? ពីមនុស្សដែលគេចងខ្សែម្តងមួយជន្លាសៗទៅហ្នឹង ឬមួយសួរពីអី?

**ស៖** ដូច្នេះខ្ញុំចង់សួរលោកអំពីមនុស្សដែលគេបណ្តើរជាជួរ ចងជាខ្សែ ដើរហ្នឹង តើលោកចាំឬក៏លោកស្គាល់មុខពួកគាត់ខ្លះទេ នៅក្នុងចំណោមហ្វូងមនុស្សដែលគេចងបណ្តើរទៅហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់បានស្គាល់ទេ។ ក៏ប៉ុន្តែគ្រាន់តែឃើញរបៀបជាទាហានជំនាន់ លន់ នល់ ហើយខ្ញុំឃើញចរិតឫកពារ ឃើញឆ្អឹងឆ្អែង។ ទាហាន លន់ នល់ ហ្នឹងគឺគេរើសទាហានស្អាតៗណាស់ របៀបជាពីឡុត ដូចពីឡុតអ៊ីចឹង ចូលសាលាទាហាននោះ។ អ៊ីចឹងខ្ញុំឃើញថា ហើយក៏ខ្ញុំបានឮដែរថា ពួកនេះសុទ្ធតែជាទាហាន លន់ នល់ ដែលគេស្រាវជ្រាវយកមក។ អាហ្នឹងពួកក្មេងមូលដ្ឋានចាស់ គេថា ពួកហ្នឹងសុទ្ធតែពួកទាហាន លន់ នល់ ហើយ គេជម្លៀស -- គេស្រាវជ្រាវយកមកដាក់គុក។

[១៤:៣៥:០៨]

**ស៖** ខ្ញុំជិតបញ្ចប់ហើយលោក។ ប៉ុន្តែខ្ញុំចង់សួរថា តើមានអ្នកដើរយាមក្រុមមនុស្សដែលគេចងបណ្តើរហ្នឹងអត់? ហើយបើសិនបើមានអ្នកឈរយាម អ្នកដើរយាមហ្នឹង តើអ្នកដែលយាមហ្នឹងគាត់មានប្រដាក់អាវុធដែរឬទេ?

**ឆ៖** អត់។ បើតាមខ្ញុំមើលនឹងភ្នែកទៅ មនុស្ស៥០-៦០នាក់ ចងមួយខ្សែហ្នឹងទៅ ដូចជាឃើញទាហានពីរនាក់អី កាំភ្លើងពីរដើមអីទេ ដែលដើរឆ្កកអ្នកទោសហ្នឹងទៅ។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណឯកឧត្តមប្រធាន។ ខ្ញុំសូមបញ្ចប់។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងអង្គជំនុំជម្រះតុលាការកំពូលប្រកាសសម្រាកទៅដល់ម៉ោងដប់បួន និងហាសិបនាទីគឺចូលមកវិញ បាទ។

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៥ នាទី)*

[១៤:៥៥:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះតុលាការកំពូលប្រកាសបន្តសវនាការ។ ហើយនៅពេលនេះ គឺតាមការពិភាក្សារបស់អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យមេធាវីការពារជនជាប់ចោទ ខៀវ សំផន មានរយៈ២០នាទីបន្ថែមទៀត។ ដូច្នេះ សូមអញ្ជើញលោកមេធាវីតាំងសំណួរដល់សាក្សី។

ពេលវេលានេះគឺអាស្រ័យទៅលើលោកទាំងពីរ ទាំងមេធាវី នួន ជា ហើយនិងមេធាវី ខៀវ សំផន ប្រើពេលវេលាប៉ុន្មានសម្រាប់ចែកគ្នាទៅដើម្បីអាចសួរសំណួរដល់សាក្សីបាន បាទ។

**លោក អាកឡូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរបន្តដោយលោក អាកឡូរ វែកគែន៖**

**ស៖** លោកសាក្សី ខ្ញុំចង់ត្រឡប់មកនិយាយអំពីបញ្ហាដែលកើតឡើងជាញឹកញាប់មួយ ដែលខ្ញុំមើលទៅឃើញនៅក្នុងចម្លើយរបស់លោកនោះគឺថា ទាក់ទងនឹងកាលបរិច្ឆេទ ដែលលោកបានជួបអ្នកស៊ើបអង្កេតដែលមកពីតុលាការយើងនេះ ហើយនិងការដែលលោកនិយាយថា លោកមិនសូវជាចាំប៉ុន្មានទេ មិនអាចបែងចែកឲ្យដាច់រវាងក្រុមការងារដែលទៅសម្ភាសលោក ដើម្បីនិយាយជាមួយលោកនូវរឿងដ៏កំសត់របស់លោក បន្ទាប់ពីការបោះពុម្ពផ្សាយនៃអត្ថបទកាសែតហ្នឹង។ នៅពេលដែលខ្ញុំពិចារណាទៅត្រង់ចំណុចនេះ ខ្ញុំក៏ចោទសំណួរដូចតទៅនេះ មកកាន់ខ្លួនឯង។ នៅពេលដែលលោកជួបអ្នកស៊ើបអង្កេតនៅតុលាការយើងនេះ តើគាត់មានឲ្យ សុំឲ្យលោកស្បថដែរឬទេ?

[១៤:៥៨:២០]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទនៅពេលដែលគាត់អញ្ជើញទៅជួបខ្ញុំ សុំការសម្ភាសពីខ្ញុំនៅខេត្តនោះ គាត់អត់បានសុំខ្ញុំឲ្យស្បថទេ។ តែគាត់គ្រាន់បានបញ្ជាក់ថា ការនិយាយរបស់លោក សូមឲ្យនិយាយតែពាក្យពិត។ ហើយនៅពេលដែលតុលាការកំពូលលោកមានការកោះអញ្ជើញហៅទៅ ជួបដើម្បីធ្វើជាសាក្សីនេះ គឺលោកត្រូវទទួលការសម្បថហើយ។ បាទ ចូលរួមសម្បថហើយ។ អ៊ីចឹងសូមឲ្យឆ្លើយតែពាក្យពិតសម្រាប់គាត់ថតខ្សែអាត់ ក៏ដូចជាកត់ត្រា។

**ស៖** បាទ ខ្ញុំយល់ហើយថា លោកកំពុងតែនិយាយអំពីកិច្ចសម្ភាសន៍ថ្មីៗទៅនេះ លោកនិយាយថាដូចប្រហែលជា២ខែមុននេះ ហើយជាមួយមនុស្សដែលមកពីតុលាការ។ ខ្ញុំចង់និយាយជាមួយលោកអំពីកិច្ចសម្ភាសន៍ដែលបានធ្វើប្រហែល២ឆ្នាំមុននេះ នៅពេលដែលលោកនិយាយថា មានក្រុមការងារដែលមានសមាជិកបួននាក់ ទៅសម្ភាសលោកនោះ។ តើថ្ងៃដែលក្រុមការងារ ដែលមានសមាជិកបួននាក់ទៅសម្ភាសលោកហ្នឹង លោកមានស្បថដែរឬទេ? នៅថ្ងៃដែលលោកផ្តិតមេដៃ ហើយនិងចុះហត្ថលេខាទៅលើកំណត់ហេតុស្តាប់ចម្លើយនេះ ហើយលោកក៏បានទទួលស្គាល់ហត្ថលេខារបស់ខ្លួន ហើយនិងហត្ថលេខា -- និងស្នាមមេដៃរបស់ខ្លួន ព្រោះថាលោកជានគរបាល លោកដឹងនីតិវិធីហើយ។ តើអ៊ីចឹងខ្ញុំសួរលោក ថាថ្ងៃហ្នឹងលោកមានបានស្បថដែរឬទេ?

**ឆ៖** ខ្ញុំដូចជាភ្លេច មិនដឹងជាបានស្បថឬមិនបានស្បថផង ប៉ុន្តែខ្ញុំគ្រាន់តែបានចុះហត្ថលេខា -- ផ្តិតស្នាមមេដៃ ហើយគាត់ឲ្យសរសេរឈ្មោះដោយខ្លួនឯង។

[១៥:០០:៣០]

**ស៖** នៅពេលដែលលោកជួបអ្នកកាសែត ហើយនិងអង្គការផ្សេងៗទៀតនោះ គេមានឲ្យលោកចុះហត្ថលេខាលើកំណត់ត្រាស្តាប់ចម្លើយរបស់លោកដែរឬទេ?

**ឆ៖** បាទ អ្នកសារព័ត៌មានហ្នឹងអត់បានឲ្យខ្ញុំចុះហត្ថលេខាអីទេ។ គេគ្រាន់តែដកស្រង់យកព័ត៌មានហ្នឹងពីខ្ញុំ ហើយគេចុះផ្សាយ។ តែអ្នកពីរក្រុមទៀតនេះ គឺគេបានឲ្យខ្ញុំផ្តិតមេដៃទៅលើកំណត់ត្រាហ្នឹង។ តែរឿងស្បថហ្នឹងខ្ញុំដូចវាភ្លេច ដឹងក្រុមណាឲ្យស្បថហើយឬនៅ ព្រោះវាមានពីរគន្លាក់ វាមាន៧ឆ្នាំហ្នឹងម្តង អា២ឆ្នាំក្រោយនេះម្តងទៀត តែគេទៅសួរតែអារឿងដដែលហ្នឹង។

**ស៖** តើលោកបានស្បថដោយតាមរយៈអ្នកតំណាងឲ្យតុលាការយើងនេះ ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំដែលខ្ញុំជម្រាបហើយថា ខ្ញុំចាំអត់បានទេរឿងស្បថ។ តែបើមកដល់ទីនេះខ្ញុំបានស្បថ តែនៅឯនុ៎ងមិនដឹងជាបាន ដឹងជាបានទទួលស្បថ ឬមួយអត់ទេ ប៉ុន្តែខ្ញុំគ្រាន់តែបានផ្តិតមេដៃជូនគេនៅលើចម្លើយ។

**ស៖** បាទៗសូមអរគុណ។ ឥឡូវលោកសាក្សី ឥឡូវលោកចាំថា លោកបានជួបអ្នកស៊ើបអង្កេតតុលាការយើងនេះពីរដង។ អ៊ីចឹងបានថា លើកទី១ហ្នឹងគឺកាលពី៧ឆ្នាំមុន ហើយលើកទី២កាលពី២ឆ្នាំមុន។ អ៊ីចឹងលោក អម្បាញ់មិញនេះលោកនិយាយអ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ប៉ុន្តែខ្ញុំអត់ដឹងថាជួបនឹងក្រុមតុលាការតែមួយ ឬក៏អ្នកអង្គការណាទៀតក៏មិនដឹងទេ

ប៉ុន្តែខ្ញុំដឹងថាគេតាមទៅសួររឿងហ្នឹង ក្នុងរឿងហ្នឹងវាពីរដង។ បាទ ៧ឆ្នាំមុនម្តង ប្រហែលជាក្រុមតុលាការកំពូលហ្នឹងហើយ។ ហើយដល់ពេលក្រោយហ្នឹងអា២ឆ្នាំក្រោយនេះទៅមួយសាទៀត ប៉ុន្តែមិនដឹង ភ្លេចទៅមិនដឹងជាខាងណា អង្គការក៏មិនដឹង ក្រុមការងារតុលាការកំពូលក៏មិនដឹង។

[១៥:០៣:២៤]

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមត្រឡប់ចូលមកនិយាយអំពីអង្គហេតុពេលដែលលោកត្រូវបានគេនាំយកទៅជាមួយនឹងគ្រួសារទាំងប្រាំពីរនេះ ពីវត្តច្រកស្តេចចូលទៅព្រៃ នាំពីវត្តហ្នឹងទៅព្រៃ។ នៅពេលដែលខ្ញុំអាចកំណត់ហេតុស្តាប់ចម្លើយរបស់លោកតែមួយគត់ ដែលយើងមាននៅទីនេះគឺឯកសារចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៨ ខ្ញុំឃើញថាលោកនិយាយដូចតទៅនេះ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយហ្នឹង។ បាទ គឺឯកសារ E3/5201, ERN ជាភាសាបារាំងគឺ 00275145, ERN ជាភាសាខ្មែរគឺ 002121-- ហើយជាអង់គ្លេស 00275139។ លោកនិយាយដូចតទៅនេះ៖ "ខ្មែរក្រហមបានប្រកាសតាមមីក្រូថា សួររកមន្ត្រីរាជការសម័យ លន់ នល់ ហើយពួកគេនិយាយថា សូមអញ្ជើញបងប្អូនធ្លាប់ធ្វើការកន្លងមក ធ្លាប់ធ្វើការងារអីកាលពីមុនមកឲ្យមកទៅធ្វើការងារចាស់មុន"។ លោកសាក្សី ខ្ញុំមើលទៅឃើញលោកកំពុងតែអានឯកសារក្នុងពេលទន្ទឹមនឹងខ្ញុំអានហ្នឹងដែរ ឯកសារអីដែរលោក?

**ឆ៖** ឯកសារហ្នឹងឯកសារដែលក្រុមការងារគេឲ្យមកខ្ញុំ។

**ស៖** អ៊ីចឹងលោកបានរក្សាឯកសារហ្នឹងដែរអ៊ីចឹង?

**ឆ៖** បាទៗ។ ក្រោយពេលគេជួបសម្ភាសជាមួយខ្ញុំហើយ គេត្រូវទុកឯកសារឲ្យខ្ញុំមួយច្បាប់ដើម្បីពិនិត្យ។

[១៥:០៥:៣៨]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកមេធាវីប្រហែលជាអាចជួយលោកបាន គឺថាមេធាវី កូប៉េ បានឲ្យសាក្សីនូវឯកសារមួយច្បាប់នេះ ដើម្បីឲ្យបញ្ជាក់អំពីហត្ថលេខារបស់សាក្សី ហើយនិងស្នាមផ្តិតមេដៃរបស់សាក្សី។ ហើយខ្ញុំប្រសិនបើខ្ញុំចាំមិនខុសទេ គឺឯកសារហ្នឹងនៅទុកនៅលើតុសាក្សីហ្នឹងនៅឡើយ អត់មានទាន់យកទៅណានោះទេ។ ដូច្នេះហើយដើម្បីចៀសវាងនូវការយល់ខុសណាមួយទៀត ខ្ញុំគិតថា ក្រុមការងារដែលនិយាយហ្នឹង គឺថាក្រុមការងារដែលមកជួបសាក្សីហ្នឹង គឺប្រហែលជាអង្គភាពសាក្សី គាំពារសាក្សី ដែលមកនិយាយអំពីបញ្ហាស្បថ ហើយនិងដើម្បីប្រគល់លិខិតកោះហៅសាក្សីតែប៉ុណ្ណោះ ព្រោះថានេះគឺជា

ការងារផ្តួចផ្តើមដោយអង្គជំនុំជម្រះតុលាការកំពូលនេះ។

**លោក អាកឡូរ វ៉ែកគែន៖**

បាទ ខ្ញុំយល់ចំណុចនេះហើយលោកស្រី គឺថា២ខែមុនហ្នឹង គាត់បានជួបអ្នកដែលមកពីតុលាការយើងនេះ ដើម្បីជូនដំណឹងគាត់ ពីសវនាការថ្ងៃនេះហ្នឹងឯង។

**សួរដោយលោក អាកឡូរ វ៉ែកគែន៖**

**ស៖** បាទ លោក ខ្ញុំសូមអានសម្រង់ហ្នឹងបន្តទៀត។ ខ្ញុំសូមការបញ្ជាក់ពីលោក គឺថាឯកសារដែលលោកនៅនឹងដៃនេះ គឺជាឯកសារដែលមេធាវី នួន ជា ផ្តល់ឲ្យលោកអម្បាញ់មិញហ្នឹង គឺមិនមែនឯកសារផ្សេងទៀតទេ។ អ៊ីចឹងមែនទេ? ឯកសារដែលលោកមេធាវី កូប៉េ ទើបតែឲ្យលោកអម្បាញ់មិញហ្នឹងមែនទេ?

[១៥:០៧:០៩]

**លោក សំ សិទ្ធី៖**

**ឆ៖** នេះ គេគ្រាន់តែឲ្យមកខ្ញុំមើល ពិនិត្យមើលស្នាមមេដៃ ស្នាមមេដៃរបស់ខ្ញុំ និងអក្សរដែល--

**ប្រធានអង្គជំនុំ៖**

លោកមេ -- លោកសាក្សី លោកសាក្សីស្តាប់សំណួរអត់បានទេ តាមមើលទៅ? គាត់សួរអំមិញថា ឯកសារនុ៎ង គឺជាឯកសារដែលមេធាវីរបស់ នួន ជា ហ្នឹងឲ្យឬ? អត់មានសួរពីរឿងស្នាមមេដៃសួរពីអីទេ។

**លោក សំ សិទ្ធី៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចេះខ្ញុំមិនចង់បញ្ជាក់ពីរឿងអីទេ ចង់បញ្ជាក់ថា លោកត្រូវស្តាប់សំណួរឲ្យបាន ដែលគេសួរ។ អត់ពន្លើស ចម្លើយអត់មានពន្លើសទៅណាទៀតទេ គឺចម្លើយដែលគេសួរអំមិញ គឺចង់សំដៅថា តើឯកសារហ្នឹងដែលកាន់នៅក្នុងដៃរបស់លោក ជាឯកសារដែលមេធាវីប្រគល់ឲ្យតាមរយៈលោកខាងនេះ ឬយ៉ាងម៉េច?

**លោក សំ សិទ្ធី៖**

--*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១៥:០៨:០៨]

**ប្រធានអង្គជំនុំ៖**

បាទ ចម្លើយតែប៉ុណ្ណឹង វា--

**សួរដោយលោក អាកឡូ វ៉ែកគែន៖**

**ស៖** បាទ លោកសាក្សី តើឯកសារដែលលោកកំពុងតែកាន់នឹងដៃហ្នឹង គឺជាឯកសារដែលមេធាវី នួន ជា អ្នកផ្តល់ជូនឲ្យលោក ឬក៏ជាឯកសារដែលលោករក្សាទុកដោយខ្លួនឯង នៅពេលដែលអ្នកស៊ើបអង្កេតបានសម្ភាសគាត់តាំងពីយូរហើយនោះ ហើយលោកបានយកមកតាមខ្លួន នៅក្នុងថ្ងៃសវនាការនេះ។ អ៊ីចឹង ឬក៏ជាឯកសារដែលលោកមេធាវីរបស់ នួន ជា ទើបតែនឹងឲ្យហ្នឹងទេ?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ឯកសារនេះ លោកមេធាវីរបស់ នួន ជា បានឲ្យខ្ញុំព្រឹកមិញ តាមរយៈលោកប្រធានខាងនោះ។

**ស៖** បាទ សូមអរគុណ។ ហើយខ្ញុំសូមចាប់ផ្តើមឡើងវិញ ខ្ញុំអានបន្តទៀត។ ERN ហ្នឹងលេខ ERN ខ្ញុំបានផ្តល់អស់ហើយ ហើយឥឡូវខ្ញុំសូមដកស្រង់បន្ត៖ "ក្រុមខ្ញុំដែលមានគ្រួសារប្រាំពីរគ្រួសារហ្នឹង ត្រូវទៅដើរទៅទិសខាងជើងនៃកោះ -- នៃវត្តច្រកស្តេច ហើយដើរតាមកាត់ព្រៃ ហើយនិងជ្រោះអូរ ទៅដល់ព្រៃរូងខ្លា។ យើងដើរជាងមួយម៉ោង ដោយមានអ្នកឈ្លបខ្មែរក្រហមជាអ្នកនាំផ្លូវ មានពាក់ក្រមាខ្មៅ -- ពណ៌ក្រហម ហើយមានកាំបិតលីលើស្មា។ ហើយម្នាក់នុ៎ង បានប្រាប់ឲ្យយើងដាក់ទុកអីវ៉ាន់ ហើយប្រាប់ឲ្យបុរសៗ និងអ្នកដែលពេញកម្លាំងហ្នឹងចូលទៅព្រៃ ដើម្បីកាប់ឈើម៉ានុយ ដើម្បីមកធ្វើជម្រកនៅបណ្តោះអាសន្នសិន។ ហើយកុមារ ហើយនិងខ្ញុំផ្ទាល់ហ្នឹងក៏នៅទីនោះសិនទៅ។ ម្នាក់នោះបាននាំបុរសៗ និងក្រុមមួយចំនួន -- ក្រុមខ្ញុំចំនួន១២នាក់ ដែលមានឪពុកខ្ញុំផង។" ខ្ញុំឈប់ត្រឹមនេះសិន។

នៅខាងក្រោមហ្នឹងបន្តិច ពីរបីបន្ទាត់ទៀត លោកនិយាយថា មនុស្សដដែលហ្នឹង ដែលមានក្រមាបង់កពណ៌ក្រហមហ្នឹងត្រឡប់មកវិញ ដើម្បីយកស្ត្រីៗទៅទៀត ហើយរួមបញ្ចូលទាំងរូបលោកផងដែរ។ អ៊ីចឹងខ្ញុំចង់សួរលោកថា នៅពេលដែលលោកឆ្លើយហ្នឹង ថាលោកឆ្លើយថាតើមានមនុស្សតែម្នាក់ទេនាំលោកពីវត្តហ្នឹងទៅក្នុងព្រៃ។ តែអម្បាញ់មិញនេះ ក្នុងសវនាការលោកនិយាយថា មានដល់ទៅបីនាក់ឯណោះអ្នកនាំនោះ។ អ៊ីចឹងលោកអាចពន្យល់តុលាការយ៉ាងម៉េចដែរ ពីព្រោះថាខ្ញុំឃើញថាមានភាពខុសគ្នារវាងមនុស្សបីនាក់ ដែលនាំគ្រួសារទាំងប៉ុន្មានហ្នឹងពីវត្តមកចូលព្រៃ ហើយនិងតែម្នាក់ទេ

ដែលនាំនោះ លោកអាចពន្យល់យ៉ាងម៉េចដែរអំពីបញ្ហានេះ?

[១៥:១១:០៩]

**ឆ៖** បាទ ខ្ញុំសូមពន្យល់ម្តងទៀតអំពីរឿងនេះ។ ព្រឹកមិញខ្ញុំពន្យល់ម្តងហើយ ខ្ញុំថាមនុស្ស -- ឈ្លបហ្នឹងដែលមានប្រើប្រាស់តែក្រមា ហើយនិងកាំបិតហ្នឹង វាបីនាក់នាំកម្លាំងប្រាំពីរគ្រួសាររបស់ខ្ញុំនេះ ចេញពីវត្តច្រកស្តេចមកកាន់ព្រៃគុម្ពោតមួយ -- ព្រៃមួយដែលមិនទាន់ឆ្លងវាលស្រែ មិនទាន់ឆ្លងអូរទេ។ តែដល់មកដល់ហ្នឹង មកដល់ក្បាលស្រែហ្នឹង គាត់ទុកពីរនាក់ឲ្យនៅមើលប្រពន្ធកូន។ គាត់នាំតែម្នាក់ -- ដែលឈ្លបហ្នឹងទៅម្នាក់នាំបុរសៗយកទៅកាប់ឈើធ្វើជំរំ។ បាទខ្ញុំបាទបញ្ជាក់ព្រឹកមិញរួចហើយរឿងហ្នឹង។ ហើយដល់ទៅពេល -- ប៉ុណ្ណឹងសិនបាទ។

**ស៖** បាទ ឥឡូវខ្ញុំយល់ហើយ។ ឥឡូវខ្ញុំសូមបន្តទៀត ពីព្រោះខ្ញុំមិនមានពេលវេលាច្រើនទេ។ អម្បាញ់មិញនេះលោកបានពិពណ៌នាអំពីអ្វីកើតឡើងនៅពេលដែលលោកដើរតាមឪពុកលោក ហើយលោកបានពន្យល់ថា លោកបានត្រឡប់មកជួបម្តាយលោកវិញ។ អ៊ីចឹងសំណួរខ្ញុំសួរដូចតទៅនេះ ដែលលោកមកជួបម្តាយលោកវិញដើម្បីប្រាប់ពួកគាត់ អង្កាល់នោះលោកអាយុ១៤ឆ្នាំ លោកនៅក្មេងទេ ខ្ញុំគិតថាកាលនោះ គឺថាបើមើលរូបរាងលោកឥឡូវហ្នឹងប្រហែលលោកសុខភាពមាំមួនដែរ។ ហើយកាលនោះលោកដឹងហើយថា មានគ្រោះថ្នាក់ហើយ លោកឃើញថាមនុស្សប្រាំមួយនាក់នាំឪពុកលោកទៅ ហើយពួកគេសុទ្ធតែមានអាវុធ។ ហើយលោកទើបតែឮស្នូរកាំភ្លើងដែលចេញពីកន្លែងដែលគេនាំឪពុកគាត់ -- ឪពុកលោកទៅ ហើយលោកបានប្រាប់ម្តាយរបស់លោកពីរឿងហ្នឹង ហើយមិនមានទាហានអី អ្នកយាមមានអាវុធអីនៅក្បែរលោកទេ។ ហើយអម្បាញ់មិញលោកបាននិយាយថា លោកចេះខាងយោធាព្រោះឪពុកលោកជាយោធា។ អ៊ីចឹងសំណួរខ្ញុំហ្នឹងសួរលោកថា ហេតុអីបានពេលនោះ ពេលដែលលោកឮគេបាញ់កាំភ្លើងហើយ លោកមិនរត់ លោកនៅទីនោះធ្វើអ្វីទៀត?

[១៥:១៣:៤៨]

**ឆ៖** បាទសំណួរនេះដូចតែសំណួរពីព្រឹកដដែលហ្នឹង។ ខ្ញុំគ្រាន់ជម្រាបលោកថា នៅពេលដែលគេបំបែកក្រុមដែលមានកម្លាំងបុរសនេះចេញទៅ ឈ្លបម្នាក់អ្នកនាំដើរទៅ ហើយឈ្លបពីរនាក់ទៀតនៅៗមើលថែទាំ មើលការពារប្រពន្ធកូននៅឯក្រោយ។ ហើយដល់តែទៅពេលខ្ញុំទៅតាម ១ឪពុក។ ដល់ទៅតាមឪពុក គាត់ងាកក្រោយមក គាត់ដេញខ្ញុំឲ្យមកវិញ ហើយខ្ញុំអត់មក ខ្ញុំចេះតែដើរតាមគាត់។ នៅពេលដែលគេឆ្លងគាត់ -- គេនាំគាត់ឆ្លងអូរ១មួយទៅ ខ្ញុំពិនិត្យឃើញមានមនុស្សដែលប្រើប្រាស់អាវុធ

ហ្នឹងប្រាំមួយនាក់ ចេញមកភ្ជង់គាត់បណ្ដើរចូលទៅៗៗព្រៃបាត់។ បាទ ហើយខ្ញុំៗគិតថាឪពុកខ្ញុំនេះត្រូវគេយកទៅសម្លាប់ហើយ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកសាក្សីសំណួរសួរថាហេតុអ្វីបានជាលោកមិនរត់គេច? ហេតុអ្វីបានលោកនៅដដែលមិនរត់ទៅកន្លែងណាផ្សេង ក្រោយពេលដែលលោកបានឮសូរសំឡេងកាំភ្លើងបាញ់ហ្នឹង? សូមលោកឆ្លើយទៅលើចំណុចនេះ។

**លោក សំ សិទ្ធី៖**

**ឆ៖** ដូចខ្ញុំបានជម្រាបហើយថា ខ្ញុំពិនិត្យមើលឃើញសកម្មភាពដែលគេភ្ជង់ឪពុកខ្ញុំយកចូលព្រៃទៅបាត់ហើយហ្នឹង ខ្ញុំរត់មកវិញ។ ខ្ញុំរត់មកវិញ ខ្ញុំមកនាំម៉ែ ម្ដាយ នាំម្ដាយ នាំបងប្អូនអីរត់ចេញ តែនៅឈ្លបពីរនាក់នៅហ្នឹង គាត់ថា អត់ទេៗ គេនាំប៉ាទៅកាប់ឈើជំរំទេ ហើយខ្ញុំៗថា អត់ទេ គេយកទៅសម្លាប់ហើយ។ ដល់តែមួយសន្ទុះក្រោយមក ថាមួយម៉ោងហ្នឹងហើយ គាត់បណ្ដើរទៅផុតព្រៃ ទៅកណ្ដាលព្រៃ ហើយឮអាវុធផ្ទុះ។ ឮអាវុធផ្ទុះ ខ្ញុំកញ្ជ្រោលឡើងម្ដងទៀត ខ្ញុំស្រែកយំកញ្ជ្រោលឡើងម្ដងទៀត ខ្ញុំរត់ចោលហ្វូងម្ដាយ ម្ដាយមីង ម្ដាយបង្កើតដែលនៅមួយជ្រុំហ្នឹង ខ្ញុំរត់ចោលគាត់ទៅ គាត់ដេញចាប់ខ្ញុំប្រវាស់ប្រទើសយកមកខ្ញុំ។ មកៗរង់ចាំនៅកន្លែងដដែលវិញ។

[១៥:១៦:១៥]

**សួរដោយលោក អាកទូរ វែកកែន៖**

**ស៖** អម្បាញ់មិញនេះ លោកបានឆ្លើយថា អ្នកយាមដែលយាមម្ដាយរបស់លោកហ្នឹង គេមានអាវុធកាន់។ អ៊ីចឹងខ្ញុំសួរថា តើគេកាន់អា.កា ឬក៏អីកាំភ្លើងគេហ្នឹង?

**ឆ៖** អាពីរនាក់ហ្នឹងកងឈ្លបទេ បីនាក់ហ្នឹងកងឈ្លបទេ នាំបុរសទៅមួយ ម្នាក់។ ប្រាំពីរនាក់ហ្នឹង កងឈ្លបនាំទៅម្នាក់។ នៅអាកងឈ្លបពីរនៅៗគ្រប់គ្រងប្រពន្ធនៅនេះ ហើយអត់មានកាំភ្លើងទេ មានតែកាំបិតទេ។

**ស៖** នៅពេលដែលម្ដាយរបស់លោក តាមចាប់លោកមកវិញ ពេលដែលលោករត់ចេញពីហ្វូងមនុស្សហ្នឹង ខ្ញុំមិនបានឮព័ត៌មានលម្អិតនោះទេពីមុនមក។ តើនៅពេលហ្នឹងហើយឬ ដែលម្ដាយរបស់លោកប្រាប់លោកថា កុំភ័យអី គេបាញ់សត្វទេនៅក្នុងព្រៃនោះ?

**ឆ៖** បាទ ដោយសារខ្ញុំកញ្ជ្រោល។ ខ្ញុំថា គេយក -- ជឿអត់ៗ គេយកប៉ាទៅសម្លាប់ហើយ គេ

យកប៉ាទៅបាញ់ចោលហើយ។ ខ្ញុំឲ្យរត់ ម៉េចក៏មិនរត់ ហើយគាត់ៗ ឱបខ្ញុំជាប់ ហើយគាត់ថា អត់ទេ គេបាញ់សត្វទេកូន អត់ទេ។ ហើយដល់តែពេលៗ ផ្ទុះអាវុធហ្នឹង ខ្ញុំស្រែកអ៊ីចឹង។ ដល់អ៊ីចឹងគាត់ចាប់ខ្ញុំជាប់ ស្រីៗ មីងផង ម៉ែផងហ្នឹង ពីរបីនាក់ហ្នឹងចាប់ខ្ញុំជាប់ ព្រោះខ្ញុំរត់ម្ដងទៅហើយ គេដេញចាប់យកបានមកវិញ។ ខ្ញុំរត់ចោលគាត់ម្ដងហើយ ដោយសារគាត់មិនស្ដាប់ខ្ញុំ នៅពេលដែលខ្ញុំបញ្ចេះឲ្យគាត់រត់នេះ។

**ស៖** បាទ ខ្ញុំអរគុណ។ អ៊ីចឹងគឺថាលោកលួចរត់ ចង់រត់ពីរដង ហើយគេចាប់លោកពីរដងវិញ។ តើនៅសម័យនោះៗ នៅកន្លែងដែលលោកជួបជុំគ្នាហ្នឹង គេបរបាញ់សត្វដោយប្រើកាំភ្លើងហ្នឹងញឹកញាប់ទេនៅកន្លែងហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបឡើងវិញដែរថា នេះជាការភូតរបស់ម្ដាយ កុំឲ្យកូនភ័យ។ ថាគេបាញ់ហ្នឹងបាញ់សត្វទេ ឮសូរកាំភ្លើងផ្ទុះប្រាវៗហ្នឹង គេបាញ់សត្វទេ។ គាត់មិនចង់ឲ្យខ្ញុំរត់ចេញពីគាត់ គាត់ថា គេបាញ់សត្វទេកូន។ ហើយដល់អ៊ីចឹង គាត់ចាប់ខ្ញុំឲ្យនៅជាមួយនឹងគាត់តែម្ដង គាត់ឲ្យខ្ញុំទៅណា។ រហូតដល់គេបណ្ដើរយកទៅចូលព្រៃហើយ គេភ្ជង់បណ្ដើរទៅរបៀបដូចឪពុកខ្ញុំនេះ បានគាត់ភ្ញាក់ខ្លួន គាត់ថា កូននិយាយមិនខុស គាត់មកឱបខ្ញុំ យំឈ្ងូពេលនុំងតែម្ដង ទាំងអស់គ្នា។

[១៥:១៩:៣៦]

**ស៖** តើរណ្ដៅគ្រាប់បែកនោះ ដែលគេឲ្យលោកអង្គុយនៅក្បែរហ្នឹងមានទំហំប៉ុនណាដែរ?

**ឆ៖** បាទ ធំដែរ។ ដូចលោកសាក្សីខាង នួន ជា បានសួរពីព្រឹកមិញហ្នឹង ខ្ញុំថាមាត់រណ្ដៅហ្នឹងវាចូលក្នុងខ្នង់៨ទៅ៩ម៉ែត្រហើយ ហើយជម្រៅវាចូលទៅក្នុង ទៅក្រោមប្រហែលជា៣ម៉ែត្រ ទៅក្រោម។

**ស៖** នៅពេលដែលលោកចេញពីរណ្ដៅហ្នឹង ២ម៉ោងក្រោយមកហ្នឹង តើកាលហ្នឹងលោកចេញមកហ្នឹងស្រាតនទល គេមានសម្រាតខោអាវលោកទេ? ព្រោះធម្មតាពេលដែលគេសម្លាប់ហើយអ៊ីចឹងគេដោះយកខោអាវ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ដែលខ្ញុំឃើញនឹងភ្នែក គឺសូម្បីតែសំពត់ សារុង ហៅថាសារុងចុះ។ សារុងដែលស្លៀកជាប់នឹងខ្លួននេះ ដែលបាញ់ស្លាប់ហើយ ហើយប្រលាក់ទៅដោយឈាម ក៏គាត់សម្រាតយកដែរ។ តែនៅពេលដែលពួកខ្ញុំបួននាក់នេះ មិនដឹងជាយ៉ាងម៉េច ចន្លោះពេលហ្នឹង ហើយក៏ខោហ្នឹងវាតូចតាចពេកវាអត់យក វាយកតែសារុង យកតែខោអាវមនុស្សចាស់ យកទៅធ្វើប្រពន្ធកូនគាត់ ប្រពន្ធគាត់ក៏មិនដឹង។

គឺគាត់សម្រាតយកទាំងអស់។ បាទ ហើយដល់ពួកខ្ញុំនេះ នៅជាប់ខោអាវនៅនឹងខ្លួន។

**ស៖** នៅពេលដែលលោកចង់ពន្យល់ កាលពីព្រឹកមិញ លោកនិយាយថា ពួកកងកម្លាំងប្រដាប់អាវុធហ្នឹងគេធ្វើការមិនស្អាត លោកថា គេប្រញាប់នោះ ដោយសារមេឃជិតភ្លៀងហើយកាលនោះ។ ហើយនៅពេលដែលលោកពិពណ៌នា ពេលដែលលោកចេញពីរណ្ដៅនោះ លោកពិពណ៌នាថា កាលនោះមេឃជិតភ្លៀង។ អ៊ីចឹងខ្ញុំសួរលោកថា តើក្រោយមកហ្នឹង មេឃភ្លៀងដែរឬទេ?

**ឆ៖** បាទ ពេលនុំងវាជិតយប់ផង ហើយមេឃងងឹតរកភ្លៀងផង។ អ៊ីចឹងហើយបានខ្ញុំថា គេធ្វើការមិនស្អាតហ្នឹង គេប្រញាប់ទៅយកជយភ័ណ្ឌយកទៅផ្ទះចែកប្រពន្ធកូនគេ។ អ៊ីចឹងហើយបានខ្ញុំរើខ្លួនបាន រយៈពេល២ម៉ោង បានខ្ញុំរើខ្លួនបានចេញពីរណ្ដៅ ដោយសារមិនហ៊ានចេញភ្លាម ខ្លាចលោគេនៅសម្ងំចាំមើលយើងត្រង់ណានោះ។

[១៥:២៣:១៤]

**ស៖** នៅដំណាក់កាលទី១ នៅពេលដែលគេយកតែបុរសៗទៅ ទៅក្នុងព្រៃ កាលនោះគេយកបុរសនោះប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ បើនិយាយទៅថា បុរសដែលជាមេគ្រួសារវាប្រាំពីរនាក់ទៅហើយ ហើយនៅកូនកំលោះ កូនកំលោះៗហ្នឹងម្នាក់ស្មើនឹងមួយ ម្នាក់ស្មើនឹងកូនកំលោះពីរនាក់។ ក្នុងមួយគ្រួសារកូនកំលោះៗ ដែលពេញកម្លាំងហ្នឹង ប្រហែលជាមួយគ្រួសារពីរនាក់ ឬម្នាក់ទៅជាមួយផងដែរ។

**ស៖** បើអ៊ីចឹងសរុបទាំងអស់ទៅមានប៉ុន្មាននាក់ដែរ បុរសៗដែលគេនាំទៅលើកទី១ ហ្នឹង?

**ឆ៖** ខ្ញុំអត់បានរាប់ទេ ឲ្យប្រាកដទេ។ ខ្ញុំគ្រាន់តែគិតថា ឪពុកមាខ្ញុំមានកូនកំលោះមួយ។ អ៊ុំខ្ញុំមានកូនកំលោះមួយ ហើយលោកគ្រូពេទ្យនុំងមានកូនកំលោះពីរនាក់។ អ៊ីចឹងគេយកអាកម្លាំង បើនិយាយជារួមគេយកអាកម្លាំង អាមនុស្សដែលមានកម្លាំងខ្លាំងក្លានេះ យកទៅសម្លាប់មុន គេទុកនារីភេទដែលទន់ខ្សោយនេះយកទៅពេលក្រោយ។ ហើយអាក្មេងតូចៗដូចខ្ញុំនេះ គេទុកយកទៅសម្លាប់ពេលក្រោយ។ គេយកអាមនុស្សខ្លាំងទៅសម្លាប់មុន។

**ស៖** លោកបាននិយាយកាលពីព្រឹកមិញ លោកនិយាយថា លោកប្រុងប្រយ័ត្នណាស់មុននឹងចេញពីរណ្ដៅហ្នឹង លោកយកដុំថ្មគប់ទៅព្រៃគុម្ពោតក្បែរហ្នឹង ចង់ដឹងថាតើមានមនុស្សនៅទីហ្នឹង ឬក៏អត់ ដើម្បីផ្ទៀងផ្ទាត់ឲ្យដឹងថា មានគេចាំឃ្លាំមើលនៅក្បែរនោះឬក៏អត់មានទេ។ អ៊ីចឹងពេលនុំង លោកហើយនិងបងប្អូនជីដូនមួយលោក ប្អូនស្រីរបស់លោកហ្នឹងក៏ត្រឡប់ទៅវត្តវិញ។ អ្វីដែលខ្ញុំឆ្ងល់នោះគឺថា

លោកនិយាយ ពេលដែលលោកនិយាយអំពីការត្រឡប់ទៅវត្តវិញហ្នឹង លោកនិយាយថា កម្មាភិបាលខ្មែរក្រហមនោះគេកំពុងតែតាមរកអ្នកទាំងបួននាក់ហ្នឹង អ្នកបួននាក់ដែលនៅរស់រានមានជីវិតហ្នឹង។ អ៊ីចឹងខ្ញុំចង់សួរលោកថា ហេតុអីបានគេដឹងថាក្មេងទាំងបួននាក់ហ្នឹងនៅរស់? ហើយសួរថា ហេតុអីក៏លោកត្រឡប់ទៅវត្តហ្នឹងវិញ? ពីព្រោះដឹងថាកន្លែងហ្នឹងជាកន្លែងគ្រោះថ្នាក់ទៅហើយ ម៉េចក៏ទៅរកឲ្យគេចាប់នៅកន្លែងហ្នឹងទៅវិញ?

[១៥:២៦:០៧]

**ឆ៖** បាទ មិនមែនទៅសំដៅឲ្យគេចាប់ទេ។ ដែលចូលទៅហ្នឹងគឺសំដៅទៅរកមិត្តភក្តិដែលនៅសល់នៅទីនោះ បងប្អូនមីងមាដែលរស់ ដែលនៅសល់នៅទីនោះ ហើយសុំបាយគេហូប។ ហើយក្រោយពេលដែលសុំបាយគេហូប គេមិនសួរ។ គេមិនសួរថា ប៉ាម៉ាក់អ្នែងទៅណា? ហើយខ្ញុំមិនលបខ្សឹបប្រាប់គេថា ប៉ាម៉ាក់ខ្ញុំគេយកទៅបាញ់ចោលអស់ហើយ។ ហើយនៅពេលនោះ វាឮពីក្អែកមួយក្អែកដប់ហើយហ្នឹង។ ឮពីម្នាក់ឆ្លើយទៅម្នាក់ ម្នាក់សួរម្នាក់ វាផ្អើលពេញវត្តហ្នឹងទៅ ហើយខ្ញុំក៏ដឹកដៃប្អូនហ្នឹងរត់ ដើរក្រឡឹងជុំវិញវត្តហ្នឹង គេចខ្លួន។ ហើយក្រោយពេលច្របូកច្របល់ខ្លាំង គេស្រែកមីក្រូថា "សូមបងប្អូនកុំជឿឃោសនារបស់ សេ.អ៊ី.អា របស់អាមេរិកាំង ខ្ញុំ -- កងទ័ពយើងកំពុងតែតាមចាប់ពួក សេ.អ៊ី.អា ទាំងបួននាក់នេះហើយ"។ គេស្រែកមីក្រូអ៊ីចឹង ដល់អ៊ីចឹងវាច្របល់តែម្តង។ ដល់ច្របល់មួយថា អ្នែ អត់ទៅតាមទេ។

**សៈ** បាទ ខ្ញុំសុំកាត់ផ្តាច់លោក។ សូមអភ័យទោសលោកសាក្សី ខ្ញុំមានពេលវេលាខ្លី។ កាលពីព្រឹកមិញ ខ្ញុំបានកត់សម្គាល់ថា នៅពេលដែលលោកទៅដល់នោះ គេនោះដឹងជាមុនអស់ទៅហើយ។ អ៊ីចឹងយើងនឹងផ្ទៀងផ្ទាត់ប្រតិចារឹក។ លោកនិយាយថា ពេលដែលលោកទៅដល់ហ្នឹង អ្នកដែលនៅទីនោះ គេដឹងថាលោកនៅរស់ទៅហើយ។ អ៊ីចឹងខ្ញុំនឹងផ្ទៀងផ្ទាត់ប្រតិចារឹកឡើងវិញ។ ខ្ញុំបានផ្ទៀងផ្ទាត់នៅក្នុងសំណុំរឿងតាមរយៈព័ត៌មានវិទ្យា ខ្ញុំឃើញថា មិនដែលមានអ្នកណានិយាយអំពីវត្តច្រកស្តេចហ្នឹងទេ នៅក្នុងឃុំពាមហ្នឹងទេ។ ពិពណ៌នាអំពីព្រឹត្តិការណ៍ដែលលោកបានរៀបរាប់នៅក្នុងសវនាការទេ។ លោកនិយាយថា នៅទីនោះមានមនុស្សរាប់ពាន់នាក់ មានបងប្អូនលោកដែលលោកត្រឡប់ទៅវត្តហ្នឹងវិញហ្នឹង ដើម្បីជួបបងប្អូនញុំងឯង ប្រថុយប្រថាន។ លោកអាចផ្តល់ឈ្មោះអ្នកដែលនៅរស់រានមានជីវិតដែរទេ ដែលនៅវត្តហ្នឹង? ឬក៏ព័ត៌មានណាមួយដែលអាចឲ្យយើងកំណត់អត្តសញ្ញាណអ្នកដែលជួបជុំគ្នានៅក្នុងបរិវេណវត្តច្រកស្តេចហ្នឹង ដើម្បីឲ្យយើងរកការពិតឃើញ? លោកអាចផ្តល់

អត្តសញ្ញាណរបស់មនុស្សមួយចំនួនបានទេ ដែលគេកាលនោះ គាត់នៅក្នុងវត្តហ្នឹងដែរ?

[១៥:២៨:៥០]

**ឆ៖** បាទ ខ្ញុំអាចផ្តល់បាន ប៉ុន្តែរឿងគេឡើងមកគេមិនឡើង ខ្ញុំអត់ដឹងទេ តែបើលោកចុះទៅជួបគេ ប្រហែលជាគេបំភ្លឺឱ្យ។ អ៊ីចឹង នៅសល់ច្រើនគ្នាដែរ ដែលជាសាច់សន្តានរបស់ឪពុកម្តាយខ្ញុំ ក្រោយពេលគាត់ឃើញខ្ញុំ ជួបខ្ញុំហើយ គាត់សួរខ្ញុំហើយ ខ្ញុំរ៉ាយរ៉ាប់ប្រាប់គាត់--

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកបញ្ជាក់ឱ្យគ្រាន់តែច្បាស់។ គាត់ចង់សួរថាអ្នកណាខ្លះនៅរស់ ហើយអ្នកហ្នឹងនៅឯណា ឈ្មោះអីៗ? លោកទៅរៀបរាប់ឯណាផ្សេងទៅវិញ។ អានេះហើយដែលនាំឱ្យពេលវេលាខាតកាន់តែយូរទៅៗ។ បញ្ជាក់ឱ្យបានច្បាស់ណ៎ា ឥឡូវនៅសល់អ្នកណាខ្លះ?

**លោក សំ សិទ្ធី៖**

**ឆ៖** ហ្នឹងយកតែសាច់សន្តានទេ។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ លោកអាចផ្តល់ឈ្មោះជូនតុលាការបានទេ?

**ឆ៖** ក្នុងឥឡូវនេះ ផ្តល់អត់បានទេ ព្រោះថាមិនដឹងឈ្មោះគេពិតប្រាកដឈ្មោះអី។

**ស៖** បាទ ខ្ញុំសូមអរគុណបាទ។ សំណួរចុងក្រោយ បងប្អូនជីដូនមួយរបស់លោក បងប្អូនជីដូនមួយស្រី បងប្អូនជីដូនមួយប្រុស ហើយនិងប្អូនស្រីរបស់លោកដែលរស់រានមានជីវិតនោះ តើ -- ខ្ញុំសួរថាតើក្នុងចំណោមអ្នកទាំងបីនាក់ហ្នឹង អ្នកណាដែលស្លាប់ដោយជំងឺតេតាណូសនោះ?

[១៥:៣០:៣៥]

**ឆ៖** --របស់ខ្ញុំ។ គាត់ជាប្អូនបង្កើតរបស់ខ្ញុំដែលៗ ប៉ុល ពត វាយៗបែកក្បាលហ្នឹង។

**ស៖** កាលអម្បាញ់មិញនេះ លោកនិយាយ -- ពីអម្បាញ់មិញនេះលោកនិយាយថា គាត់ស្លាប់ហ្នឹងដោយសារសម្លាប់ខ្លួនឯង។ អ៊ីចឹងខ្ញុំដូចមិនយល់ដែរ គាត់ស្លាប់ជំងឺតេតាណូស ឬក៏ងាប់ដោយសម្លាប់ខ្លួនឯង?

**ឆ៖** លោក--

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សាក្សីសូមឆ្លើយសំណួរនេះ។ ប៉ុន្តែគាត់សាកឆ្លើយអំពីប្អូនស្រីរបស់គាត់ដែលនៅរស់រានមាន

ជីវិតពីការសម្លាប់រង្គាល មុនពេលឈប់សម្រាកនោះ។

**លោក អាកទូរ វែកគែន៖**

បាទ លោកស្រីចៅក្រម តាមពិតខ្ញុំអត់បានស្ដាប់ឮតាមរយៈការបកប្រែមកជាភាសាបារាំងទេត្រង់ចម្លើយគាត់ហ្នឹង។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡូត៖**

ខ្ញុំគិត តាមការយល់ឃើញរបស់យើង គឺសាក្សីនិយាយអំពីមូលហេតុនៃការស្លាប់របស់ប្អូនស្រីរបស់គាត់ ហើយគាត់បង្ហាញអំពីមូលហេតុនៃការស្លាប់។

**លោក អាកទូរ វែកគែន៖**

បាទ ការពិតហើយ ក៏ប៉ុន្តែគ្រាន់តែថាព្រឹកមិញហ្នឹងគាត់និយាយថាស្លាប់ដោយជំងឺតេតាណូសមិនមែនស្លាប់ដោយធ្វើអត្តឃាតខ្លួនឯងទេ។

[១៥:៣១:៥៩]

**ប្រធានអង្គជំនុំ៖**

អ៊ីចេះខ្ញុំព្រឹកមិញហ្នឹង លោកមេធាវីខ្ញុំស្ដាប់បានច្បាស់ណាស់ព្រឹកមិញហ្នឹង ហើយអ៊ីចឹងដើម្បីបញ្ជាក់ឡើងវិញហ្នឹង គឺសូមលោកសាក្សីបញ្ជាក់ហ្នឹងឡើងវិញ ឱ្យបានខ្លី ហើយច្បាស់មកបានហើយ។

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ គោរពឯកឧត្ដម។ ខ្ញុំបានបំភ្លឺព្រឹកមិញហើយ ឥឡូវខ្ញុំសូមបញ្ជាក់សាថ្មីតាមសំណួមពរ។ ខ្ញុំបានបញ្ជាក់ថា ប្អូនស្រីខ្ញុំហ្នឹង និងដែល១១ត្រូវគេវាយនោះ គេវាយត្រូវនឹងដំបងបែកក្បាលមួយចំហៀងនេះ ព្យាបាលវាអត់ជា រហូតទៅដល់កើតរោគសរសៃប្រសាទ។ បាទរហូតដល់ដែលថ្នាក់ដល់គាត់មានកំហឹងក្នុងចិត្តពីរឿងអ្វីមួយ ដែលទប់មិនបាននោះរហូតដល់ទៅចងកសម្លាប់ខ្លួនដោយខ្លួនឯង ដោយសារអាការៈ ហៅថាសរសៃប្រសាទនេះឯង ដែលសល់ពីការវាយនឹងដំបង មិនមានលទ្ធភាពព្យាបាល។

**លោក អាកទូរ វែកគែន៖**

បាទ លោកប្រធានខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងជាបន្តនេះ គឺសូមចូលដល់ការតាំងសំណួររបស់ចៅក្រម។ អ៊ីចឹងលោកចៅក្រម សោម

សិរិវឌ្ឍ។ សូមអញ្ជើញ!

[១៥:៣៣:៤១]

**សួរដោយចៅក្រម សោម សិរិវឌ្ឍ៖**

**ស៖** ខ្ញុំមានសំណួរដើម្បីសួរបញ្ជាក់លោកសាក្សី គឺថាសំណួរខ្ញុំនេះ គឺថាជុំវិញបញ្ហាដែលមានការបាញ់សម្លាប់ទៅលើប្រជាជនដែលបណ្តាលឲ្យស្លាប់យ៉ាងច្រើន។ ថាតាមចំនួនដែលខ្ញុំពិចារណាហើយនិងគិតតាមការលើកឡើងរបស់លោក គឺថាមានការស្លាប់ចំនួន២៦នាក់។ កន្លងមកពីព្រឹកមិញមកដល់ពេលនេះ គឺថាលោកសាក្សីបានទទួលស្គាល់ចម្លើយរបស់លោកដែលឆ្លើយនៅក្នុងកំណត់ហេតុយកចម្លើយរបស់អ្នកស៊ើបអង្កេតនៃអ.វ.ត.ក របស់យើងរួចហើយ។ ហើយនៅពេលសវនាការកន្លងមកនេះក៏លោកបានលើកឡើងដែរ ថាក្រុមរបស់លោក ខ្ញុំនិយាយថាក្រុមរបស់លោកដែលនេះទេណ៎ា គឺថាមានទាំងអស់គ្នា៣០នាក់ ក្នុងប្រាំពីរគ្រួសាររបស់លោក។ នេះដោយផ្អែកទៅលើកំណត់ហេតុដែលលោកបានទទួលស្គាល់។ ហើយកម្លាំងប្រដាប់អាវុធ ដែលគេមានកាន់កាំភ្លើង អា.កា ចំនួនប្រាំមួយដើម ហើយប្រាំមួយនាក់ ហើយគឺថាបានបាញ់ ពេលដែលថានេះហ្នឹង គឺថាគេឲ្យក្រុមលោកអង្គុយ អ៊ីចឹងអ្នេស៎! បាទ អង្គុយលើដី ហើយបាញ់ស្រោច បាញ់ទៅលើតែម្តង។ បញ្ហានេះ ខ្ញុំចង់សួរលោកថា តើសភាពនៃការឈរបាញ់របស់ក្រុមគេហ្នឹងយ៉ាងម៉េច? លោកមានចាំបានទេ?

[១៥:៣៥:១៩]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ខ្ញុំទទួលសំណូមពររបស់លោកៗចៅក្រមថា ខ្ញុំបានបញ្ជាក់អស់ហើយថា គេឲ្យយើងអង្គុយជារង់ ហើយគេឈរបាញ់ផ្ទាច់ទៅតែម្តង។

**ស៖** អង្គុយៗយ៉ាងម៉េច?

**ឆ៖** បាទ?

**ស៖** គេព័ទ្ធក្រុមលោកជុំវិញហ្នឹងតែម្តង ឬយ៉ាងម៉េច?

**ឆ៖** ព័ទ្ធជុំវិញ គេលាតទៅទីឆ្ងាយ ហើយគេឲ្យយើងអង្គុយកណ្តាលអ៊ីចឹង គេទៅនៅឲ្យឆ្ងាយតាមកៀនជញ្ជាំងអ៊ីចឹងទៅ ហើយគេបាញ់ផ្ទាច់មកសំដៅយើងដែលកំពុងតែអង្គុយនេះ។

**ស៖** បាទ ហើយក្រុមលោកអត់មានអ្នកណារត់ៗគេចចេញពីពេលបាញ់ហ្នឹងទេ ក៏យ៉ាងម៉េច? ពេលដែលគេបាញ់ស្រោចមកលើយើង បាញ់ទៅលើយើងហើយមានរត់ចេញទេ មាននាំគ្នារត់ចេញទេ

ឬក៏អង្គុយស្ងៀមឲ្យគេបាញ់តទៅទៀត?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

អត់ទាន់មានភ្លើងទេ ដូច្នេះមិនអាចនេះបានទេលោក។

**លោក សំ សិទ្ធី៖**

**ឆ៖** ពេលគេធ្វើសកម្មភាពបាញ់ហ្នឹង គឺអត់មាននរណាប៉ានរត់ចេញទេ ព្រោះថានៅនុំងវាមានកូនៗ មានចៅមូលគ្នាទាំងអស់ហ្នឹងហើយ ម្ដាយហ្នឹងក៏វាដាច់ចិត្តរត់ចោលកូន អាកូនក៏មិនដាច់ចិត្តរត់ចោលម្ដាយដែរ សុខចិត្តទៅស្លាប់ទាំងអស់គ្នាហ្នឹងហើយ។

[១៥:៣៦:៣៦]

**សួរដោយចៅក្រម សោម សិរីវឌ្ឍ៖**

**ស៖** ចុះរបៀបនៃការបាញ់ គេបាញ់ស្រោចតែម្ដង ក៏របៀបម៉េច? លោកៗអាចលើកបានទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកអត់ទាន់បានមានសំឡេងនៅឡើយទេ នៅ--

**លោក សំ សិទ្ធី៖**

**ឆ៖** នៅពេលដែលគេរៀបចំឲ្យយើងអង្គុយ គេចង្អុលកន្លែងឲ្យយើងអង្គុយហើយ ចង្អុលឲ្យយើងអង្គុយម្ដុំហ្នឹងហើយ គេនាំគ្នាគេដែលមានកាំភ្លើងហ្នឹងគេចេញព័ទ្ធយើងជុំវិញ។ ហើយគេបាញ់ស្រោចទៅលើរង្វង់ដែលយើងកំពុងតែអង្គុយហ្នឹង។

**សួរដោយចៅក្រម សោម សិរីវឌ្ឍ៖**

**ស៖** នៅពេលដែលគេបាញ់ហ្នឹង ប្រជាជនទាំងអស់ទាំងរូបលោកនៅតែសម្ងំនៅក្នុងហ្នឹងឲ្យគេបាញ់រហូតដល់គេចប់ក៏យ៉ាងម៉េច?

**ឆ៖** បាទ ជម្រាបប្រសាសន៍ដែរថា នៅពេលដែលគេឲ្យយើងអង្គុយហ្នឹងហើយ អត់មាននរណារត់ចេញម្នាក់ទេ គឺអង្គុយឲ្យគេបាញ់ទាល់តែស្លាត់នៅហ្នឹងតែម្ដង។ សូម្បីតែកូនក្មេងតូចដែលខ្ញុំបញ្ជាក់ពីព្រឹក សូម្បីតែកូនក្មេងតូចជៀវរាវនៅហ្នឹងគេឈរបាញ់ហើយ។ គេបាញ់សម្លាប់មនុស្សចាស់ៗហ្នឹងឲ្យអស់ហើយ នៅកូនក្មេងតូចតាចដែលយំជៀវរាវ ដែលលូនកាត់ខ្មោចរកម្ដាយរកអីហ្នឹង គឺគេកាន់

ដំបងទៅដល់ឃ្លួរជើងឡើង រ៉ៃផ្ទូសបោះៗ ចោលនៅក្នុងគំនរហ្នឹងតែម្តង។

**ស៖** សំណួរខ្ញុំមួយទៀតថា លោកៗជឿជាក់ទេថាអ្នកទាំងអស់ហ្នឹងសុទ្ធតែស្លាប់ដោយសារការបាញ់ហ្នឹង?

[១៥:៣៨:៤០]

**ឆ៖** បាទ ខ្ញុំជឿជាក់។ ដោយសារអី ដោយសារក្រោយពីការបាញ់សម្លាប់ហើយ គឺខ្ញុំនៅជំអក់ស្លួរស្រាវជ្រាវរកអ្នករស់ អ្នកណាខ្លះនៅរស់ ឲ្យចេញមកជួបខ្ញុំដើម្បីនាំគ្នារត់គេចចេញរណ្ដៅទៅវត្តនោះវិញ វត្តច្រកស្ដេចនោះវិញ។

**ស៖** អ៊ីចឹងលោកជឿជាក់យ៉ាងរឹងមាំថា អ្នកទាំងអស់នោះត្រូវតែស្លាប់តែម្ដងណ៎ា បាទ។ ខ្ញុំអស់សំណួរ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីចៅក្រម មីឡាត។ បាទ សូមអញ្ជើញ!

**សួរបន្តដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

**ស៖** ទាក់ទងទៅនឹងសំណួរនេះ តើលោកអាចជម្រាបអង្គជំនុំជម្រះថា តើអ្នកដែលបាញ់ គេបាញ់ចម្ងាយប៉ុន្មានពីជនរងគ្រោះ? តើកងទ័ពដែលគេកាន់អាវុធហើយបាញ់ជនរងគ្រោះហ្នឹងមានចម្ងាយប៉ុន្មាន?

**លោក សំ សិទ្ធី៖**

**ឆ៖** បើយើងគិតទៅតាមរង្វង់មូលដែលគេឲ្យយើងទៅអង្គុយម៉ុំហ្នឹង ហើយគេនឹងថយចេញចម្ងាយពីរង្វង់មនុស្សដែលកំពុងតែអង្គុយហ្នឹង បើតាមការស្មានរបស់ខ្ញុំ ប្រហែលជា៨ម៉ែត្រ ចេញពីរង្វង់មនុស្ស។ ហើយបាញ់ចុចមកសំដៅរង្វង់មនុស្សហ្នឹងតែម្តង។

[១៥:៤០:២៨]

**ស៖** ៨ៗម៉ែត្រ អ៊ីចឹងអ្ហ៎? អ៊ីចឹងមើលទៅ ដូចជាចម្ងាយនោះ ពីម៉ាស៊ីនត្រជាក់ លោកបែរមើលនោះ ពីម៉ាស៊ីនត្រជាក់នៅខាងជញ្ជាំងខាងស្ដាំនេះមកលោក។ ចម្ងាយប្រហែលប៉ុណ្ណឹងទេ?

**ឆ៖** ខ្ញុំគិតថា ម៉ាស៊ីនត្រជាក់នេះ មិនមែនត្រឹម៨ម៉ែត្រទេ វាចូល១០ម៉ែត្រជាងហើយ បាទ។ បើថាគិតតាំងពី--

**ស៖** ខ្ញុំៗសួរលោក ខ្ញុំសួរលោកទេ។ សួរថា តើជនប្រាប់អាវុធនេះ នៅចម្ងាយប៉ុន្មានម៉ែត្រពី

ជនរងគ្រោះ? ដើម្បីឲ្យលោករៀបរាប់អំពីចម្ងាយនេះ ឲ្យបានសុក្រឹតបន្តិច។ ឥឡូវចាត់ទុកថា កៅអីដែលលោកអង្គុយនេះ គឺជាកន្លែងជនរងគ្រោះអង្គុយ ហើយចង្អុលមើល ទៅចម្ងាយជនប្រដាប់អាវុធហ្នឹង ចម្ងាយប្រហែលប៉ុន្មាន?

**ឆ៖** ចាក្នុងរង្វង់ខ្ញុំអង្គុយនេះថា ក្នុងរង្វង់កណ្តាល ក្នុងចង្កោមមនុស្សទៅចុះ ហើយមនុស្សដែលៗបាញ់សម្លាប់ មនុស្សដែលមានអាវុធ ហើយបាញ់មកសំដៅហ្នឹងគឺ--

**ស៖** ត្រឹមត្រូវហើយ។

**ឆ៖** គឺគិតថា ពីខ្ញុំនេះទៅ វាហៀរហួរទៅដល់នោះ ព្រោះខ្ញុំនៅកណ្តាល ហើយវាមនុស្សអ្នកដែលបាញ់ហ្នឹង បាញ់ពីចុងតុនោះមក បាទ។ បាញ់ពីចុងតុនោះមក មកៗផ្តុច គេ -- យើងដាក់មួយរង្វង់ហើយគេវាយគ្នាគេមួយរង្វង់ ហើយបាញ់ផ្តុចមកលើយើង។ អ៊ីចឹងខ្ញុំថា អត់ឆ្ងាយទេ បើៗបើគំនរមនុស្សខ្ញុំនៅកណ្តាល គំនរមនុស្សដល់នោះហើយនោះ។ ហើយបាញ់ពីចុងខ្ពស់នោះមកនោះ ចុងតុរបស់លោកៗចៅក្រម។ បាញ់ពីនុ៎ងមកហើយ សំដៅមករង្វង់នេះហើយ។ អ៊ីចឹងវាស្មើនឹងប្រាំមួយ -- ប្រាំពីរប្រាំបីម៉ែត្រហ្នឹងហើយ។

**ស៖** សូមអរគុណ។ តើកន្លែងគេបាញ់ហ្នឹង គេបាញ់ចេញពីចំហៀងខ្លួនលោក ឬក៏ចេញពីខាងមុខលោក ឬក៏ចេញពីខាងក្រោយខ្នងលោក លោកនៅកណ្តាល?

[១៥:៤២:៤២]

**ឆ៖** បាទ ខ្ញុំនៅកណ្តាលហ្នឹង វាទទួលរងគ្រាប់ច្រើនហើយ ទទួលកាណុងច្រើនហើយ។ ម្តាយខ្ញុំអង្គុយបែរមុខទៅឯនុ៎ង ឧទាហរណ៍។ ហើយខ្ញុំអង្គុយពីក្រោយម្តាយខ្ញុំអ៊ីចឹង។ ហើយដល់គេបាញ់មកត្រូវម្តាយខ្ញុំ អ្នកដែលឈរនៅនុ៎ង បាញ់ពីនុ៎ងមកត្រូវម្តាយខ្ញុំ ត្រូវគល់ដោះហើយ--

**ស៖** ពេលនុ៎ង តើលោកឈរបែរមុខទៅទល់មុខទៅនឹងជនប្រដាប់អាវុធ ឬក៏លោកបែរខ្នងទៅជនប្រដាប់អាវុធ ឬក៏ជនប្រដាប់អាវុធហ្នឹង នៅចំហៀងខ្លួនលោក?

**ឆ៖** បាទ--

**ស៖** តើលោកចាំទេ?

**ឆ៖** ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀតថា ខាងមុខ ក៏អ្នកកាន់កាំភ្លើង ខាងក្រោយខ្នងខ្ញុំ ក៏អ្នកកាន់កាំភ្លើង ចំហៀងក៏អ្នកកាន់កាំភ្លើង ព្រោះមនុស្សវាប្រាំមួយប្រាំពីរនាក់ទៅហើយ អ្នកកាន់កាំភ្លើងនោះ។ អ៊ីចឹងឲ្យខ្ញុំបែរមុខទៅរកអ្នកណាមួយ អត់មានទេ ប៉ុន្តែមនុស្សដែលបាញ់ត្រូវម្តាយខ្ញុំដំបូង គឺមនុស្សនៅ

ឈរពីមុខ បាញ់មកត្រូវម្ដាយខ្ញុំ។ ហើយខ្ញុំក្រាបទៅជាមួយគាត់។ ហើយយើងនៅប៉ុន្មានដើម ពីរបីដើម អមសងខាងទៀត វាបាញ់ផ្ដួចមក។ វាមិនមែនយកម្ដងមួយ ទៅឈរបាញ់ទេ គឺវាចេញជារង្វង់ហើយ វាបាញ់ផ្ទាច់យកតែម្ដង ទាំងប្រាំមួយនាក់ហ្នឹង។

[១៥:៤៤:០២]

**ស៖** តើការបាញ់ហ្នឹង គឺបាញ់អស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** បាទ ការបាញ់ហ្នឹង បើតាមខ្ញុំស្មានមើលទៅ វាសឹងតែកន្លះម៉ោងហ្នឹងដែរ ប្រហែលជាកន្លះម៉ោងដែរ ព្រោះមនុស្សវាច្រើនដែរ។ អ៊ីចឹងវាទុកពេលកន្លះម៉ោងហ្នឹង គឺវាស្លាប់អស់ហើយ ហើយនៅអាតូចៗហ្នឹង គេអត់បាញ់ទេ គេឡើងទៅវាយយកៗតែម្ដង។

**ប្រធានអង្គជំនុំ៖**

សំណួរអំមិញ ខ្ញុំស្ដាប់មិនច្រឡំទេ គឺចៅក្រមគាត់ចង់សួរថា មិនមែនរយៈពេលនៃការបាញ់ -- រយៈពេលនៃការបាញ់ផង ទាំងទៅវាយផងទេ។ គាត់ចង់សួរថា អាពេលដែលបាញ់ប្រាវៗហ្នឹង អាហ្នឹងរយៈប៉ុន្មាន? ពេលដែលផ្ទុះអាវុធសុទ្ធប៉ុន្មាន?

**លោក សំ សិទ្ធី៖**

**ឆ៖** ផ្ទុះអាវុធហ្នឹង វាមិនដល់កន្លះម៉ោងទេ ព្រោះថាបើបូកទាំងដើរទៅវាយក្បាលនៅក្នុងរង្វង់ខ្មោចហ្នឹងផង ហើយអំមិញខ្ញុំឆ្លើយអំមិញ។ ប៉ុនថាក្នុងពេលផ្ទុះអាវុធហ្នឹងវាប្រហែលជា១៥នាទីអីប៉ុណ្ណឹងទេ។ បាទ គេបាញ់ផ្ដួចមកក្នុងអំឡុង១៥នាទី ព្រោះកាំភ្លើងវាប្រាំមួយដើមទៅហើយ ប្រាំប្រាំមួយដើមហើយ បាញ់ផ្ដុចមួយកន្លែងនោះ។ ម្នាក់បាញ់អស់តែបួនប្រាំគ្រាប់ហ្នឹង វានេះទៅហើយ វាងាប់អស់បាត់ទៅហើយ។

[១៥:៤៥:៤៧]

**សួរដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

**ស៖** លោកសាក្សី យើងខ្ញុំយល់ឃើញថា ប្រធានបទនេះជាប្រធានបទមួយដែលលំបាកណាស់ ប៉ុន្តែតើលោកអាចជម្រាបជូនតុលាការមើលថា ប្រជាជនទាំងនោះត្រូវបានគេសម្លាប់ភ្លាមៗតែម្ដង ឬក៏ថាអ្នកដែលបាញ់ហ្នឹង គឺថាបាញ់ហ្នឹងគឺវាតឹងតែងមែនទែនក្នុងការបាញ់សម្លាប់ប្រជាជនហ្នឹង ឬក៏វាប្រាវៗទៅស្រួលតែម្ដង? តើការបាញ់ហ្នឹងជាការបាញ់មួយគ្រាប់ម្ដង ឬក៏បាញ់រ៉ាហ្វាល់តែម្ដង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទជម្រាបប្រសាសន៍ផងដែរថា ការបាញ់ហ្នឹង វាអត់មានអីពិបាកនឹងបាញ់ទេ ព្រោះគេព័ទ្ធជុំវិញអស់ទៅហើយ។ មនុស្សរត់ហ្នឹង ក៏មិនអាចនឹងរត់ដែរ ហើយបាញ់ហ្នឹងមិនបាច់ប្រើពេលវេលាច្រើនទេ បាទ។

**ប្រធានអង្គជំនុំ៖**

អ៊ីចេះលោកសាក្សី ៗនៅតែអត់ស្ដាប់សំណួរអត់បាន។ ការបាញ់ហ្នឹង គឺតើបាញ់ជាបាញ់រះជារ៉ាហ្វាល់ហ្នឹងណា ដែលយើងអានថារ៉ាហ្វាល់ ឬក៏បាញ់មួយម្ដង ហៅថាគូប៉ាគូនោះ មួយៗនោះ បាញ់អ៊ីចឹង ឬក៏បាញ់ម៉េច?

[១៥:៤៧:០៥]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ជម្រាបជូនឯកឧត្ដម ការបាញ់ហ្នឹងគេមិនមែនបាញ់រ៉ាហ្វាល់ទេ គឺបាញ់ប៉ាគូៗហ្នឹងហើយ។ បើថានៅក្នុងចង្កោមហ្នឹង គេបាញ់ប៉ាគូហ្នឹងហើយ។ បើបាញ់រ៉ាហ្វាល់ទៅ ក្រែងលោវាលោតឡើងទៅៗប៉ះអាគ្នាវាឯមុខហ្នឹងទៀត។ គេបាញ់ផ្ទូងៗ អាហ្នឹងគេហៅប៉ាគូ ដូចឯកឧត្ដមសួរហ្នឹងហើយបាទ។ ហើយអាណានៅងើប អាណានៅអង្គុយគេបាញ់ថែមហ្នឹងទៅ អាហ្នឹងប្រកាច់ត្រឹងៗហ្នឹង គេបាញ់ថែមទៅ។ វាអត់មានអីពិបាកនឹងបាញ់ទេ ព្រោះគេព័ទ្ធជុំវិញអស់ហើយ។

**សួរដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

**សៈ** លោកឮសូរសំឡេងស្រែកសម្រែកយំនៅពេលគេបាញ់ហ្នឹង ហើយនិងនៅពេលគេអូសមនុស្សទម្លាក់ទៅក្នុងរណ្ដៅ។ តើលោកមានស្ដាប់ឮសូរសម្រែក ឬក៏ការស្រែកយំ ឬក៏ដង្ហក់ ការដង្ហោយណាមួយពីអ្នកដែលត្រូវរបួសទេ?

**ឆ៖** បាទ ឮ។ នៅពេលគេបាញ់ហ្នឹង គឺស្រែកយំជៀវរាវពេញហ្នឹងហើយ។ ម៉ែអើយជួយផងឪអើយជួយផងហ្នឹងហើយ ប៉ុនគេបាញ់ដល់ស្ងាត់មាត់ទាំងអស់ហ្នឹង។

**សៈ** ហើយក្រោយពេលគេឈប់បាញ់ តើវាស្ងៀមស្ងាត់ ឬក៏នៅតែមានសម្រែករបស់អ្នករង -- អ្នកទទួលរងរបួស?

[១៥:៤៨:៥៣]

**ឆ៖** អត់មានសម្រែកអីទៀតទេ។ នៅពេលដែលគេបាញ់ស្លាប់អស់ហើយ គឺវាបាត់សម្រែកហើយ។ នៅតែកូនក្មេងតូចៗហ្នឹងយំជៀវរាវហ្នឹង គេដើរយកដំបងទៅវ៉ៃភ្ញូសៗតែម្ដងហ្នឹង។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំយល់ហើយ។ សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ម៉ុមបា!

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានតែមួយសំណួរទេ។

**សួរដោយចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

**ស៖** នៅពេលគេជម្លៀសប្រជាជន ពេលគ្រួសាររបស់លោកចាកចេញ គឺលោកមានអាយុប្រហែល១៤ឆ្នាំ។ ពេលហ្នឹងលោករៀនសូត្រដល់ថ្នាក់ទីប៉ុន្មានដែរ?

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំរៀនបានថ្នាក់ បើថ្នាក់ពីដើម គេថាចូលថ្នាក់ទី៧ហើយ ប៉ុន្តែក្នុងសម័យនោះ និយាយទៅថាបានត្រឹមថ្នាក់ទី៩ ឈានឡើងថ្នាក់ទី៨ ជម្លៀសតែម្ដង។

[១៥:៥០:១៧]

**ប្រធានអង្គជំនុំ៖**

លោកបញ្ជាក់បន្តិចទាក់ទងបញ្ហាថ្នាក់នេះ នឹងអាចនាំឲ្យភាគី ហើយនិងមេធាវីច្រឡំ។ ដោយហេតុអី ដោយហេតុថា សម័យបច្ចុប្បន្ននេះ គេរៀនពីថ្នាក់ទី១ រហូតដល់ថ្នាក់ទី១២។ ប៉ុន្តែពីសង្គមចាស់ គេរៀនពីថ្នាក់ទី១២ ទៅថ្នាក់ទីបញ្ចប់ ថ្នាក់បាក់ឌុប។ អ៊ីចឹងសូមលោកបញ្ជាក់ម្ដងទៀត ឲ្យបានច្បាស់ថ្នាក់ទី៨ ថ្នាក់ទី៩, ៨ហ្នឹង ទី៧ហ្នឹង តើនៅពេលណាឲ្យបានច្បាស់បាទ?

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ជូន។ ដូចឯកឧត្តមលោកប្រសាសន៍អំមិញហើយថា ពីសម័យនោះ គេរៀនពីថ្នាក់ទី គេរាប់ពីថ្នាក់១២ ទៅថ្នាក់ទីបញ្ចប់។ ហើយសម័យហ្នឹងគឺសម័យ លន់ នល់ ហើយសម័យសង្គម លន់ នល់ ហ្នឹង គឺខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ -- ទី៨ -- អឺបានត្រឹមថ្នាក់៩ ឈានចូលដល់ថ្នាក់ទី៨ហ្នឹង អឺថ្នាក់ទី៨ហ្នឹងវានេះម្ដង វាត្រូវជម្លៀសចេញម្ដង។ អ៊ីចឹងសម័យនោះគឺគេ ដូចឯកឧត្តមមានប្រសាសន៍អ៊ីចឹងថា សម័យហ្នឹងគេរៀនពីថ្នាក់ធំទៅថ្នាក់តូច។ ហើយដល់មកយើងឥឡូវនេះ រៀនពីថ្នាក់តូចទៅថ្នាក់ធំ ទៅលេខធំ។

[១៥:៥១:៤៧]

**សួរដោយចៅក្រម ផ្លូវិនស៍ ម៉ុមបា៖**

**ស៖** ដើម្បីឲ្យបញ្ជាក់ឲ្យបានច្បាស់ មានន័យថា លោកចាប់រៀនសូត្រមកហ្នឹង នៅពេលហ្នឹងគឺបាន៨ឆ្នាំដែរ មិនអ៊ីចឹង?

**ឆ៖** បាទ។

**ចៅក្រម ផ្លូវិនស៍ ម៉ុមបា៖**

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីបញ្ជាក់ឡើងវិញ បើសិនជាលោករៀនពីសង្គមចាស់ ហើយបើលោកថា រៀនថ្នាក់ទី៩ តាមខ្ញុំគិតគឺបានតែ៤ឆ្នាំ។ ១២, ១១, ១០ និង៩ ដូច្នេះបានតែ៤ឆ្នាំទេ។ ហើយលោកអំមិញបញ្ជាក់ថាប៉ុន្មានឆ្នាំ? មើលលោកបញ្ជាក់ឡើងវិញ។

**លោក សំ សិទ្ធី៖**

**ឆ៖** ខ្ញុំចូលរៀនថ្នាក់ទី១២ហ្នឹង គឺអត់ទាន់គ្រប់អាយុ ក៏ចេញមកវិញ។ បាទ ទី១២ហ្នឹង ថ្នាក់អង់តាំងគេហ្នឹង អត់ទាន់គ្រប់អាយុ គ្រូដេញមកផ្ទះវិញ។ ដល់ពេលចូលទៅរៀន គ្រប់អាយុចូលរៀន ខ្ញុំរៀនតាំងពីថ្នាក់ទី១២ ដល់ថ្នាក់ទី៩ហ្នឹង ខ្ញុំរៀនឌុប៣ឆ្នាំ។ បាទ ឌុបថ្នាក់៣ឆ្នាំ ថ្នាក់ទី១២ហ្នឹងទៅអត់រួចមួយឆ្នាំ ដល់មកថ្នាក់ទី១១ហ្នឹងឌុបមួយឆ្នាំទៀត ដល់ថ្នាក់ទី១០ហ្នឹងឌុបមួយឆ្នាំទៀត។ បាទ ដូចថារៀនវាមិនចូល។

[១៥:៥៣:២៤]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

លោកសាក្សី អ៊ីចឹងគិតពីបច្ចុប្បន្នវិញនេះ លោករៀនសូត្របានត្រឹមណាដែរ?

**លោក សំ សិទ្ធី៖**

តាំងពីជម្លៀសចេញទៅ ខ្ញុំរៀនបានតែប៉ុណ្ណឹង។ បានត្រឹមថ្នាក់ទី៩ចាស់ សង្គមចាស់។

**ប្រធានអង្គជំនុំ៖**

សាក្សីនៅតែស្តាប់មិនបានសំណួរ។ គាត់ចង់សួរថា ចាប់ពេលរំដោះមក រហូតមកទល់ឥឡូវនេះលោកបានរៀនទៅដល់ថ្នាក់ណាដែរទេ? កម្រិតវប្បធម៌របស់លោក?

**លោក សំ សិទ្ធី៖**

ដូចខ្ញុំបានបញ្ជាក់អំមិញហើយឯកឧត្តម។ ខ្ញុំអត់បានរៀនទៀតទេ ព្រោះខ្ញុំចុះពី៧៥មកនេះ អាល័យទៅធ្វើឈ្លប យកអង្គរមកចិញ្ចឹមអាប្អូនប្អូននាក់នេះ អត់បានរៀនសូត្របន្តទេ។ បាទអ៊ីចឹងបានតែថ្នាក់ទី៩ ពីសង្គមនុ៎ងហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ចាយ៉ាស៊ីញហេ! មានសួរសំណួរទេ?

[១៥:៥៤:៤០]

**សួរដោយចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរខ្លីមួយដើម្បីសួរលោក។ ក្រោយពេលដែលលោកជម្លៀសចេញពីផ្ទះរបស់លោកនៅថ្ងៃទី១៧ មេសា ៧៥ លោកបាននិយាយថា លោកធ្វើដំណើរ៤ថ្ងៃដើម្បីទៅដល់វត្ត។ តើលោកធ្វើយ៉ាងណាដើម្បីឲ្យមានម្ហូបអាហារគ្រប់គ្រាន់ នៅពេលធ្វើដំណើរ? តើលោកចម្អិនអាហារជារៀងរាល់ថ្ងៃ? តើលោករៀបចំម្ហូបអាហារ អាហារព្រឹក ថ្ងៃត្រង់ ល្ងាច តើលោកធ្វើយ៉ាងណា? លោកធ្វើខ្លួនឯង ឬក៏លោកធ្វើរួមគ្នាជាមួយអ្នកដែលធ្វើដំណើរជាមួយលោកនោះ? សូមលោកពន្យល់បន្តិចមើល៍។

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ កាលនុ៎ង នៅមានឪពុកម្តាយធ្វើដំណើរចេញពីគេហដ្ឋានទៅ។ អ៊ីចឹងហើយយើងធ្លាប់នៅផ្ទះយើងវាមានពេលព្រឹក ថ្ងៃត្រង់ និងល្ងាច។ តែដល់តែពេលយើងចេញពីផ្ទះទៅហ្នឹង បានតែពីរពេលទេ តែថ្ងៃត្រង់ និងល្ងាចទេ។ អ៊ីចឹងឪពុកម្តាយអ្នកចម្អិនម្ហូបអាហារអស់ហ្នឹង។ ហើយម្ហូបអាហារហ្នឹងក៏មែនថា មានសម្លសម្លុកអីដូចយើងឥឡូវទេ គឺមានតែហៅថាត្រីប្រហុក ត្រីឆ្អើរ ត្រីងៀត ប្រហុកអំបិលតែប៉ុណ្ណឹងទេ ទឹកត្រីអីប៉ុណ្ណឹងទេ។ អត់មានជាម្ហូបអីឲ្យដូចរាល់ថ្ងៃទេ។

**ស៖** អ៊ីចឹងបានន័យថា លោកនិយាយពីការចម្អិនម្ហូបអាហារទាំងអស់នេះ នៅពេលដែលលោកធ្វើដំណើរទៅវត្ត អ៊ីចឹងមែនទេ?

[១៥:៥៦:២៥]

**ឆ៖** ការធ្វើដំណើរទៅនេះ គឺវាអត់មានគោលដៅទេ។ ដែលគេជម្លៀសយើងចេញពីផ្ទះទៅ អត់មានគោលដៅថាគេយកយើងទៅណាទេ។ ចេះតែនាំគ្នាដើរអ្លែងរហូត បាទដល់កន្លែងណាមានទឹក ដល់ម៉ោងបាយ ឈប់ដាំបាយទៅ។ ញុំាបាយហើយអីហើយ នាំគ្នាដើរទៅទៀតទៅ។ អត់មានពេលវេលាអី

ច្បាស់លាស់។

**ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ៖**

អរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម យ៉ា ណារិន ក្រោយគេ!

**សួរដោយចៅក្រម យ៉ា ណារិន៖**

**ស៖** បាទ លោកសាក្សី នេះជាសំណួរខ្ញុំតែមួយសំណួរទេ ចុងក្រោយ។ ខ្ញុំដឹងថា លោកសាក្សីមានការនឿយហត់ខ្លាំង មួយថ្ងៃពេញ ហើយប្រឈមទៅនឹងបញ្ហាសួរគ្រប់ទិសទៅ។ ហើយសំណួរទាំងនោះវាធ្វើឲ្យលោកសាក្សីមានការរន្ធត់ចិត្ត ពេលនឹកឃើញរឿងដើម ប៉ុន្តែរឿងនេះគឺជារឿងភស្តុតាង។ ដូច្នេះខ្ញុំសួរសំណួរលោកសាក្សីតែមួយសំណួរទេ។ លោកបង្ហាញថា នៅពេលជម្លៀសចេញពីទីក្រុង -- ទីរួមខេត្តកំពង់ឆ្នាំងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ប្រជាពលរដ្ឋចេញពីទីក្រុងដើរតាមផ្លូវហ្នឹងណែនតាន់តាប់។ ហើយខ្ញុំចង់សួរឲ្យលោកបញ្ជាក់បន្តិចថា តើដើរតាមផ្លូវចេញពីទីរួមខេត្តកំពង់ឆ្នាំងទៅហ្នឹងណែនតាន់តាប់ហ្នឹងតាមផ្លូវជាតិ ឬក៏ផ្លូវលំ?

[១៥:៥៨:២២]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ជម្រាបប្រសាសន៍។ ការធ្វើដំណើរទៅ គឺទៅតាមផ្លូវជាតិលេខម្ភៃ -- អើ និយាយទៅថាចេញពីក្រុងកំពង់ឆ្នាំងទៅ ធ្វើដំណើរទៅស្រុកទឹកផុស។ ស្រុកទឹកផុសហើយ បានចេញពីស្រុកទឹកផុសហ្នឹងទៅ ទៅលើខ្ពងពពកធ្លាក់ទៅលើជំរាយ ធ្លាក់ទៅលើឱរ៉ាល់ ធ្លាក់មកកន្លែងនេះវិញវត្តច្រកស្ដេចវិញ ហើយយើងបានផ្លូវជាតិតែត្រឹមស្រុកទឹកផុសនេះទេ ថ្នល់កៅស៊ូ។

**ស៖** បាទខ្ញុំសូមបញ្ជាក់សំណួរលោកសាក្សី។ ខ្ញុំចង់សួរលោកធ្វើដំណើរណែនតាន់តាប់ហ្នឹង តែនៅលើផ្លូវជាតិឬទេ ឬក៏ណែនតាន់តាប់ហ្នឹងទៅដល់ផ្លូវលំ? ព្រោះខ្ញុំជឿជាក់ថា លោកធ្វើដំណើរហ្នឹងមិនអាចលើផ្លូវជាតិទាំងអស់ទេ?

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹងថា ផ្លូវកៅស៊ូហ្នឹងវាមានតែត្រឹមស្រុកទឹកផុសហ្នឹងទេ ទៅពីស្រុកទឹកផុសទៅផ្លូវលំរហូត។ ហើយមិនអាចដើរជាបំបែកគ្នាបានទេ ទៅដោយសារមានគេអ្នកនាំដើរ គេឆ្កកដើរទៅ។ អ៊ីចឹងមែនរាត់រាយ ហើយញែកគ្នាឲ្យទូលាយក្នុងការដើរបានទេ។ រំកិលបន្តិចម្ដងៗ

ដើរដូចយើងអាដែងនេះហ្នឹង។

**ស៖** ខ្ញុំចង់បញ្ជាក់បន្ថែមទៀត។ អ៊ីចឹងទិសដៅហ្នឹងទិសដៅតែមួយទេ អត់មានបែកផ្លូវទៅណា ចេញពីក្រុងកំពង់ឆ្នាំងទៅ អត់មានបែកផ្លូវចេញជាពីរ ជាបីតទៅទៀតទេ អ៊ីចឹងផ្លូវតែមួយទេ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។

**ឆ៖** បាទ។

**ប្រធានអង្គជំនុំ៖**

ដោយសារយើងដល់ពេលវេលាដែលត្រូវសម្រាកហើយ។ អ៊ីចឹង យើងខ្ញុំសុំអរគុណចំពោះសាក្សី -- ថែមទៀត? អ៊ីចឹងជាចុងក្រោយហ្នឹង គឺលោកចៅក្រមចង់សុំថែមមួយសំណួរទៀត។ គឺអ៊ីចឹងសូមអញ្ជើញលោក មីឡាត – លោកចៅក្រម មីឡាត បាទ!

**សួរបន្តដោយចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

**ស៖** ខ្ញុំមានសំណួរមួយចង់សួរលោក ទាក់ទងទៅនឹងអ្នកសារព័ត៌មានដែលសម្ភាសលោក។ លោកនិយាយថា អ្នកស៊ើបអង្កេតនៅក្នុងក្រុមការងារ គេមកសួរលោកក្រោយពេលដែលមានអត្ថបទសារព័ត៌មាន។ ដូច្នេះ តើហេតុអ្វីបានជាគេសរសេរអត្ថបទអំពីរឿងរបស់លោកហ្នឹង? ឬមួយក៏លោកជាអ្នកសរសេរអត្ថបទហ្នឹងដោយខ្លួនឯង?

[១៦:០១:០៥]

**លោក សំ សិទ្ធី៖**

**ឆ៖** បាទ ជម្រាបប្រសាសន៍ដែរថា អ្នកសារព័ត៌មានហ្នឹងវាត្រូវជាមិត្តភក្តិ ហើយគាត់ដឹងរឿងរបស់ខ្ញុំដែលដឹងថា ប៉ុល ពត យកឪពុកម្តាយបងប្អូនទៅសម្លាប់។ អ៊ីចឹង គេសួរខ្ញុំថា គេអាចសុំសម្ភាសអាចជួបសម្ភាសជាមួយគេបានអត់? គេនឹងជួយសម្ភាស ស្រាវជ្រាវក្រែងលោមានបងប្អូនឯណានៅស្រុកក្រៅនៅអីឯណា គេដឹង គេស្គាល់ គេជួយចិញ្ចឹមប្អូន ចិញ្ចឹមបងប្អូន អ៊ីចឹងណ៎ះ! ហើយដល់តែពេលអ៊ីចឹងទៅខ្ញុំក៏គិតថា វាមានបាត់ពូមីងខ្លះដែរ។ អ៊ីចឹងដាក់ឈ្មោះយើង ឈ្មោះឪពុកម្តាយយើងទៅដើម្បីក្រែងលោមានអ្នកសេសសល់ដែលមិនបានចូលរួមស្លាប់ជាមួយយើងនោះ នៅសេសសល់ គេឮអ៊ីចឹង គេមានការជួយគាំទ្រក្នុងការ កិច្ចការងារចិញ្ចឹមប្អូនបន្ត -- បន្ថែម។

**ស៖** តើមានមូលហេតុអ្វីដែលលោកមិនបង្ហាញឈ្មោះអ្នកព័ត៌មានហ្នឹងទេ? ឬមួយជាទូទៅគឺថា

អ្នកសារព័ត៌មានទេជាអ្នករក្សាមិនបញ្ចេញអត្តសញ្ញាណប្រភពព័ត៌មាន ប៉ុន្តែឥឡូវផ្ទុយទៅវិញ គឺប្រភពព័ត៌មានបែរជាមិនបញ្ចេញឈ្មោះអ្នកសារព័ត៌មានទៅវិញ។ តើមានមូលហេតុអ្វីដែរ? តើលោកអាចបញ្ជាក់ឈ្មោះអ្នកសារព័ត៌មានហ្នឹងបានទេ?

**ឆ៖** បាទ ខ្ញុំគ្រាន់តែបញ្ជាក់ប្រាប់ថា -- ជូនថា អ្នកសារព័ត៌មានហ្នឹងជាមិត្តភក្តិនឹងខ្ញុំ ហើយគេកាន់សារព័ត៌មានកោះសន្តិភាព ឈ្មោះ ប៉ាន អាហ្នឹងឈ្មោះគេហៅក្រៅឈ្មោះ ប៉ាន។ ប៉ុន្តែក្នុងសារព័ត៌មានមិនដឹងគេសរសេរឈ្មោះម៉េចទេ។ ខ្ញុំអត់បានចាំផង។

[១៦:០៣:១៣]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងយើងអស់ពេលហើយ ៗដល់ពេលវេលាបញ្ចប់ហើយ។ អ៊ីចឹងខ្ញុំសុំអរគុណចំពោះសាក្សីដែលបានប្រើប្រាស់ពេលវេលាមួយថ្ងៃនេះពេញ ហើយមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការកំពូល – អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះតុលាការវិសាមញ្ញក្នុងតុលាការកម្ពុជា។ អ៊ីចឹង លោកអាចអញ្ជើញត្រឡប់ទៅវិញបាន។

ហើយខ្ញុំសុំជម្រាបលោកមេធាវី និងភាគីទាំងអស់ជ្រាបថា ថ្ងៃស្អែកយើងនឹងបន្ត -- ថ្ងៃចន្ទទី០៦ ខែកក្កដា ឆ្នាំ២០១៥ យើងនឹងបន្តសវនាការមួយថ្ងៃទៀត។ ហើយយើងសាគួមួយថ្ងៃនៅថ្ងៃទី០៧ បើសិនជាមានករណីចាំបាច់ ហើយយើងនឹងបន្តវេលាម៉ោងប្រាំបួន។

ឯនៅពេលដែលបញ្ចប់នេះ គឺសូមមន្ត្រីពន្ធនាគារហ្នឹង គឺនាំជនជាប់ចោទទៅពន្ធនាគារវិញ ហើយនឹងនាំមកវិញនៅវេលាថ្ងៃចន្ទ មុនវេលាម៉ោងប្រាំបួនព្រឹក។ អ៊ីចឹងអង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាកសវនាការនៅពេលនេះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*